# ការណែនាំសម្រាប់អ្នកប្រើ

សូមអានឯកសារណែនាំនេះដោយប្រុងប្រយ័ត្នសិន មុននឹងដំណើរការទូរទស្សន៍របស់អ្នក និងរក្សាវាទុកជាឯកសារយោងនាពេលអនាគត។

www.lg.com

# តារាងមាតិកា

## ការចាប់ផ្ដើមប្រើទូរទស្សន៍ LG webOS


កម្មវិធីបង្រៀនលើអេក្រង់ដើម . . . 5
គ្រប់គ្រងអេក្រង់ដើម . . . 7
ការរៀបចំទូរទស្សន៍សម្រាប់ផ្សាយបន្តផ្ទាល់ . . . 9
ការភ្ជាប់ទៅបណ្ដាញ . . . 10
ការគ្រប់គ្រងគណនី LG របស់អ្នក . . . 12
អំពី ការណែនាំសម្រាប់អ្នកប្រើប្រាស់ . . . 13


## របៀបប្រើទូរទស្សន៍


ការផ្គូផ្គងMagic Remote . . . 14
ការប្រើMagic Remote . . . 15
ការប្រើប្រាស់លក្ខណៈពិសេសរបស់ទូរទស្សន៍ តាមរយៈ ការគ្រប់គ្រងសំឡេងដោយមិនប្រើតេឡេបញ្ជា . . . 17
ការប្រើប្រាស់មុខងារទូរទស្សន៍តាមរយៈការនិយាយ . . . 18
ការបម្លែងពីការនិយាយទៅជាអត្ថបទ . . . 20
ដើម្បីមើលលក្ខណៈពិសេសច្រើនទៀតនៃតេឡេបញ្ជា . . . 22
ការប្រើប្រាស់តេឡេបញ្ជាសកល . . . 23
ចាប់ផ្ដើមកម្មវិធីតាមរយៈ មុខងារចូលប្រើរហ័ស . . . 24
ការភ្ជាប់ទៅ SIMPLINK (HDMI-CEC) . . . 25
វិធីកាត់ៗ (សតខាត់) ចំពោះ លទ្ធភាពប្រើប្រាស់ . . . 27
ការភ្ជាប់ឧបករណ៍ផ្ទុកបញ្ចូលទៅ USB . . . 27


## រីករាយជាមួយទូរទស្សន៍បន្តផ្ទាល់


ការទទួលបានអត្ថប្រយោជន៍ច្រើនបំផុតពី ម៉ឺនុយផ្សាយផ្ទាល់ . . . 28
ការមើល ការណែនាំ . . . 30
ការពិនិត្យមើលព័ត៌មានអំពីប៉ុស្តិ៍ . . . 31
Live Playback . . . 32
ការថត . . . 33
ការចាប់យកតន្ត្រី . . . 35
ការប្រើ កម្មវិធីកាលវិភាគទូរទស្សន៍ . . . 36
ការចាក់កម្មវិធីទូរទស្សន៍ដែលបានថត . . . 37
អក្សរសន្ទស្សន៍ . . . 39
HbbTV . . . 41


## ការរីករាយប្រើប្រាស់ LG Content Store


ការរុករកនៅក្នុង LG Content Store . . . 43
ការណែនាំអំពីមាតិកា . . . 44
ការស្វែងរកមាតិកា . . . 45

## ការភ្ជាប់ទៅឧបករណ៍ខាងក្រៅ


ការប្រើ ផ្ទាំងគ្រប់គ្រងផ្ទះ . . . 46
ការភ្ជាប់ ឧបករណ៍ IoT នៅក្នុងផ្ទះ . . . 48
ការភ្ជាប់ឧបករណ៍ឆ្លាតវៃ . . . 49
ការមើលអេក្រង់ឧបករណ៍ឆ្លាតវៃនៅលើទូរទស្សន៍ . . . 51
លេងសំឡេងពីឧបករណ៍ឆ្លាតវៃតាមរយៈអូប៉ាល័ររបស់ទូរទស្សន៍ . . . 52
ការតភ្ជាប់យូអេសប៊ី . . . 52
មើលរូបថត និងវីដេអូ . . . 54
ការស្ដាប់តន្ត្រី . . . 60
ចែករំលែកមាតិកាកុំព្យូទ័រ . . . 63
ការមើលអេក្រង់កុំព្យូទ័រនៅលើទូរទស្សន៍ . . . 65


## ការទទួលបានអត្ថប្រយោជន៍ច្រើនបំផុតពីទូរទស្សន៍ឆ្លាតវៃ


កំពុងប្រើ ការចែករំលែកពីរវាងបន្ទប់ . . . 65
ការទទួលបានអត្ថប្រយោជន៍ច្រើនបំផុតពី វិចិត្រសាល . . . 67
ការរុករកនៅលើអ៊ីនធឺណិតលើទូរទស្សន៍ . . . 68
ការប្រើ ការជូនដំណឹងអំពីកីឡា . . . 71


## ការកំណត់


ការកំណត់រហ័ស . . . 72
រូបភាព . . . 73
សំឡេង . . . 86
ប៉ុស្តិ៍ . . . 94
ការតភ្ជាប់ . . . 100
ទូទៅ . . . 103
លទ្ធភាពប្រើប្រាស់ . . . 114
ជំនួយ . . . 117


## ការដោះស្រាយបញ្ហា


ធ្វើការត្រួតពិនិត្យដោយប្រើ Quick Help . . . 120
ការដោះស្រាយបញ្ហាគេឡេបញ្ហា/ថាមពល . . . 121
ការដោះស្រាយបញ្ហាអេក្រង់ . . . 122
ការដោះស្រាយបញ្ហាសំឡេង . . . 125
ការដោះស្រាយបញ្ហានៃការតភ្ជាប់ទៅកុំព្យូទ័រ . . . 126
ការដោះស្រាយបញ្ហានៃការចាក់ភាពយន្ត . . . 127
ការដោះស្រាយបញ្ហានៃការថត . . . 129
ការដោះស្រាយបញ្ហានៃការតភ្ជាប់បណ្ដាញ . . . 130
ការដោះស្រាយបញ្ហាគណនី LG . . . 131
ការដោះស្រាយបញ្ហាខ្លឹមសារ . . . 132
ការដោះស្រាយបញ្ហាកម្មវិធីរុករកនៅលើអ៊ីនធឺណិត . . . 132

## ការទទួលបានព័ត៌មាន

គុណភាពបង្ហាញដែលបានគាំទ្រ៖ HDMI-DTV . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . 134
គុណភាពបង្ហាញដែលបានគាំទ្រ៖ HDMI-PC. . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . 136
ព័ត៌មានអំពីអាជ្ញាប័ណ្ណ . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . 140
។ល។ . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . 141

# ការចាប់ផ្តើមប្រើទូរទស្សន៍ LG webOS

## កម្មវិធីបង្រៀនលើអេក្រង់ដើម

### ការប្រើមុខងារដើមនៃទូរទស្សន៍ LG webOS TV

អ្នកអាចបើកអេក្រង់ដើម ដោយចុចប៊ូតុង ⌂ លើតេឡេរបស់អ្នក។
រំកិលប៊ូតុង **ដំណើរការ (OK)** នៅលើ Magic Remote ដើម្បីរំកិលតាមរយៈម៉ឺនុយ។
អ្នកអាចបើកកម្មវិធី និងមាតិកា ឬប្រើលក្ខណៈពិសេសផ្សេងៗរបស់ទូរទស្សន៍ឆ្លាតវៃ។

- តេឡេបញ្ជាស្តង់ដារអនុញ្ញាតឱ្យអ្នករំកិលតាមរយៈម៉ឺនុយដោយប្រើ ▼/▲។




❶ ចាប់ផ្តើម **ស្វែងរក**។
ដើម្បីមើលព័ត៌មានលម្អិត សូមចុច **ការរីករាយប្រើប្រាស់ LG Content Store** → **ការស្វែងរកមាតិកា** ក្នុង **ការណែនាំសម្រាប់អ្នកប្រើប្រាស់**។

❷ ចាប់ផ្តើម **ការកំណត់រហ័ស**។
ដើម្បីមើលព័ត៌មានលម្អិត សូមចុច **ការកំណត់** → **ការកំណត់រហ័ស** ក្នុង **ការណែនាំសម្រាប់អ្នកប្រើប្រាស់**។

❸ ចាប់ផ្តើម **ការជូនដំណឹង**។
ដើម្បីមើលព័ត៌មានលម្អិត សូមចុច **ការកំណត់** → **ជំនួយ** → **ការជូនដំណឹង** ក្នុង **ការណែនាំសម្រាប់អ្នកប្រើប្រាស់**។

❹ ត្រឡប់ទៅកាន់កម្មវិធីទូរទស្សន៍ដែលបានប្រើថ្មីៗបំផុត ឬការបញ្ចូលខាងក្រៅ។

❺ អ្នកអាចទទួលបានការណែនាំពីកម្មវិធី និងប៉ុស្តិ៍ផ្សេងៗ។

- អ្នកត្រូវតែភ្ជាប់ទៅបណ្តាញ ដើម្បីប្រើលក្ខណៈពិសេសនៃការណែនាំ។

❻ អ្នកអាចដំណើរការ ផ្លាស់ទី និងលុបកម្មវិធី ដែលដំឡើងក្នុងទូរទស្សន៍របស់អ្នកបាន។

- **បញ្ជីកម្មវិធី** និង **មាតិកាពេញនិយមរបស់** ○○ ត្រូវបានបង្ហាញដោយស្វ័យប្រវត្តិនៅលើអេក្រង់រាល់ពេលដែលទូរទស្សន៍ត្រូវបានបើក។ ប្រសិនបើអ្នកមិនចង់ឱ្យបង្ហាញអេក្រង់ដើមទេ សូមកំណត់ **ការចាប់ផ្ដើមទំព័រដើមដោយស្វ័យប្រវត្តិ** នៃ ⚙ → ⋮ → **ទូទៅ** → **ការកំណត់ទំព័រដើម** ទៅ **បិទ**។
- លទ្ធភាពផ្ដល់ជូន និងការចូលប្រើប្រាស់មាតិកា និងសេវាកម្មក្នុងឧបករណ៍ LGE អាចនឹងមានការផ្លាស់ប្ដូរគ្រប់ពេល ដោយគ្មានការជូនដំណឹងជាមុន។
- មុខងារដែលអាចប្រើបានមានភាពខុសគ្នាទៅតាមតំបន់ ឬសេវាកម្ម។

## ការប្រើ **អេក្រង់ដើម**

កំណត់ ⚙ → ⋮ → **ទូទៅ** → **ការកំណត់ទំព័រដើម** → **ស្ពាយ៍លើអេក្រង់** ទៅ **អេក្រង់ដើម**។
ចុចប៊ូតុង ⌂ លើតេឡេ។ អ្នកអាចបញ្ចូលកម្មវិធីដែលប្រើញឹកញាប់លើអេក្រង់តែមួយ និងប្រើមួយណាក៏បានគ្រប់ពេលវេលា។




❶ ចាប់ផ្ដើម **ស្វែងរក**។
ដើម្បីមើលព័ត៌មានលម្អិត សូមចុច **ការរីករាយប្រើប្រាស់ LG Content Store**→ **ការស្វែងរកមាតិកា** ក្នុង **ការណែនាំសម្រាប់អ្នកប្រើប្រាស់**។

❷ ផ្លាស់ទីទៅ **ផ្ទាំងគ្រប់គ្រងផ្ទះ**។
អ្នកអាចជ្រើសរើស ឬគ្រប់គ្រងឧបករណ៍ (ឧបករណ៍ចល័ត ឧបករណ៍ខាងក្រៅ ឧបករណ៍ IoT នៅក្នុងផ្ទះ ។ល។) ដែលភ្ជាប់ជាមួយទូរទស្សន៍។
សម្រាប់ព័ត៌មានបន្ថែម សូមមើល **ការភ្ជាប់ទៅឧបករណ៍ខាងក្រៅ** → **ការប្រើ ផ្ទាំងគ្រប់គ្រងផ្ទះ** ក្នុង **ការណែនាំសម្រាប់អ្នកប្រើប្រាស់**។

❸ ផ្លាស់ទីទៅធាតុបញ្ចូលទូរទស្សន៍ ដែលអ្នកបានប្រើថ្មីៗនេះ។

❹ ផ្លាស់ទីទៅកម្មវិធីដែលបានប្រើថ្មីៗនេះ។
ចុចប៊ូតុង ⌂ នៅលើតេឡេបញ្ជាឱ្យជាប់ ឬផ្ដោតលើ **ថ្មីៗនេះ**។
អ្នកអាចដំណើរការ ឬបិទកម្មវិធីដែលបានប្រើថ្មីៗនេះនៅក្នុងបញ្ជីដែលបានផ្ដល់ជូននៅក្នុងផ្នែកមើលជាមុន ខាងលើបំផុតផងដែរ។

❺ អ្នកអាចដំណើរការ ផ្លាស់ទី និងលុបកម្មវិធី ដែលដំឡើងក្នុងទូរទស្សន៍របស់អ្នកបាន។

❻ ផ្ដោតលើផ្នែកកម្មវិធីនីមួយៗ។ វាផ្ដល់ មើលជាមុន នៅផ្នែកខាងលើ។

អ្នកអាចពិនិត្យមើល ឬដំណើរការលក្ខណៈពិសេសដែលមានប្រយោជន៍របស់កម្មវិធីនីមួយៗ និងណែនាំមាតិកាអំពី មើលជាមុន ដោយមិនចាំបាច់ចូលកម្មវិធីបាន។

- កម្មវិធីខ្លះប្រហែលជាមិនផ្តល់ មើលជាមុន ទេ។

- អេក្រង់ដើមនឹងបង្ហាញដោយស្វ័យប្រវត្តិ នៅពេលបើកទូរទស្សន៍។ ប្រសិនបើអ្នកមិនចង់ឱ្យបង្ហាញអេក្រង់ដើមទេ សូមកំណត់ **ការចាប់ផ្តើមទំព័រដើមដោយស្វ័យប្រវត្តិ** នៃ ⚙ → ⋮ → **ទូទៅ** → **ការកំណត់ទំព័រដើម** ទៅ **បិទ**។
- លទ្ធភាពផ្តល់ជូន និងការចូលប្រើប្រាស់មាតិកា និងសេវាកម្មក្នុងឧបករណ៍ LGE អាចនឹងមានការផ្លាស់ប្តូរគ្រប់ពេល ដោយគ្មានការជូនដំណឹងជាមុន។

# គ្រប់គ្រងអេក្រង់ដើម

## ការគ្រប់គ្រង LG webOS TV Home

### ការកែសម្រួល **អេក្រង់ថ្មី**

អ្នកអាចប្តូរលំដាប់នៃបញ្ជីខ្លឹមសារ ឬកម្មវិធីដែលបានបង្ហាញដោយចុចប៊ូតុង ⌂ នៅលើឧបករណ៍បញ្ជាពីចម្ងាយ។
រំកិលប៊ូតុង **ដំណើរការ (OK)** នៅលើ Magic Remote ដើម្បីរំកិលតាមរយៈម៉ឺនុយ។
អ្នកអាចចូលមុខងារកែដោយជ្រើសរើស ✎ ដែលស្ថិតនៅផ្នែកខាងក្រោមនៃអេក្រង់។




❶ ចូលមុខងារ **កែសម្រួលបញ្ជីកម្មវិធី**។

- បន្ទាប់ពីជ្រើសរើសកម្មវិធីដែលអ្នកចង់កែពី **បញ្ជីកម្មវិធី** នៅលើអេក្រង់ដើម សូមចុចប៊ូតុង **ដំណើរការ (OK)** នៅលើឧបករណ៍បញ្ជាពីចម្ងាយឱ្យជាប់ ឬជ្រើសរើសប៊ូតុង **កែសម្រួលបញ្ជីកម្មវិធី** ដែលស្ថិតនៅផ្នែកខាងចុងនៃ **បញ្ជីកម្មវិធី** ដើម្បីចូលមុខងារ **កែសម្រួលបញ្ជីកម្មវិធី**។

2. ចូលមុខងារ **កែសម្រួលបញ្ជីមាតិកា**។
   អ្នកអាចកែលំដាប់នៃបញ្ជីខ្លឹមសារដែលបានបង្ហាញនៅក្នុងទំព័រដើមដោយផ្ទាល់បាន។
3. **កំណត់លំដាប់កម្មវិធីឡើងវិញ** : កំណត់លំដាប់លំដោយធាតុនៅក្នុងបញ្ជីកម្មវិធីឡើងវិញ។
   **ការកំណត់ទំព័រដើម** : នៅពេលបើកថាមពល
   សូមចូលទៅកាន់អេក្រង់ដែលកំណត់សកម្មភាពទំព័រដើម ឬការបង្ហាញការផ្សាយពាណិជ្ជកម្ម។
   **ការណែនាំសម្រាប់អ្នកប្រើប្រាស់** : ទៅកាន់កម្មវិធី **ការណែនាំសម្រាប់អ្នកប្រើប្រាស់** ។

   - ធាតុដែលអាចកំណត់បានអាចមានភាពខុសគ្នាទៅតាមមុខងារកែ។

4. ចាកចេញពីមុខងារកែ។

## ការកែសម្រួល អេក្រង់ដើម

01 កំណត់ ⚙ → ⋮ → **ទូទៅ** → **ការកំណត់ទំព័រដើម** → **ស្គាល់លើអេក្រង់** ទៅ **អេក្រង់ដើម**។
ចុចប៊ូតុង ⌂ លើតេឡេ។

02 ជ្រើសរើសកម្មវិធីដែលអ្នកចង់កែប្រែ បន្ទាប់មកចុចហើយសង្កត់ឲ្យជាប់ប៊ូតុង **ដំណើរការ (OK)** លើតេឡេ។
វានឹងបើកមុងកែប្រែកម្មវិធី។
ឬអ្នកអាចជ្រើសរើសប៊ូតុងរបៀបកែសម្រួលនៅផ្នែកខាងជ្រុងខាងស្តាំនៃបញ្ជីអេក្រង់ដើម
ដើម្បីបញ្ចូលរបៀបកែសម្រួលកម្មវិធី។

03 ដើម្បីប្តូរទៅកម្មវិធីនៅទីតាំងដែលចង់បានរបស់អ្នក សូមចូលទៅទីតាំងនោះ
ហើយចុចប៊ូតុង **ដំណើរការ (OK)**។
ដើម្បីលុបកម្មវិធី សូមជ្រើសរើសអាយខុន × ខាងលើកម្មវិធី។

- អ្នកអាចផ្លាស់ទី និងលុបកម្មវិធីជាច្រើនតាមដែលអ្នកចង់ នៅមុនពេលចាកចេញពីម៉ូដកែប្រែបាន។
- អ្នកក៏អាចប្តូរកម្មវិធីដោយប្រើប៊ូតុង ◀/▶ លើតេឡេរបស់អ្នកផងដែរ។

04 បន្ទាប់ពីកែសម្រួលរួចរាល់ហើយ សូមចុច ×
នៅជ្រុងផ្នែកខាងលើបំផុតដើម្បីចាកចេញពីរបៀបកែសម្រួលកម្មវិធី។

- មិនអាចកែសម្រួលកម្មវិធីទូរទស្សន៍លំនាំដើមបានទេ។




❶ អ្នកអាចបន្ថែមប៉ុស្តិ៍សេវាកម្មវិដេអូដែលអ្នកចូលចិត្ត ទៅក្នុងបញ្ជីនេះបានផងដែរ។

- អាចប្រើលក្ខណៈពិសេសនេះបាន តែនៅពេលដែលភ្ជាប់បណ្ដាញប៉ុណ្ណោះ។
- អាចនឹងមិនស្គាល់ម៉ូដែលមួយចំនួន។

# ការរៀបចំទូរទស្សន៍សម្រាប់ផ្សាយបន្តផ្ទាល់

## ការមើលការផ្សាយតាមទូរទស្សន៍

01 តភ្ជាប់អង់តែនផ្សព្វផ្សាយជាមួយទូរទស្សន៍។
អ្នកក៏អាចតភ្ជាប់ឧបករណ៍មួយដែលអាចទទួលការផ្សាយ ដូចជាឧបករណ៍ចាប់រលកសញ្ញាជំនួសអង់តែនបានដែរ។
បើកដំណើរការ ⚙ → ⋮ → **ការតភ្ជាប់** → **ការកំណត់ការតភ្ជាប់ឧបករណ៍** → **ការកំណត់អង្គបញ្ជាសកល**។



02 ចាប់ផ្ដើម ⚙ → ⋮ → **ប៉ុស្តិ៍** → **ការរាវប៉ុស្តិ៍ (ការរាវប៉ុស្តិ៍ និងការកំណត់)** → **ការរាវប៉ុស្តិ៍ដោយស្វ័យប្រវត្តិ**។
ស្វែងរក និងបន្ថែមតែប៉ុស្តិ៍ដែលកំពុងផ្សាយប៉ុណ្ណោះ។

- ដើម្បីដោះស្រាយបញ្ហាដែលទាក់ទងនឹងមុខងារនេះ សូមមើល **ការដោះស្រាយបញ្ហា** ផ្នែករបស់ **ការណែនាំសម្រាប់អ្នកប្រើប្រាស់**។

# ការភ្ជាប់ទៅបណ្ដាញ

## ការភ្ជាប់ទៅបណ្ដាញ

ប្រសិនបើអ្នកកែប្រែការកំណត់របស់បណ្ដាញ អ្នកអាចប្រើសេវាជាច្រើន ដូចជាមាតិកា និងកម្មវិធីលើប្រព័ន្ធអ៊ីនធឺណិត។

### ការកំណត់បណ្ដាញមានខ្សែ



01 តភ្ជាប់រន្ធ LAN របស់ទូរទស្សន៍ និងរ៉ោតទ័រដោយប្រើខ្សែ LAN ។
អ្នកគួរតភ្ជាប់រ៉ោតទ័រជាមួយអ៊ីនធឺណិតជាមុន។

- ប្រសិនបើរ៉ោតទ័រគាំទ្រ DHCP ទូរទស្សន៍នឹងតភ្ជាប់បណ្ដាញដោយស្វ័យប្រវត្តិ នៅពេលអ្នកតភ្ជាប់ទូរទស្សន៍ជាមួយបណ្ដាញដែលមានខ្សែ LAN ។

### ប្រសិនបើបណ្ដាញមិនត្រូវបានភ្ជាប់ដោយស្វ័យប្រវត្តិទេ

02 ចុចប៊ូតុង ⚙ លើតេឡេ។

03 ជ្រើសរើស ⋮ → **ការតភ្ជាប់** → **ការកំណត់ការតភ្ជាប់បណ្ដាញ** → **ការតភ្ជាប់ដោយប្រើខ្សែ (អ៊ីសឺណិត)**។
ដើម្បីមើលព័ត៌មានលម្អិត សូមចុច **ការកំណត់** → **ការតភ្ជាប់** → **ការកំណត់ការតភ្ជាប់បណ្ដាញ** ក្នុង **ការណែនាំសម្រាប់អ្នកប្រើប្រាស់**។

### ការកំណត់បណ្ដាញឥតខ្សែ



01 បើករ៉ោតទ័រដែលតភ្ជាប់អ៊ីនធឺណិត។

02 ចុចប៊ូតុង ⚙ លើតេឡេ។

03 ជ្រើសរើស ⋮ → **ការតភ្ជាប់** → **ការកំណត់ការតភ្ជាប់បណ្ដាញ** → **ការតភ្ជាប់ Wi-Fi**។

04 នៅពេលការស្វែងរកបណ្ដាញបានបញ្ចប់ បញ្ជីបណ្ដាញដែលមានដើម្បីតភ្ជាប់នឹងបង្ហាញ។

05 ជ្រើសរើសបណ្ដាញដែលត្រូវតភ្ជាប់។
ប្រសិនបើរ៉ោតទ័រឥតខ្សែ ការពារដោយពាក្យសម្ងាត់ សូមបញ្ចូលពាក្យសម្ងាត់របស់រ៉ោតទ័រ ។
ដើម្បីមើលព័ត៌មានលម្អិត សូមចុច **ការកំណត់** → **ការតភ្ជាប់** →
**ការកំណត់ការតភ្ជាប់បណ្ដាញ** ក្នុង **ការណែនាំសម្រាប់អ្នកប្រើប្រាស់**។

## ការព្រមានស្ដីពីការកំណត់បណ្ដាញ

- ប្រើខ្សែ LAN ស្តង់ដារ (តភ្ជាប់ជាមួយ Cat7 ឬខ្ពស់ជាងនេះជាមួយឧបករណ៍តភ្ជាប់ RJ45 10 Base-T, ឬរន្ធ 100 Base TX LAN )។
- ការកំណត់ម៉ូដឹមអាចដោះស្រាយបញ្ហាតភ្ជាប់បណ្ដាញបានមួយចំនួន។ ចុចបិទ ផ្ដាច់ ហើយតភ្ជាប់ម្ដងទៀត បន្ទាប់មកចុចបើកវិញដើម្បីដោះស្រាយបញ្ហា។
- LG Electronics មិនទទួលខុសត្រូវចំពោះ កំហុស ឬបញ្ហាក្នុងការតភ្ជាប់បណ្ដាញ ការខូចខាត ឬការមិនដំណើរការបណ្ដាលមកពីការតភ្ជាប់បណ្ដាញឡើយ។
- ការតភ្ជាប់បណ្ដាញអាចដំណើរការមិនប្រក្រតី ដោយសារការកំណត់បណ្ដាញ ឬអ្នកផ្ដល់សេវាអ៊ីនធឺណិត។
- សេវា DSL ត្រូវប្រើម៉ូដឹម DSL និងខ្សែសេវាត្រូវប្រើម៉ូដឹមខ្សែ។
ដោយសារតែចំនួនការតភ្ជាប់បណ្ដាញមានកំណត់ ការកំណត់បណ្ដាញទូរទស្សន៍អាចមិនត្រូវបានប្រើ អាស្រ័យលើកិច្ចសន្យាជាមួយអ្នកផ្ដល់សេវាអ៊ីនធឺណិត។
(ប្រសិនបើកិច្ចសន្យាមិនអនុញ្ញាតឲ្យមានឧបករណ៍ច្រើនជាងមួយក្នុងមួយជួរ មានតែកុំព្យូទ័រដែលបានតភ្ជាប់ហើយប៉ុណ្ណោះដែលត្រូវប្រើ។)
- បណ្ដាញឥតខ្សែអាចមានការរំខានពីឧបករណ៍ផ្សេងទៀតដែលប្រើប្រេកង់ 2.4 GHz (ទូរសព្ទឥតខ្សែ ឧបករណ៍ Bluetooth ឬម៉ាស៊ីនអាំងសាច់)។
ទោះបីជាការរំខានអាចកើតឡើងនៅពេលប្រើប្រេកង់ 5 GHz វាហាក់ដូចជាមិនអាចកើតឡើងទេ។
- បរិយាកាសឥតខ្សែអាចបណ្ដាលឲ្យសេវាបណ្ដាញឥតខ្សែដំណើរការយឺត។
- ការមិនបានបិទបណ្ដាញក្នុងផ្ទះអាចបណ្ដាលឲ្យមានចរាចរណ៍លើសកម្រិតលើឧបករណ៍មួយចំនួន។
- ឧបករណ៍ចំណុចចូលប្រើត្រូវគាំទ្រការតភ្ជាប់ដោយឥតខ្សែ ហើយមុខងារតភ្ជាប់ដោយឥតខ្សែត្រូវតែបើកលើឧបករណ៍ដើម្បីតភ្ជាប់ (ចំណុចចូលប្រើ) AP។ ទាក់ទងអ្នកផ្ដល់សេវាសម្រាប់ការតភ្ជាប់ដោយឥតគិតខ្សែលើចំណុចចូលប្រើ។

- ពិនិត្យ SSID និងការកំណត់សុវត្ថិភាពរបស់ AP ។ សូមមើលឯកសារត្រឹមត្រូវសម្រាប់ SSID និងការកំណត់សុវត្ថិភាពរបស់ AP ។
- ការកំណត់ឧបករណ៍បណ្ដាញមិនត្រឹមត្រូវ (រ៉ោទ័រ ឧបករណ៍ចែកបណ្ដាញប្រើខ្សែនិងឥតខ្សែ) អាចធ្វើឲ្យទូរទស្សន៍ដំណើរការយឺត ឬដំណើរការមិនប្រក្រតី។ ដំឡើងឧបករណ៍ឲ្យបានត្រឹមត្រូវយោងតាមបណ្ដាញ និងសៀវភៅណែនាំត្រឹមត្រូវ។
- វិធីសាស្ត្រតភ្ជាប់អាចខុសគ្នាអាស្រ័យលើក្រុមហ៊ុនផលិត AP។
- ដើម្បីដោះស្រាយបញ្ហាដែលទាក់ទងនឹងមុខងារនេះ សូមមើល **ការដោះស្រាយបញ្ហា** ផ្នែករបស់ **ការណែនាំសម្រាប់អ្នកប្រើប្រាស់**។

# ការគ្រប់គ្រងគណនី LG របស់អ្នក

## ការបង្កើតគណនី LG

នៅក្នុងផ្នែក **ការគ្រប់គ្រងគណនី** អ្នកអាចប្រើអាសយដ្ឋានអ៊ីមែលរបស់អ្នក ដើម្បីបង្កើតគណនី LG ថ្មីមួយបាន។
ឬអ្នកអាចបង្កើត និងចូលគណនី LG ដោយប្រើពាក្យសម្ងាត់ និងលេខសម្គាល់របស់គណនីសេវាកម្មខាងក្រៅ។

01 ចុចប៊ូតុង ⚙ លើតេឡេ។

02 ជ្រើសរើស ⋮ → **ទូទៅ** → **ការគ្រប់គ្រងគណនី** → **ការចូលគណនី LG**។

03 ជ្រើសរើស**បង្កើតគណនី**។ អាន និងព្រមទទួលយកលក្ខខណ្ឌប្រើប្រាស់។

04 វាយបញ្ចូលលេខសម្គាល់ និងពាក្យសម្ងាត់។ លេខសម្គាល់របស់អ្នកត្រូវតែជាអាសយដ្ឋានអ៊ីមែលរបស់អ្នក។

05 វាយបញ្ចូលថ្ងៃខែឆ្នាំកំណើតរបស់អ្នក។

06 ប្រសិនបើអ្នកជ្រើសរើស **OK** តំណផ្ទៀងផ្ទាត់នឹងត្រូវបានផ្ញើទៅកាន់អាសយដ្ឋានអ៊ីមែលដែលអ្នកបានបញ្ចូល។ សូមបញ្ចប់ការផ្ទៀតផ្ទាត់តាមអ៊ីមែល ក្នុងរយៈដែលមានសុពលភាព។

07 ប្រសិនបើការផ្ទៀងផ្ទាត់តាមអ៊ីមែលទទួលបានជោគជ័យ គណនី LG នឹងត្រូវបានបង្កើត ហើយអ្នកអាចចូលដោយប្រើព័ត៌មានគណនីនេះបាន។

- អាចនឹងមិនស្គាល់ម៉ូដែលមួយចំនួន។
- ចាំបាច់ត្រូវមានការភ្ជាប់អ៊ីនធឺណិត ដើម្បីបង្កើតគណនីបាន។
- ព័ត៌មានដែលចាំបាច់អាចប្រែប្រួលតាមប្រទេស។
- អ្នកអាចត្រូវបានដាក់កម្រិតពីសេវាកម្មដោយអាស្រ័យតាមអាយុរបស់អ្នក។
- ដើម្បីដោះស្រាយបញ្ហាដែលទាក់ទងនឹងមុខងារនេះ សូមមើល **ការដោះស្រាយបញ្ហា** ផ្នែករបស់ **ការណែនាំសម្រាប់អ្នកប្រើប្រាស់**។

# ការគ្រប់គ្រងគណនី LG របស់អ្នក

អ្នកអាចគ្រប់គ្រងព័ត៌មានគណនី LG របស់អ្នកបាន។

01 ចុចប៊ូតុង ⚙ លើតេឡេ។

02 ចូលទៅ ⋮ → **ទូទៅ** → **ការគ្រប់គ្រងគណនី** ដើម្បីចូល។

### ព័ត៌មានផ្ទាល់ខ្លួន

អ្នកអាចមើលឬកែសម្រួលព័ត៌មានគណនីរបស់អ្នកដែលបច្ចុប្បន្នអ្នកបានចូល។
អ្នកអាចប្តូរពាក្យសម្ងាត់ ឬចុច **កែសម្រួល** ដើម្បីកែសម្រួលព័ត៌មានផ្ទាល់ខ្លួនរបស់អ្នកបាន។

- អាចនឹងមិនស្គាល់ម៉ូដែលមួយចំនួន។

# អំពី ការណែនាំសម្រាប់អ្នកប្រើប្រាស់

## អំពី ការណែនាំសម្រាប់អ្នកប្រើប្រាស់

សម្រាប់ព័ត៌មានស្តីពីមុខងារនីមួយៗរបស់ LG webOS TV, សូមអាន **ការណែនាំសម្រាប់អ្នកប្រើប្រាស់** ដែលមានអំពីទូរទស្សន៍។
ប្រសិនបើអ្នកចុច ? នៅខាងលើផ្នែកខាងស្តាំអេក្រង់ នោះការណែនាំខ្លីមួយសម្រាប់ណែនាំអ្នកប្រើប្រាស់នឹងត្រូវបង្ហាញ។
ប្រសិនបើអេក្រង់ដែលមានការពិពណ៌នាមុខងាររបស់ **ការណែនាំសម្រាប់អ្នកប្រើប្រាស់** មាន ➦, សូមចុច ➦ ដើម្បីទៅមុខងារដែលត្រូវគ្នា ឬការកំណត់ដោយផ្ទាល់។
ពណ៌អត្ថបទនៅក្នុងសៀវភៅណែនាំការប្រើនេះ ត្រូវបានប្រើដើម្បីបញ្ជាក់ ដូចខាងក្រោម៖

- ■ ក្រហម : ឈ្មោះប៊ូតុងតេឡេ។
- ■ លឿង : ប៊ូតុង និងអត្ថបទ ដែលត្រូវបង្ហាញលើអេក្រង់ទូរទស្សន៍។
- ■ បៃតង : ឈ្មោះឧបករណ៍តភ្ជាប់ចូលទូរទស្សន៍។

- រូបភាព និងព័ត៌មាន នៅក្នុង **ការណែនាំសម្រាប់អ្នកប្រើប្រាស់** អាចខុសគ្នា អាស្រ័យលើម៉ូដែល និងបរិយាកាសប្រតិបត្តិការ។
- ព័ត៌មានស្តីពីផលិតផលអាចត្រូវបានផ្លាស់ប្តូរដោយមិនជូនដំណឹងជាមុន ដោយសារការធ្វើមុខងាររបស់ផលិតផលឱ្យកាន់តែប្រសើរឡើង។

# របៀបប្រើទូរទស្សន៍

## ការផ្គូផ្គងMagic Remote

### ស្វែងយល់បន្ថែមអំពីតេឡេបញ្ជាវេទមន្ត




អ្នកអាចជ្រើសរើសមុខងារដែលអ្នកចង់ដោយងាយស្រួល និងលឿនដោយផ្លាស់ទី និងទស្សន៍ទ្រនិចលើកញ្ចក់ទូរទស្សន៍ ដូចដែលអ្នកប្រើកណ្ដុរលើកញ្ចក់កុំព្យូទ័រដែរ។

- អ្នកអាចទិញMagic Remoteដោយឡែក ប្រសិនបើគេមិនបានផ្ដល់ជូន។

### ការផ្គូផ្គងMagic Remote

អ្នកត្រូវផ្គូផ្គងMagic Remoteជាមួយទូរទស្សន៍ LG webOS ដើម្បីប្រើវា។ ផ្គូផ្គងតេឡេពិសេសសិន មុននឹងប្រើដូចខាងក្រោម៖

01 បើកទូរទស្សន៍។ ប្រហែល 20 វិនាទី ចង្អុរតេឡេតម្រង់ទៅទូរទស្សន៍ ហើយចុច **ដំណើរការ (OK)**។

02 តេឡេនឹងចុះឈ្មោះដោយស្វ័យប្រវត្តិ ហើយសារដែលបង្ហាញថាការផ្គូផ្គងបានបញ្ចប់ នឹងបង្ហាញលើកញ្ចក់ទូរទស្សន៍។

- បើការចុះបញ្ជីMagic Remoteមិនបានសម្រេច បិទទូរទស្សន៍ រួចបើកវិញ បន្ទាប់ព្យាយាមចុះបញ្ជីសារជាថ្មី។

### ការចុះឈ្មោះតេឡេពិសេសម្ដងទៀត

បើសញ្ញាព្រួញរបស់ Magic Remote មិនបង្ហាញលើទូរទស្សន៍ទេនោះ អ្នកត្រូវតែចុះបញ្ជីវាម្ដងទៀត។

01 តម្រង់តេឡេបញ្ជាទៅទូរទស្សន៍ រួចចុចប៊ូតុង **GUIDE** ឱ្យជាប់ រហូតដល់ការណែនាំលេចឡើង។

02 តេឡេដែលបានចុះឈ្មោះពីមុនត្រូវបានលុបចោល ហើយចុះឈ្មោះម្ដងទៀត។

# ការប្រើMagic Remote

## ការប្រើប្រាស់ប៊ូតុងលើតេឡេ

ចុចដោយរហ័ស ឬចុច ហើយសង្កត់ ប៊ូតុងលើតេឡេ ដើម្បីចូលប្រើប្រាស់មុខងារផ្សេងៗទៀត។




សម្រាប់ប៊ូតុងដែលមាន # សូមចុចឱ្យជាប់ (ចុចឱ្យជាប់ឱ្យយូរជាងមួយវិនាទី)។

- : អ្នកអាចបើក/បិទថាមពលប្រអប់ចាប់ប៉ុស្តិ៍បាន។
- **9** # : ចាប់ផ្ដើម **Quick Help**។
- **LIST** : ការពិនិត្យមើលប៉ុស្តិ៍ដែលបានរក្សាទុក។
- **0** # : អេក្រង់កែសម្រួល **មុខងារចូលប្រើរហ័ស** លេចចេញមក។
- ••• : វាបង្ហាញប៊ូតុងបន្ថែមនៅលើតេឡេបញ្ជា។
  ••• # : ពណ៌នាមាតិកាលើអេក្រង់តាមសំឡេង។
  (អាចនឹងមិនស្គាល់ម៉ូដែលមួយចំនួន។)
- : វាកែតម្រូវកម្រិតសំឡេង។
- : ជ្រើសរើស ដើម្បីបិទសំឡេងពីទូរទស្សន៍។
  # : ចូលម៉ឺនុយ **លទ្ធភាពប្រើប្រាស់**។
- : អ្នកអាចប្ដូរប៉ុស្តិ៍បាន។
- : ពិនិត្យមើលមាតិកាដែលបានណែនាំ។
  (ប្រហែលជាមិនអាចប្រើសេវាកម្មណែនាំបានទេ ដោយអាស្រ័យលើប្រទេសដែលអ្នកស្ថិតនៅ។)
  ចុចរួចសង្កត់ប៊ូតុងឱ្យជាប់នៅពេលនិយាយ ដើម្បីប្រើមុខងារសម្គាល់សំឡេង។
- : បង្ហាញម៉ឺនុយដើមទំព័រដើម។
  # : បង្ហាញបញ្ជីដែលបានប្រើប្រាស់ពីមុន។
- : ចូលម៉ឺនុយការកំណត់រហ័ស។
  # : ចូលម៉ឺនុយការកំណត់ទាំងអស់។
- : ផ្លាស់ទីទៅជំហានពីមុន។

- # : បិទម៉ឺនុយ។
- **GUIDE** : អ្នកអាចពិនិត្យមើលកម្មវិធីបាន។
- **RECENTS** : បង្ហាញបញ្ជីដែលបានប្រើប្រាស់ពីមុន។
(អាចនឹងមិនស្គាល់ម៉ូដែលមួយចំនួន។)
- : ជ្រើសរើសប្រភពចូល។
# : ការចូលទៅក្នុង **ផ្ទាំងគ្រប់គ្រងផ្ទះ**។
- **STB MENU** : វាបង្ហាញម៉ឺនុយនៃប្រអប់ចាប់ប៉ុស្តិ៍។
(អាចនឹងមិនស្គាល់ម៉ូដែលមួយចំនួន។)
- # : ចាប់ផ្តើម **ថត**។

- ចំណុចសម្គាល់ និងទីតាំងរបស់ប៊ូតុងនៅលើតេឡេបញ្ជាអាចនឹងខុសគ្នាទៅតាមប្រភេទម៉ូឌែល។

# ការប្រើMagic Remote

01 បើអ្នកអង្រួនតេឡេពិសេសទៅឆ្វេង និងស្តាំខណៈកំពុងចង្អុលវាលើទូរទស្សន៍ សញ្ញាព្រួញនឹងបង្ហាញនៅលើអេក្រង់ទូរទស្សន៍។
បើអ្នកចល័តតេឡេបញ្ជាពីចម្ងាយតាមទិសដៅដែលអ្នកចង់បាន សញ្ញាព្រួញនឹងទៅតាមចលនានោះ។

02 ចល័តសញ្ញាព្រួញទៅកាន់ទៅទីតាំងដែលអ្នកចង់បាន ហើយចុចប៊ូតុង **ដំណើរការ (OK)** ដើម្បីប្រតិបត្តិមុខងារ។

03 បើមិនទាន់មានការប្រើសញ្ញាព្រួញក្នុងមួយរយៈពេល វានឹងបាត់ទៅវិញ។ នៅពេលសញ្ញាព្រួញបាត់ពីអេក្រង់ទៅវិញ អង្រួនMagic Remoteទៅស្តាំ និងទៅឆ្វេង។ ពេលនោះវានឹងលេចសារជាថ្មី។
ទស្សន៍ទ្រនិចនឹងបាត់ ប្រសិនបើអ្នកចុចប៊ូតុង ឡើង ចុះ ឆ្វេង ស្តាំ ហើយតេឡេពិសេសនឹងដំណើរការជាការបញ្ជាធម្មតា។

- បើសញ្ញាព្រួញមិនដើររលូនទេនោះ អ្នកអាចប្តូរកំណត់សញ្ញាព្រួញដោយចល័តវាទៅជ្រុងនៃអេក្រង់។
- ប្រើតេឡេក្នុងចម្ងាយដែលបានបញ្ជាក់ (ក្នុងចម្ងាយ 33 ហ្វីត ឬ 10 ម៉ែត្រ)។ ឧបករណ៍នេះអាចនឹងដំណើរការមិនប្រក្រតីទេ នៅពេលដែលស្ថិតនៅឆ្ងាយពីចម្ងាយដែលវាដំណើរការ ឬនៅពេលដែលមានឧបសគ្គបាំងវា។
- អាស្រ័យទៅតាមឧបករណ៍ភ្ជាប់ខាងក្រៅ (រ៉ោតទ័រឥតខ្សែ ម៉ាស៊ីនមីក្រូវ៉េវ ។ល។) បញ្ហាក្នុងការទំនាក់ទំនងអាចនឹងកើតមានឡើង។
- ឥទ្ធិពលនានាអាចបណ្តាលឲ្យMagic Remoteមានមុខងារខុសប្រក្រតិទៅបាន។
- សូមប្រយត្ន័ មិនត្រូវបុកជាមួយនឹងគ្រឿងសង្ហារឹម ឧបករណ៍អេឡិចត្រូនិច ឬមនុស្សនៅជិតៗនោះ នៅពេលប្រើMagic Remote។
- សម្រាប់ព័ត៌មានលម្អិតអំពីការកំណត់រចនាសម្ព័ន្ធសញ្ញាព្រួញរបស់តេឡេបញ្ជាវេទមន្ត សូមមើល **ការណែនាំសម្រាប់អ្នកប្រើប្រាស់** → **ការកំណត់** → **ទូទៅ** → **ជម្រើសទ្រនិច**។

# ការប្រើប្រាស់លក្ខណៈពិសេសរបស់ទូរទស្សន៍ តាមរយៈ ការគ្រប់គ្រងសំឡេងដោយមិនប្រើតេឡេបញ្ជា

## ការប្រើប្រាស់លក្ខណៈពិសេសរបស់ទូរទស្សន៍ តាមរយៈ ការគ្រប់គ្រងសំឡេងដោយមិនប្រើតេឡេបញ្ជា

អ្នកអាចប្រើលក្ខណៈពិសេសផ្សេងៗរបស់ទូរទស្សន៍ តាមរយៈ ការគ្រប់គ្រងសំឡេងដោយមិនប្រើតេឡេបញ្ជា។

01 និយាយថា “Hi LG” ក្នុងចម្ងាយទស្សនាពីទូរទស្សន៍របស់អ្នក។

02 អេក្រង់សម្គាល់ការនិយាយលេចឡើង។



03 និយាយលក្ខណៈពិសេសដែលអ្នកចង់ប្រើ។
ឧទាហរណ៍) រកមើលអ្វីមួយសម្រាប់ទស្សនា/លេខប៉ុស្តិ៍ OO/ដំឡើងសំឡេង/បើក OOO/តើអាកាសធាតុនៅថ្ងៃនេះយ៉ាងម៉េចដែរ?/ជំនួយសម្រាប់ការសម្គាល់សំឡេង ។ល។

### ការបើកទូរទស្សន៍ តាមរយៈ ការគ្រប់គ្រងសំឡេងដោយមិនប្រើតេឡេបញ្ជា

01 ប្រសិនបើអ្នកនិយាយថា “Hi LG” ទៅកាន់ទូរទស្សន៍ អ្នកនឹងឮសំឡេងជូនដំណឹងពីទូរទស្សន៍នោះ។

02 និយាយថា "បើកទូរទស្សន៍" បន្ទាប់ពីឮសំឡេងនោះ។
ប៉ុន្តែ នៅពេលដែលបិទទូរទស្សន៍ ការសម្គាល់សំឡេងនឹងមិនអាចប្រើបានទេ ក្រៅតែពី "បើកទូរទស្សន៍"។

- ប្រសិនបើ ការគ្រប់គ្រងសំឡេងដោយមិនប្រើតេឡេបញ្ជា មិនដំណើរការទេ សូមកំណត់

**ប្រើការគ្រប់គ្រងសំឡេងដោយមិនប្រើតេឡេបញ្ជា** ទៅ **បើក** នៅក្នុង ⚙ → ⋮ → **ទូទៅ** → **សេវាកម្ម AI** → **សំគាល់សម្លេង** → **ការកំណត់ការសម្គាល់សំឡេង**។

- លក្ខណៈពិសេសសម្រាប់បើកទូរទស្សន៍តាមរយៈ ការគ្រប់គ្រងសំឡេងដោយមិនប្រើតេឡេបញ្ជា នឹងដំណើរការ ក្នុងករណីដែល ⚙ → ⋮ → **ទូទៅ** → **ការកំណត់បន្ថែម** → **ចាប់ផ្ដើមរហ័ស+** ត្រូវបានកំណត់ទៅ **បើក** តែប៉ុណ្ណោះ។
- ទោះបីជាបើកលក្ខណៈពិសេស **ចាប់ផ្ដើមរហ័ស+** ក៏ដោយ ក៏ក្នុងករណីលើកលែងមួយចំនួន លក្ខណៈពិសេសសម្រាប់បើកទូរទស្សន៍តាមរយៈ ការគ្រប់គ្រងសំឡេងដោយមិនប្រើតេឡេបញ្ជា ប្រហែលជាមិនអាចប្រើបានដែរ។

  - ប្រសិនបើការអាប់ដេតផ្នែកទន់កំពុងដំណើរការ
  - នៅពេលដែលកំណត់ទៅរបៀបហាង
  - ប្រសិនបើបើកទូរទស្សន៍យូរជាង 96 ម៉ោង

## ការប្រុងប្រយ័ត្នជាមុន នៅពេលប្រើប្រាស់ ការគ្រប់គ្រងសំឡេងដោយមិនប្រើតេឡេបញ្ជា

- ម៉ូដែលមួយចំនួនមិនស្គាល់មុខងារនេះទេ។
- ប្រតិបត្តិការប្រហែលជាមានកម្រិត ផ្អែកតាមការកំណត់ភាសា និងប្រទេស។
- មុខងារនេះអាចប្រើបាន តែនៅពេលដែលទូរទស្សន៍ភ្ជាប់ទៅអ៊ីនធឺណិតប៉ុណ្ណោះ។
- នៅពេលដំឡើងកំណែទូរទស្សន៍ មុខងារដែលមានស្រាប់ ឬប្រតិបត្តិការដែលអ្នកបានប្រើអាចនឹងផ្លាស់ប្ដូរ។
- មុខងារ ការគ្រប់គ្រងសំឡេងដោយមិនប្រើតេឡេបញ្ជា អនុញ្ញាតឱ្យតួទូរទស្សន៍ស្គាល់សំឡេងរបស់អ្នកប្រើប្រាស់។ ដើម្បីទទួលបានប្រតិបត្តិការដែលរលូន សូមប្រើមុខងារនេះចម្ងាយ 3 ម៉ែត្រពីទូរទស្សន៍។
- អាស្រ័យទៅតាមស្ថានភាព ប្រហែលជាមិនស្គាល់និមិត្តសញ្ញា លេខ និងតួអក្សរពិសេសទេ។
- វាអាចនឹងរងការប៉ះពាល់ពីមជ្ឈដ្ឋានដូចជា កម្រិតសំឡេង ឬសូរសំឡេង ការបញ្ចេញសំឡេងមិនច្បាស់ និងសំឡេងរំខាននៅជុំវិញ។
- នៅពេលដែលអ្នកប្រើឧបករណ៍បំពងសំឡេងខាងក្រៅដែលភ្ជាប់ជាមួយទូរទស្សន៍ ការបញ្ចេញសំឡេងពីឧបករណ៍បំពងសំឡេងខាងក្រៅប្រភេទនេះអាចត្រូវបានសម្គាល់ថាជាសំឡេងរំខាន។ យើងសូមណែនាំឱ្យប្រើមុខងារសម្គាល់សំឡេងជាមួយតេឡេបញ្ជាវេទមន្ត។
- ប្រសិនបើមុខងារ ការគ្រប់គ្រងសំឡេងដោយមិនប្រើតេឡេបញ្ជា ដំណើរការ នៅពេលដែលគ្មានបំណងឱ្យដំណើរការ សូមសាកល្បងបន្ថយកម្រិតឆ្លើយតប ដោយចូលទៅកាន់ ⚙ → ⋮ → **ទូទៅ** → **សេវាកម្ម AI** → **សំគាល់សម្លេង** → **ការកំណត់ការសម្គាល់សំឡេង** → **កំណត់កម្រិតឆ្លើយតប**។
- សម្រាប់លក្ខណៈពិសេសនៃការសម្គាល់សំឡេង ដោយប្រើតេឡេបញ្ជា សូមមើល **របៀបប្រើទូរទស្សន៍** → **ការប្រើប្រាស់មុខងារទូរទស្សន៍តាមរយៈការនិយាយ** នៅក្នុង **ការណែនាំសម្រាប់អ្នកប្រើប្រាស់**។

# ការប្រើប្រាស់មុខងារទូរទស្សន៍តាមរយៈការនិយាយ

# ការប្រើប្រាស់មុខងារទូរទស្សន៍តាមរយៈការនិយាយ

អ្នកអាចចូលប្រើមុខងារផ្សេងៗរបស់ទូរទស្សន៍បានយ៉ាងរហ័ស និងងាយស្រួលតាមរយៈការស្គាល់ការនិយាយ។

01 ចុច ហើយសង្កត់ប៊ូតុង 🎙 នៅលើតេឡេ ហើយនិយាយមុខងារដែលអ្នកចង់ចាប់ផ្ដើម ឬ ពាក្យគន្លឹះដែលអ្នកចង់ប្រើប្រាស់សម្រាប់ការស្វែងរករបស់អ្នក។

02 នៅពេលអ្នកលែងប៊ូតុង 🎙 បន្ទាប់ពីបញ្ចូលការនិយាយរបស់អ្នក មុខងារដែលទាក់ទងត្រូវបានចាប់ផ្ដើម។



- អាចនឹងមិនស្គាល់ម៉ូដែលមួយចំនួន។
- **ទីតាំង** របស់អ្នក និង ត្រូវតែទាក់ទងនឹងភាសាសម្រាប់លទ្ធផលស្វែងរកជាក់លាក់។ មុខងារមួយចំនួនប្រហែលជាមិនអាចប្រើបានទេ ប្រសិនបើការកំណត់ទីតាំង និងការកំណត់ភាសារបស់អ្នកមិនដូចគ្នា។
- អ្នកអាចប្ដូរភាសានៅក្នុង ⚙ → ⋮ → **ទូទៅ** → **ភាសា (Language)** → **ភាសាក្នុងម៉ឺនុយ (Menu Language)**។
- ភាសាដែលអាចប្រើបានសម្រាប់លក្ខណៈពិសេសនៃការសម្គាល់សំឡេងអាចនឹងមានការផ្លាស់ប្ដូរ ទៅតាមគោលការណ៍ប្រតិបត្តិការនៃសេវាកម្ម។
- សេចក្ដីលម្អិតអំពីសេវាកម្មអាចនឹងខុសគ្នាទៅតាមម៉ូឌែល។
- សូមកត់ចំណាំសេវាកម្ម AI អាចត្រូវបានផ្លាស់ប្ដូរ លុប ឬបញ្ឈប់ដោយមិនមានការជូនដំណឹង ពីសំណាក់ LGE ឬក្រុមហ៊ុនផ្ដល់សេវាភាគីទីបីទេ។
- អ្នកអាចប្ដូរការកំណត់ពាក់ព័ន្ធនឹងសំឡេង ឬមើលថាតើលក្ខណៈពិសេសណាខ្លះដែលអាចប្រើបានជាមួយសំឡេងនៅក្នុង ⚙ → ⋮ → **ទូទៅ** → **សេវាកម្ម AI** → **សំគាល់សម្លេង** → **ការកំណត់ការសម្គាល់សំឡេង/ជំនួយសម្រាប់ការសម្គាល់សំឡេង**។

## ការប្រុងប្រយ័ត្នចំពោះការស្គាល់សម្ដី

- ម៉ូដស្គាល់សំឡេងទាមទារឲ្យមានMagic Remoteដែលម៉ូដែលជាក់លាក់នានាអាចមិនស្គាល់។
- ដើម្បីប្រើលក្ខណៈពិសេសនៃការសម្គាល់ការនិយាយទាំងអស់ អ្នកត្រូវកំណត់ប៉ុស្តិ៍ តំបន់របស់អ្នក ។ល។ បើពុំដូច្នោះទេ អ្នកមិនអាចប្រើលក្ខណៈពិសេសមួយចំនួនបានឡើយ។

- អ្នកត្រូវមានការតភ្ជាប់បណ្ដាញ ដើម្បីអាចប្រើលក្ខណៈពិសេសនៃការសម្គាល់ការនិយាយបាន។
- បើអ្នកមានការភ្ជាប់បណ្ដាញ អ្នកចាំបាច់ត្រូវយល់ព្រមទទួលយកលក្ខខណ្ឌទូទៅដើម្បីប្រើមុខងារស្គាល់ការនិយាយបាន។
- ដើម្បីគ្រប់គ្រងឧបករណ៍ចាប់រលកសញ្ញាទូរទស្សនដែលភ្ជាប់ជាមួយទូរទស្សន៍តាមរយៈមុខងារសម្គាល់ដោយសំឡេង សូមចូលទៅកាន់ ⚙ → ⋮ → **ការតភ្ជាប់** → **ការកំណត់ការតភ្ជាប់ឧបករណ៍** → **ការកំណត់អង្គបញ្ជាសកល** ដើម្បីរៀបចំតេឡេបញ្ជាសកល។
- សូមណែនាំឱ្យតម្រង់សញ្ញាព្រួញតេឡេ Magic Remote ទៅកាន់ឧបករណ៍ចាប់រលកសញ្ញាទូរទស្សនបន្ទាប់ពីបញ្ចូលសំឡេងហើយ។
- កម្រិតល្បឿននៃមុខងារស្គាល់សម្ដីនិយាយអាចប្រែប្រួលដោយអាស្រ័យលើលក្ខណៈនៃអ្នកប្រើ (កម្រិតសំឡេង ការបញ្ចេញសំឡេង សំនៀង និងល្បឿននៃការនិយាយ) និងបរិយាកាសជុំវិញ (សំឡេង និងកម្រិតសំឡេងនៃទូរទស្សន៍)។
- ដើម្បីទទួលបានលទ្ធផលនៃការស្គាល់សម្ដីនិយាយរបស់អ្នកបានត្រឹមត្រូវ អ្នកត្រូវតែបន្លឺពាក្យតាមរបៀបយឺតៗ ច្បាស់ៗតាមកម្រិតសំឡេងសមស្របដែលមានចម្ងាយប្រហែលជា 4 អ៊ីញ (10 សម) ពីមីក្រូហ្វូននៃMagic Remote
- បើគ្មានការនិយាយរបស់អ្នកឲ្យបានត្រឹមត្រូវទេនោះ មុខងារស្គាល់សម្ដីនិយាយអាចដំណើរការខុសគ្នាពីអ្វីដែលអ្នកចង់បានខាងដើម។

# ការបម្លែងពីការនិយាយទៅជាអត្ថបទ

## ការប្រើសម្ដីទៅអត្ថបទ

អ្នកអាចបញ្ចូលអត្ថបទក្នុងវាលអត្ថបទ ដោយប្រើប្រាស់មុខងារស្គាល់ការនិយាយ។
ជ្រើសរើសប៊ូតុង 🎙 នៅលើក្ដារចុចលើអេក្រង់ ដើម្បីប្ដូរទៅទម្រង់បញ្ចូលការនិយាយ។

- អាចនឹងមិនស្គាល់ម៉ូដែលមួយចំនួន។

01 រំកិលទស្សន៍ទ្រនិចMagic Remoteនៅក្នុងប្រអប់អត្ថបទដើម្បីបើកក្ដារចុចដាក់ស្លែង។



02 ចុចប៊ូតុង 🎤 លើក្តារចុចដាក់ស្លែង។ ឬចុចប៊ូតុង 🎤 នៅលើតេឡេបញ្ជា។

03 បន្ទាប់ពីបើកផ្ទាំងព័ត៌មានចំណាំសំឡេង ដូចបង្ហាញនៅខាងក្រោម និយាយដាក់ មីក្រូហ្វូន លើឧបករណ៍បញ្ជា យឺតៗ និងច្បាស់ៗ។







04 ប្រសិនបើមានពាក្យស្រដៀងគ្នាដែលអ្នកបាននិយាយឮៗ អ្នកអាចឃើញបញ្ជីលទ្ធផលជាច្រើនដូចបានបង្ហាញខាងក្រោម។
ប្រសិនបើអ្នកមិនទទួលបានលទ្ធផលដែលអ្នកចង់បាន ចុច **ព្យាយាមម្តងទៀត** ដើម្បីព្យាយាមម្តងទៀត។ ជ្រើសរើសលទ្ធផល ហើយវានឹងបង្ហាញលើប្រអប់អត្ថបទ។



### ការប្រុងប្រយត្ន័ពេលប្រើប្រាស់សម្ដីទៅជាអត្ថបទ

- ពិនិត្យការផ្គាប់បណ្ដាញ មុនពេលប្រើប្រាស់មុខងារសម្ដីទៅជាអត្ថបទ។
- អ្នកអាចប្ដូរភាសានៅក្នុង ⚙ → ⋮ → **ទូទៅ** → **ភាសា (Language)** → **ភាសាក្នុងម៉ឺនុយ (Menu Language)**។ ដើម្បីប្ដូរទៅជាភាសាចំណាំពាក្យសម្ដីមួយផ្សេងទៀតជាអចិន្ត្រៃយ៍ ចុចប៊ូតុង ⬬ នៅក្នុងផ្ទាំងបង្ហាញព័ត៌មានចំណាំសំឡេងដែល។
- អ្នកអាចប្រើប្រាស់មុខងារនេះ នៅពេលអ្នកយល់ព្រមនឹងលក្ខខណ្ឌការសម្គាល់សំឡេង។
- អត្រាសម្ដីទៅជាអត្ថបទអាចខុសគ្នាផ្អែកលើលក្ខណៈអ្នកប្រើប្រាស់ (សំឡេង ការបញ្ចេញសំឡេង ការលើដាក់សំឡេង និងការនិយាយ) និងបរិស្ថាន (សំឡេង និងកម្រិតសំឡេងទូរទស្សន៍)។
- ដើម្បីបង្កើនភាពត្រឹមត្រូវនៃសម្ដីទៅជាអត្ថបទ អ្នកត្រូវនិយាយឱ្យច្បាស់ និងឮៗ ប្រហែល 10 សង់ទីម៉ែត្រពីមីក្រូហ្វូនMagic Remote។
- ការចំណាំសំឡេងមិនអាចប្រើបាននៅក្នុងចន្លោះដាក់លេខសម្ងាត់ និងរបាអាសយដ្ឋាននៃ **កម្មវិធីរុករកលើអ៊ីនធឺណិត** របស់អ្នកទេ (លើកលែងតែការស្វែងរកទូទៅ)។

# ដើម្បីមើលលក្ខណៈពិសេសច្រើនទៀតនៃតេឡេបញ្ជ ា

## ដើម្បីមើលលក្ខណៈពិសេសច្រើនទៀតនៃតេឡេបញ្ជា

អ្នកអាចគ្រប់គ្រងលក្ខណៈពិសេសច្រើនទៀត
ឬឧបករណ៍ដែលបានភ្ជាប់ខាងក្រៅជាមួយទូរទស្សន៍របស់អ្នកបាន
ដោយប្រើប៊ូតុងដែលបង្ហាញនៅលើអេក្រង់ទូរទស្សន៍របស់អ្នក។

01 ចុចប៊ូតុង ••• លើតេឡេ។

02 ដោយប្រើតេឡេបញ្ជា សូមជ្រើសរើសប៊ូតុងដែលអ្នកពេញចិត្តនៅលើ **សកម្មភាពច្រើនទៀត** ដែលបង្ហាញនៅលើអេក្រង់ទូរទស្សន៍របស់អ្នក។



❶ អ្នកអាចថតអ្វីដែលលើកញ្ចក់ទូរទស្សន៍បាន។

- អាចនឹងមិនស្គាល់ម៉ូដែលមួយចំនួន។
- អ្នកអាចមើល/លុបរូបដែលថតចេញពីកញ្ចក់ទូរទស្សន៍ក្នុងកម្មវិធី **រូបថត និងវីដេអូ**។
- អ្នកអាចចម្លងរូបភាពថតលើអេក្រង់ទៅក្នុងឧបករណ៍ផ្ទុកយូអេសប៊ីនៅក្នុងកម្មវិធី **រូបថត និងវីដេអូ**។
  (អាចនឹងមិនស្គាល់ម៉ូដែលមួយចំនួន។)

❷ ចាប់ផ្ដើម **កម្មវិធីកាលវិភាគទូរទស្សន៍**។

❸ ភ្ជាប់ទៅ **ការណែនាំសម្រាប់អ្នកប្រើប្រាស់**។
ជ្រើសរើស **ការណែនាំសម្រាប់អ្នកប្រើប្រាស់** នៅក្នុងធាតុការកំណត់មួយចំនួនរបស់ទូរទស្សន៍ ដើម្បីឱ្យអ្នកអាចមើលការណែនាំសម្រាប់អ្នកប្រើប្រាស់សម្រាប់ធាតុនោះបាន។

❹ ព័ត៌មានអំពីកម្មវិធីទូរទស្សន៍ដែលអ្នកកំពុងទស្សនា និងធាតុបញ្ចូលពីខាងក្រៅត្រូវបានបង្ហាញនៅលើអេក្រង់។

❺ អ្នកអាចកំណត់របៀបរូបភាព/សំឡេងសម្រាប់ទស្សនាការប្រកួតកីឡា។

❻ អ្នកអាចកំណត់លក្ខណៈពិសេសដែលទាក់ទងនឹងកម្មវិធីដែលអ្នកកំពុងតែទស្សនាបាន។

- លក្ខណៈពិសេសដែលអាចប្រើបានអាចនឹងខុសគ្នា អាស្រ័យលើរលកសញ្ញាផ្សាយ។

- ប្រភេទប៊ូតុងដែលលេចឡើងនៅលើ **សកម្មភាពច្រើនទៀត** មានលក្ខណៈខុសគ្នា អាស្រ័យទៅតាមតំបន់ និងប្រភេទឧបករណ៍ដែលបានភ្ជាប់។

# ការប្រើប្រាស់តេឡេបញ្ជាសកល

## ការកំណត់តេឡេបញ្ជាសកលដោយស្វ័យប្រវត្តិ

នៅពេលអ្នករៀបចំតេឡេបញ្ជាសកល អ្នកអាចគ្រប់គ្រងឧបករណ៍ភ្ជាប់ខាងក្រៅ (ម៉ាស៊ីនចាក់ Blu-ray/ DVD ភាពយន្តនៅផ្ទះ ប្រអប់ចាប់ប៉ុស្តិ៍ ។ល។) ដោយប្រើតេឡេបញ្ជា AI ជាជាងប្រើតេឡេបញ្ជាដែលពួកគេបានកំណត់។

ភ្ជាប់ឧបករណ៍ដែលត្រូវកំណត់ទៅ **HDMI IN** របស់ទូរទស្សន៍ រួចបើកថាមពលរបស់ឧបករណ៍។ ទូរទស្សន៍នឹងស្គាល់ឧបករណ៍ដែលភ្ជាប់ ដើម្បីកំណត់តេឡេបញ្ជាសកលដោយស្វ័យប្រវត្តិ ដោយមិនចាំបាច់កំណត់ដោយផ្ទាល់។

- បន្ទាប់ពីកំណត់តេឡេបញ្ជាសកលរួចហើយ នោះអ្នកអាចនឹងត្រូវធ្វើការកំណត់អ្នកប្រើប្រាស់បន្ថែមមួយចំនួនទៀត។
- វាអាចចំណាយពេលពីរបីវិនាទី ដើម្បីបញ្ចប់ការកំណត់សម្រាប់តេឡេបញ្ជាសកល។
- ក្នុងម៉ូដែលមួយចំនួន អ្នកអាចកំណត់តេឡេបញ្ជាសកលបាន បន្ទាប់ពីបានប្ដូរវាទៅជាធាតុបញ្ចូលនៃឧបករណ៍ដែលបានភ្ជាប់ប៉ុណ្ណោះ។
- អាស្រ័យលើឧបករណ៍ដែលបានភ្ជាប់

វាអាចនឹងមិនស្គាល់លក្ខណៈពិសេសនៃការកំណត់ដោយស្វ័យប្រវត្តិសម្រាប់តេឡេបញ្ជាសកល (ការភ្ជាប់ឧបករណ៍ដោយស្វ័យប្រវត្តិ) ទេ។

### ការកំណត់តេឡេបញ្ជាសកលដោយផ្ទាល់

ប្រសិនបើតេឡេបញ្ជាសកលមិនត្រូវបានកំណត់ដោយស្វ័យប្រវត្តិទេ ឬវាត្រូវបានភ្ជាប់ជាមួយ **AV IN/COMPONENT IN** នោះអ្នកអាចកំណត់វាដោយផ្ទាល់បាន។

01 ជ្រើសរើស ⚙ → ⋮ → **ការតភ្ជាប់** → **ការកំណត់ការតភ្ជាប់ឧបករណ៍** → **ការកំណត់អង្គបញ្ជាសកល**។

02 ជ្រើសរើសប្រភេទឧបករណ៍ដែលអ្នកចង់កំណត់។

03 បញ្ចប់ការកំណត់សម្រាប់តេឡេបញ្ជាសកល ដោយផ្អែកតាមការណែនាំនៅលើអេក្រង់។ អ្នកអាចប្តូរ ឬបោះបង់ការកំណត់តេឡេបញ្ជាសកលបាន។

- មុខងារនេះអាចប្រើបានតែជាមួយMagic Remoteប៉ុណ្ណោះ។
- អ្នកអាចទិញMagic Remoteដោយឡែក ប្រសិនបើគេមិនបានផ្តល់ជូន។
- អាចនឹងមិនស្គាល់ម៉ូដែលមួយចំនួន។
- រន្ធ**AV IN/COMPONENT IN** មានតែក្នុងម៉ូដែលជាក់លាក់មួយចំនួនប៉ុណ្ណោះ។
- នៅពេលប្តូរការកំណត់នៅលើឧបករណ៍ណាមួយ ត្រូវប្រាកដថាបើកឧបករណ៍នោះជាមុនសិន។
- បន្ទាប់ពីភ្ជាប់ជាមួយបណ្ដាញរួចហើយ អ្នកអាចរៀបចំតេឡេបញ្ជាសកល ដោយប្រើព័ត៌មានថ្មីបំផុត។
- សម្រាប់ម៉ាស៊ីនលេងហ្គេម វាមិនស្គាល់លក្ខណៈពិសេសនៃការកំណត់ដោយផ្ទាល់សម្រាប់តេឡេបញ្ជាសកលទេ។
- ប៊ូតុងមួយចំនួនអាចមិនដំណើរការ អាស្រ័យលើម៉ូដែលនៃឧបករណ៍ខាងក្រៅនោះ។
- ដើម្បីគ្រប់គ្រងឧបករណ៍ដែលអ្នកចង់គ្រប់គ្រង សូមតម្រង់តេឡេបញ្ជាវេទមន្តទៅឧបករណ៍នោះ។ ត្រូវប្រាកដថា មិនមានវត្ថុនៅពីមុខឧបករណ៍ទេ ដើម្បីធានាថាអាចទទួលរលកសញ្ញាតេឡេបញ្ជាបានល្អ។

# ចាប់ផ្តើមកម្មវិធីតាមរយៈ មុខងារចូលប្រើរហ័ស

## ការប្រើកម្មវិធីនានាបានយ៉ាងលឿន និងងាយស្រួលជាមួយនឹង មុខងារចូលប្រើរហ័ស។

ចុច ហើយសង្កត់ប៊ូតុងលេខមួយលើតេឡេបញ្ជាដើម្បីបើកកូនកម្មវិធីមួយ ឬដើម្បីដាក់ឲ្យសកម្មនូវទិន្នន័យបញ្ចូលខាងក្រៅដែលបានចុះបញ្ជីចំពោះប៊ូតុង។

### Magic Link

01 ចាប់ផ្ដើមកម្មវិធី ឬជ្រើសរើសប៉ុស្តិ៍ ឬបញ្ចូលអ្វីដែលអ្នកចង់ផ្ដល់។

02 ចុច ហើយសង្កត់ប៊ូតុងលេខ (1~8) ដែលអ្នកចង់ចុះឈ្មោះ។
លេខ 9 ត្រូវបានកំណត់ទៅ **Quick Help**។

03 នៅពេលដែលវិនដូផុសឡើងសម្រាប់ការចុះឈ្មោះលេចចេញមក ជ្រើសរើសចុច **បាទ/ចាស**។

- បើអ្នកចុច ហើយសង្កត់លើប៊ូតុងលេខមួយដែលមានចុះឈ្មោះរួចហើយ នឹងមានការបំពេញមុខងារដែលបានចុះបញ្ជី។
- ដើម្បីពិនិត្យមើលធាតុដែលអាចមានការចុះឈ្មោះបាន ជ្រើសរើសលេខតួលេខមួយដែលមិនទាន់មានការចុះបញ្ជីនៅក្នុងម៉ូដកែសម្រួល **មុខងារចូលប្រើរហ័ស**។
- បើអ្នកកំពុងស្ថិតក្នុងម៉ូដមួយដែល **មុខងារចូលប្រើរហ័ស** មិនអាចដំណើរការបាន នឹងមិនមានការបំពេញសកម្មភាពអ្វីឡើយ។
- បើអ្នកលុបកូនកម្មវិធីដែលបានចុះឈ្មោះ **មុខងារចូលប្រើរហ័ស** នឹងមានការលុបចេញពីបញ្ជីវិញយ៉ាងដូច្នោះដែរ។

## ការពិនិត្យមើល និងការកែសម្រួល មុខងារចូលប្រើរហ័ស។

ចុច ហើយសង្កត់ឲ្យយូរលើប៊ូតុងលេខ 0 ដែលលើតេឡេបញ្ជាពីចម្ងាយរបស់អ្នក។
អេក្រង់កែសម្រួល **មុខងារចូលប្រើរហ័ស** លេចចេញមក។




❶ ការជ្រើសរើសតួលេខមួយដែលមានការចុះឈ្មោះរួចហើយ នឹងបើកឲ្យមានការលុបវាចេញពីបញ្ជីវិញ។

❷ នៅពេលដែលអ្នកជ្រើសរើសតួលេខមួយដែលមិនទាន់មានការចុះឈ្មោះធាតុនានាដែលអាចមានការចុះបញ្ជីបាន នឹងមានការបង្ហាញឲ្យឃើញ។

❸ ធាតុមួយដែលមានការចុះឈ្មោះហើយទៅនឹងតួលេខមួយផ្សេងទៀត មានការបញ្ជាក់ប្រាប់ដោយសញ្ញាគួសធីក។

❹ អ្នកអាចមើលសេចក្ដីណែនាំសង្ខេបសម្រាប់មុខងារនេះបាន។

# ការភ្ជាប់ទៅ SIMPLINK (HDMI-CEC)

# ការប្រើ SIMPLINK

តាមរយៈការប្រើប្រាស់តេឡេបញ្ជាតែមួយ អ្នកអាចងាយស្រួលគ្រប់គ្រងឧបករណ៍ផ្សេងៗដូចជារបារសំឡេង ឬប្រអប់ចាប់ប៉ុស្តិ៍ដែលភ្ជាប់ជាមួយទូរទស្សន៍ ដែលមានរន្ធ HDMI។

- អាចភ្ជាប់ឧបករណ៍បានរហូតដល់បី និងអាចប្រើដំណាលគ្នាបាន។

01 សូមភ្ជាប់រន្ធចេញ SIMPLINK HDMI ទៅរន្ធរបស់ទូរទស្សន៍ **HDMI IN** ដោយប្រើខ្សែ HDMI។

02 ចុចប៊ូតុង ⚙ លើតេឡេ។

03 ជ្រើសរើស ⋮ → **ការតភ្ជាប់** → **ការកំណត់ការតភ្ជាប់ឧបករណ៍**។

04 កំណត់ **SIMPLINK (HDMI-CEC)** ទៅ **បើក**។

05 ផ្លាស់ប្តូរការកំណត់ **ការធ្វើសមកាលកម្មថាមពលដោយស្វ័យប្រវត្តិ** ទៅ **បើក** ឬ **បិទ**
(ប្រសិនបើ Auto Power Sync ត្រូវបានកំណត់ទៅ **បើក**នោះការបើកឧបករណ៍ដែលភ្ជាប់ SIMPLINK នឹងធ្វើឲ្យទូរទស្សន៍បើក។ នៅពេលអ្នកបិទទូរទស្សន៍នោះឧបករណ៍នឹងបិទដែរ។)

06 សូមបើកឧបករណ៍ភ្ជាប់។ នៅពេលទូរទស្សន៍ភ្ជាប់ទៅនឹងឧបករណ៍ដោយស្វ័យប្រវត្តិនោះឧបករណ៍បញ្ចូលនឹងប្តូរ។
ប្រសិនបើឧបករណ៍មិនបានភ្ជាប់ទៅនឹងទូរទស្សន៍ដោយស្វ័យប្រវត្តិទេ សូមចុចប៊ូតុង Input។

- មុខងារនេះដំណើរការជាមួយតែឧបករណ៍ដែលមានឡូហ្គោ SIMPLINK ប៉ុណ្ណោះ។ សូមពិនិត្យឡូហ្គោ SIMPLINK លើឧបករណ៍ភ្ជាប់ខាងក្រៅ។
  ការប្រើប្រាស់ផលិតផលក្រៅពីផលិតផលដែលបានបញ្ជាក់អាចបណ្តាលឱ្យមានបញ្ហាអំឡុងពេលប្រតិបត្តិការ។
- ដើម្បីប្រើ Simplink អ្នកចាំបាច់ត្រូវប្រើខ្សែ HDMI® ដែលមានល្បឿនលឿនជាមួយមុខងារ CEC (Consumer Electronics Control)។ ខ្សែ HDMI® ដែលមានល្បឿនលឿនមានកន្លែងភ្ជាប់ទី 13 សម្រាប់អនុញ្ញាតឱ្យផ្លាស់ប្តូរព័ត៌មានរវាងឧបករណ៍នានា។
- ប្រសិនបើអ្នកចង់ភ្ជាប់សំឡេងចេញក្រៅទៅឧបករណ៍បំពងសំឡេងខាងក្រៅដោយភ្ជាប់តាមខ្សែ HDMI សូមកំណត់ **SIMPLINK (HDMI-CEC)** ទៅ **បើក**។

## មុខងារ SIMPLINK ដែលបានគាំទ្រ

### លេងភ្លាមៗ

នៅពេលអ្នកចាប់ផ្តើមឧបករណ៍ពហុផ្សព្វផ្សាយ
នោះអ្នកអាចមើលឃើញមាតិកាបានភ្លាមៗពីឧបករណ៍លើទូរទស្សន៍
ដោយមិនបាច់បញ្ជាអ្វីទេ។

### បញ្ជាឧបករណ៍ដោយប្រើប្រាស់តេឡេទូរទស្សន៍

ជួយឱ្យអ្នកប្រើប្រាស់បញ្ជាឧបករណ៍ពហុផ្សព្វផ្សាយជាមួយតេឡេទូរទស្សន៍ ដើម្បីមើលមាតិកា។

- មុខងារទស្សន៍ទ្រនិចរបស់Magic Remoteអាចត្រូវបានគេកំណត់។

បិទថាមពលមេ

ប្រសិនបើ **ការធ្វើសមកាលកម្មថាមពលដោយស្វ័យប្រវត្តិ** ត្រូវបានកំណត់ទៅ **បើក** នៅក្នុង **ការកំណត់ការតភ្ជាប់ឧបករណ៍** ហើយអ្នកបិទទូរទស្សន៍ នោះឧបករណ៍ដែលបានភ្ជាប់ជាមួយទូរទស្សន៍របស់អ្នកតាមរយៈ SIMPLINK ក៏នឹងត្រូវបិទផងដែរ។

- មុខងារនេះមាននៅក្នុងឧបករណ៍ជាក់លាក់ប៉ុណ្ណោះ។

បើកថាមពលមេ

ប្រសិនបើ **ការធ្វើសមកាលកម្មថាមពលដោយស្វ័យប្រវត្តិ** ត្រូវបានកំណត់ទៅ **បើក** នៅក្នុង **ការកំណត់ការតភ្ជាប់ឧបករណ៍** ការបើកឧបករណ៍ដែលភ្ជាប់ជាមួយ SIMPLINK ក៏នឹងបើកទូរទស្សន៍ផងដែរ។

- ប្រសិនបើ **SIMPLINK (HDMI-CEC)** ត្រូវបានកំណត់ទៅ **បិទ**នោះ **ការធ្វើសមកាលកម្មថាមពលដោយស្វ័យប្រវត្តិ** មិនអាចកំណត់ទៅជា **បើក**បានទេ។
- អាចនឹងមិនស្គាល់ម៉ូដែលមួយចំនួន។

# វិធីកាត់ៗ (សតខាត់) ចំពោះ លទ្ធភាពប្រើប្រាស់

## វិធីកាត់ៗ (សតខាត់) ចំពោះ លទ្ធភាពប្រើប្រាស់

អ្នកអាចឆ្ពោះទៅកាន់ **លទ្ធភាពប្រើប្រាស់** ដោយផ្ទាល់ ដោយមិនចាំបាច់ចូលម៉ឺនុយសំណុំកំណត់កម្រិតខ្ពស់បាន។

ចុចហើយសង្កត់ឲ្យយូរលើប៊ូតុង ដែលលើតេឡេបញ្ជាពីចម្ងាយរបស់អ្នក។

អ្នកអាចកំណត់ **ភាពឌិតខ្លាំង**, **មាត្រដ្ឋានប្រផេះ**, **បញ្ច្រាសពណ៌**។ល។

# ការភ្ជាប់ឧបករណ៍ធាតុបញ្ចូលទៅ USB

## ការប្រើកណ្ដុរយូអេសប៊ីមានខ្សែ ឬគ្មានខ្សែ

ភ្ជាប់កូនកណ្ដុលរបស់អ្នកទៅរន្ធយូអេសប៊ី។
ប្រើកូនកណ្ដុលដើម្បីរំកិលទស្សន៍ទ្រនិចលើកញ្ចក់ទូរស្សន៍

និងជ្រើសរើសមីនុយដែលអ្នកចង់បាន។

- ប៊ូតុងខាងស្តាំ និងប៊ូតុងពិសេសលើកូនកណ្តុលមិនដំណើរការទេ។
- នៅពេលប្រើកណ្តុរ ឬក្តារចុចយូអេសប៊ីគ្មានខ្សែ ការប្រើអាចប៉ះពាល់ដោយសារចម្ងាយ និងស្ថានភាពគ្មានខ្សែ។

## ការប្រើក្តារចុចយូអេសប៊ីមានខ្សែ ឬគ្មានខ្សែ

ភ្ជាប់ក្តារចុចរបស់អ្នកទៅរន្ធយូអេសប៊ី។
អ្នកអាចបញ្ចូលអត្ថបទដោយប្រើក្តារចុចដែលបានភ្ជាប់។

- យើងមិនអាចបញ្ចូលអត្ថបទលើកញ្ចក់ទូរទស្សន៍មួយចំនួនទេ។
- អ្នកគួរប្រើផលិតផលដែលត្រូវបានធ្វើតេស្តសមត្ថភាពប្រើប្រាស់ជាមួយទូរទស្សន៍ LG។ Logitech K360, Logitech K400, Logitech K750, LG Electronics MKS-1200
- អ្នកអាចប្តូរភាសាដែលត្រូវបញ្ចូលដោយចុចគ្រាប់ចុចប្តូរភាសា ឬគ្រាប់ចុច Alt ខាងស្តាំ និងដោយចុច Ctrl និង Space ដំណាលគ្នា។
- ការប្រើក្តារចុចយូអេសប៊ីគ្មានខ្សែអាចប៉ះពាល់ដោយសារចម្ងាយប្រើប្រាស់ និងបរិយាកាសគ្មានខ្សែ។
- ដើម្បីបញ្ចូលអត្ថបទនៅក្នុងចន្លោះអត្ថបទ ប្រើក្តារចុចលើកញ្ចក់ទូរទស្សន៍របស់អ្នក ឬក្តារចុចយូអេសប៊ី។

## ការប្រើដៃបញ្ជាហ្គេម

ភ្ជាប់ដៃបញ្ជាហ្គេមទៅរន្ធយូអេសប៊ីលើទូរទស្សន៍ ប្រសិនបើហ្គេម ទាមទារដៃបញ្ជា។

- អ្នកគួរប្រើដៃបញ្ជាហ្គេមដែលបានធ្វើតេស្តសមត្ថភាពប្រើប្រាស់ជាមួយទូរទស្សន៍ LG។ Logitech F310, Logitech F510, Logitech F710, Logitech Rumblepad 2, Logitech Cordless Rumblepad 2, Logitech Dual Action Gamepad, MICROSOFT Xbox 360 Controller (cable), SONY Playstation(R)3 Controller

# រីករាយជាមួយទូរទស្សន៍បន្តផ្ទាល់

## ការទទួលបានអត្ថប្រយោជន៍ច្រើនបំផុតពីម៉ឺនុយផ្សាយផ្ទាល់

# ការប្រើម៉ឺនុយបន្តផ្ទាល់

អ្នកអាចប្រើប្រាស់មុខងារពាក់ព័ន្ធដោយងាយស្រួល នៅពេលមើលការផ្សព្វផ្សាយតាមទូរទស្សន៍។
ចុចប៊ូតុង **LIST** លើឧបករណ៍បញ្ជា។
ឬចុចប៊ូតុង **ដំណើរការ (OK)** នៅលើតេឡេបញ្ជា រួចជ្រើសរើស **ប៉ុស្តិ៍**។




1 **ប៉ុស្តិ៍** : មើលតារាងមាតិកាផ្សព្វផ្សាយដែលកំពុងតែចាក់ផ្សាយ។

2 **ការណែនាំ** : អ្នកអាចមើលកម្មវិធី និងពេលវេលារបស់កម្មវិធីនីមួយៗ។
ដើម្បីមើលព័ត៌មានលម្អិត សូមចុច **រីករាយជាមួយទូរទស្សន៍បន្តផ្ទាល់** → **ការមើល ការណែនាំ** ក្នុង **ការណែនាំសម្រាប់អ្នកប្រើប្រាស់**។

3 **កម្មវិធីកាលវិភាគទូរទស្សន៍** : អ្នកអាចបញ្ចូលម៉ោង និងកាលបរិច្ឆេទនៃកម្មវិធី ដើម្បីកំណត់កាលវិភាគសម្រាប់មើល ឬថតវា នៅក្នុងពេលកំណត់ណាមួយ។
ដើម្បីមើលព័ត៌មានលម្អិត សូមចុច **រីករាយជាមួយទូរទស្សន៍បន្តផ្ទាល់** → **ការប្រើ កម្មវិធីកាលវិភាគទូរទស្សន៍** ក្នុង **ការណែនាំសម្រាប់អ្នកប្រើប្រាស់**។

4 **ការថត** : អ្នកអាចពិនិត្យមើលការថតដែលផ្ទុកនៅក្នុងឧបករណ៍ផ្ទុក និងចាក់ការថតបាន។
ដើម្បីមើលព័ត៌មានលម្អិត សូមចុច **រីករាយជាមួយទូរទស្សន៍បន្តផ្ទាល់** → **ការចាក់កម្មវិធីទូរទស្សន៍ដែលបានថត** ក្នុង **ការណែនាំសម្រាប់អ្នកប្រើប្រាស់**។

  - ម៉ឺនុយលេចឡើង ក្នុងករណីដែលបានភ្ជាប់ឧបករណ៍ផ្ទុកខាងក្រៅ និងអាចមើលវីដេអូដែលបានថតតែប៉ុណ្ណោះ។

- ប៉ុស្តិ៍ដែលបង្ហាញនៅក្នុងបញ្ជីប៉ុស្តិ៍គឺជាការកំណត់ ប៉ុស្តិ៍ដែលផ្តល់ដោយអ្នកផ្តល់សេវាផ្សព្វផ្សាយ។ ដូច្នេះ ប្រសិនបើអ្នកផ្តល់សេវាផ្សព្វផ្សាយបានផ្លាស់ប្តូរការកំណត់ប៉ុស្តិ៍របស់ខ្លួនដោយមិនបានជូនដំណឹង នោះប៉ុស្តិ៍ដែលបង្ហាញនៅក្នុងបញ្ជីប៉ុស្តិ៍ អាចខុសពីប៉ុស្តិ៍ទូរទស្សន៍ជាក់ស្តែង។
- ដោយសារព័ត៌មានរបស់ប៉ុស្តិ៍ដែលបង្ហាញនៅក្នុងបញ្ជីប៉ុស្តិ៍មានព័ត៌មានដែលផ្តល់ដោយអ្នកផ្តល់ Electronic Program Guide (EPG) ខាងក្រៅ វាអាចខុសពីប៉ុស្តិ៍ទូរទស្សន៍ជាក់ស្តែង។
- អ្នកត្រូវបញ្ចប់ការកំណត់បណ្តាញ ការកំណត់តំបន់ និងការកំណត់ប៉ុស្តិ៍ស្វ័យប្រវត្តិ ទើបអាចទទួលសេវានៃការផ្សាយផ្ទាល់ធម្មតាបាន។
- ធាតុដែលអាចកំណត់រចនាសម្ព័ន្ធបានខុសគ្នាទៅតាមម៉ូដែល។

# ការមើល ការណែនាំ

## ការមើល **ការណែនាំ**

អ្នកអាចមើលកម្មវិធី និងពេលវេលារបស់កម្មវិធីនីមួយៗ។
ចុចប៊ូតុង **LIST** របស់តេឡេបញ្ជា រួចជ្រើសរើសផ្ទាំង **ការណែនាំ** នៅផ្នែកខាងឆ្វេងនៃអេក្រង់។




1. ចុចលើផ្នែកនីមួយៗ ដើម្បីឱ្យអ្នកអាចផ្លាស់ទីទៅកម្មវិធីបាន។
2. អ្នកមើលព័ត៌មាននៅលើប៉ុស្តិ៍ និងកម្មវិធីផ្សាយបាន។
3. អ្នកអាចមើលព័ត៌មានអំពីកម្មវិធីដែលអ្នកកំពុងមើលក៏ដូចជាព័ត៌មានរបស់កម្មវិធីដែលចង់មើល។
4. ជ្រើសរើសប៊ូតុង ≡ ឬចំណងជើងរបស់កម្មវិធីដែលត្រូវការ។ អ្នកអាចមើលព័ត៌មានអំពីកម្មវិធី និងប្រតិបត្តិការ **ទស្សនា**/**ថត** (មានសម្រាប់តែម៉ូឌែលជាក់លាក់ប៉ុណ្ណោះ) ឬ **ការរំលឹក**/**ការថតដែលបានកំណត់ពេល** (មានសម្រាប់តែម៉ូឌែលជាក់លាក់ប៉ុណ្ណោះ) ។ល។
5. អ្នកនឹងត្រូវបាននាំទៅបញ្ជីកម្មវិធីសម្រាប់ពេលវេលា និងកាលបរិច្ឆេទបច្ចុប្បន្ន។
6. ចាប់ផ្ដើម **កម្មវិធីគ្រប់គ្រងប៉ុស្តិ៍**។
7. អ្នកអាចប្ដូរទំហំបញ្ជីកម្មវិធី ដើម្បីកែតម្រូវចំនួនប៉ុស្តិ៍បានបង្ហាញនៅលើអេក្រង់។
8. កំណត់តម្រង។
9. អ្នកអាចបើក/បិទទូរទស្សន៍ខ្នាតតូចបាន។

- ព័ត៌មានកម្មវិធីមិនត្រូវបានបង្ហាញសម្រាប់ប៉ុស្តិ៍ដែលគ្មានព័ត៌មានប្រកាសដែលបានផ្ដល់ឲ្យនោះទេ។
- អាចនឹងមិនស្គាល់ម៉ូដែលមួយចំនួន។
- ធាតុដែលអាចកំណត់រចនាសម្ព័ន្ធបានខុសគ្នាទៅតាមម៉ូដែល។

# ការពិនិត្យមើលព័ត៌មានអំពីប៉ុស្តិ៍

## ការមើលព័ត៌មានអំពីកម្មវិធី

នៅពេលកំពុងមើលការផ្សាយផ្ទាល់ សូមចុចប៊ូតុង **ដំណើរការ (OK)**។ បដាប៉ុស្តិ៍នឹងបង្ហាញ។




1. ផ្លាស់ទីទៅ **ប៉ុស្តិ៍**។
ដើម្បីមើលព័ត៌មានលម្អិត សូមចុច **រីករាយជាមួយទូរទស្សន៍បន្តផ្ទាល់ → ការទទួលបានអត្ថប្រយោជន៍ច្រើនបំផុតពី ម៉ឺនុយផ្សាយផ្ទាល់** ក្នុង **ការណែនាំសម្រាប់អ្នកប្រើប្រាស់**។

2. វាបង្ហាញព័ត៌មានអំពីកម្មវិធីដែលអ្នកកំពុងមើល។
ជ្រើសរើសផ្ទាំងប៉ុស្តិ៍សម្រាប់បញ្ចូលផ្ទាំងលោតឡើងព័ត៌មានលម្អិត
ដើម្បីឃើញព័ត៌មានលម្អិតអំពីកម្មវិធី
ឬដំណើរការលក្ខណៈពិសេសបន្ថែមដែលពាក់ព័ន្ធនឹងផ្ទាំងនេះ។

   អ្នកអាចមើលព័ត៌មានការផ្សព្វផ្សាយអំពីប៉ុស្តិ៍ផ្សេងៗទៀតដោយការប្រើប៊ូតុង ▲/▼។

   អ្នកអាចមើលព័ត៌មានការផ្សព្វផ្សាយអំពីប៉ុស្តិ៍ដែលអ្នកកំពុងមើលដោយប្រើប៊ូតុង ◀/▶។

   ចុចប៊ូតុង (ពណ៌ខៀវ) នៅលើតេឡេ ដើម្បីផ្លាស់ទីទីតាំងរបស់បដា។

   - លក្ខណៈពិសេសនេះអាចត្រូវបានគ្រប់គ្រងនៅក្នុងផ្ទាំងលោតឡើងព័ត៌មានលម្អិតតែប៉ុណ្ណោះ។

3. វាបង្ហាញមាតិកាដែលទាក់ទងនឹងការថត/Live Playback។
ដើម្បីមើលព័ត៌មានលម្អិត សូមចុច **រីករាយជាមួយទូរទស្សន៍បន្តផ្ទាល់ → Live Playback** ក្នុង **ការណែនាំសម្រាប់អ្នកប្រើប្រាស់**។

4. ប្រសិនបើកម្មវិធីដែលអ្នកកំពុងមើលមានព័ត៌មានដូចជា **អត្ថបទពិពណ៌នា** ឬ **ភាសាជាសំឡេង**
នោះអ្នកអាចកំណត់លក្ខណៈពិសេសទាំងនេះបាន។

- : អ្នកអាចកំណត់ **អត្ថបទពិពណ៌នា**។
- : អ្នកអាចកំណត់ **ភាសាជាសំឡេង**។

- ប្រើបានតែជាមួយការផ្សព្វផ្សាយតាមបែបឌីជីថលប៉ុណ្ណោះ។

· ◉ : អ្នកអាចកំណត់ **ពហុសំឡេង**។

- ប្រើបានតែជាមួយការផ្សព្វផ្សាយតាមបែបអាណាឡូកប៉ុណ្ណោះ។

- លក្ខណៈពិសេសដែលអាចប្រើបានអាចនឹងខុសគ្នា អាស្រ័យលើរលកសញ្ញាផ្សាយ។

# Live Playback

## ការប្រើការលេងឡើងវិញផ្ទាល់ (លេងឡើងវិញតាមពេលវេលាជាក់ស្ដែង)

វាជាមុខងារដែលអ្នកអាចប្រើប្រាស់ដើម្បីរក្សាទុកកម្មវិធីដែលអ្នកកំពុងមើលទៅក្នុងថាសរឹងយូអេសប៊ីជាបណ្ដោះអាសន្ន ដូច្នេះអ្នកអាចចាក់មើលឈុតណាមួយដែលអ្នកមិនបានមើលនៅពេលមើលទូរទស្សន៍។ មុខងារនេះអាចឱ្យអ្នកបន្តមើលពីកន្លែងដែលអ្នកបានមើលពីមុន ប្រសិនបើអ្នកចេញទៅក្រៅ។

01 ស៊កថាសរឹងយូអេសប៊ីចូលទៅក្នុងរន្ធយូអេសប៊ី។

02 ចុចលើប៊ូតុង **ដំណើរការ (OK)** លើតេឡេរបស់អ្នក។

03 ចុចប៊ូតុង **ចាប់ផ្ដើម Live Playback** នៅផ្នែកខាងក្រោមនៃអេក្រង់។

04 នៅពេលមើលការផ្សព្វផ្សាយបន្តផ្ទាល់ ប្រើទស្សន៍ទ្រនិចដើម្បីជ្រើសរើសចំណុចមួយលើរបាដំណើរការដែលអ្នកចង់បន្តការមើល។ អ្នកក៏អាចចុចប៊ូតុង ◀/▶ លើតេឡេរបស់អ្នក ដើម្បីប្រើប្រាស់មុខងារនេះ។
ជ្រើសរើសចំណុចមួយ មុនចំណុចបច្ចុប្បន្នលើរបាដំណើរការ។



- អាចប្រើមុខងារ Live Playback សម្រាប់តែប៉ុស្ដិ៍ផ្សាយដែលអ្នកមើល

ដោយប្រើរន្ធដោតអង់តែនប៉ុណ្ណោះ។ ប៉ុន្តែ អ្នកមិនអាចប្រើប្រាស់ជម្រើសនេះបានទេ នៅពេលកំពុងស្តាប់ប៉ុស្តិ៍វិទ្យុ។

- ជ្រើសរើសឧបករណ៍មួយដែលត្រូវប្រើជាមួយនឹងការលេងឡើងវិញផ្ទាល់នៅពេលថាសរឹងយូអេសប៊ីពីរ ឬច្រើនត្រូវបានភ្ជាប់ទៅទូរទស្សន៍។
- អ្នកមិនអាចប្រើប្រាស់ផ្លាសយូអេសប៊ីបានទេ។ ភា្ជប់ថាសរឹងយូអេសប៊ីមួយដែលមានទំហំ 80 ជីកាបៃឬលើសពីនេះ។
- ប្រសិនបើមិនមានទំហំទំនេរនៅសល់គ្រប់គ្រាន់នៅក្នុង HDD USB ទេ នោះLive Playback អាចដំណើរការមិនបានល្អ។ ដើម្បីប្រើមុខងារ Live Playback អ្នកត្រូវការ HDD USB ដែលមានទំហំយ៉ាងតិច 2.3 ជីកាបៃ។
- ជាមួយនឹងមុខងារលេងឡើងវិញផ្ទាល់ អ្នកអាចដំណើរការកម្មវិធីឡើងវិញរហូតដល់ទៅពីរម៉ោង អាស្រ័យលើសមត្ថភាពផ្ទុកដែលនៅសល់របស់ថាសរឹងយូអេសប៊ី។ ពេលនេះប្រហែលជាមានភាពខុសគ្នាអាស្រ័យទៅលើតំបន់របស់អ្នក។
- វីដេអូដែលរក្សាទុកនៅក្នុងទម្រង់ការលេងឡើងវិញផ្ទាល់ត្រូវបានលុប ប្រសិនបើអ្នកបិទទូរទស្សន៍ដោយមិនបានថតទុក។
- ការប្តូរពីប៉ុស្តិ៍មួយទៅប៉ុស្តិ៍មួយទៀតអំឡុងពេល Live Playback នឹងលុបទិន្នន័យរបស់ប៉ុស្តិ៍ពីមុន។
- អាចនឹងមិនស្គាល់ម៉ូដែលមួយចំនួន។

# ការថត

## ការប្រើមុខងារ

ជាមួយនឹងទូរទស្សន៍ LG webOS អ្នកអាចប្រើមុខងាថតបាន។

### ការប្រើប្រាស់ការថតភ្លាមៗ

01 ភ្ជាប់ថាសរឹងយូអេសប៊ី ឬដ្រាយយូអេសប៊ីទៅរន្ធយូអេសប៊ី។
ជាការល្អ អ្នកគួរថតទុកក្នុងថាសរឹងយូអេសប៊ី។

02 នៅពេលកំពុងមើលការផ្សាយផ្ទាល់ សូមចុចប៊ូតុង **ដំណើរការ (OK)**។

03 ចុចប៊ូតុង នៅផ្នែកខាងក្រោមនៃអេក្រង់។

04 ប្រសិនបើអ្នកចង់ឈប់ថត សូមចុចប៊ូតុង ។




## បញ្ហាដែលត្រូវយកចិត្តទុកដាក់នៅពេលថត

- នៅពេលថត សូមចុចប៊ូតុង **ដំណើរការ (OK)** ដើម្បីបង្ហាញព័ត៌មានអំពីការថត។
- រយៈពេលនៃការថតអាចកំណត់មុនពេលចាប់ផ្ដើមថតបាន។
- ប្រសិនបើឧបករណ៍ផ្ទុកយូអេសប៊ីជាច្រើនត្រូវបានភ្ជាប់ នោះឧបករណ៍ផ្ទុកដែលបានថតទុកចុងក្រោយគេ នឹងត្រូវបានជ្រើសរើសដោយស្វ័យប្រវត្តិ។
- ទំហំទំនេររបស់ថាសរឹងយូអេសប៊ីត្រូវតែមានទំហំយ៉ាងតិចណាស់ 1 ជាកាបៃ។
- ត្រូវតែមានទំហំភាគថាសយ៉ាងហោចណាស់ 4 ជីកាបៃនៅលើដ្រាយយូអេសប៊ី។
- រយៈពេលដែលអាចថតបានអាចខុសគ្នា អាស្រ័យលើសមត្ថភាពផ្ទុករបស់ឧបករណ៍ផ្ទុកយូអេសប៊ីរបស់អ្នក។
- នៅពេលប៉ុនប៉ងថតទុកក្នុងមេម៉ូរី USB លើកដំបូង ទូរទស្សន៍នឹងធ្វើតេស្តលើដំណើរការ។ ចាប់ផ្ដើមថត បន្ទាប់ពីបញ្ចប់ការធ្វើតេស្តជាធម្មតា។
- ដោយសារតែបច្ចេកវិទ្យាការពារមាតិកាត្រូវបានប្រើប្រាស់ វីដេអូដែលបានថតទុកមិនអាចបើកបានលើកុំព្យូទ័រ ឬម៉ូដែលទូរទស្សន៍ផ្សេងៗបានឡើយ។ ហើយវីដេអូក៏មិនអាចចាក់បាន ប្រសិនបើសៀគ្វីវីដេអូទូរទស្សន៍ត្រូវបានប្ដូរ។
- មិនត្រូវដកខ្សែយូអេសប៊ីចេញនៅពេលកំពុងថតឡើយ។
- ប្រសិនបើអ្នកបង្ខំបិទទូរទស្សន៍របស់អ្នកនៅពេលកំពុតថត នោះមាតិកាដែលកំពុងថតអាចមិនត្រូវបានរក្សាទុកបានទេ។ ជាការល្អ អ្នកត្រូវឈប់ថត និងពិនិត្យមើលថាប៉ុស្តិ៍ត្រូវបានថតទុករួច មុនពេលបិទទូរទស្សន៍។
- គុណភាពនៃការថតគឺអាស្រ័យលើដំណើរការរបស់ឧបករណ៍ផ្ទុក USB។
- ប្រសិនបើឧបករណ៍ផ្ទុកយូអេសប៊ីមានបញ្ហា ការថតអាចមិនបញ្ចប់ត្រឹមត្រូវទេ។
- ឧបករណ៍ផ្ទុកយូអេសប៊ីអាចមិនដំណើរការ ឬដំណើរការមិនពេញលេញទេ នៅពេលហាប់យូអេសប៊ី ឬខ្សែតត្រូវបានប្រើ។
- ការថតអាចនឹងត្រូវបានរំខាន ប្រសិនបើទំហំផ្ទុកដែលនៅសល់មានមិនគ្រប់គ្រាន់។ ការប្រើប្រាស់ឧបករណ៍ផ្ទុកដែលមានទំហំគ្រប់គ្រាន់សម្រាប់ថត ត្រូវបានណែនាំ។
- ធាតុដែលអាចកំណត់រចនាសម្ព័ន្ធបានខុសគ្នាទៅតាមម៉ូដែល។
- មុខងារមួយចំនួនប្រហែលមិនអាចប្រើបានទេ នៅពេលការថតកំពុងដំណើរការ។
- មានតែប៉ុស្តិ៍ផ្សាយដែលអ្នកមើល ដោយប្រើរន្ធដោតអង់តែនប៉ុណ្ណោះដែលអាចថតបាន។

- Bluetooth និងរន្ធយូអេសប៊ីអាចមិនដំណើរការបានត្រឹមត្រូវនៅពេលកំពុងថតជាមួយឧបករណ៍យូអេសប៊ីឡើយ។
- ការថតដែលមានរយៈពេលតិចជាង 10 វិនាទីនឹងមិនត្រូវបានរក្សាទុកទេ។
- អ្នកអាចរក្សាទុកមាតិការហូតដល់ចំនួន 600 នៅលើឧបករណ៍ផ្ទុកមួយ។

# ការចាប់យកតន្ត្រី

## ការប្រើការទទួលយកតន្ត្រី

វាជាមុខងារមួយដែលអ្នកអាចប្រើប្រាស់ដើម្បីថតតន្ត្រីពីទូរទស្សន៍បានគ្រប់ពេល។

01 នៅពេលកំពុងមើលការផ្សាយផ្ទាល់ សូមចុចប៊ូតុង **ដំណើរការ (OK)**។

02 ចុចប៊ូតុង ◉ នៅខាងក្រោមជ្រុងខាងឆ្វេងនៃអេក្រង់។

03 ចុចប៊ូតុង **ចាប់ផ្ដើមការថតតន្ត្រី**។




- ជ្រើសរើសឧបករណ៍មួយដែលត្រូវប្រើជាមួយការថតតន្ត្រីនៅពេលថាសរឹងយូអេសប៊ីត្រូវបានភ្ជាប់ជាមួយទូរទស្សន៍។
- ប្រសិនបើមិនមានទំហំទំនេរគ្រប់គ្រាន់ក្នុងឧបករណ៍ ថាសរឹងយូអេសប៊ីទេ ការទទួលយកតន្ត្រីអាចមិនដំណើរការបានពេញលេញឡើយ។ ដើម្បីប្រើប្រាស់មុខងារការទទួលយកតន្ត្រីអ្នកត្រូវមានថាសរឹងយូអេសប៊ីដែលមានទំហំយ៉ាងតិច 100MB។
- ឯកសារដែលបានរក្សាទុកអាចមើលបាននៅក្នុងកម្មវិធី **តន្ត្រី** ហើយអ្នកអាចបើកវាបានលើកំព្យូទ័រ ឬឧបករណ៍ដែលអាចយកតាមខ្លួនបាន។
- ឯកសារដែលបានថតត្រូវបានរក្សាទុកជាប្រភេទ acc ឬ mp3។ (ប្រភេទនៃការរក្សាទុកអាចខុសគ្នាទៅតាមម៉ូដែលទូរទស្សន៍។)
- ប្រសិនបើអ្នកប្ដូរកម្មវិធី ឬបញ្ចូលពេលកំពុងថត នោះការថតត្រូវបញ្ចប់ដោយស្វ័យប្រវត្តិ និងឯកសារដែលបានថតនឹងត្រូវបានរក្សាទុក។
- ប្រើបានតែជាមួយការផ្សព្វផ្សាយតាមបែបអាណាឡូកប៉ុណ្ណោះ។

- ជាមួយមុខងារការទទួលយកតន្ត្រី អ្នកអាចបើកតន្ត្រីបានរហូតដល់ទៅពីរម៉ោង។
- អាចនឹងមិនស្គាល់ម៉ូដែលមួយចំនួន។

# ការប្រើ កម្មវិធីកាលវិភាគទូរទស្សន៍

## ការប្រើ **កម្មវិធីកាលវិភាគទូរទស្សន៍**

អ្នកអាចបញ្ចូលម៉ោង និងកាលបរិច្ឆេទនៃកម្មវិធី ដើម្បីកំណត់កាលវិភាគសម្រាប់មើល ឬថតវា នៅក្នុងពេលកំណត់ណាមួយ។

01 ចុចប៊ូតុង **LIST** របស់តេឡេបញ្ជា រួចជ្រើសរើសផ្ទាំង **កម្មវិធីកាលវិភាគទូរទស្សន៍** នៅផ្នែកខាងឆ្វេងនៃអេក្រង់។

02 ជ្រើសរើស នៅជ្រុងផ្នែកខាងលើ។




❶ អ្នកអាចប្ដូរលំដាប់នៃការតម្រឹម ឬប្រើតម្រងបាន។

❷ អ្នកអាចកំណត់ទម្រង់លុប។

❸ អ្នកអាចកំណត់ការថតដែលបានកំណត់កាលវិភាគថ្មី។

❹ អ្នកអាចកំណត់ការរំលឹកថ្មី។

❺ ចាប់ផ្ដើម **ការណែនាំ**។

### ការកំណត់កាលវិភាគកម្មវិធី

អ្នកអាចជ្រើសរើសកម្មវិធីប៉ុស្តិ៍ទូរទស្សន៍មួយដើម្បីកំណត់ពេលមើល ឬថតទុក។

01 ចុចប៊ូតុង **LIST** របស់តេឡេបញ្ជា រួចជ្រើសរើសផ្ទាំង **ការណែនាំ** នៅផ្នែកខាងឆ្វេងនៃអេក្រង់។

02 ជ្រើសរើសកម្មវិធីដែលអ្នកចង់ថត។
ប្រសិនបើអ្នកចង់ថតការផ្សាយផ្ទាល់ សូមចុចប៊ូតុង **ថត** ឬ **ទស្សនា**។
ក្នុងករណីមានកម្មវិធីដែលជិតមកដល់ សូមចុចប៊ូតុង **ការថតដែលបានកំណត់ពេល** ឬ **ការរំលឹក**។

- ការថតដែលបានកំណត់ពេលមិនធានាពេលវេលាថតទុកត្រឹមត្រូវរបស់កម្មវិធីទេ ពីព្រោះកម្មវិធីនឹងត្រូវថតទុកផ្អែកលើព័ត៌មានដែលផ្តល់ដោយអ្នកផ្សព្វផ្សាយ។
- អនុវត្តចំពោះការផ្សព្វផ្សាយបែបឌីជីថល។

### ការកំណត់កាលវិភាគដោយផ្ទាល់ដៃ

អ្នកអាចជ្រើសរើសកាលបរិច្ឆេទ ម៉ោង និងប៉ុស្តិ៍ដើម្បីមើល ឬថតប៉ុស្តិ៍ទុក។

01 ចុចប៊ូតុង **LIST** របស់តេឡេបញ្ជា រួចជ្រើសរើសផ្ទាំង **កម្មវិធីកាលវិភាគទូរទស្សន៍** នៅផ្នែកខាងឆ្វេងនៃអេក្រង់។

02 ជ្រើសរើស នៅជ្រុងផ្នែកខាងលើ។

03 ជ្រើសរើស ឬ នៅជ្រុងផ្នែកខាងលើ។

04 ជ្រើសរើស **បង្កើតដោយផ្ទាល់**។

05 ចូរកំណត់កាលបរិច្ឆេទ ម៉ោង និងប៉ុស្តិ៍ដែលត្រូវថត ឬមើល។

- រយៈពេលការថតដែលបានកំណត់ពេលត្រូវមានយ៉ាងតិច 1 នាទី។

# ការចាក់កម្មវិធីទូរទស្សន៍ដែលបានថត

## ការគ្រប់គ្រងការថត

អ្នកអាចមើល និងចាក់ការថតដែលផ្ទុកក្នុងឧបករណ៍ផ្ទុកដោយប្រើកម្មវិធី **ការថត**។

01 ចុចប៊ូតុង **LIST** របស់តេឡេបញ្ជា រួចជ្រើសរើសផ្ទាំង **ការថត** នៅផ្នែកខាងឆ្វេងនៃអេក្រង់។

02 ជ្រើសរើស នៅជ្រុងផ្នែកខាងលើ។




1. ជ្រើសរើសឧបករណ៍ផ្ទុកសម្រាប់ចាក់ ប្រភេទនៃការថត វិធីតម្រៀប និងប្រភេទនៃទិដ្ឋភាព។
2. ជ្រើសរើស និងលុបមាតិកា។
3. បង្ហាញព័ត៌មានលម្អិតអំពីមាតិកា។
   អ្នកអាចប្ដូរចំណងជើងរបស់មាតិកានៅក្នុងព័ត៌មានដែលបង្ហាញឡើង។
4. ចាប់ផ្ដើម **ស្វែងរក**។

- អ្នកអាចលេងការថតដែលបានធ្វើឡើងនៅលើទូរទស្សន៍បច្ចុប្បន្ននៅក្នុង **ការថត**។

# ការបើកស្ដាប់ការថត

អ្នកអាចចូលប្រើ និងដំណើរការមុខងារងាយៗដូចជា ការចាក់ និងផ្អាកលើអេក្រង់ដែលកំពុងចាក់។

01 ជ្រើសរើសការថតដែលអ្នកចង់បានពីកម្មវិធី **ការថត**។

02 អ្នកអាចគ្រប់គ្រងការចាក់ការថតរបស់អ្នកដោយចុចប៊ូតុង **ដំណើរការ (OK)** នៅពេលកំពុងចាក់។



❶ អ្នកអាចដំណើរការមុខងារដែលទាក់ទងនឹងការចាក់ងាយៗបាន។
❷ អ្នកអាចរៀបចំការកំណត់ដែលទាក់ទងនឹងការចាក់វីដេអូឡើងវិញ។
❸ វានឹងប្ដូរអេក្រង់ដែលអ្នកអាចកំណត់មុខងារបន្ថែមទៀត។

### ការកំណត់មុខងារបន្ថែម

01 ចុចប៊ូតុង **ដំណើរការ (OK)** នៅពេលកំពុងចាក់ចាក់ស្ដាប់ការថតដែលចង់បាន។

02 ជ្រើសរើស ⋯ នៅលើកញ្ចក់ទូរទស្សន៍។




❶ ត្រឡប់ទៅកាន់ **ការថត**។
❷ បង្ហាញបញ្ជីនៃការថតក្រោមរូបភាពតូចៗ នៅពេលចាក់ការថត។
❸ បិទ ឬបើកអក្សររត់ពីក្រោម។
❹ ជ្រើសរើសភាសាសម្លេងដែលអាចដាក់ចេញក្រៅ
❺ អ្នកអាចកំណត់ការមើលបន្ត ដើម្បីបន្តលេងពីឈុតដែលមានមើលចុងក្រោយ។
❻ ត្រឡប់ទៅអេក្រង់ប្រតិបត្តិការមូលដ្ឋាន។

- ធាតុដែលអាចកំណត់រចនាសម្ព័ន្ធបានខុសគ្នាទៅតាមម៉ូដែល។

# អក្សរសន្ទស្សន៍

## ដើម្បីប្រើអត្ថបទបង្ហាញលើទូរទស្សន៍

អត្ថបទបង្ហាញលើទូរទស្សន៍ជាសេវាឥតគិតថ្លៃមួយដែលផ្ដល់ដោយស្ថានីយទូរទស្សន៍ដែលផ្ដល់ព័ត៌មានជាអក្សរអំពីកម្មវិធីទូរទស្សន៍ ព័ត៌មាន និងអាកាសធាតុ។
កម្មវិធីបម្លែងអត្ថបទបង្ហាញលើទូរទស្សន៍របស់ទូរទស្សន៍នេះអាចគាំទ្រប្រព័ន្ធ SIMPLE, TOP

និង FASTEXT ។

01 ចុចប៊ូតុង ••• លើតេឡេ។

02 ជ្រើសរើស **អក្សរសន្ទស្សន៍**។

03 បង្អួចអត្ថបទបង្ហាញលើទូរទស្សន៍លេចឡើង។

04 ដើម្បីមើលការផ្សាយទូរទស្សន៍ និងអក្សរសន្ទស្សន៍ព្រមគ្នា សូមចុចប៊ូតុង ••• នៅលើតេឡេបញ្ជា រួចជ្រើសរើស **អក្សរសន្ទស្សន៍**។

ប៊ូតុងពណ៌

ជ្រើសរើសទំព័របន្ទាប់ ឬខាងក្រោម។

ប៊ូតុងលេខ

បញ្ចូលលេខទំព័រដើម្បីផ្លាស់ប្តូរ។

ប៊ូតុង (ប៉ុស្តិ៍) ∧/∨

ជ្រើសរើសទំព័របន្ទាប់ ឬខាងក្រោម។

- អាចនឹងមិនស្គាល់ម៉ូដែលមួយចំនួន។

# មុខងារអត្ថបទបង្ហាញលើទូរទស្សន៍ពិសេស

01 ចុចប៊ូតុង ••• លើតេឡេ។

02 ជ្រើសរើស **ជម្រើសអក្សរសន្ទស្សន៍**។

03 ជ្រើសរើសមីនុយ **អក្សរសន្ទស្សន៍**។

### Index

ជ្រើសរើសទំព័រលិបិក្រមនីមួយៗ។

### ម៉ោង

នៅពេលមើលប៉ុស្តិ៍ទូរទស្សន៍ សូមជ្រើសរើសមីនុយនេះ ដើម្បីបង្ហាញពេលវេលានៅខាងលើផ្នែកខាងស្តាំនៃកញ្ចក់ទូរទស្សន៍។ នៅក្នុងទម្រង់អត្ថបទបង្ហាញលើទូរទស្សន៍ ចុចប៊ូតុងនេះ ដើម្បីជ្រើសរើសលេខទំព័ររង។ លេខទំព័ររងត្រូវបានបង្ហាញនៅផ្នែកខាងក្រោមនៃអេក្រង់។ ដើម្បីបន្ត ឬប្តូរទំព័ររង សូមចុច /, ◀/▶ ឬប៊ូតុង Number។

### រង់ចាំ

បញ្ឈប់ទំព័រមិនឲ្យប្តូរដោយស្វ័យប្រវត្តិដែលនឹងកើតឡើង ប្រសិនបើទំព័រអត្ថបទបង្ហាញលើ

ទូរទស្សន៍មានទំព័ររង 2 ឬច្រើនជាងនេះ។ ចំនួនទំព័ររងនិងទំព័ររងតាមធម្មតាត្រូវបានបង្ហាញលើអេក្រង់ខាងក្រោមម៉ោង។ នៅពេលម៉ឺនុយនេះត្រូវបានជ្រើសរើស និមិត្តសញ្ញាបញ្ឈប់ត្រូវបានបង្ហាញនៅជ្រុងខាងលើផ្នែកខាងឆ្វេងនៃអេក្រង់ ហើយការប្តូរលេខទំព័រស្វ័យប្រវត្តិមិនអាចប្រើបានទេ។

### បង្ហាញ

ជ្រើសរើសមីនុយនេះដើម្បីបង្ហាញព័ត៌មានលាក់ ដូចជាចម្លើយប្រស្នា ឬល្បែងប្រាជ្ញា។

### អាប់ដេត

បង្ហាញរូបភាពទូរទស្សន៍លើកញ្ចក់ នៅពេលកំពុងរង់ចាំទំព័រអត្ថបទបង្ហាញលើទូរទស្សន៍។ ការបង្ហាញលេងលេចឡើងនៅជ្រុងខាងឆ្វេងដៃផ្នែកខាងលើនៃអេក្រង់។ នៅពេលមានទំព័របានធ្វើបច្ចុប្បន្នភាព បន្ទាប់មកការបង្ហាញនឹងប្តូរទៅលេខទំព័រ។ ជ្រើសរើសម៉ឺនុយនេះម្តងទៀត ដើម្បីមើលទំព័រអត្ថបទបង្ហាញលើទូរទស្សន៍បានធ្វើបច្ចុប្បន្នភាព។

### ភាសា

កំណត់ភាសារបស់អត្ថបទដែលបង្ហាញលើទូរទស្សន៍។

- តែក្នុងទម្រង់ឌីជីថលប៉ុណ្ណោះ

## ដើម្បីកំណត់ភាសារបស់អត្ថបទដែលបង្ហាញលើទូរទស្សន៍

ប្រើមុខងារភាសាអត្ថបទបង្ហាញលើទូរទស្សន៍នៅពេលភាសាអត្ថបទបង្ហាញលើទូរទស្សន៍ពីរ ឬច្រើនកំពុងត្រូវបានផ្សាយ។

01 ចុចប៊ូតុង ⚙ លើតេឡេ។

02 ជ្រើសរើស ⋮ → **ទូទៅ** → **ភាសា (Language)** → **ភាសាអក្សរសន្ទស្សន៍ចម្បង/ភាសាអក្សរសន្ទស្សន៍ទីពីរ**។

- តែក្នុងទម្រង់ឌីជីថលប៉ុណ្ណោះ
- ប្រសិនបើទិន្នន័យអត្ថបទបង្ហាញលើទូរទស្សន៍មិនត្រូវផ្សាយជាភាសាដែលបានជ្រើសរើសទេ ភាសាលំនាំដើមនឹងបង្ហាញ។
- ប្រសិនបើអ្នកជ្រើសរើសប្រទេសក្នុងតំបន់ខុសអត្ថបទបង្ហាញលើទូរទស្សន៍នឹងបង្ហាញមិនបានត្រឹមត្រូវលើកញ្ចក់ទូរទស្សន៍ទេ ហើយបញ្ហាមួយចំនួនអាចកើតឡើងនៅក្នុងប្រតិបត្តិការអត្ថបទបង្ហាញលើទូរទស្សន៍។

# HbbTV

# ស្វែងយល់បន្ថែមអំពី HbbTV

HbbTV (Hybrid Broadcast Broadband TV)
គឺជាស្តង់ដារផ្សព្វផ្សាយថ្មីមួយដែលអាចប្រើសេវាប្រភេទអត្ថបទបង្ហាញលេងទូរទស្សន៍ពិសេស ដែលផ្សព្វផ្សាយដោយកម្មវិធីផ្សព្វផ្សាយទូរទស្សន៍ ដើម្បីបញ្ចូល ឬភ្ជាប់ទៅនឹងសេវាលើប្រព័ន្ធអ៊ីនធឺណិតលើរលកអាកាសទៅ Smart TV ដែលបានភ្ជាប់។ ដូច្នេះ អតិថិជនអាចប្រើប្រាស់សេវាលើប្រព័ន្ធអ៊ីនធឺណិតជាច្រើនដូចជា catch-up TV និង Video on Demand (VOD) និងកម្មវិធីដែលទាក់ទងនឹងការប្រើ និងសេវាព័ត៌មានសម្បូរបែបដទៃទៀត ដែលបន្ថែមពីលើសេវាអត្ថបទបង្ហាញលើទូរទស្សន៍ឌីជីថលចាស់ៗដែល ទាំងអស់នេះនឹងបញ្ចូលក្នុងទូរទស្សន៍ដោយផ្ទាល់ជាមួយបទពិសោធន៍គ្មានកំណត់។ សេវាទូរទស្សន៍ HbbTV អាចដំណើរការតាមវិធីជាច្រើន ហើយវិធីដែល ដែលគេពេញនិយមចុចបំផុតគឺ ។ ជាធម្មតា អ្នកប្រើប្រាស់ស្វែងរកសេវាដោយប្រើគ្រាប់ចុចស្វែងរកធម្មតា (ដូចជាប៊ូតុងយល់ព្រម និង , , , )។ កំណែបច្ចុប្បន្នរបស់ទូរទស្សន៍ HbbTV ក៏មានការគាំទ្រ “ការផ្សាយយកលំនាំតាម” របស់វីដេអូលើការភ្ជាប់រលកអាកាស ដែលធានាគុណភាពរូបភាពដែលមានល្អបំផុតសម្រាប់អ្នកមើល។ សម្រាប់ព័ត៌មានបន្ថែមអំពី HbbTV សូមចូលទៅ www.hbbtv.org

- អាចនឹងមិនស្គាល់ម៉ូដែលមួយចំនួន។

# ដើម្បីប្រើទូរទស្សន៍ HbbTV

→ → **ប៉ុស្តិ៍** → **HbbTV**

កំណត់ទូរទស្សន៍ HbbTV ទៅបើក។
រីករាយជាមួយមាតិកាជាច្រើនពីសេវារបស់ទូរទស្សន៍ Hbb TV។

- មុខងារសេវាអាចមានកំណត់ នៅពេលទូរទស្សន៍មិនបានភ្ជាប់អ៊ីនធឺណិត។
- មុខងារ និងគុណភាពរបស់សេវាទូរទស្សន៍ HbbTV អាចខុសៗគ្នាអាស្រ័យលើគុណភាពនៃការភ្ជាប់រលកអាកាសរបស់អ្នក។
- សេវាទូរទស្សន៍ HbbTV មិនធានាថាអាចប្រើកម្មវិធីទាំងអស់ទេ - បានតែកម្មវិធីដែលអ្នកផ្សព្វផ្សាយរបស់អ្នកជ្រើសរើសដើម្បីគាំទ្រប៉ុណ្ណោះ។
- អាចនឹងមិនស្គាល់ម៉ូដែលមួយចំនួន។
- នៅពេល Live Playback កំពុងដំណើរការ HbbTV នឹងត្រូវបានបិទ។
- នៅពេលកំពុងប្រើប្រាស់សេវាទូរទស្សន៍ HbbTV គ្រាប់ចុចស្វែងរក និងប៊ូតុង **ដំណើរការ (OK)** អាចត្រូវបានបិទ ប្រសិនបើទស្សន៍ទ្រនិចរបស់គេឡើពិសេសដំណើរការលើកញ្ចក់ទូរទស្សន៍។ ក្នុងករណីនេះ សូមចុចគ្រាប់ចុចឆ្វេង ស្តាំ លើ និងក្រោម ដើម្បីបញ្ឈប់ទស្សន៍ទ្រនិច។ (ការធ្វើបែបនេះអនុវត្តចំពោះតែម៉ូដែលដែលមានMagic Remoteប៉ុណ្ណោះ។)

# ការរីករាយប្រើប្រាស់ LG Content Store

## ការរុករកនៅក្នុង LG Content Store

### ការប្រើ LG Content Store

អ្នកអាចទាញយក និងប្រើកម្មវិធីពីប្រភេទផ្សេងៗដូចជា ការអប់រំ ការកម្សាន្ត បែបផែនជីវិត ព័ត៌មាន និងហ្គេមជាដើម។

01 ចុចប៊ូតុង ⌂ លើតេឡេ។

02 បើកដំណើរការ **LG Content Store**។




- មាតិកាដែលបានផ្តល់ជូនអាចនឹងខុសគ្នា ឬលក្ខណៈពិសេសមួយចំនួនអាចនឹងមានកំណត់អាស្រ័យទៅតាមម៉ូដែល។
- ត្រូវចេះប្រុងប្រយ័ត្ននៅពេលកំពុងមានការប្រើដោយកុមារ។ កុមារអាចនឹងមានលទ្ធភាពមើលមេឌៀ ឬមាតិកាមិនត្រឹមត្រូវនៅអនឡាញតាមរយៈផលិតផលនេះបាន។ អ្នកអាចទប់ស្កាត់មាតិកាលើអ៊ីនធឺណិតដែលមិនសមរម្យ ដោយកម្រិតការចូលប្រើប្រាស់កម្មវិធីមួយចំនួន។ កំណត់រចនាសម្ព័ន្ធឲ្យសំណុំកំណត់នេះនៅ ⚙ → ⋮ → **ទូទៅ** → **សុវត្ថិភាព** → **ការចាក់សោកម្មវិធី**។

### ការដំឡើងកម្មវិធី

អ្នកអាចដំឡើងកម្មវិធីផ្សេងៗនៅលើទូរទស្សន៍របស់អ្នកពី **LG Content Store**។




01 ចុចប៊ូតុង លើតេឡេ។

02 បើកដំណើរការ **LG Content Store**។

03 ជ្រើសរើសប្រភេទ **កម្មវិធីទាំងអស់** ដែលបង្ហាញនៅជ្រុងខាងលើនៃអេក្រង់។ បញ្ជីកម្មវិធីដែលមាននៅក្នុងប្រភេទដែលបានជ្រើសរើសនឹងត្រូវបានបង្ហាញ។

04 ជ្រើសរើសកម្មវិធី ដើម្បីរៀបចំពីបញ្ជី។

05 អានព័ត៌មានលម្អិតអំពីកម្មវិធី រួចចុច **ដំឡើង**។

06 នៅពេលការដំឡើងបានបញ្ចប់ អ្នកអាចដំណើរការកម្មវិធីបានភ្លាមៗ។

- ប្រភេទដែលមាននឹងប្រែប្រួលតាមប្រទេស ឬស្ថានភាពសេវាកម្ម។
- បើទំហំផ្ទុកក្នុងទូរទស្សន៍របស់អ្នកមិនគ្រប់គ្រាន់ អ្នកអាចដំឡើងកម្មវិធីដោយតភ្ជាប់ឧបករណ៍អង្គចងចាំខាងក្រៅ។
- ឧបករណ៍ផ្ទុកយូអេសប៊ីមួយចំនួន អាចមិនស្គាល់ ឬមានដំណើរការមិនស្រួល។
- ដ្រាយយូអេសប៊ីដែលមានកម្មវិធីពីទូរទស្សន៍ផ្សេងអាចមិនត្រូវបានប្រើប្រាស់ទេ។
- អ្នកអាចលុបកម្មវិធី ដែលអ្នកបានទាញយកនៅក្នុង **កម្មវិធីរបស់ខ្ញុំ**។

# ការណែនាំអំពីមាតិកា

## ការណែនាំអំពីមាតិកា

អ្នកអាចទទួលបានការណែនាំអំពីមាតិកា ដោយផ្អែកលើកម្មវិធីទូរទស្សន៍ដែលអ្នកកំពុងទស្សនា ឬទម្លាប់នៃការមើលទូរទស្សន៍។ ប្រសិនបើអ្នកកំពុងទស្សនាទូរទស្សន៍ ដោយប្រើប្រអប់ចាប់ប៉ុស្តិ៍ អ្នកត្រូវតែបញ្ចប់ការរៀបចំតេឡេបញ្ជាសកល ដើម្បីអាចប្រើលក្ខណៈពិសេសនៃការណែនាំបានធម្មតា។ សម្រាប់ព័ត៌មានបន្ថែម សូមមើល

របៀបប្រើទូរទស្សន៍ → ការប្រើប្រាស់តេឡេបញ្ជាសកល ក្នុង ការណែនាំសម្រាប់អ្នកប្រើប្រាស់។

01 ចុចប៊ូតុង លើតេឡេ។

02 បើកដំណើរការ ។




- អាចនឹងមិនស្គាល់ម៉ូដែលមួយចំនួន។
- អ្នកត្រូវតែភ្ជាប់ទៅបណ្ដាញ ដើម្បីប្រើលក្ខណៈពិសេសនៃការណែនាំ។
- សេវាកម្មមានភាពខុសគ្នាទៅតាមប្រទេស ដូច្នេះហើយការណែនាំអាចនឹងត្រូវបានផ្ដល់ជូនខុសៗគ្នា។
- បញ្ជីការណែនាំអាចនឹងមិនសូវពាក់ព័ន្ធ ឬមិនពាក់ព័ន្ធ អាស្រ័យលើព័ត៌មានរបស់កម្មវិធីទូរទស្សន៍ដែលអ្នកកំពុងទស្សនា។

# ការស្វែងរកមាតិកា

## ការស្វែងរកមាតិកា

អ្នកអាចទទួលបានការណែនាំអំពីមាតិកា ដោយផ្អែកលើទម្លាប់នៃការទស្សនា ឬស្វែងរកមាតិកាដែលអ្នកចង់បានដោយខ្លួនអ្នក។

01 ចុចប៊ូតុង លើតេឡេ។

02 បើកដំណើរការ ។

03 ស្វែងរកមើលមេឌៀ ឬមាតិកា និងព័ត៌មាននានាដែលប្រើពាក្យស្វែងរកដែលចង់បាន។




❶ ត្រឡប់ទៅអេក្រង់មុន។

❷ លក្ខណៈពិសេសនេះផ្តល់ជូនបញ្ជីមាតិកាសម្រាប់ប្រភេទដែលបានជ្រើសរើស។

❸ វាយបញ្ចូលពាក្យស្វែងរក។

❹ ចាកចេញពី ស្វែងរក។

- អ្នកត្រូវភ្ជាប់ទៅបណ្ដាញ ដើម្បីប្រើលក្ខណៈពិសេសនៃការស្វែងរក។
- លទ្ធផលស្វែងរកអាចប្រែប្រួលដោយអាស្រ័យលើប៉ុស្តិ៍ តំបន់ កំណត់បណ្ដាញ និងលក្ខខណ្ឌទូទៅដែលបានយល់ព្រមទទួលយករួចមកហើយ។

# ការភ្ជាប់ទៅឧបករណ៍ខាងក្រៅ

## ការប្រើ ផ្ទាំងគ្រប់គ្រងផ្ទះ

### ការប្រើ ផ្ទាំងគ្រប់គ្រងផ្ទះ

អ្នកអាចជ្រើសរើស ឬគ្រប់គ្រងឧបករណ៍ (ឧបករណ៍ចល័ត ឧបករណ៍ខាងក្រៅ ឧបករណ៍ IoT នៅក្នុងផ្ទះ ។ល។) ដែលភ្ជាប់ជាមួយទូរទស្សន៍។
ចុចប៊ូតុង ⌂ នៅលើតេឡេបញ្ជា រួចជ្រើសរើស **ផ្ទាំងគ្រប់គ្រងផ្ទះ**។
អ្នកក៏អាចចុចឲ្យជាប់លើប៊ូតុង ⏏ នៅលើតេឡេបញ្ជា។




❶ អ្នកអាចពិនិត្យមើល និងជ្រើសរើសឧបករណ៍ឆ្លាតវៃដែលភ្ជាប់ជាមួយកម្មវិធី LG ThinQ ។ សូមពិនិត្យមើល **ការភ្ជាប់ទៅឧបករណ៍ខាងក្រៅ** → **ការភ្ជាប់ឧបករណ៍ឆ្លាតវៃ** នៅក្នុង **ការណែនាំសម្រាប់អ្នកប្រើប្រាស់** សម្រាប់ព័ត៌មានបន្ថែមអំពីសកម្មភាពនេះ។

❷ ប្រើ AirPlay/HomeKit ដើម្បីគ្រប់គ្រងទូរទស្សន៍របស់អ្នក និងមើលមាតិកាពី iPad ឬ Mac របស់អ្នកនៅលើអេក្រង់ទូរទស្សន៍។

- លទ្ធភាពផ្តល់ជូន និងការចូលប្រើប្រាស់មាតិកា និងសេវាកម្មក្នុងឧបករណ៍ LGE អាចនឹងមានការផ្លាស់ប្តូរគ្រប់ពេល ដោយគ្មានការជូនដំណឹងជាមុន។

❸ អ្នកអាចចាក់សំឡេងពីឧបករណ៍ឆ្លាតវៃ ដែលភ្ជាប់តាមរយៈ Bluetooth បាន។ សូមពិនិត្យមើល **ការភ្ជាប់ទៅឧបករណ៍ខាងក្រៅ** → **លេងសំឡេងពីឧបករណ៍ឆ្លាតៃតាមរយៈអូប៉ាល័ររបស់ទូរទស្សន៍** នៅក្នុង **ការណែនាំសម្រាប់អ្នកប្រើប្រាស់** សម្រាប់ព័ត៌មានបន្ថែមអំពីសកម្មភាពនេះ។

❹ អ្នកអាចពិនិត្យមើល និងជ្រើសរើសឧបករណ៍ដែលភ្ជាប់ខាងក្រៅ តាមរយៈរន្ធបញ្ចូលខាងក្រៅ ឬបណ្តាញបាន។

❺ ឧបករណ៍បំពងសំឡេងដែលបានជ្រើសរើសបច្ចុប្បន្នត្រូវបានបង្ហាញ ហើយអ្នកអាចទៅកាន់អេក្រង់ការកំណត់របស់ឧបករណ៍បំពងសំឡេងបាន។

❻ អ្នកអាចមើល ហើយជ្រើសរើសឧបករណ៍ផ្ទុកដែលបានជ្រើសរើស។

❼ អ្នកអាចពិនិត្យមើល និងគ្រប់គ្រងឧបករណ៍ដែលភ្ជាប់តាមរយៈ IoT នៅក្នុងផ្ទះ។ សូមពិនិត្យមើល **ការភ្ជាប់ទៅឧបករណ៍ខាងក្រៅ** → **ការភ្ជាប់ ឧបករណ៍ IoT នៅក្នុងផ្ទះ** នៅក្នុង **ការណែនាំសម្រាប់អ្នកប្រើប្រាស់** សម្រាប់ព័ត៌មានបន្ថែមអំពីសកម្មភាពនេះ។

❽ អ្នកអាចគ្រប់គ្រងឧបករណ៍របស់អ្នកបានយ៉ាងងាយស្រួល តាមរយៈការកំណត់ប្រតិបត្តិការដែលចង់ធ្វើជាមុន។

❾ **ចូលគណនី** : អ្នកអាចចូល/ចេញពីគណនី LG ThinQ ដែលអ្នកបានបង្កើតនៅលើឧបករណ៍ចល័តបាន។
**កែសម្រួល** : អ្នកអាចកែឈ្មោះរបស់ឧបករណ៍ដែលភ្ជាប់ជាមួយ **ធាតុបញ្ចូល** ឬ **ឧបករណ៍ IoT នៅក្នុងផ្ទះ** ឬប្រើការកំណត់ដែលពាក់ព័ន្ធ។
**ភ្ជាប់ទៅឧបករណ៍បំពងសំឡេងឆ្លាតវៃ** : អ្នកអាចគ្រប់គ្រងទូរទស្សន៍របស់អ្នកបាន តាមរយៈការភ្ជាប់ទៅ ឧបករណ៍បំពងសំឡេងឆ្លាតវៃ ខាងក្រៅ។

❿ វាវិប្រែសបញ្ជីឧបករណ៍។

⓫ ចាកចេញពី **ផ្ទាំងគ្រប់គ្រងផ្ទះ**។

- ធាតុដែលអាចកំណត់បានមានភាពខុសគ្នា ទៅតាមម៉ូដែល ឬតំបន់។

# ការភ្ជាប់ ឧបករណ៍ IoT នៅក្នុងផ្ទះ

## ការភ្ជាប់ ឧបករណ៍ IoT នៅក្នុងផ្ទះ

អ្នកអាចពិនិត្យមើល និងគ្រប់គ្រងស្ថានភាពនៃ ឧបករណ៍ IoT នៅក្នុងផ្ទះ ដែលបានភ្ជាប់។

01 ដំឡើងកម្មវិធី LG ThinQ នៅលើស្មាតហ្វូនរបស់អ្នក។

02 ចូលគណនី LG ThinQ របស់អ្នក រួចចុះឈ្មោះឧបករណ៍ LG ThinQ របស់អ្នក។

03 ចុចប៊ូតុង ⌂ នៅលើតេឡេបញ្ជា រួចជ្រើសរើស **ផ្ទាំងគ្រប់គ្រងផ្ទះ**។

04 ចុច ⚙ នៅខាងលើផ្នែកខាងស្តាំ ដើម្បីជ្រើសរើស **ចូលគណនី**។

05 ចូលគណនី LG ThinQ របស់អ្នក។ បញ្ជីឧបករណ៍ LG ThinQ ដែលបានចុះឈ្មោះរួចហើយនឹងលេចឡើង។

- ប្រសិនបើអ្នកនៅតំបន់ដែលមិនអាចប្រើកម្មវិធី LG ThinQ បាន ការតភ្ជាប់ឧបករណ៍ LG ThinQ នឹងមិនអាចប្រើបានទេ។
- ដើម្បីចុះឈ្មោះ ឧបករណ៍ដែលអាចប្រើ OCF (Open Connectivity Foundation)[1] របស់អ្នក ឬឧបករណ៍ IoT ផ្សេងទៀត សូមជ្រើសរើស **ភ្ជាប់ឧបករណ៍ IoT នៅក្នុងផ្ទះ** រួចអនុវត្តតាមការណែនាំ ដើម្បីប្រើការកំណត់។
  1) ឧបករណ៍ដែលអាចប្រើ OCF (Open Connectivity Foundation): ឧបករណ៍ដែលមានការទទួលស្គាល់ពីស្ថាប័នអភិវឌ្ឍស្តង់ដារឧបករណ៍ដែលភ្ជាប់អ៊ីនធឺណិត
- ប្រសិនបើអ្នកកំពុងតែបញ្ជាឧបករណ៍ខាងក្រៅពីកម្មវិធីឧបករណ៍ចល័តរបស់អ្នក អ្នកប្រហែលជាមិនអាចបញ្ជាឧបករណ៍ពីទូរទស្សន៍របស់អ្នកបានទេ។ ចាកចេញពីកម្មវិធីឧបករណ៍ចល័ត ដើម្បីបញ្ជាវាពីទូរទស្សន៍របស់អ្នក។



❶ អ្នកអាចគ្រប់គ្រងឧបករណ៍របស់អ្នកបានយ៉ាងងាយស្រួល តាមរយៈការកំណត់ប្រតិបត្តិការដែលចង់ធ្វើជាមុន។

❷ អ្នកអាចចូល/ចេញពីគណនី LG ThinQ ដែលអ្នកបានបង្កើតនៅលើឧបករណ៍ចល័តបាន។

❸ **បញ្ជីកែសម្រួល** : អ្នកអាចប្ដូរឈ្មោះ **បង្ហាញ/លាក់** ឬប្ដូរលំដាប់របស់ឧបករណ៍ដែលភ្ជាប់ជាមួយ **ឧបករណ៍ IoT នៅក្នុងផ្ទះ**។
**ការជូនដំណឹង** : ប្រសិនបើអ្នក **បើក** វា
នោះអ្នកនឹងអាចទទួលបានការជូនដំណឹងអំពីស្ថានភាពនៃ ឧបករណ៍ IoT នៅក្នុងផ្ទះ។
**លុប** : អ្នកអាចលុបឧបករណ៍ដែលបានភ្ជាប់។
អ្នកអាចលុបឧបករណ៍មួយចំនួនពីទូរទស្សន៍តែប៉ុណ្ណោះ។

❹ អ្នកអាចគ្រប់គ្រងទូរទស្សន៍របស់អ្នកបាន តាមរយៈការភ្ជាប់ទៅ ឧបករណ៍បំពងសំឡេងឆ្លាតវៃខាងក្រៅ។

❺ អ្នកអាចពិនិត្យមើលការណែនាំអំពីការតភ្ជាប់ សម្រាប់ប្រភេទនីមួយៗនៃ **ឧបករណ៍ IoT នៅក្នុងផ្ទះ**បាន។ អ្នកអាចភ្ជាប់ និងបង្ហាញឧបករណ៍ដែលចុះឈ្មោះទៅគណនី LG ThinQ, ឧបករណ៍ដែលអាចប្រើ OCF (Open Connectivity Foundation)របស់អ្នក និងឧបករណ៍ IoT ផ្សេងទៀតបាន។
បន្ទាប់ពីភ្ជាប់ឧបករណ៍រួចហើយ កាតនឹង ប្ដូរទៅទំហំតូចជាងមុន ហើយលេចឡើងនៅខាងក្រោមបញ្ជីភ្ជាប់ឧបករណ៍។

- ធាតុដែលអាចកំណត់បានមានភាពខុសគ្នា ទៅតាមម៉ូដែល ឬតំបន់។
- មានតែ ឧបករណ៍ដែលអាចប្រើ OCF (Open Connectivity Foundation) មួយចំនួនដែលមានការទទួលស្គាល់ពី OCF v1.3 ប៉ុណ្ណោះដែលអាចភ្ជាប់បាន។
- ឧបករណ៍ដែលភ្ជាប់អ៊ីនធឺណិតដែលអាចភ្ជាប់ទៅទូរទស្សន៍បាន អាចនឹងមានការផ្លាស់ប្ដូរដោយគ្មានការជូនដំណឹង។
- ឧបករណ៍ LG ThinQ ដែលអាចភ្ជាប់បាន និងមុខងារដែលអាចប្រើបានអាចខុសគ្នារវាងឧបករណ៍ចល័ត និងទូរទស្សន៍។
- នៅពេលកំណត់ទូរទស្សន៍ឡើងវិញ វាក៏តម្រូវឱ្យកំណត់ ឧបករណ៍ដែលអាចប្រើ OCF (Open Connectivity Foundation) ដែលបានភ្ជាប់ទៅការកំណត់នេះឡើងវិញផងដែរ។

# ការភ្ជាប់ឧបករណ៍ឆ្លាតវៃ

## ការភ្ជាប់ឧបករណ៍ឆ្លាតវៃ

អ្នកអាចប្រើលក្ខណៈពិសេសផ្សេងៗគ្នា ដោយភ្ជាប់ទូរទស្សន៍ជាមួយឧបករណ៍ឆ្លាតវៃ។

### ការភ្ជាប់ឧបករណ៍ទំនើបរបស់អ្នកទៅនឹងទូរទស្សន៍ដែលប្រើកម្មវិធី LG ThinQ

01 ទាញយកកម្មវិធី LG ThinQ ពីស្ដ័រនៃកម្មវិធីក្នុងឧបករណ៍ឆ្លាតវៃរបស់អ្នក។
អ្នកអាចទាញយកកម្មវិធីនេះបានយ៉ាងងាយស្រួលដោយការស្កេនកូដ QR។

- Android

- iOS

02 តភ្ជាប់ទូរទស្សន៍ ទាំងឧបករណ៍ឆ្លាតវៃរបស់អ្នកទៅកាន់បណ្តាញ Wi-Fiតែមួយ។
អ្នកអាចពិនិត្យមើលបណ្តាញ Wi-Fi របស់ទូរទស្សន៍អ្នកនៅ ⚙ → ⋮ → **ការតភ្ជាប់** → **ការកំណត់ការតភ្ជាប់បណ្តាញ** → **ការតភ្ជាប់ Wi-Fi**។

03 បើកដំណើរការកូនកម្មវិធី LG ThinQ ដែលបានបញ្ចូលក្នុងឧបករណ៍ទំនើបរបស់អ្នក។

04 សូមអនុវត្តតាមការណែនាំពីកម្មវិធី LG ThinQ ដើម្បីភ្ជាប់ឧបករណ៍ឆ្លាតវៃរបស់អ្នកទៅទូរទស្សន៍។
នៅពេលដែលព័ត៌មានគណនី LG ThinQ របស់អ្នកត្រូវបានភ្ជាប់ទៅទូរទស្សន៍ អ្នកអាចគ្រប់គ្រងឧបករណ៍ IoT ដែលភ្ជាប់ជាមួយគណនីរបស់អ្នកបាន ដោយប្រើ **ផ្ទាំងគ្រប់គ្រងផ្ទះ** របស់ទូរទស្សន៍។

- ប្រសិនបើអ្នកចុះឈ្មោះ LG ThinQ នៅក្នុងកម្មវិធីរបស់ ឧបករណ៍បំពងសំឡេងឆ្លាតវៃ ដែលអ្នកចង់ប្រើ នោះអ្នកក៏អាចប្រើវា ដោយប្រើការបញ្ជាដោយសំឡេងតាមរយៈ ឧបករណ៍បំពងសំឡេងឆ្លាតវៃ បានផងដែរ។

## ការបញ្ជាទូរទស្សន៍របស់អ្នកដោយប្រើកូនកម្មវិធី LG ThinQ

អ្នកអាចចុចលើប៊ូតុងនានាដែលមានលើអេក្រង់នៃឧបករណ៍ទំនើបរបស់អ្នកដើម្បីបញ្ជាទូរទស្សន៍បាន។

- ការបញ្ជាខ្លះអាចត្រូវបានកម្រិតនៅត្រឹមម៉ូដជាតុចូលពីខាងក្រៅ។
- អេក្រង់ និងលទ្ធភាពបំពេញមុខងារនៃកម្មវិធី ស្ថិតនៅក្រោមការកែប្រែដោយគ្មានការជូនដំណឹងប្រាប់ជាមុន។
- មុខងារពិសេសៗដែលអាចរកបានអាចនឹងប្រែប្រួលតាមប្រទេស និងប្រព័ន្ធប្រតិ (OS)។

# ការមើលអេក្រង់ឧបករណ៍ឆ្លាតវៃនៅលើទូរទស្សន៍

## ការមើលអេក្រង់ឧបករណ៍ឆ្លាតវៃនៅលើទូរទស្សន៍

01 បើកមុខងារ Screen Share នៅលើឧបករណ៍ឆ្លាតវៃ។

02 ទូរទស្សន៍របស់អ្នកនឹងបង្ហាញក្នុងបញ្ជីឧបករណ៍។

03 ជ្រើសរើសទូរទស្សន៍របស់អ្នក ហើយស្នើការភ្ជាប់។

04 ជ្រើសរើស **ទទួលយក** ក្នុងបង្អួចលេចឡើងស្នើការតភ្ជាប់។

05 បន្ទាប់ពីបានតភ្ជាប់ ទូរទស្សន៍នឹងបង្ហាញអេក្រង់របស់ឧបករណ៍ដែលបានតភ្ជាប់។




❶ ប្តូរទីតាំងអេក្រង់របស់ឧបករណ៍ឆ្លាតវៃ។

❷ ប្តូរឆ្លាស់រវាងសំឡេងពីទូរទស្សន៍ និងឧបករណ៍ឆ្លាតវៃ។

❸ អ្នកអាចប្តូរទំហំអេក្រង់នៅលើឧបករណ៍ឆ្លាតវៃរបស់អ្នកបាន។

❹ បង្ហាញអេក្រង់របស់ឧបករណ៍ឆ្លាតវៃនៅក្នុងមុខងារអេក្រង់ពេញ។

❺ ចាកចេញពី **Screen Share**។

- នៅពេលអ្នកភ្ជាប់ **Screen Share** ជាលើកដំបូង ផ្ទាំងលោតឡើងនឹងបង្ហាញ ដែលអនុញ្ញាតឱ្យអ្នកជ្រើសរើស **បដិសេធ**, **ទទួលយក** ឬ **ទប់ស្កាត់**។
  - **បដិសេធ** : កុំភ្ជាប់ឧបករណ៍។ ប្រសិនបើអ្នកព្យាយាមភ្ជាប់ម្តងទៀត ផ្ទាំងលោតឡើងនឹងបង្ហាញ។
  - **ទទួលយក** : អ្នកអាចភ្ជាប់ឧបករណ៍បាន។ ផ្ទាំងលោតឡើងបង្ហាញពីការតភ្ជាប់នឹងមិនបង្ហាញជាលើកទីពីរទេ។
  - **ទប់ស្កាត់** : កុំភ្ជាប់ឧបករណ៍។ ទោះបីជាអ្នកព្យាយាមភ្ជាប់ម្តងទៀត ក៏ផ្ទាំងលោតឡើងមិនបង្ហាញដែរ ហើយការតភ្ជាប់នឹងមិនដំណើរការទេ។ ដើម្បីបោះបង់ **ទប់ស្កាត់**សូមចូលទៅកាន់ ⚙ → ⋮ → **ការតភ្ជាប់** → **ការគ្រប់គ្រងការតភ្ជាប់ឧបករណ៍ចល័ត** → **Screen Share**។

- ទម្រង់ត្រួតគ្នា ការប្រើប្រាស់អាចត្រូវបានកម្រិតដោយអាស្រ័យលើកម្មវិធី ឬវីដេអូដែលបានបើក។
- ធ្វើបច្ចុប្បន្នភាពឧបករណ៍ដែលត្រូវតភ្ជាប់ជាមួយទូរទស្សន៍របស់អ្នកទៅកំណែចុងក្រោយបង្អស់ដើម្បីធានាការតភ្ជាប់ដែលអាចជឿទុកចិត្តបាន។
- ឧបករណ៍ដែលមិនមែន LGE នឹងមិនអាចតភ្ជាប់បានទេ ទោះបីជាបានរកឃើញក៏ដោយ។
- តភ្ជាប់ឧបករណ៍ជាមួយរ៉ោតទ័រ 5 Ghz ពីព្រោះការប្រើអាចមានការរំខានដោយបរិយាកាសឥតខ្សែ។
- កម្រិតឆ្លើយតបអាចខុសគ្នា អាស្រ័យលើបរិយាកាសអ្នកប្រើប្រាស់។
- វាខុសគ្នាទៅតាមឧបករណ៍។ សម្រាប់ព័ត៌មានបន្ថែមអំពីឧបករណ៍ដែលអ្នកចង់តភ្ជាប់ សូមអានការណែនាំពីរបៀបប្រើប្រាស់របស់វា។
- ប្រសិនបើនៅតែតភ្ជាប់មិនបានច្រើនដង សូមបិទទូរទស្សន៍ និងឧបករណ៍ដែលអ្នកចង់តភ្ជាប់ បន្ទាប់មកបើកវិញ ហើយព្យាយាមម្តងទៀត។

# លេងសំឡេងពីឧបករណ៍ឆ្លាតវៃតាមរយៈអូប៉ាល័ររបស់ទូរទស្សន៍

## លេងសំឡេងពីឧបករណ៍ឆ្លាតវៃតាមរយៈអូប៉ាល័ររបស់ទូរទស្សន៍

តភ្ជាប់ឧបករណ៍ឆ្លាតវៃជាមួយទូរទស្សន៍តាមរយៈ Bluetooth ដើម្បីលេងសំឡេងពីឧបករណ៍ឆ្លាតវៃតាមរយៈអូប៉ាល័ររបស់ទូរទស្សន៍។

01 បើក Bluetooth របស់ឧបករណ៍ឆ្លាតវៃ បន្ទាប់មកជ្រើសរើសទូរទស្សន៍ពីបញ្ជីឧបករណ៍។

02 ទូរទស្សន៍នឹងត្រូវបានត្រូវបានតភ្ជាប់ទៅឧបករណ៍ឆ្លាតវៃ។

- ប្រសិនបើឧបករណ៍បំពងសម្លេងបានកំណត់ទៅ **Bluetooth** ឬធ្លាប់មានប្រវត្តិជាប់នោះ ទូរទស្សន៍មិនអាចបង្ហាញនៅក្នុងបញ្ជីឧបករណ៍ឆ្លាតវៃទេ។
- ប្រសិនបើកំណត់ឧបករណ៍បំពងសំឡេងទៅ **Bluetooth** សូមចុចប៊ូតុង នៅលើតេឡេបញ្ជាឱ្យជាប់ ដើម្បីដំណើរការ **ផ្ទាំងគ្រប់គ្រងផ្ទះ** រួចជ្រើសរើស **ការចែករំលែកសំឡេង** នៅក្នុងផ្នែក **ឧបករណ៍ចល័ត** ដើម្បីភ្ជាប់។

# ការតភ្ជាប់យូអេសប៊ី

## ការតភ្ជាប់យូអេសប៊ី

តភ្ជាប់ឧបករណ៍រក្សាទុកយូអេសប៊ី (ថាសរឹងយូអេសប៊ី ផ្លាសយូអេសប៊ី) ជាមួយរន្ធយូអេសប៊ីលើទូរទស្សន៍ ដើម្បីរីករាយជាមួយឯកសារមាតិកាដែលបានរក្សាទុកក្នុងឧបករណ៍ផ្ទុកយូអេសប៊ីលើ

ទូរទស្សន៍របស់អ្នក។

# ជំនួយសម្រាប់ប្រើប្រាស់ឧបករណ៍ផ្ទុកយូអេសប៊ី

- ឧបករណ៍ផ្ទុកយូអេសប៊ីដែលមានកម្មវិធីស្គាល់ដែលភ្ជាប់មកជាមួយដោយស្វ័យប្រវត្តិ ឬប្រើកម្មវិធីបញ្ជាផ្ទាល់របស់អ្នកមិនអាចស្គាល់។
- ឧបករណ៍ផ្ទុកយូអេសប៊ីមួយចំនួន អាចមិនស្គាល់ ឬមានដំណើរការមិនស្រួល។
- បើអ្នកប្រើខ្សែយូអេសប៊ី ឧបករណ៍ផ្ទុកយូអេសប៊ីអាចមិនស្គាល់ឬមិនដំណើរការត្រឹមត្រូវ។
- សូមប្រើតែឧបករណ៍ផ្ទុកយូអេសប៊ីដែលបានហ្វ័រម៉ាតជាមួយប្រព័ន្ធឯកសារ FAT32 ឬ NTFS ដែលបានផ្តល់ដោយប្រព័ន្ធប្រតិបត្តិការ Windows។
- វាត្រូវបានផ្តល់យោបល់ឲ្យអ្នកប្រើថាសរឹងយូអេសប៊ីខាងក្រៅដែលមានតង់ស្យុង5V ឬតិចជាងនេះ ហើយតង់ស្យុងបច្ចុប្បន្នគឺ 500 mA ឬតិចជាងនេះ។ ប្រសិនបើអ្នកប្រើឧបករណ៍ដែលប្រើរ៉ុល/ចរន្តភ្លើង ច្រើនជាងរ៉ុល/ចរន្តភ្លើងដែលបានកំណត់ ឧបករណ៍នោះអាចនឹងដំណើរការមិនបានត្រឹមត្រូវទេ ដោយសារតែកង្វះចរន្តភ្លើង។
- យើងសូមណែនាំឱ្យអ្នកប្រើប្រាស់ឧបករណ៍ផ្ទុក USB ឬហាប់ USB ដែលមានឧបករណ៍ផ្គត់ផ្គង់ថាមពល។
- យើងសូមណែនាំឱ្យប្រើឧបករណ៍ផ្ទុកដែលមានទំហំ 32GB សម្រាប់ USB ហើយសម្រាប់ Hard disk ត្រូវមានទំហំត្រឹម 2TB ចុះ។
- បើថាសរឹងយូអេសប៊ីមានមុខងារសន្សំថាមពលមិនដំណើរការ បិទថាសរឹង ហើយបើកឡើងវិញ ដើម្បីឲ្យវាដំណើរការត្រឹមត្រូវ។ សូមមើលសៀវភៅរបស់ម្ចាស់សម្រាប់ព័ត៌មានបន្ថែមអំពីថាសរឹងយូអេសប៊ី។
- ទិន្នន័យក្នុងឧបករណ៍ផ្ទុកយូអេសប៊ីអាចខូច ដូច្នេះវាត្រូវបានផ្តល់យោបល់ឲ្យអ្នកបម្រុងទុកឯកសារដែលសំខាន់។ អ្នកប្រើទទួលខុសត្រូវសម្រាប់ការគ្រប់គ្រងឯកសារ។ ក្រុមហ៊ុនផលិតមិនទទួលខុសត្រូវ។
- ចុចប៊ូតុង លើតេឡេ។ ដើម្បីលុបឧបករណ៍ផ្ទុក USB សូមចុចប៊ូតុង **ដកចេញ** ដែលលេចឡើងនៅផ្នែកខាងលើ នៅពេលដែលអ្នកផ្តោតលើឧបករណ៍ផ្ទុកដែលអ្នកចង់លុប។ បើអ្នកផ្តាច់ឧបករណ៍ផ្ទុកយូអេសប៊ីដោយមិនជ្រើសរើស **ដកចេញ**, បញ្ហាមួយអាចកើតឡើងក្នុងទូរទស្សន៍ ឬឧបករណ៍ផ្ទុក។
- នៅពេលដែលអ្នកភ្ជាប់ឧបករណ៍ផ្ទុក USB នៃប្រព័ន្ធឯកសារដែលទូរទស្សន៍មិនស្គាល់ជាមួយនឹងរន្ធ **USB IN** សារទម្រង់នេះនឹងលេចឡើង។ ដើម្បីប្រើឧបករណ៍ផ្ទុក USB ដែលបានភ្ជាប់ អ្នកគួរតែលុបឧបករណ៍ជាមុនសិន។ បន្ទាប់ពីធ្វើហ្វ័រម៉ាត ទិន្នន័យទាំងអស់ក្នុងឧបករណ៍ផ្ទុកយូអេសប៊ីនឹងត្រូវបានលុបនិងហ្វ័រម៉ាតជាប្រព័ន្ធឯកសារ NTFS ឬ FAT32។
- ចុច ហើយសង្កត់ឲ្យយូរលើប៊ូតុង ដែលនៅលើតេឡេបញ្ជាពីចម្ងាយរបស់អ្នក។ ជ្រើសរើសយូអេសប៊ីដែលបានតភ្ជាប់ពី **ផ្ទាំងគ្រប់គ្រងផ្ទះ** → **ទំហំផ្ទុក** ហើយជ្រើសរើសប៊ូតុង **សម្អាត** ដើម្បីហ្វ័រម៉ាតឧបករណ៍ផ្ទុកយូអេសប៊ី។
- នៅពេលតភ្ជាប់ឧបករណ៍ផ្ទុកយូអេសប៊ី ថតឯកសារ/ឯកសារចៃដន្យអាចត្រូវបានបង្កើតដើម្បីផ្តល់សេវាកម្មទូរទស្សន៍ឆ្លាតវៃដូចជា ការរក្សាទុក និងទទួលយករូបភាពតូចៗ។

# មើលរូបថត និងវីដេអូ

## មើលរូបថត និងវីដេអូ

អ្នកអាចមើលរូបថត និងវីដេអូ ដោយប្រើកម្មវិធី **រូបថត និងវីដេអូ**។

01 ចុចប៊ូតុង ⌂ លើតេឡេ។

02 ដំណើរការកម្មវិធី **រូបថត និងវីដេអូ**។

03 ជ្រើសរើសឧបករណ៍រក្សាទុកដែលអ្នកត្រូវការ។

04 ជ្រើសរើសនិងមើលរូបថត ឬវីដេអូដែលអ្នកត្រូវការ។




❶ ជ្រើសរើសប្រភេទមាតិកា និងវិធីសាស្ត្រមើលដែលអ្នកត្រូវការ។

❷ ជ្រើសរើស និងលុបមាតិកា។

- អ្នកមិនអាចលុបឯកសារដែលត្រូវបានចែករំលែកពីឧបករណ៍ផ្សេងបានទេ។

❸ ជ្រើសរើសមាតិកាដែលអ្នកចង់លេង។ អ្នកអាចជ្រើសរើសតែប្រភេទមាតិកាដូចគ្នាដូចដែលអ្នកបានជ្រើសរើសពីដំបូង។

❹ អ្នកអាចចម្លងមាតិកាទៅឧបករណ៍ផ្ទុកយូអេសប៊ីបាន។

- អាចនឹងមិនស្គាល់ម៉ូដែលមួយចំនួន។

❺ ចាប់ផ្ដើម **ស្វែងរក**។

- មានមាតិកាដែលមិនអាចត្រូវបានបង្ហាញលើបញ្ជីនបើចំនួនមាតិកាលើសពី 40,000។

## ការប្រើប្រាស់កម្មវិធីមើលរូបថត

ការជ្រើសរើសរូបថតក្នុងកម្មវិធី **រូបថត និងវីដេអូ** នឹងបើកកម្មវិធីមើលរូបថត។ អ្នកអាចមើល

រូបថតដែលអ្នកបានរក្សាទុក។




❶ ត្រឡប់ទៅបញ្ជីមាតិកាទាំងមូល។

❷ អ្នកអាចលេងតន្ត្រីក្នុងផ្ទៃខាងក្រោយ ដោយបើកកម្មវិធីលេងតន្ត្រី។

❸ អ្នកអាចពង្រីក/បង្រួមរូបថត។

❹ ចាប់ផ្ដើមការបញ្ចាំងស្លាយ។

❺ បង្វិលរូបថត។

❻ រូបថត 360 ដឺក្រេអាចត្រូវបានមើលក្នុងទិដ្ឋភាព 360 ដឺក្រេ។

- 360° VR Playលើរូបថតធម្មតាអាចធ្វើឲ្យរូបភាពខូចទ្រង់ទ្រាយ។
- អាចនឹងមិនស្គាល់ម៉ូដែលមួយចំនួន។

❼ អ្នកអាចកំណត់ទំហំរូបថត ឬផ្លាស់ប្ដូរល្បឿន និងបែបផែននៃការបញ្ចាំងស្លាយ។

- អាចនឹងមិនស្គាល់ម៉ូដែលមួយចំនួន។

## ឯកសាររូបថតដែលបានគាំទ្រ

| ទ្រង់ទ្រាយឯកសារ | ទ្រង់ទ្រាយ | កម្រិតគុណភាព |
|---|---|---|
| jpeg, jpg, jpe | JPEG | អប្បបរមា : 64 × 64<br>អប្បបរមា<br>ប្រភេទធម្មតា : 15360 (W) × 8640 (H)<br>ប្រភេទទំនើប : 1920 (W) × 1440 (H) |
| png | PNG | អប្បបរមា : 64 × 64<br>អប្បបរមា : 5760 (W) × 5760 (H) |

| | | |
|---|---|---|
| bmp | BMP | អប្បបរមា : 64 × 64<br>អប្បបរមា : 1920 (W) × 1080 (H) |

# ការប្រើប្រាស់កម្មវិធីចាក់វីដេអូ

ការជ្រើសរើសវីដេអូក្នុង **រូបថត និងវីដេអូ** នឹងបើកកម្មវិធីលេងវីដេអូ។ អ្នកអាចមើលវីដេអូដែលអ្នកបានរក្សាទុក។




1. ត្រឡប់ទៅបញ្ជីមាតិកាទាំងមូល។
2. អ្នកអាចជ្រើសរើសមាតិកាផ្សេង ដោយបង្ហាញបញ្ជីលេងពេលមើលវីដេអូ។
3. អ្នកអាចបញ្ជាមុខងារលេងវីដេអូឡើងវិញជាមូលដ្ឋានបាន។
4. ការបង្វិលវីដេអូ។
   - អាចនឹងមិនស្គាល់ម៉ូដែលមួយចំនួន។
5. វីដេអូ 360 ដឺក្រេអាចត្រូវបានមើលក្នុងទិដ្ឋភាព 360 ដឺក្រេ។
   - 360° VR Playលើវីដេអូធម្មតាអាចធ្វើឲ្យរូបភាពខូចទ្រង់ទ្រាយ។
   - អាចនឹងមិនស្គាល់ម៉ូដែលមួយចំនួន។
6. អ្នកអាចរៀបចំការកំណត់ដែលទាក់ទងនឹងការចាក់វីដេអូឡើងវិញ។
7. អ្នកអាចកំណត់ជម្រើសបន្ថែម។

## កំណត់ជម្រើសបន្ថែម




❶ អ្នកអាចប្ដូរការកំណត់អក្សររត់។

❷ អ្នកអាចកំណត់បទចម្រៀងបាន។

❸ អ្នកអាចកំណត់ការមើលបន្ត ដើម្បីបន្តលេងពីឈុតដែលមានមើលចុងក្រោយ។

❹ ត្រឡប់ទៅអេក្រង់ប្រតិបត្តិការមូលដ្ឋាន។

# ឯកសារវីដេអូដែលបានគាំទ្រ

## អត្រាផ្ទេរទិន្នន័យអប្បបរមា៖

- វីដេអូ HD ពេញលេញ
  H.264 1920 × 1080@60P BP/MP/HP@L4.2 អតិបរមា 40Mbps
  HEVC 1920 × 1080@60P Main/Main10@L4.1 អតិបរមា 40Mbps
- វីដេអូ HD ធំសម្បើម (សម្រាប់ម៉ូដែល ULTRA HD តែប៉ុណ្ណោះ)
  H.264 3840 × 2160@30P BP/MP/HP@L5.1 អតិបរមា 50Mbps
  HEVC 3840 × 2160@60P Main/Main10@L5.1 អតិបរមា 60Mbps
- វីដេអូ HFR (សម្រាប់ម៉ូដែលដែលស្គាល់ HFR តែប៉ុណ្ណោះ)
  HEVC 3840 × 2160@120P Main/Main10@L5.2 អតិបរមា 60Mbps
- វីដេអូរូបភាព Dolby (សម្រាប់ម៉ូដែលដែលស្គាល់ Dolby Vision តែប៉ុណ្ណោះ)
  HEVC 3840 × 2160@60P Main/Main10@L5.1 អតិបរមា 50Mbps
- វីដេអូ 8K (សម្រាប់ម៉ូដែល 8K តែប៉ុណ្ណោះ)
  VP9 7680 × 4320@60P អតិបរមា 50Mbps (អាចនឹងមិនស្គាល់ម៉ូដែលមួយចំនួន។)
  AV1 7680 × 4320@60P
  HEVC 7680 × 4320@60P Main/Main10@L6.1 អតិបរមា 100Mbps

## អក្សររត់ខាងក្រៅដែលបានគាំទ្រ

smi, srt, sub (MicroDVD, SubViewer 1.0/2.0), ass, ssa, txt (TMPlayer), psb (PowerDivX),

dcs (DLP Cinema)

## ទ្រង់ទ្រាយអក្សររត់បានបង្កប់ដែលបានគាំទ្រ៖

Matroska (mkv) : អាល់ហ្វាស្ថានីយរង (SSA), អាល់ហ្វាស្ថានីយរងកម្រិតខ្ពស់ (ASS), SRT
MP4 : Timed Text

## កូឌិកវីដេអូដែលបានគាំទ្រ

| ផ្នែកបន្ថែម | កូឌិក | |
|---|---|---|
| asf<br>wmv | វីដេអូ | ទម្រង់កម្រិតខ្ពស់ VC-1 (លើកលែងសម្រាប់ WMVA), ទម្រង់VC-1 ធម្មតា និងចម្បង |
| | គន្ត្រី | ស្តង់ដារ WMA (លើកលែងសម្រាប់ WMA v1/WMA Speech) |
| avi | វីដេអូ | Xvid (GMC មិនអាចប្រើបានទេ), H.264/AVC, Motion Jpeg, MPEG-4 |
| | គន្ត្រី | MPEG-1 Layer I, II, MPEG-1 Layer III (MP3), Dolby Digital, LPCM, ADPCM |
| mp4<br>m4v<br>mov | វីដេអូ | H.264/AVC, MPEG-4, HEVC, AV1 |
| | គន្ត្រី | Dolby Digital, Dolby Digital Plus, AAC, MPEG-1 Layer III (MP3), Dolby AC-4 |
| 3gp<br>3g2 | វីដេអូ | H.264/AVC, MPEG-4 |
| | គន្ត្រី | AAC, AMR-NB, AMR-WB |
| mkv | វីដេអូ | MPEG-2, MPEG-4, H.264/AVC, VP8, VP9, HEVC, AV1 |
| | គន្ត្រី | Dolby Digital, Dolby Digital Plus, AAC, PCM, MPEG-1 Layer I, II, MPEG-1 Layer III (MP3) |

| | | |
|---|---|---|
| ts<br>trp<br>tp<br>mts | វីដេអូ | H.264/AVC, MPEG-2, HEVC |
| | គន្រ្ទី | MPEG-1 Layer I, II, MPEG-1 Layer III (MP3), Dolby Digital, Dolby Digital Plus, AAC, PCM, Dolby AC-4 |
| mpg<br>mpeg<br>dat | វីដេអូ | MPEG-1, MPEG-2 |
| | គន្រ្ទី | MPEG-1 Layer I, II, MPEG-1 Layer III (MP3) |
| vob | វីដេអូ | MPEG-1, MPEG-2 |
| | គន្រ្ទី | Dolby Digital, MPEG-1 Layer I, II, DVD-LPCM |

- Dolby AC-4 : អាចនឹងមិនស្គាល់ម៉ូដែលមួយចំនួន។

# ប្រយ័ត្នចំពោះការលេងវីដេអូឡើងវិញ

- អក្សររត់ដែលបានបង្កើតដោយអ្នកប្រើមួយចំនួនមិនអាចដំណើរការបានត្រឹមត្រូវ។
- ឯកសារវីដេអូ និងឯកសារអក្សររត់របស់វាត្រូវតែស្ថិតនៅក្នុងថតតែមួយ។ ដើម្បីឱ្យអក្សររត់បង្ហាញបានត្រឹមត្រូវ ត្រូវប្រាកដថាឯកសារវីដេអូ និងឯកសារអក្សររត់មានឈ្មោះដូចគ្នា។
- អក្សររត់លើឧបករណ៍ផ្ទុកដែលបានភ្ជាប់បណ្ដាញ (NAS) មិនអាចត្រូវបានគាំទ្រអាស្រ័យលើក្រុមហ៊ុនផលិត និងម៉ូដែល។
- ការផ្សាយដែលរួមមានការត្រឡប់ចលនាសកល (GMC) និងការប៉ាន់ស្មានចលនាខ្ទង់រងើភែល (Qpel) មិនត្រូវបានគាំទ្រទេ។
- វីដេអូ HD ធំសម្បើម (សម្រាប់ម៉ូដែល ULTRA HD តែប៉ុណ្ណោះ) : 3840 × 2160, 4096 × 2160
  វីដេអូ HD ធំសម្បើមដែលបានអ៊ិនកូដតាម HEVC មួយចំនួននិងមាតិកាដែលបានផ្ដល់ជាផ្លូវការដោយLG Electronics អាចមិនត្រូវបានគាំទ្រទេ។
  កូឌិកមួយចំនួនអាចត្រូវបានគាំទ្របន្ទាប់ពីធ្វើបច្ចុប្បន្នកម្មវិធី។

| ផ្នែកបន្ថែម | កូឌិក | |
|---|---|---|
| mkv/mp4/ts | វីដេអូ | H.264/AVC, HEVC |
| | គន្រ្ទី | Dolby Digital, Dolby Digital Plus, AAC |

- គាំទ្រតែWindow Media Audio V7 និងថ្មីជាងនេះ។
- ទម្រង់AAC ចម្បងមិនត្រូវបានគាំទ្រ។

- ឯកសារវីដេអូដែលបានបង្កើតដោយកម្មវិធីកូឌិកមួយចំនួនមិនអាចលេងបានទេ។
- ឯកសារវីដេអូមានទ្រង់ទ្រាយផ្សេងពីទ្រង់ទ្រាយបានបញ្ជាក់មិនលេងបានត្រឹមត្រូវទេ។
- ឯកសារវីដេអូបានរក្សាទុកក្នុងឧបករណ៍ផ្ទុកយូអេសប៊ីដែលមិនគាំទ្រល្បឿនលឿនមិនអាចលេងបានត្រឹមត្រូវទេ។

# ការស្តាប់តន្ត្រី

## កំពុងលេងតន្ត្រី

អ្នកអាចស្តាប់តន្ត្រីដោយប្រើកម្មវិធី **តន្ត្រី**។

01 ចុចប៊ូតុង ⌂ លើតេឡេ។

02 ដំណើរការកម្មវិធី **តន្ត្រី**។

03 ជ្រើសរើសឧបករណ៍រក្សាទុកដែលអ្នកត្រូវការ។
អ្នកអាចជ្រើសរើសបទចម្រៀងដែលត្រូវការពីឧបករណ៍ផ្ទុកទាំងអស់ ហើយបន្ថែមពួកវាទៅ **បញ្ជីចាក់របស់ខ្ញុំ**។

04 ជ្រើសរើសមាតិកាតន្ត្រីដែលអ្នកត្រូវការ ហើយរីករាយជាមួយវា។




❶ ជ្រើសរើសប្រភេទបញ្ជីមាតិកាដែលត្រូវការ។

❷ ជ្រើសរើស និងលុបមាតិកា។

- អ្នកមិនអាចលុបឯកសារដែលត្រូវបានចែករំលែកពីឧបករណ៍ផ្សេងបានទេ។

❸ ជ្រើសរើសមាតិកា ហើយបន្ថែមវាទៅ **បញ្ជីចាក់របស់ខ្ញុំ**។

❹ អ្នកអាចចម្លងមាតិកាទៅឧបករណ៍ផ្ទុកយូអេសប៊ីបាន។

- អាចនឹងមិនស្គាល់ម៉ូដែលមួយចំនួន។

❺ បើកកម្មវិធីលេងតន្ត្រី។

❻ ចាប់ផ្ដើម **ស្វែងរក**។

# កំពុងប្រើកម្មវិធីលេងតន្ត្រី

អ្នកអាចចាក់តន្ត្រីបានយ៉ាងងាយស្រួល ដោយជ្រើសរើសឯកសារតន្ត្រីដែលរក្សាទុកនៅក្នុងកម្មវិធី **តន្ត្រី** ឬដោយជ្រើសរើសរូបកម្មវិធីចាក់តន្ត្រី អំឡុងពេលចាក់មាតិកានៅក្នុងកម្មវិធីដូចជា **រូបថត និងវីដេអូ** ជាដើម។




❶ អ្នកអាចចាក់លេងតន្ត្រីចេញពីឧបករណ៍ផ្ទុកដែលជ្រើសរើសបាន។

❷ អ្នកអាចកំណត់ការលេងឡើងវិញដដែលៗ និងការលេងឡើងវិញដោយចៃដន្យ។

❸ ធាតុដែលអាចកំណត់រចនាសម្ព័ន្ធបានខុសគ្នាទៅតាមម៉ូដែល។
: អ្នកអាចបិទអេក្រង់នេះបាន នៅខណៈពេលកំពុងស្ដាប់តន្ត្រី ឬបង្ហាញអង្គចាក់លេងតន្ត្រីនៅក្នុងទម្រង់អេក្រង់ពេញបាន។
: អ្នកអាចស្ដាប់តន្ត្រីនៅពេលបិទអេក្រង់ក៏បាន។

❹ អ្នកអាចផ្លាស់ប្ដូរទីតាំងកម្មវិធីលេងតន្ត្រីបាន។

❺ អ្នកអាចបង្រួមកម្មវិធីលេងតន្ត្រីអប្បបរមា។

❻ មុខងារនេះបិទកម្មវិធីលេងតន្ត្រី។

❼ មានទំនុកបទចម្រៀងសម្រាប់ឯកសារតន្ត្រីដែលផ្ដល់ពួកវា។ នៅក្នុងឯកសារតន្ត្រីមួយចំនួន អ្នកអាចជ្រើសរើសផ្នែកទំនុកបទចម្រៀងហើយផ្លាស់ទីទៅទីតាំងលេងឡើងវិញ។

- គ្រាន់តែមានការស្គាល់មុខងារពិសេសសម្រាប់អត្ថបទចម្រៀងនៅលើឧបករណ៍មួយចំនួនប៉ុណ្ណោះ។
- ទំនុកភ្លេងអាចមិនត្រូវបានបង្ហាញក្នុងពេលធ្វើសមកាលកម្ម អាស្រ័យលើទិន្នន័យទំនុកភ្លេងក្នុងឯកសារតន្ត្រី។

- បើកកម្មវិធីលេងតន្ត្រីរបស់ឡើងវិញ ដោយចុចប៊ូតុងកម្រិតសំឡេងលើគេឡេរបស់អ្នក។
- អ្នកមិនអាចប្រើកម្មវិធីលេងតន្ត្រីសម្រាប់មុខងារចំនួនបានទេ។

# ទ្រង់ទ្រាយតន្ត្រី

| ទ្រង់ទ្រាយឯកសារ | ធាតុ | ព័ត៌មាន |
|---|---|---|
| mp3 | អត្រាប៊ីត | 32 kbps ~ 320 kbps |
| | ប្រេកង់គំរូ | 16 kHz ~ 48 kHz |
| | គាំទ្រ | MPEG-1, MPEG-2 |
| | ប៉ុស្តិ៍ | ម៉ូណូ, ស្តេរ៉េអូ |
| wav | អត្រាប៊ីត | - |
| | ប្រេកង់គំរូ | 8 kHz ~ 96 kHz |
| | គាំទ្រ | PCM |
| | ប៉ុស្តិ៍ | ម៉ូណូ, ស្តេរ៉េអូ |
| ogg | អត្រាប៊ីត | 64 kbps ~ 320 kbps |
| | ប្រេកង់គំរូ | 8 kHz ~ 48 kHz |
| | គាំទ្រ | Vorbis |
| | ប៉ុស្តិ៍ | ម៉ូណូ, ស្តេរ៉េអូ |
| wma | អត្រាប៊ីត | 128 kbps ~ 320 kbps |
| | ប្រេកង់គំរូ | 8 kHz ~ 48 kHz |

| | | |
|---|---|---|
| | គាំទ្រ | WMA |
| | ប៉ុស្តិ៍ | រហូតដល់6 ប៉ុស្តិ៍ |
| flac | អត្រាប៊ីត | - |
| | ប្រេកង់គំរូ | 8 kHz ~ 96 kHz |
| | គាំទ្រ | FLAC |
| | ប៉ុស្តិ៍ | ម៉ូណូ, ស្តេរ៉េអូ |

- ចំនួនប៉ុស្តិ៍ដែលបានគាំទ្រអាចខុសគ្នា អាស្រ័យលើប្រេកង់គំរូ។

# ចែករំលែកមាតិកាកុំព្យូទ័រ

## មើលមាតិកាដែលរក្សាទុកក្នុងកុំព្យូទ័ររបស់អ្នកនៅលើទូរទស្សន៍

អ្នកអាចរីករាយជាមួយវីដេអូ/តន្ត្រី/រូបថត ដែលរក្សាទុកនៅក្នុងកុំព្យូទ័ររបស់អ្នកនៅលើទូរទស្សន៍ នៅពេលឧបករណ៍ទាំងនេះភ្ជាប់ជាមួយបណ្តាញតែមួយ។

### ស្វែងរកមាតិកានៅក្នុងកុំព្យូទ័រដើម្បីមើលនៅលើទូរទស្សន៍ (Window10)

01 តភ្ជាប់ទាំងទូរទស្សន៍ និងកុំព្យូទ័ររបស់អ្នកជាមួយបណ្តាញតែមួយ។

02 ចុចកណ្តុរខាងស្តាំលើឯកសារដែលអ្នកចង់ចាក់ រួចជ្រើសរើស “ដោតចូលឧបករណ៍”។

03 ជ្រើសរើសឈ្មោះទូរទស្សន៍ដែលអ្នកចង់មើលពីបញ្ជីដែលបង្ហាញ នោះការចាក់នឹងចាប់ផ្តើមតាមទូរទស្សន៍នោះ។

- សូម្បីតែមានទូរទស្សន៍ ឬឧបករណ៍ច្រើនបានតភ្ជាប់ ឯកសារដែលបានជ្រើសរើសត្រូវបានលេងតែលើឧបករណ៍មួយប៉ុណ្ណោះ។ អត្រាលេងឡើងវិញអាចខុសគ្នា អាស្រ័យលើការតភ្ជាប់បណ្តាញ។
- ដើម្បីចាក់តាមឧបករណ៍ ឬប្រព័ន្ធប្រតិបត្តិការផ្សេងទៀត សូមមើលការណែនាំអំពីឧបករណ៍/ប្រព័ន្ធប្រតិបត្តិការដោយផ្ទាល់។

## រុករក និងមើលមាតិកាដែលរក្សាទុកនៅក្នុងកុំព្យូទ័រដោយប្រើទូរទស្សន៍ (Windows 10)

01 តភ្ជាប់ទាំងទូរទស្សន៍ និងកុំព្យូទ័ររបស់អ្នកជាមួយបណ្តាញតែមួយ។

02 បើកម៉ឺនុយ “ចាប់ផ្តើម” នៅលើអេក្រង់កុំព្យូទ័ររបស់អ្នក ស្វែងរក “ជម្រើសស្ទ្រីមមេឌៀ” បន្ទាប់មកជ្រើសរើសលទ្ធផលដែលបង្ហាញ។

03 ជ្រើសរើសប៊ូតុង “បើកមេឌៀកំពុងស្ទ្រីម” នៅក្នុងវិនដូដែលបើក។

04 អនុញ្ញាត “ជម្រើសស្ទ្រីមមេឌៀ” ទាំងអស់។

05 ជ្រើសរើស “យល់ព្រម” ដើម្បីរក្សាទុកការកំណត់នោះ។

06 ជ្រើសរើសកុំព្យូទ័រដែលបានភ្ជាប់នៅក្នុងកម្មវិធី **ផ្ទាំងគ្រប់គ្រងផ្ទះ** នៅលើទូរទស្សន៍ បន្ទាប់មកជ្រើសរើស និងចាក់ឯកសារតាមដែលអ្នកចង់។

- ដើម្បីចាក់តាមឧបករណ៍ ឬប្រព័ន្ធប្រតិបត្តិការផ្សេងទៀត សូមមើលការណែនាំអំពីឧបករណ៍/ប្រព័ន្ធប្រតិបត្តិការដោយផ្ទាល់។

## បញ្ហាគឺថាវាទាមទារការយកចិត្តទុកដាក់ពិសេសកំឡុងពេលចែករំលែកមាតិកា

- ពិនិត្យមើលការកំណត់បណ្តាញរបស់អ្នក បើជម្រើសចែករំលែកមាតិកាមិនដំណើរការត្រឹមត្រូវ។
- មិនអាចដំណើរការត្រឹមត្រូវលើបណ្តាញឥតខ្សែ។ វាត្រូវបានផ្តល់យោបល់ឲ្យអ្នកតភ្ជាប់បណ្តាញមានខ្សែ។
- មិនអាចដំណើរការត្រឹមត្រូវ អាស្រ័យលើបរិស្ថានបណ្តាញ។
- បើមានទូរទស្សន៍ច្រើនត្រូវបានតភ្ជាប់ទៅឧបករណ៍តែមួយ មាតិកាមិនអាចត្រូវបានលេងត្រឹមត្រូវទេ អាស្រ័យលើការអនុវត្តរបស់ម៉ាស៊ីនមេ។
- តម្រូវឱ្យមានរូតទ័រដែលប្រើប្រេកង់កម្រិត 5 GHz ដើម្បីមើលវីដេអូកម្រិត 1080p តាមរយៈមុខងារចែករំលែកខ្លឹមសារ។ ប្រសិនបើអ្នកប្រើរូតទ័រកម្រិត 2.4 GHz ដែលមានស្រាប់វីដេអូអាចនឹងមានភាពយឺតយ៉ាវ ឬបញ្ចាំងមិនបានត្រឹមត្រូវ។
- មុខងារចែករំលែកមាតិកាមិនអាចត្រូវបានគាំទ្រសម្រាប់រ៉ោតទ័រដែលមិនគាំត្រការបញ្ជូនច្រើន។ សម្រាប់ព័ត៌មានបន្ថែម សូមយោងតាមមគ្គុទ្ទេសក៍អ្នកប្រើ ដែលភ្ជាប់មកជាមួយរ៉ោតទ័ររបស់អ្នក ឬទាក់ទងក្រុមហ៊ុនផលិត។
- ចំណងជើងត្រូវបានគាំទ្រតែលើឧបករណ៍បានតភ្ជាប់មួយចំនួនតែប៉ុណ្ណោះ។
- យើងសូមណែនាំឱ្យប្រើប្រាស់កម្មវិធីកុំព្យូទ័រ SmartShare នៅពេលមើលអក្សររត់របស់វីដេអូ។
- នៅពេលឯកសារអក្សររត់ត្រូវបានបន្ថែមពេលក្រោយ បិទថតបានចែករំលែកហើយបន្ទាប់មកបើកវាឡើងវិញ។
- ឯកសារ DRM ក្នុងឧបករណ៍បានតភ្ជាប់មិននឹងលេងទេ។
- សូម្បីតែសម្រាប់ទ្រង់ទ្រាយឯកសារដែលបានគាំទ្រដោយទូរទស្សន៍ ទ្រង់ទ្រាយឯកសារដែលបានគាំទ្រអាចខុសគ្នាអាស្រ័យលើបរិស្ថានឧបករណ៍ដែលបានតភ្ជាប់។
- បើមានថតឯកសារ ឬឯកសារច្រើនពេកក្នុងថតឯកសារ វាមិនអាចដំណើរការត្រឹមត្រូវទេ។
- ព័ត៌មានលើឯកសារដែលបាននាំចូលពីឧបករណ៍ដែលបានតភ្ជាប់មិនអាចលេងបានត្រឹមត្រូវទេ។
- ដោយអាស្រ័យលើការអ៊ិនកូដ ការផ្សាយមួយចំនួនមិនអាចលេងក្នុងទម្រង់ចែករំលែកមាតិកា។

# ការមើលអេក្រង់កុំព្យូទ័រនៅលើទូរទស្សន៍

## ដើម្បីមើលអេក្រង់កុំព្យូទ័រលើទូរទស្សន៍

### តភ្ជាប់ដោយឥតខ្សែ

01 បើកមុខងារ Screen Share នៅលើកុំព្យូទ័រ។
ទូរទស្សន៍របស់អ្នកនឹងបង្ហាញក្នុងបញ្ជីឧបករណ៍។

02 ជ្រើសរើសទូរទស្សន៍របស់អ្នក ហើយស្នើការភ្ជាប់។

03 បន្ទាប់ពីបានតភ្ជាប់ ទូរទស្សន៍នឹងបង្ហាញអេក្រង់របស់ឧបករណ៍ដែលបានតភ្ជាប់។

- ធ្វើបច្ចុប្បន្នភាពឧបករណ៍ដែលត្រូវតភ្ជាប់ជាមួយទូរទស្សន៍របស់អ្នកទៅកំណែចុងក្រោយបង្អស់ដើម្បីធានាការតភ្ជាប់ដែលអាចជឿទុកចិត្តបាន។
- អ្នកគួរប្រើមុខងារនេះនៅចម្ងាយជិតៗ។
- ចាប់ផ្ដើម Screen Share រហ័សជាងមុនដោយភ្ជាប់ឧបករណ៍ចល័ត ឬកុំព្យូទ័ររបស់អ្នកទៅបណ្ដាញតែមួយជាមួយទូរទស្សន៍។
- ទោះបីជាវាអាចភ្ជាប់ដោយគ្មានរ៉ោតទ័រឥតខ្សែក៏ដោយ ការភ្ជាប់ឧបករណ៍របស់អ្នកជាមួយរ៉ោតទ័រ 5 GHz ត្រូវបានណែនាំពីព្រោះវាអាចប៉ះពាល់ដំណើរការដោយបរិស្ថានឥតខ្សែនៅជុំវិញ។
- កម្រិតឆ្លើយតបអាចខុសគ្នា អាស្រ័យលើបរិយាកាសអ្នកប្រើប្រាស់។
- វាខុសពីកំណែរបស់ Windows ។ សម្រាប់ព័ត៌មានបន្ថែមអំពីឧបករណ៍ដែលអ្នកចង់តភ្ជាប់ សូមអានការណែនាំពីរបៀបប្រើប្រាស់របស់វា។
- ប្រសិនបើនៅតែតភ្ជាប់មិនបានច្រើនដង សូមបិទទូរទស្សន៍ និងឧបករណ៍ដែលអ្នកចង់តភ្ជាប់ បន្ទាប់មកបើកវិញ ហើយព្យាយាមម្ដងទៀត។

### តតភ្ជាប់ដោយប្រើខ្សែ

តភ្ជាប់កុំព្យូទ័រជាមួយទូរទស្សន៍ដោយប្រើខ្សែ HDMI។

# ការទទួលបានអត្ថប្រយោជន៍ច្រើនបំផុតពីទូរទស្សន៍ឆ្លាតវៃ

## កំពុងប្រើ ការចែករំលែកពីរវាងបន្ទប់

# កំពុងប្រើ **ការចែករំលែកពីរវាងបន្ទប់**

តាមរយៈការភ្ជាប់ទូរទស្សន៍ច្រើនជាមួយបណ្ដាញតែមួយ
អ្នកអាចនឹងទទួលបានរូបភាពវីដេអូពីទូរទស្សន៍ផ្សេងទៀត។

01 ចុចប៊ូតុង ⌂ លើតេឡេ។

02 ដំណើរការកម្មវិធី **ការចែករំលែកពីរវាងបន្ទប់**។

03 ជ្រើសរើស **ភ្ជាប់ទូរទស្សន៍** រួចអនុវត្តតាមការណែនាំនៅលើអេក្រង់ ដើម្បីភ្ជាប់។




❶ អ្នកអាចមើលទូរទស្សន៍ដែលអ្នកកំពុងប្រើនាពេលបច្ចុប្បន្ន។

❷ ចូលអេក្រង់កែ។ អ្នកអាចមើលទូរទស្សន៍ដែលបានភ្ជាប់ និងទប់ស្កាត់ ឬលុបការតភ្ជាប់។

❸ អ្នកអាចជ្រើសរើសទូរទស្សន៍ដែលត្រូវបង្ហាញពីអេក្រង់។ ប្រសិនបើចុច **ភ្ជាប់ទូរទស្សន៍** អ្នកក៏អាចភ្ជាប់ជាមួយឧបករណ៍ថ្មីផងដែរ។

❹ ភ្ជាប់ទៅ **ការណែនាំសម្រាប់អ្នកប្រើប្រាស់**។

- មុខងារ **ការចែករំលែកពីរវាងបន្ទប់** អាចនឹងឈប់ផ្ដល់ជូនដោយគ្មានការជូនដំណឹង។
- មុខងារមួយចំនួនមិនអាចប្រើបានទេ អាស្រ័យទៅតាមម៉ូដែល។
- មានតែម៉ូដែលដែលអាចប្រើមុខងារ **ការចែករំលែកពីរវាងបន្ទប់** ប៉ុណ្ណោះទើបអាចភ្ជាប់ និងប្រើបាន។
- ទូរទស្សន៍មួយអាចភ្ជាប់បានរហូតដល់ប្រាំ។
- ការដំណើរការអាចនឹងមិនរលូនទេ ដោយផ្អែកលើការកំណត់បណ្ដាញ ឬមជ្ឈដ្ឋាន។
  ទូរទស្សន៍ដែលអ្នកចង់ភ្ជាប់ត្រូវតែភ្ជាប់ជាមួយបណ្ដាញតែមួយ។
  ប្រសិនបើមុខងារនេះមិនដំណើរការត្រឹមត្រូវទេ សូមពិនិត្យមើលការកំណត់បណ្ដាញ និងការកំណត់ WOL របស់រ៉ោតទ័រ។
  ដោយផ្អែកលើប្រតិបត្តិការរ៉ោទ័រ គុណភាពរូបភាព
  ឬគុណភាពសំឡេងនៃវីដេអូដែលបានបញ្ជូនអាចកាន់តែអន់។
- គុណភាពរូបភាព

ឬគុណភាពសំឡេងនៃវីដេអូដែលបានបញ្ជូនអាចមានកម្រិតទាបជាងវីដេអូដើម។

- នៅពេលភ្ជាប់ជាមួយកម្មវិធី LG ThinQ នៅក្នុង **ភ្ជាប់ទូរទស្សន៍**
ទូរទស្សន៍ទាំងអស់ដែលត្រូវប្រើជាមួយ **ការចែករំលែកពីរវាងបន្ទប់** ត្រូវតែចុះឈ្មោះជាមួយគណនី LG ThinQ តែមួយ។
- អាចមើលបាននៅលើទូរទស្សន៍ដែលបានទទួលអេក្រង់តែប៉ុណ្ណោះ។
ការផ្សាយដែលបានទទួលអាចនឹងមានការរឹតបន្តឹងចំពោះការមើល។
សម្រាប់ការផ្សាយមួយចំនួន អ្នកមិនអាចបញ្ជូន ឬបង្ហាញអេក្រង់បានទេ។
- ទូរទស្សន៍ដែលបានទទួលវីដេអូនឹងបើកអេក្រង់ដោយស្វ័យប្រវត្តិ
ហើយទូរទស្សន៍ដែលបានបញ្ជូនវីដេអូនឹងបិទអេក្រង់ដោយស្វ័យប្រវត្តិ។

# ការទទួលបានអត្ថប្រយោជន៍ច្រើនបំផុតពីវិចិត្រសាល

## ការទទួលបានអត្ថប្រយោជន៍ច្រើនបំផុតពី វិចិត្រសាល

អ្នកអាចរីករាយនឹងរូបភាពកម្រិតគុណភាពខ្ពស់ដែលផ្ដល់ដោយធីមនីមួយៗ។

01 ចុចប៊ូតុង ⌂ លើតេឡេ។

02 ដំណើរការកម្មវិធី **វិចិត្រសាល**។




❶ មើលរូបភាពដែលមានបញ្ចូលមកស្រាប់សម្រាប់រូបរាងនីមួយៗ។

❷ អ្នកអាចមើលព័ត៌មាន និងរូបភាពនៃធីមសំខាន់ជាមុនបាន។

❸ អ្នកអាចលុបធីមដែលបានដោនឡូត ឬជ្រើសរើសធីមដែលអ្នកពេញចិត្តដើម្បីចាក់បាន។

❹ ចាកចេញពី **វិចិត្រសាល**។

# ការរុករកនៅលើអ៊ីនធឺណិតលើទូរទស្សន៍

## ការប្រើ **កម្មវិធីរុករកលើអ៊ីនធឺណិត**

អ្នកអាចចូលវេបសាយបាននៅពេលដែលអ្នកវាយបញ្ចូលអាសយដ្ឋានវេបសាយទៅក្នុងរបារ URL។
បើអ្នកវាយបញ្ចូលពាក្យស្វែងរក វានឹងរកមើលព័ត៌មានអំពីមូលដ្ឋាននៃពាក្យស្វែងរកលើកម្មវិធីស្វែងរក។

01 ចុចប៊ូតុង ⌂ លើតេឡេ។

02 បើកដំណើរការកម្មវិធី **កម្មវិធីរុករកលើអ៊ីនធឺណិត**។




❶ អ្នកអាចរីហ្វ្រេសគេហទំព័រ ដែលអ្នកកំពុងមើលបាន។

❷ អ្នកអាចវាយបញ្ចូលអាសយដ្ឋានគេហទំព័រ ដើម្បីទៅកាន់គេហទំព័រជាក់លាក់ណាមួយ ឬបញ្ចូលពាក្យស្វែងរកដោយផ្ទាល់។

❸ អ្នកអាចមើលផ្ទាំង ដែលកំពុងតែបើកបច្ចុប្បន្ននេះ។

❹ អ្នកអាចទប់ស្កាត់ការផ្សាយពាណិជ្ជកម្មនៅក្នុងគេហទំព័រ ដែលអ្នកកំពុងមើល។
ប៉ុន្តែ ប៊ូតុងនេះបង្ហាញឡើង ក្នុងករណីដែលលក្ខណៈពិសេសនៃ ☰ → **ការកំណត់** → **ប្រើការរារាំងការផ្សាយពាណិជ្ជកម្ម** ត្រូវបានកំណត់ទៅ **បើក** ប៉ុណ្ណោះ។

❺ ញែកអេក្រង់ ដើម្បីបង្ហាញអេក្រង់ទូរទស្សន៍។ អ្នកអាចរុករកនៅក្នុងគេហទំព័រពេលកំពុងមើលទូរទស្សន៍។

❻ អ្នកអាចពង្រីក ឬបង្រួម នៅពេលរុករកនៅលើគេហទំព័រ។
**បន្ថែមទៅចំណាំ** : អ្នកអាចបញ្ចូលគេហទំព័រ ដែលអ្នកកំពុងទស្សនាទៅក្នុងសំណព្វរបស់អ្នកបាន។
**ប្រវត្តិ** : អ្នកអាចមើល និងលុបប្រវត្តិចូលមើលគេហទំព័របាន។
**ចំណាំ** : អ្នកអាចមើល និងលុបបញ្ជីគេហទំព័រដែលអ្នកបានបញ្ចូលទៅក្នុងសំណព្វរបស់អ្នកបាន។
**ការកំណត់** : អ្នកអាចប្ដូរការកំណត់កម្មវិធីរុករកលើអ៊ីនធឺណិតបាន។

❼ ចាកចេញពី **កម្មវិធីរុករកលើអ៊ីនធឺណិត**។

❽ អេក្រង់ផ្ទាំងថ្មីផ្តល់បញ្ជី **គេហទំព័រដែលបានណែនាំ** និង **គេហទំព័រដែលបានចូលច្រើនបំផុត**។ ប្រសិនបើអ្នកមិនចង់ឱ្យបង្ហាញ **គេហទំព័រដែលបានណែនាំ** ទេ សូមកំណត់លក្ខណៈពិសេសនៃ → **ការកំណត់** → **បង្ហាញគេហទំព័រដែលបានណែនាំ** ទៅ **បិទ**។
**គេហទំព័រដែលបានណែនាំ** អាចខុសគ្នា ទៅតាមប្រទេស និងអាចប្រើបានតែនៅក្នុងប្រទេសមួយចំនួនប៉ុណ្ណោះ។

- កម្មវិធី **កម្មវិធីរុករកលើអ៊ីនធឺណិត** នៅលើទូរទស្សន៍របស់អ្នកគឺជាកម្មវិធីរុករកលើអ៊ីនធឺណិតរបស់ទូរទស្សន៍ ដូច្នេះវាអាចដំណើរការខុសពីកម្មវិធីរុករកលើអ៊ីនធឺណិតសម្រាប់កុំព្យូទ័ររបស់អ្នក។
  - មាតិកាខ្លះអាចនឹងចាក់មិនបានត្រឹមត្រូវទេ។
  - មិនស្គាល់កម្មវិធីជំនួយ Flash ទេ ស្គាល់តែមេឌៀ HTML5 ប៉ុណ្ណោះ។
  - មិនស្គាល់ការដំឡើងកម្មវិធីជំនួយទេ។
  - មេឌៀដែលមានទម្រង់ខុសពី JPEG/PNG/GIF ប្រហែលជាមិនអាចចាក់បានទេ។
  - កម្មវិធីអាចនឹងត្រូវបានបង្ខំឱ្យបិទ ប្រសិនបើទូរទស្សន៍អស់មេម៉ូរី។
  - ពុម្ពអក្សរដែលភ្ជាប់ជាមួយទូរទស្សន៍ត្រូវបានប្រើប្រាស់។ ផ្អែកលើមាតិកា តួអក្សរអាចនឹងបង្ហាញខុសពីកម្មវិធីរុករកលើអ៊ីនធឺណិតរបស់ឧបករណ៍ចល័ត ឬកុំព្យូទ័រ។
  - មិនស្គាល់ការទាញយកពុម្ពអក្សរ និងឯកសារទេ។
  - តម្រូវឱ្យមានការប្រុងប្រយ័ត្ន ដោយសារតែគេហទំព័របោកបញ្ឆោត ឬមានគ្រោះថ្នាក់មិនត្រូវបានទប់ស្កាត់ដោយស្វ័យប្រវត្តិនោះទេ។
  - មុខងារមួយចំនួនរបស់កម្មវិធីរុករកតាមអ៊ីនធឺណិតប្រហែលជាមិនអាចប្រើបានជាបណ្ដោះអាសន្ន ដោយសារកត្តាខាងក្រៅ។

- គេអាចចូលប្រើគេហទំព័របានតាមរយៈកម្មវិធី **កម្មវិធីរុករកលើអ៊ីនធឺណិត** របស់ទូរទស្សន៍ ដូច្នេះសូមមានការប្រុងប្រយ័ត្នចំពោះការចូលប្រើមាតិកានៅលើអ៊ីនធឺណិតដែលមានគ្រោះថ្នាក់របស់កូនៗ។
  អ្នកអាចចាក់សោកម្មវិធី **កម្មវិធីរុករកលើអ៊ីនធឺណិត** ដើម្បីការពារមិនឱ្យចូលប្រើមាតិកានៅលើអ៊ីនធឺណិតដែលមានគ្រោះថ្នាក់។
  កំណត់រចនាសម្ព័ន្ធឲ្យសំណុំកំណត់នេះនៅ → → **ទូទៅ** → **សុវត្ថិភាព** → **ការចាក់សោកម្មវិធី**។
- ប្រសិនបើអ្នកជួបនឹងបញ្ហា នៅពេលប្រើប្រាស់ **កម្មវិធីរុករកលើអ៊ីនធឺណិត** សូមពិនិត្យមើល **ការដោះស្រាយបញ្ហា** នៅក្នុង **ការណែនាំសម្រាប់អ្នកប្រើប្រាស់**។

## ការផ្លាស់ប្តូរការកំណត់ កម្មវិធីរុករកលើអ៊ីនធឺណិត

ជ្រើសរើស → **ការកំណត់** នៅផ្នែកខាងលើនៃកម្មវិធី **កម្មវិធីរុករកលើអ៊ីនធឺណិត** ។

### នៅពេលចាប់ផ្ដើម

អ្នកអាចជ្រើសរើសទំព័រដែលបង្ហាញ នៅពេលអ្នកចាប់ផ្តើមកម្មវិធី**កម្មវិធីរុករកលើអ៊ីនធឺណិត**។

### ម៉ាស៊ីនស្វែងរក

អ្នកអាចជ្រើសរើសម៉ាស៊ីនស្វែងរក

សម្រាប់ស្វែងរកនៅពេលបញ្ចូលពាក្យគន្លឹះនៅក្នុងរបាររាសយដ្ឋាន។

- ការកំណត់ម៉ាស៊ីនស្វែងរកអាចជាកម្មវត្ថុចំពោះការផ្លាស់ប្តូរដោយមិនជូនដំណឹងផ្អែកតាមកាលៈទេសៈរបស់អ្នកផ្គត់ផ្គង់។

## បង្ហាញគេហទំព័រដែលបានណែនាំ

អ្នកអាចកំណត់ថាត្រូវបង្ហាញបញ្ជី **គេហទំព័រដែលបានណែនាំ** នៅលើអេក្រង់ផ្ទាំងថ្មីបានឬអត់។

## បង្ហាញរបាររាសយដ្ឋានជានិច្ច

នៅពេលកំណត់ទៅ **បើក** របាររាសយដ្ឋាន និងរបារម៉ឺនុយនៅខាងលើនឹងបង្ហាញជានិច្ច។

## របាយការណ៍ស្វ័យប្រវត្តិអំពីបញ្ហាកម្មវិធីរុករកលើអ៊ីនធឺណិត

នៅពេលកំណត់ទៅ **បើក**ប្រសិនបើមានបញ្ហាកើតឡើង ដោយសារតែគ្មានមេម៉ូរីគ្រប់គ្រាន់ (ការពន្យារពេលរបស់ប្រតិបត្តិការ ឬដំណើរការខុសប្រក្រតី ការមិនអាចចាក់មេឌៀបាន ការមិនអាចផ្ទុកទំព័របាន ការបិទខុសប្រក្រតី ។ល។)
នោះព័ត៌មាននេះនឹងត្រូវផ្ញើដោយស្វ័យប្រវត្តិ
ទៅកាន់ក្រុមការងារអភិវឌ្ឍន៍កម្មវិធីរុករកលើអ៊ីនធឺណិតរបស់ក្រុមហ៊ុន LG Electronics (កូរ៉េ)។
ព័ត៌មានដែលផ្ញើនឹងត្រូវបានប្រើសម្រាប់តែកែលម្អដំណើរការរបស់កម្មវិធីរុករកលើអ៊ីនធឺណិតប៉ុណ្ណោះ។

## ប្រើការរារាំងការផ្សាយពាណិជ្ជកម្ម

នៅពេលកំណត់ទៅ **បើក** ប៊ូតុងមួយនឹងលេចឡើងនៅក្នុងកន្លែងរបារម៉ឺនុយ ដែលនៅផ្នែកខាងលើនៃ **កម្មវិធីរុករកលើអ៊ីនធឺណិត** សម្រាប់បើក ឬបិទលក្ខណៈពិសេសនៃ **ប្រើការរារាំងការផ្សាយពាណិជ្ជកម្ម** ។ ការបើកលក្ខណៈពិសេសនៃ **ប្រើការរារាំងការផ្សាយពាណិជ្ជកម្ម** ជួយបង្កើនល្បឿនក្នុងការផ្ទុកទំព័រ តាមរយៈការទប់ស្កាត់ការផ្សាយពាណិជ្ជកម្ម ដែលមាននៅក្នុងគេហទំព័រ។

## ការត្រងគេហទំព័រ

អ្នកអាចចុះឈ្មោះគេហទំព័រដែលត្រូវទប់ស្កាត់ ឬអនុញ្ញាតបាន។
**គេហទំព័រដែលបានយល់ព្រម** : អ្នកអាចកំណត់រចនាសម្ព័ន្ធសំណុំកំណត់ដើម្បីបើកតែទំព័រវេបសាយដែលមានចុះបញ្ជីបាន។
**គេហទំព័រដែលបានរារាំង** : អ្នកអាចកំណត់រចនាសម្ព័ន្ធសំណុំកំណត់ដើម្បីដើម្បីខ្ទប់វេបសាយជាក់លាក់នានាបាន។

- ដើម្បីប្រើមុខងារ **ការត្រងគេហទំព័រ** បាន អ្នកត្រូវវាយបញ្ចូលពាក្យសម្ងាត់នៃទូរទស្សន៍។ ពាក្យសម្ងាត់ចាប់ផ្តើមដំបូងត្រូវបានគេកំណត់ជា “0000”។
នៅពេលភាសាបារាំង ឬន័រវេត្រូវបានជ្រើសរើសសម្រាប់ប្រទេស ពាក្យសម្ងាត់មិនមែន “0000” ទេប៉ុន្តែគឺ “1234”។

## កម្មវិធីទប់ស្កាត់សារលោតឡើង

វាទប់ស្កាត់ផ្ទាំងលោតឡើង ដែលគេហទំព័របង្ហាញដោយស្វ័យប្រវត្តិ។

### ការរុករកឯកជន

ប្រសិនបើកំណត់ទៅ **បើក** នោះវានឹងមិនរក្សាទុកប្រវត្តិនៃការចូលមើលគេហទំព័រទេ។

### កុំតាមដាន

អ្នកអាចស្នើកុំឱ្យគេហទំព័ររក្សាទុកប្រវត្តិនៃការចូលមើលរបស់អ្នកបាន។
ប្រតិបត្តិការនេះអាចមានភាពខុសគ្នា ទៅតាមគោលការណ៍របស់គេហទំព័រ។

### បច្ចេកវិទ្យាស្ទ្រីមមានភាពប្រែប្រួលដែលប្រើ JavaScript

បច្ចេកវិទ្យាចាក់មេឌៀតាមរយៈ JavaScript
ជួយឱ្យអ្នកអាចមើលវីដេអូដែលមានគុណភាពបង្ហាញខ្ពស់។
ប្រសិនបើវាត្រូវបានកំណត់ជា **បិទ** គុណភាពបង្ហាញរបស់វីដេអូបានលេងនៅក្នុង
**កម្មវិធីរុករកលើអ៊ីនធឺណិត** ត្រូវបានកម្រិតត្រឹម 720p ។

### ការកំណត់ខូគី

វាផ្តល់លទ្ធភាពឱ្យគេហទំព័រអាចរក្សាទុក និងប្រើទិន្នន័យខូគី។

### សម្អាតទិន្នន័យរុករក

**សម្អាតខូគី** : លុបទិន្នន័យខូគី។ នៅពេលលុបហើយ អ្នកនឹងត្រូវចេញពីគេហទំព័រភាគច្រើន។
**សម្អាតទិន្នន័យរុករកទាំងអស់** : លុបប្រវត្តិរុករកទាំងអស់ រួមទាំងខូគីផងដែរ។

# ការប្រើ ការជូនដំណឹងអំពីកីឡា

## ការប្រើ ការជូនដំណឹងអំពីកីឡា

01 ចុចប៊ូតុង លើតេឡេ។

02 ដំណើរការកម្មវិធី **ការជូនដំណឹងអំពីកីឡា**។

03 ជ្រើសរើស **បន្ថែមក្រុមរបស់ខ្ញុំ** ដើម្បីបញ្ចូលក្រុមកីឡាដែលចូលចិត្ត ទៅក្នុងក្រុមរបស់ខ្ញុំ។
អ្នកអាចពិនិត្យមើលកាលវិភាគការប្រកួតរបស់ក្រុមដែលបានចុះឈ្មោះ
ឬកំណត់ម៉ោងរោទ៍បាន។

- ស្ថានភាព ឬកាលវិភាគនៃការប្រកួតអាចខុសគ្នាពីស្ថានភាព ឬកាលវិភាគជាក់ស្តែង
ផ្អែកលើស្ថានភាពរបស់ក្រុមហ៊ុនផ្តល់ទិន្នន័យ។
- ប្រហែលជាមិនអាចប្រើម៉ោងរោទ៍ក្នុងពេលជាក់ស្តែងបានទេ នៅពេលប្រើកម្មវិធីមួយចំនួន។

- អាចប្រើលក្ខណៈពិសេសនេះបាន តែនៅពេលដែលភ្ជាប់បណ្ដាញប៉ុណ្ណោះ។
- អាចនឹងមិនស្គាល់ម៉ូដែលមួយចំនួន។

# ការកំណត់

## ការកំណត់រហ័ស

### ដើម្បីប្រើមុខងារកំណត់បានរហ័ស

បង្ហាញរូបភាពប្រព័ន្ធបញ្ជាស្រាលៗយ៉ាងរហ័ស និងសាមញ្ញដែលមានប្រភេទដូចជា **របៀបរូបភាព**, **សំឡេងចេញ**, **កម្មវិធីកំណត់ម៉ោងដេក** ជាដើម។

ចុចប៊ូតុង ⚙ លើតេឡេ។




1. អ្នកអាចកំណត់ **របៀបរូបភាព**។
2. អ្នកអាចកំណត់ **របៀបសំឡេង**។
3. អ្នកអាចជ្រើសរើស **សំឡេងចេញ**។
4. អ្នកអាចកំណត់ **កម្មវិធីកំណត់ម៉ោងដេក**។
5. ផ្លាស់ទីទៅអេក្រង់ **ការតភ្ជាប់**។
6. អ្នកអាចកំណត់ជម្រើសច្រើនទៀតបាន។
7. អ្នកអាចបញ្ចូល/លុបធាតុកំណត់រហ័ស ឬប្ដូរលំដាប់នៃធាតុបាន។

- បន្ទាប់ពីបញ្ចូលធាតុនីមួយៗរួច សូមចុចប៊ូតុង **ដំណើរការ (OK)** នៅលើតេឡេបញ្ជាឱ្យជាប់ ដើម្បីចូលទៅកាន់ម៉ឺនុយដែលពាក់ព័ន្ធ។

# រូបភាព

## ការជ្រើសរើសទម្រង់រូបភាព

⚙ → ⋮ → **រូបភាព** → **ការកំណត់របៀបរូបភាព** → **របៀបរូបភាព**

ជ្រើសរើសទម្រង់រូបភាពដែលត្រូវគ្នាល្អបំផុតទៅនឹងប្រព័ន្ធកម្មវិធីមើលរូបភាព ចំណូលចិត្ត ឬ ប្រភេទវីដេអូសម្រាប់ការមើលរបស់អ្នក។
ជ្រើសរើសរបៀបរូបភាព។ តាមរយៈការកែសម្រួល
និងកំណត់ធាតុនីមួយៗដោយលម្អិតជាងមុនទៅតាមម៉ូដែល
វីដេអូរបស់អ្នកត្រូវបានបង្កើនប្រសិទ្ធភាពឱ្យប្រសើរជាងមុនសម្រាប់លក្ខណៈរបស់វា។

- ធាតុដែលអាចកំណត់រចនាសម្ព័ន្ធបានខុសគ្នាទៅតាមម៉ូដែល។

**នៅពេលដែលអ្នកប្រើសញ្ញាធម្មតាៗ។**

### ពណ៌ដិត

ការបង្កើនកម្រិតច្បាស់នៃរូបភាពដោយការបង្កើនកម្រិតពណ៌ ភាពភ្លឺច្បាស់ និងកម្រិតពណ៌។

### ស្តង់ដារ

បង្ហាញរូបភាពដែលមានកម្រិតនៃពណ៌ ភាពភ្លឺច្បាស់ និងភាពច្បាស់ធម្មតាៗ។

### អេកូ / APS

មុខងារពិសេសនៃអង្គសន្សំសំចៃថាមពល ផ្លាស់ប្តូរសំណុំកំណត់លើទូរទស្សន៍ដើម្បីកាត់បន្ថយការស៊ីថាមពលខ្លាំង។

- ធាតុដែលអាចកំណត់រចនាសម្ព័ន្ធបានខុសគ្នាទៅតាមម៉ូដែល។

### រោងកុន

រូបភាពសមស្របសម្រាប់ភាពយន្ត។

### កីឡា / បាល់ទាត់ / Cricket

រូបភាពសមស្របសម្រាប់ហ្គេមកីឡា។ បង្កើនភាពច្បាស់នៃរូបភាពមានចល័តរហ័សដែលមានប្រភេទដូចជាការទាត់ ឬគប់បាល់។

- ឈ្មោះកីឡាអាចខុសៗគ្នាទៅតាមតំបន់។

## ហ្គេម

រូបភាពសមស្របសម្រាប់ការលេងហ្គេម។

## បែបផែន HDR

មុខងារពិសេសនេះ អនុញ្ញាតឲ្យអ្នករីករាយនឹងរូបភាពដែលកាន់តែមានលក្ខណៈឌីណាមិក និងកាន់តែច្បាស់តាមរយៈការកែតម្រូវផ្នែកភ្លឺ និងងងឹតនៃការបង្ហាញរូបភាព។
មុខងារពិសេសនេះ ផ្តល់នូវរូបភាពពិត សូម្បីតែនៅពេលកម្រិតឡើងចុះនៃរូបភាពដើមឡើងខ្ពស់ក៏ដោយ។

- បើអ្នកកំណត់ **របៀបរូបភាព** ទៅជា **បែបផែន HDR**អ្នកនឹងមិនអាចប្រើ **ការកំណត់របៀបរូបភាព**មួយចំនួនបានទេ។

## FILMMAKER MODE

វាផ្តល់នូវគុណភាពរូបភាពបែបរោងភាពយន្តកម្រិតខ្ពស់ ដែលទទួលស្គាល់ដោយ UHD Alliance ដែលជាផ្នែកនៃការកំណត់ស្តង់ដារ សម្រាប់បច្ចេកវិទ្យាដែលពាក់ព័ន្ធនឹង UHD ។

- ដើម្បីប្តូរទៅ **FILMMAKER MODE** ដោយស្វ័យប្រវត្តិ នៅពេលមានការបញ្ចូលរលកសញ្ញាដែលអាចដំណើរការជាមួយរបៀបនេះបាន សូមកំណត់ **ការប្តូរដោយស្វ័យប្រវត្តិចំពោះ FILMMAKER MODE** ទៅ **បើក**។

## isf អ្នកជំនាញ (បន្ទប់ភ្លឺ) / isf អ្នកជំនាញ (បន្ទប់ងងឹត)

របៀបនេះគឺស័ក្តិសមសម្រាប់ភាពយន្ត ។ល។ សម្រាប់ទស្សនានៅក្នុងមជ្ឈដ្ឋានងងឹត។
**អ្នកជំនាញ (បន្ទប់ងងឹត)** មានកម្រិតពណ៌ពីព្រឿងៗមកស្រទន់ទាបជាង **អ្នកជំនាញ (បន្ទប់ភ្លឺ)**។
ជ្រើសរើសរបៀបដែលស័ក្តិសមសម្រាប់ភាពយន្ត ដែលអ្នកកំពុងទស្សនា។
ISFccc : ការត្រួតពិនិត្យរៀបចំដែលមានបញ្ជាក់ដោយមូលនិធិវិទ្យាសាស្ត្របង្កើតរូបភាព។

### នៅពេលដែលអ្នកប្រើសញ្ញា HDR/Dolby Vision

## ពណ៌ឌិត

ការបង្កើនកម្រិតច្បាស់នៃរូបភាពដោយការបង្កើនកម្រិតពណ៌ ភាពភ្លឺច្បាស់ និងកម្រិតពណ៌។

## ស្តង់ដារ

ស្ថិតក្នុងប្រព័ន្ធកម្មវិធីមើលធម្មតា វាបើកឡើងនូវអេក្រង់ដែលអាចបង្ហាញយ៉ាងត្រឹមត្រូវនូវវិញ្ញត្តិភាព និងភាពភ្លឺច្បាស់របស់ HDR។

## របៀបកុននៅផ្ទះ

អេក្រង់លេចចេញមកជាអេក្រង់ដែលពន្លឺភ្លឺថ្លាជាង **រោងកុន**។

### រោងកុន

រូបភាពសមស្របសម្រាប់សញ្ញាវីដេអូ HDR ។

### ហ្គេម

រូបភាពសមស្របសម្រាប់ការលេងហ្គេម។

### FILMMAKER MODE

វាផ្តល់នូវគុណភាពរូបភាពបែបរោងភាពយន្តកម្រិតខ្ពស់ ដែលទទួលស្គាល់ដោយ UHD Alliance ដែលជាផ្នែកនៃការកំណត់ស្តង់ដារ សម្រាប់បច្ចេកវិទ្យាដែលពាក់ព័ន្ធនឹង UHD ។

- ដើម្បីប្តូរទៅ **FILMMAKER MODE** ដោយស្វ័យប្រវត្តិ នៅពេលមានការបញ្ចូលរលកសញ្ញាដែលអាចដំណើរការជាមួយរបៀបនេះបាន សូមកំណត់ **ការប្តូរដោយស្វ័យប្រវត្តិចំពោះ FILMMAKER MODE** ទៅ **បើក**។

- បើកសញ្ញាវីដេអូ HDR/Dolby Vision មានចូលទៅកាន់ទម្រង់◌ែលនានាដែលមិនស្គាល់បច្ចេកវិទ្យា HDR/Dolby Vision នោះ វានឹងត្រូវផ្តល់នូវជម្រើសនៃទម្រង់រូបភាពសញ្ញាធម្មតាៗ។
- ដោយអាស្រ័យសញ្ញាចូល ទម្រង់រូបភាពដែលមានអាចនឹងមានលក្ខណៈខុសគ្នា។
- នៅពេលកំពុងមើលមេឌៀ ឬមាតិកានៃសេវាកម្មនេះនៅអនឡាញ គេអាចប្តូរទម្រង់រូបភាព ឲ្យត្រូវគ្នានឹងមេឌៀ ឬមាតិកាដែលកំពុងមានការបង្ហាញឲ្យឃើញបាន។
- isf ជំនាញ គឺជាជម្រើសមួយដែលអនុញ្ញាតឲ្យអ្នកជំនាញខាងគុណភាពរូបភាពធ្វើការលៃតម្រូវគុណភាពនៃរូបភាពដែលមានបទដ្ឋានត្រឹមត្រូវបាន។ ដូច្នេះ វាអាចនឹងមិនមានប្រសិទ្ធភាពសម្រាប់រូបភាពធម្មតាមួយបាន។
- **របៀបរូបភាព** ការផ្លាស់ប្តូរអាចកែប្រែ **ការសន្សំសំចៃថាមពល** និងការកំណត់ **ការថែរក្សាចលនាភ្នែក** ហើយវាអាចប៉ះពាល់ដល់ការប្រើប្រាស់ថាមពល។ អ្នកអាចកែតម្រូវការកំណត់របស់ពួកគេដោយដៃ នៅក្នុង **ការសន្សំសំចៃថាមពល** និងម៉ឺនុយ **ជម្រើ◌ាសរូបថត**។

## ទម្រង់រូបភាពធ្វើការលៃតម្រូវបន្តិចបន្តួច

→ → **រូបភាព** → **ការកំណត់របៀបរូបភាព**

មុខងារពិសេសនេះ អនុញ្ញាតឲ្យអ្នកលៃតម្រូវទម្រង់នៃរូបភាពដែលមានជ្រើសរើសយ៉ាងលម្អិត។

### ពន្លឺខាងក្រោយ

គ្រប់គ្រងកម្រិតនៃភាពភ្លឺច្បាស់របស់អេក្រង់ដោយការលៃតម្រូវពន្លឺផ្ទៃខាងក្រោយ។ កាន់តែរំកិលខិតជិតលេខ 100 រូបភាពក៏កាន់តែឡើងពន្លឺកាលនោះដែរ។

- បន្ថយ **ពន្លឺខាងក្រោយ** ដើម្បីកុំឲ្យស៊ីថាមពលខ្លាំង។
- ដោយអាស្រ័យលើ **ការសន្សំសំចៃថាមពល** (**ស្វ័យប្រវត្តិ**/**អតិបរមា**) អ្នកមិនអាចនឹងកែតម្រូវ **ពន្លឺខាងក្រោយ** បានឡើយ។
  ស្ថិតក្នុងករណីនេះ រុករកទៅកាន់អេក្រង់ → → **រូបភាព** → **ការសន្សំសំចៃថាមពល** ហើយ

ដាក់កំណត់ទៅជា **បិទ** ឬ **អប្បបរមា**។

- ផ្អែកលើម៉ូដែលទូរទស្សន៍របស់អ្នក អ្នកប្រហែលជាមិនមានការកំណត់ **ពន្លឺខាងក្រោយ** ទេ។

## ពន្លឺ OLED

កែតម្រូវពន្លឺបង្ហាញដោយធ្វើឲ្យពន្លឺបន្ទះOLED ខុសគ្នា។

- ផ្អែកលើម៉ូដែលទូរទស្សន៍របស់អ្នក អ្នកប្រហែលជាមិនមានការកំណត់ **ពន្លឺ OLED** ទេ។

## ភាពងងឹត

កែតម្រូវកម្រិតពន្លឺនៃផ្ទៃដែលភ្លឺ និងងងឹតរបស់រូបភាព។ កាន់តែជិត 100 នោះកម្រិតពន្លឺកាន់តែខ្ពស់។

## ពន្លឺ

កែតម្រូវពន្លឺអេក្រង់សរុប។ កាន់តែរំកិលខិតជិតលេខ 100 រូបភាពក៏កាន់តែឡើងពន្លឺកាលនោះដែរ។
អ្នកអាចប្រើការកំណត់ **ពន្លឺ** ដាក់លាក់ ដើម្បីកំណត់ផ្នែកងងឹតរបស់រូបភាព។

## ភាពម៉ត់

លៃតម្រូវភាពច្បាស់នៃរូបភាព។ កាន់តែរំកិលខិតជិតលេខ 50 កាលណា រូបភាពក៏កាន់តែមានភាពច្បាស់និងឡើងថ្លាកាលនោះដែរ។

## ពណ៌

ដំឡើង ឬបន្ថយកម្រិតពណ៌ដែលមានបង្ហាញលើអេក្រង់។ កាន់តែរំកិលខិតជិតលេខ 100 ពណ៌ក៏កាន់តែឡើងដិតកាលនោះដែរ។

## គុណពណ៌

កែតម្រូវតុល្យភាពពណ៌រវាងពណ៌ក្រហម និងបៃតង ដែលបានបង្ហាញលើអេក្រង់។ កាន់តែជិតពណ៌ក្រហម 50 នោះពណ៌កាន់តែក្រហម។ កាន់តែជិតពណ៌បៃតង 50 នោះពណ៌កាន់តែបៃតង។

## កម្រិតពណ៌ពីត្រជាក់មកក្តៅ

កែសម្រួលកម្រិតពណ៌នៃរូបភាពទាំងមូល។ នៅពេលដែលអ្នកបន្ថយកម្រិត អ្នកនឹងទទួលបានកម្រិតពណ៌ឆេីត ហើយនៅពេលដែលអ្នកបន្ថែមកម្រិត អ្នកនឹងទទួលបានកម្រិតពណ៌ស្រទន់។

- សំណុំកំណត់ដែលអ្នកបញ្ជាក់ គ្រាន់តែប្រើចំពោះទម្រង់ទិន្នន័យបញ្ចូលដែលបានជ្រើសរើសប៉ុណ្ណោះ។ ដើម្បីប្រើសំណុំកំណត់នៃរូបភាពបច្ចុប្បន្នរបស់អ្នកទៅនឹងទម្រង់បញ្ចូលទិន្នន័យទាំងអស់បានជ្រើសរើសចុចលើ **អនុវត្តចំពោះធាតុបញ្ចូលទាំងអស់**។
- ដោយអាស្រ័យសញ្ញាទិន្នន័យចូលរទម្រង់នៃរូបភាពដែលបានជ្រើសរើស ជម្រើសដែលអាចរកបាន

នឹងប្រែខុសគ្នា។

- ធាតុដែលអាចកំណត់រចនាសម្ព័ន្ធបានខុសគ្នាទៅតាមម៉ូដែល។

**ការកំណត់ទម្រង់រូបភាព**

⚙ → ⋮ → **រូបភាព** → **ការកំណត់របៀបរូបភាព** → **កំណត់ឡើងវិញ**

ប្រសិនបើអ្នកចង់កំណត់ការកំណត់រូបភាពទៅលំនាំដើមឡើងវិញបន្ទាប់ពីប្រើការកំណត់ សូមកំណត់ឡើងវិញសម្រាប់របៀបរូបភាពនីមួយៗ។

## ការកំណត់ជម្រើសពណ៌កម្រិតខ្ពស់

⚙ → ⋮ → **រូបភាព** → **ការកំណត់របៀបរូបភាព** → **អង្គបញ្ជាកម្រិតខ្ពស់**

### ពណ៌ឌិតឌីណាមិក

កែភាពខុសគ្នារវាងពន្លឺ និងផ្នែងងងឹតរបស់អេក្រង់សម្រាប់លទ្ធផលល្អបំផុតដោយអាស្រ័យលើពន្លឺរបស់រូបភាព។

### ការធ្វើឲ្យចេញជាពណ៌តែមួយ

ធ្វើឲ្យការកំណត់កម្រិតពន្លឺសមស្របផ្អែកតាមពន្លឺរូបភាពរបស់មាតិកា HDR ។

### ពណ៌ឌីណាមិច

កែតម្រូវពណ៌ និងតិត្ថិភាពរបស់រូបភាពដើម្បីធ្វើឲ្យរូបភាពកាន់តែមានពណ៌ និងរស់រវើក។

### ដែននៃពណ៌

ជ្រើសរើសចន្លោះពណ៌ដើម្បីបង្ហាញ។ ការកំណត់ពណ៌ទៅជា **ស្វ័យប្រវត្តិ** វាអាស្រ័យទៅតាមរលកសញ្ញា ឬការបង្ហាញដែលពោរពេញទៅតាមលំដាប់លំដោយនៃរូបភាព **ពង្រីក** និង **ធំ**។

### គុណភាពបង្ហាញច្បាស់អស្ចារ្យ

កែតម្រូវគុណភាពបង្ហាញដើម្បីធ្វើឲ្យរូបភាពព្រិលៗ និងស្រអាប់ច្បាស់។

### អក្សរហ្គាម៉ា

កែតម្រូវពន្លឺមធ្យមរបស់រូបភាព។
ជ្រើសរើស **ទាប** សម្រាប់រូបភាពភ្លឺច្បាស់ ជ្រើសរើស **ខ្ពស់1** ឬ **ខ្ពស់2** សម្រាប់រូបភាពងងឹត ឬជ្រើសរើស **មធ្យម** សម្រាប់កម្រិតពន្លឺមធ្យម។
**រោងកុន** ឬ **អ្នកជំនាញ (បន្ទប់ភ្លឺ)**/**អ្នកជំនាញ (បន្ទប់ងងឹត)** អាចជ្រើសរើសបានពី **1.9**/**2.2**/**2.4**/**BT.1886**។

- **ខ្ពស់2**/**BT.1886** បង្ហាញពីកម្រិតនៅក្នុង ITU-R BT.1886 ដែលជាស្តង់ដារអន្តរជាតិ។

## កម្រិតពណ៌ស

មុខងារសម្រាប់កែសម្រួលពណ៌នីមួយៗ ដែលត្រូវបានបង្កើតឡើងវិញឱ្យកាន់តែត្រឹមត្រូវជាងមុនដោយផ្អែកលើពណ៌សអនុញ្ញាតឱ្យអ្នកកែសម្រួលកម្រិតពណ៌ទូទៅរបស់អេក្រង់ទៅតាមការចង់បានរបស់អ្នក។

### កម្រិតពណ៌ពីព្រឿងៗមកស្រទន់

សូមជ្រើសរើស **Warm1**/**Warm2**/**Warm3** សម្រាប់ពណ៌ស្រគាំ សូមជ្រើសរើស **ត្រជាក់** សម្រាប់ពណ៌ដិត សូមជ្រើសរើស **មធ្យម** សម្រាប់ពណ៌ល្មម

### វិធីសាស្ត្រ

វិធីនេះគឺប្រើសម្រាប់កែសម្រួលការកំណត់កម្រិតពណ៌។ អ្នកអាចគ្រប់គ្រងកម្រិតពណ៌ពីព្រឿងៗមកស្រទន់នៅកម្រិតពីរនៃចំណុចភ្លឺ និងចំណុចងងឹតរបស់វីដេអូ ប្រសិនបើអ្នកជ្រើសរើស **2 ចំណុច** នៅគ្រប់ចំណុចនៃកម្រិត 10 ប្រសិនបើអ្នកជ្រើសរើស **10 ចំណុច IRE** និងនៅគ្រប់ចំណុចនៃកម្រិត 22 របស់វីដេអូ ប្រសិនបើអ្នកជ្រើសរើស **22 ចំណុច IRE**។

### ចំណុច

ជ្រើសរើសកម្រិតពន្លឺពណ៌សម្រាប់ការកែសម្រួលកម្រិតពណ៌។
ប្រសិនបើ **វិធីសាស្ត្រ** ត្រូវបានកំណត់ទៅ **2 ចំណុច** សូមប្រើ Low ដើម្បីជ្រើសរើសស្រមោល និង High ដើម្បីជ្រើសរើសហាយឡាយ៍។
ប្រសិនបើ **វិធីសាស្ត្រ** ត្រូវបានកំណត់ទៅ **10 ចំណុច IRE** អ្នកអាចជ្រើសរើសពន្លឺ ដោយប្រើលេខដែលបង្ហាញ 10 កម្រិត។
នៅពេល **វិធីសាស្ត្រ** ត្រូវបានកំណត់ទៅ **22 ចំណុច IRE** នោះអ្នកអាចជ្រើសរើសពន្លឺក្នុងកម្រិតភ្លឺ 22។

### IRE

ជ្រើសរើសកម្រិតពន្លឺពណ៌សម្រាប់ការកែសម្រួលកម្រិតពណ៌។
ប្រសិនបើ **វិធីសាស្ត្រ** ត្រូវបានកំណត់ទៅ **10 ចំណុច IRE** អ្នកអាចជ្រើសរើសពន្លឺ ដោយប្រើលេខដែលបង្ហាញ 10 កម្រិត។
នៅពេល **វិធីសាស្ត្រ** ត្រូវបានកំណត់ទៅ **22 ចំណុច IRE** នោះអ្នកអាចជ្រើសរើសពន្លឺក្នុងកម្រិតភ្លឺ 22។

### កម្រិតពន្លឺ

អ្នកអាចកែសម្រួលពន្លឺដែលបានជ្រើសរើសជាកម្រិតបាន។

- អ្នកអាចធ្វើការកំណត់ទាំងនេះបាននៅពេល **របៀបរូបភាព** គឺជា **រោងកុន**, **អ្នកជំនាញ (បន្ទប់ភ្លឺ)** ឬ **អ្នកជំនាញ (បន្ទប់ងងឹត)** និងនៅពេល **វិធីសាស្ត្រ** ត្រូវបានកំណត់ទៅ **10 ចំណុច IRE** ឬ **22 ចំណុច IRE** តែប៉ុណ្ណោះ។

### ក្រហម / បៃតង / ខៀវ

កែសម្រួលកម្រិតពណ៌នៃចំណុចដែលបានជ្រើសរើស។
កែសម្រួលតង់ស៊ីតេនៃពណ៌ **ក្រហម**/**បៃតង**/**ខៀវ** ក្នុងកម្រិត -50 ដល់ 50។
អ្នកអាចកែសម្រួលតម្លៃខាងលើ សម្រាប់ពន្លឺដែលបានជ្រើសរើសនៅក្នុង **ចំណុច**។

## ប្រព័ន្ធគ្រប់គ្រងពណ៌

វាត្រូវបានប្រើប្រាស់ នៅពេលអ្នកជំនាញគ្រប់គ្រងវាដោយប្រើលំនាំសាកល្បង។
អ្នកអាចគ្រប់គ្រងវាបានដោយជ្រើសរើសផ្ទៃកទាំងប្រាំមួយពណ៌ (**ក្រហម**/**បៃតង**/**ខៀវ**/**បៃតងលាយខៀវ**/**ស្វាយលាយក្រហម**/**លឿង**)។
សម្រាប់រូបភាពធម្មតា ការកែតម្រូវមិនអាចបង្ហាញលទ្ធផលក្នុងការប្តូរពណ៌គួរឲ្យកត់សម្គាល់ទេ។

### ពណ៌

ចាប់ពីពណ៌ **ក្រហម**/**បៃតង**/**ខៀវ**/**បៃតងលាយខៀវ**/**ស្វាយលាយក្រហម**/**លឿង**
សូមជ្រើសរើសពណ៌ សម្រាប់កែសម្រួល។

### ភាពឆ្អែតពណ៌ / គុណពណ៌ / កម្រិតពន្លឺ

កែសម្រួលពណ៌ដិត/ពណ៌ព្រឿងៗ/ពណ៌ពន្លឺចាំងនៃកម្រិតពណ៌ក្នុងកម្រិត -30 ដល់ +30។

## កម្រិតពន្លឺខ្ពស់បំផុត

កែសម្រួលកម្រិតពន្លឺខ្ពស់បំផុត ដើម្បីទទួលបានពន្លឺចាំងផ្លាតភ្លឺបំផុត។

- ដោយអាស្រ័យសញ្ញាទិន្នន័យចូលរទម្រង់នៃរូបភាពដែលបានជ្រើសរើស ជម្រើសដែលអាចរកបាននឹងប្រែខុសគ្នា។
- ធាតុដែលអាចកំណត់រចនាសម្ព័ន្ធបានខុសគ្នាទៅតាមម៉ូដែល។

# ការកំណត់ជម្រើសរូបភាព។

⚙ → ⋮ → **រូបភាព** → **ការកំណត់របៀបរូបភាព** → **ជម្រើាសរូថតត**

## ការកាត់បន្ថយសំឡេងរំខាន

លុបចេញនូវចំណុចតូចៗដែលលេចចេញមកដើម្បីធ្វើឲ្យរូបភាពច្បាស់។

## ការកាត់បន្ថយសំឡេងរំខានក្នុង MPEG

បន្ថយសំឡេងរំខានដែលកើតឡើងក្នុងពេលបង្កើតសញ្ញាវីដេអូឌីជីថល។

## ការប្តូរពណ៌យ៉ាងរលូន

វាជួយកាត់បន្ថយគុណភាពនៃរូបភាពមានលក្ខណៈរដិបរដុបនិងមិនច្បាស់ដោយបង្ហាញអោយរូបភាពច្បាស់ល្អ។

## កម្រិតពណ៌ខ្មៅ

កែសម្រួលពន្លឺនៃផ្នែកងងឹតរបស់រូបភាព។
ជ្រើសរើស **ខ្ពស់** សម្រាប់អេក្រង់ភ្លឺ ឬជ្រើសរើស **ទាប** សម្រាប់អេក្រង់ងងឹត។

- អាចប្រើលក្ខណៈពិសេសនេះបាន នៅពេលកំពុងទស្សនាមាតិកាតាមរយៈធាតុបញ្ចូលខាងក្រៅ។

## រោងកុនពិត

បង្កើនគុណភាពការបញ្ចាំងភាពយន្ត

## ការថែរក្សាចលនាភ្នែក

ស្វ័យលៃតម្រូវភាពភ្លឺច្បាស់ និងបន្ថយភាពព្រិលៗនៃរូបភាពដោយអាស្រ័យលើទិន្នន័យរូបភាព ដែលនឹងបន្ថយការរោយភ្នែក។

- ការដាក់ជម្រើសនេះទៅជា **បិទ** អាចនឹងបង្កើនការស៊ីថាមពលកាន់តែច្រើន។

## ការចុះស្រអាប់ LED ខាងក្នុង

បង្កើតកម្រិតពណ៌អតិបរមាដោយធ្វើឲ្យផ្ទៃដែលភ្លឺច្បាស់នៃអេក្រង់កាន់តែមានពន្លឺ និងផ្នែកងងឹតនៃអេក្រង់កាន់តែឡើងខ្មៅ។

- **បិទ** : បិទមុខងារ **ការចុះស្រអាប់ LED ខាងក្នុង** ។
- **ទាប** / **មធ្យម** / **ខ្ពស់** : ផ្លាស់ប្ដូរផលធៀបកម្រិតពណ៌។

- ការដាក់ជម្រើសនេះទៅជា **បិទ** អាចនឹងបង្កើនការស៊ីថាមពលកាន់តែច្រើន។

## TruMotion

ធ្វើឲ្យគុណភាពរូបភាពសមស្របសម្រាប់រូបភាពដែលមានចលនាលឿន។

- **បិទ** : បិទ **TruMotion**។
- **និយមន័យច្បាស់លាស់របស់រោងភាពយន្ត** : កែសម្រួលចលនាញ័រនៅលើអេក្រង់ ដើម្បីធ្វើឱ្យមានអារម្មណ៍ថាអ្នកកំពុងស្ថិតនៅក្នុងរោងភាពកុន។
- **ធម្មជាតិ** : កំណត់រូបភាព ដោយប្រើចលនាជាច្រើន ដើម្បីធ្វើឱ្យរូបភាពមានភាពរស់រវើកបែបធម្មជាតិ និងភ្លឺច្បាស់។
- **រលោង** : ធ្វើឲ្យរូបភាពដែលកំពុងមានចលនាលឿនមើលទៅស្រទន់។
- **អ្នកប្រើ** : កំណត់ **TruMotion** ដោយដៃឯង។
  - **De-Judder** : លៃតម្រូវរូបភាពញ័រព្រិលៗលើអេក្រង់។
  - **De-Blur** : បន្ថយភាពព្រិលៗនៃចលនា។
  - **OLED Motion** / **Motion Pro** : ធ្វើឲ្យរូបភាពដែលមានចលនាលឿនកាន់តែច្បាស់ ដោយប្រើប្រព័ន្ធបញ្ចាពន្លឺ។

- សំណុំកំណត់កម្រិតខ្ពស់ អាចមានការផ្លាស់ប្តូរតែនៅក្នុងទម្រង់ **អ្នកប្រើ** ប៉ុណ្ណោះ។

- ដោយអាស្រ័យសញ្ញាទិន្នន័យចូលរទម្រង់នៃរូបភាពដែលបានជ្រើសរើស ជម្រើសដែលអាចរកបាននឹងប្រែខុសគ្នា។
- ធាតុដែលអាចកំណត់រចនាសម្ព័ន្ធបានខុសគ្នាទៅតាមម៉ូដែល។

## ការកំណត់ទំហំអេក្រង់

⚙ → ⋮ → **រូបភាព** → **ការកំណត់ផលធៀប** → **អត្រាទ្រង់ទ្រាយ**

អ្នកអាចប្តូរទំហំអេក្រង់ ទៅតាមប្រភេទមាតិកាដែលអ្នកកំពុងទស្សនា។

### 16:9

បង្ហាញសមាមាត្រ16:9។

### ដើម

ប្តូរសមាមាត្រទៅ 4:3 ឬ 16:9 ដោយអាស្រ័យលើសញ្ញាវីដេអូចូល។

### 4:3

បង្ហាញសមាមាត្រ4:3។

### ពង្រីកបញ្ឈរ

អ្នកអាចកែតម្រូវវិមាត្រអេក្រង់បញ្ឈររបស់អេក្រង់ និងតម្រឹមអេក្រង់បញ្ឈរដោយប្រើ **សម្រួលអត្រាពង្រីក** និង **កែសម្រួលទីតាំងអេក្រង់**។

### ការពង្រីកបង្រួមដោយប្រើប៊ូតុង 4 ទិស

អ្នកអាចកែតម្រូវវិមាត្រអង្កត់ទ្រូងផ្តេក/បញ្ឈររបស់អេក្រង់ និងតម្រឹមអេក្រង់ផ្តេក/បញ្ឈរដោយប្រើ **សម្រួលអត្រាពង្រីក** និង **កែសម្រួលទីតាំងអេក្រង់**។

- ធាតុដែលអាចកំណត់រចនាសម្ព័ន្ធបានខុសគ្នាទៅតាមម៉ូដែល។
- រូបភាពអាចនឹងបែក នៅពេលពង្រីក ឬបង្រួម។
- ការជ្រើសរើសទំហំអេក្រង់ខុសពីទំហំដើមអាចនឹងបណ្តាលឱ្យរូបភាពមានលក្ខណៈខុសប្លែក។
- អាស្រ័យលើការរួមបញ្ចូលគ្នារវាងទម្រង់រូបភាព និងទំហំអេក្រង់ គែមអាចនឹងត្រូវបានលាក់ ឬបង្ហាញជាពណ៌ខ្មៅ ឬផ្នែកទាំងសងខាងរបស់រូបភាពអាចនឹងភ្លឹភ្លឹបភ្លែតៗ។ ដូចគ្នានេះដែរ នៅពេលជ្រើសរើសធាតុណាមួយនៅលើអេក្រង់ផ្សាយ បន្ទាត់អាចនឹងមិនស្របគ្នាបានត្រឹមត្រូវនោះទេ។
- ដោយអាស្រ័យលើសញ្ញាចូល ទំហំអេក្រង់ដែលអាចប្រើបានអាចខុសគ្នា។

## ដើម្បីមើលអេក្រង់ការប្រើ ទើបស្មេន

⚙ → ⋮ → **រូបភាព** → **ការកំណត់ផលធៀប** → **ទើបស្មេន**

បើអ្នកដាក់កំណត់បើកមុខងារពិសេសនេះទៅ**បើក**នោះអ្នកនឹងអាចមើលមេឌៀ ឬមាតិកានៅក្នុងទំហំសមាមាត្រដែលស្ថិតនៅក្នុងសញ្ញាផ្សាយ និងប្រភពមេឌៀ / មាតិកាបាន។ បើជ្រុងនៃអេក្រង់មិនច្បាស់ សូមកំណត់បិទវាទៅ**បិទ**។
ប្រសិនបើជ្រើសរើសទៅជា **ស្វ័យប្រវត្តិ** លក្ខណៈពិសេសនឹងប្តូរគ្នារវាងស្ថានភាព **បើក** ឬ **បិទ** អាស្រ័យលើព័ត៌មាននៅក្នុងសញ្ញាវីដេអូ។

- ធាតុដែលអាចជ្រើសរើសបាន អាចប្រែប្រួលទៅតាមធាតុចូលបច្ចុប្បន្ន។

## ដើម្បីប្រើមុខងារ Energy Saving

⚙ → ⋮ → **រូបភាព** → **ការសន្សំសំចៃថាមពល**

កាត់បន្ថយការប្រើប្រាស់ថាមពល ដោយកែតម្រូវពន្លឺអេក្រង់កម្រិតខ្ពស់។

### ស្វ័យប្រវត្តិ

ឧបករណ៍ចាប់សញ្ញាទូរទស្សន៍រកឃើញពន្លឺនៅជុំវិញ ហើយកែតម្រូវពន្លឺអេក្រង់ដោយស្វ័យប្រវត្តិ។

- អាចនឹងមិនស្គាល់ម៉ូដែលមួយចំនួន។

### បិទ

បិទម៉ូដ Energy Saving ។

### អប្បបរមា / មធ្យម / អតិបរមា

អនុវត្តម៉ូដសន្សំថាមពលដែលបានកំណត់ទុករួច។

### បិទអេក្រង់

អេក្រង់ត្រូវបានបិទ និងបន្លឺតែសំឡេងប៉ុណ្ណោះ។
ចុចប៊ូតុងណាមួយ លើកលែងតែប៊ូតុងថាមពល និងកម្រិតសំឡេង ដើម្បីបើកអេក្រង់វិញ។

- ប្រសិនបើអ្នកប្រើមុខងារ **ការសន្សំសំចៃថាមពល** នឹងប៉ះពាល់ដល់ពន្លឺរបស់ទូរទស្សន៍។

## ពន្លឺអប្បបរមា

⚙ → ⋮ → **រូបភាព** → **ពន្លឺអប្បបរមា**

អ្នកអាចកំណត់កម្រិតងងឹតនៃអេក្រង់បាន នៅពេលកំណត់ **ការសន្សំសំចៃថាមពល** ទៅ **ស្វ័យប្រវត្តិ**។

### ដើម្បីប្រើមុខងារ **របៀបផាសុខភាពភ្នែក**

⚙ → ⋮ → **រូបភាព** → **ការកំណត់បន្ថែម** → **របៀបផាសុខភាពភ្នែក**

សីតុណ្ហភាពពណ៌នឹងត្រូវបានកែតម្រូវ ដើម្បីកាត់បន្ថយការឈឺភ្នែក។

**បើក**

សីតុណ្ហភាពពណ៌អេក្រង់ទូរទស្សន៍របស់អ្នកត្រូវបានកែតម្រូវ។

**បិទ**

បិទ **របៀបផាសុខភាពភ្នែក**។

- អាចនឹងមិនស្គាល់ម៉ូដែលមួយចំនួន។

## HDMI ULTRA HD Deep Color

⚙ → ⋮ → **រូបភាព** → **ការកំណត់បន្ថែម** → **HDMI ULTRA HD Deep Color**

ប្រសិនបើអ្នកភ្ជាប់ឧបករណ៍ដែលស្គាល់ **HDMI ULTRA HD Deep Color** នោះអ្នកអាចរីករាយជាមួយរូបភាពដែលកាន់តែច្បាស់ជាងមុន។
បន្ទាប់ពីភ្ជាប់ឧបករណ៍ចាក់រួចហើយ សូមកំណត់ **HDMI ULTRA HD Deep Color** ទៅ **បើក**។
ប្រសិនបើឧបករណ៍ដែលភ្ជាប់មិនស្គាល់មុខងារនេះទេ នោះវាអាចនឹងដំណើរការមិនត្រឹមត្រូវឡើយ។
ក្នុងករណីនេះ ប្តូរការកំណត់ពណ៌ជ្រៅ HD ធំសម្បើមនៃ HDMI របស់ទូរទស្សន៍ទៅ **បិទ**។

**គុណភាពបង្ហាញដែលបានគាំទ្រ**

- បើក : គាំទ្រ 4K@120 Hz (4:4:4, 4:2:2, និង 4:2:0)
- បិទ : គាំទ្រ 4K@60 Hz (4:2:0)

ទ្រង់ទ្រាយគាំទ្រ 4K @ 100/120 Hz

| កម្រិតគុណភាព | កម្រិតរូបភាព (Hz) | ជម្រៅពណ៌/គំរូក្រុម | | |
|---|---|---|---|---|
| | | 8 bit | 10 bit | 12 bit |
| 3840 × 2160p<br>4096 × 2160p | 50<br>59.94<br>60 | YCbCr 4:2:0 | YCbCr 4:2:0 1) | YCbCr 4:2:0 1) |
| | | YCbCr 4:2:2 1) | YCbCr 4:2:2 1) | YCbCr 4:2:2 1) |
| | | YCbCr 4:4:4 1) | YCbCr 4:4:4 1) 2) | YCbCr 4:4:4 1) 2) |

| | | | |
|---|---|---|---|
| | RGB 4:4:4 [1] | RGB 4:4:4 [1,2] | RGB 4:4:4 [1,2] |
| 100<br>120 | YCbCr 4:2:0 [1,2] | YCbCr 4:2:0 [1,2] | YCbCr 4:2:0 [1,2] |
| | YCbCr 4:2:2 [1,2] | YCbCr 4:2:2 [1,2] | YCbCr 4:2:2 [1,2] |
| | YCbCr 4:4:4 [1,2] | YCbCr 4:4:4 [1,2] | - |
| | RGB 4:4:4 [1,2] | RGB 4:4:4 [1,2] | - |

1) ដំណើរការបាននៅពេល **HDMI ULTRA HD Deep Color** ត្រូវកំណត់ទៅជា **បើក**។
2) ស្គាល់តែរន្ធនៃធាតុបញ្ចូល HDMI មួយចំនួនប៉ុណ្ណោះ។

- អ្នកអាចផ្លាស់ប្តូរតែការកំណត់នៃ **HDMI IN** ដែលអ្នកកំពុងមើល។
- អ្នកអាចបញ្ជាក់ពីការកំណត់ផ្សេងគ្នាសម្រាប់រន្ធ HDMI នីមួយៗបាន។

## ការប្រើ ការឆ្លើយតបនៅក្នុងហ្គេមភ្លាមៗ

⚙ → ⋮ → **រូបភាព** → **ការកំណត់បន្ថែម** → **ការឆ្លើយតបនៅក្នុងហ្គេមភ្លាមៗ**

កំណត់រន្ធ HDMI ដែលភ្ជាប់ជាមួយឧបករណ៍ឱ្យ **បើក**
ដើម្បីរីករាយក្នុងការលេងហ្គេមជាមួយនឹងវីដេអូកម្រិតគុណភាពខ្ពស់បំផុតសម្រាប់ហ្គេម។
ប្រសិនបើឧបករណ៍ដែលភ្ជាប់មិនស្គាល់មុខងារនេះទេ
នោះវាអាចនឹងដំណើរការមិនត្រឹមត្រូវឡើយ។

- កំណត់លក្ខណៈពិសេស **HDMI ULTRA HD Deep Color** ទៅ **បើក** សម្រាប់ភ្ជាប់ច្រក HDMI ទៅឧបករណ៍លេងហ្គេម ដើម្បីបើក **ការឆ្លើយតបនៅក្នុងហ្គេមភ្លាមៗ**។
- វាដំណើរការនៅពេល ⚙ → ⋮ → **សំឡេង** → **សំឡេងចេញ** គឺ **ឧបករណ៍បំពងសំឡេងខាងក្នុងទូរទស្សន៍**/**សំឡេងចេញ (ខ្សែក្រៅ)**/**កាសមានខ្សែ**/**កាសមានខ្សែ + ឧបករណ៍បំពងសំឡេងខាងក្នុងទូរទស្សន៍** ប៉ុណ្ណោះ។ (ធាតុដែលអាចកំណត់រចនាសម្ព័ន្ធបានខុសគ្នាទៅតាមម៉ូដែល។)
- នៅពេលចាប់ផ្តើម**ការឆ្លើយតបនៅក្នុងហ្គេមភ្លាមៗ** វីដេអូអាចនឹងភ្លឹបភ្លែតៗបណ្តោះអាសន្ន។
- ប្រសិនបើអ្នក **បើក** លក្ខណៈពិសេសនេះ អ្នកមិនអាចប្តូរធាតុការកំណត់វីដេអូមួយចំនួនបានទេ។

## ការប្រើ AMD FreeSync Premium

⚙ → ⋮ → **រូបភាព** → **ការកំណត់បន្ថែម** → **AMD FreeSync Premium**

សកម្មភាពនេះកាត់បន្ថយការប្រេះអេក្រង់ និងវីដេអូដើរយឺតក្នុងអំឡុងពេលលេងហ្គេម។

- ដើម្បីប្រើលក្ខណៈពិសេស **AMD FreeSync Premium** អ្នកត្រូវតែកំណត់ **HDMI ULTRA HD Deep Color** នៃច្រកដែលត្រូវគ្នាទៅ **បើក** ឬ **4K/8K**។
- នៅពេលប្រតិបត្តិការ **AMD FreeSync Premium**អាចនឹងមានការប្រែប្រួលពន្លឺតិចតួច អាស្រ័យលើហ្វ្រេកង់របស់ឧបករណ៍ខាងក្រៅ។
- អាចនឹងមិនស្គាល់ម៉ូដែលមួយចំនួន។

## កែសម្រួលផ្ទៃកងងឹតឱ្យស័ក្តិសមបំផុត

⚙ → ⋮ → **រូបភាព** → **ការកំណត់បន្ថែម** → **កែសម្រួលផ្ទៃកងងឹតឱ្យស័ក្តិសមបំផុត**

អ្នកអាចកែសម្រួលពន្លឺនៃកន្លែងងងឹតដែល **ការឆ្លើយតបនៅក្នុងហ្វ្រេមភ្លាមៗ** ឬ **AMD FreeSync Premium** ត្រូវបានកំណត់ទៅ **បើក**។

- វាប្រហែលជាមិនដំណើរការប្រក្រតីទេ អាស្រ័យលើមុខងារ ឬការកំណត់របស់កុំព្យូទ័រដែលបានភ្ជាប់ ឬកុងសូលហ្គេម។

## ការប្តូរដោយស្វ័យប្រវត្តិចំពោះ FILMMAKER MODE

⚙ → ⋮ → **រូបភាព** → **ការកំណត់បន្ថែម** → **ការប្តូរដោយស្វ័យប្រវត្តិចំពោះ FILMMAKER MODE**

ប្រសិនបើកំណត់ទៅ **បើក** **របៀបរូបភាព** នឹងត្រូវបានប្តូរទៅ **FILMMAKER MODE** ដោយស្វ័យប្រវត្តិ នៅពេលមានការបញ្ចូលរលកសញ្ញា ដែលអាចដំណើរការជាមួយ **FILMMAKER MODE** បាន។

- ថ្វីបើរបៀបនេះបង្ហាញពីបំណងរបស់អ្នកបង្កើតយ៉ាងមានប្រសិទ្ធភាពក៏ពិតមែន ប៉ុន្តែវាអាចមានភាពងងឹតជាង **របៀបរូបភាព** ផ្សេងទៀត។

## ការកំណត់អេក្រង់ OLED

⚙ → ⋮ → **រូបភាព** → **ធាតុរក្សាអេក្រង់ OLED**

ជាមួយនឹង **ធាតុរក្សាអេក្រង់ OLED**, អ្នកអាចកែលម្អបញ្ហាគុណភាពរូបភាពទាក់ទងនឹងការប៉ះរូបភាព នៅពេលអេក្រង់ត្រូវបានបើកសម្រាប់រយៈពេលជាក់លាក់។

### មុខងារវិញ្ញាសភិចសែល

វាកែតម្រូវបញ្ហាណាមួយដែលអាចកើតឡើងលើអេក្រង់ នៅពេលទូរទស្សន៍របស់អ្នកត្រូវបានបើករយៈពេលយូរ។
ការកែតម្រូវត្រូវប្រើពេលជាងមួយម៉ោង។

- **ដំណើរការតែម្តង នៅពេលបិទទូរទស្សន៍** : ចុចប៊ូតុងPower ដើម្បីបិទទូរទស្សន៍ នៅពេលអ្នកមើលចប់។ **មុខងារវិញ្ញាសភិចសែល** នឹងចាប់ផ្តើមដំណើរការ។
- **ចាប់ផ្តើមឥឡូវនេះ** : ទូរទស្សន៍របស់អ្នកបិទភ្លាម ហើយ **មុខងារវិញ្ញាសភិចសែល** ចាប់ផ្តើមដំណើរការ។ ទូរទស្សន៍របស់អ្នកនឹងបើកវិញដោយស្វ័យប្រវត្តិនៅពេលរួចរាល់។

- មិនត្រូវដកឌុយភ្លើង នៅពេលដែលវាកំពុងដំណើរការទេ។
- ប្រសិនបើអ្នកបើកទូរទស្សន៍ **មុខងាររីហ្វ្រែសភិចសែល** នឹងឈប់ដំណើរការ។

### ការប្ដូរអេក្រង់

វារំកិលអេក្រង់បន្តិចម្ដងៗតាមចន្លោះពេលទៀងទាត់ ដើម្បីការពារការប៉ះរូបភាពលើបន្ទះបង្ហាញ។

### ការកែសម្រួលពន្លឺនិមិត្តសញ្ញា

កែតម្រូវភាពភ្លឺរបស់រូបភាពថេរដូចជារូបសញ្ញានៅក្នុងមាតិកា ដើម្បីកែបញ្ហាគុណភាពរូបភាពដែលមាន។

# សំឡេង

## Dolby Atmos

→ → **សំឡេង** → **Dolby Atmos**

Dolby Atmos ផ្អែកលើការយល់ឃើញរបស់វត្ថុបំណងសំឡេង។ សំឡេងណាមួយអាចត្រូវត្រូវបានបញ្ចូលគ្នាជាសំឡេងតែមួយ, វត្ថុតែមួយ ដែលដាក់នៅកន្លែងឯករាជ្យក្នុងកន្លែងបីវិមាត្រ។ ទូរទស្សន៍ LG ថ្មីរបស់អ្នកត្រូវបានបើកជាមួយបច្ចេកវិទ្យាសំឡេងរបស់ Dolby Atmos ចុងក្រោយបំផុត។ Dolby Atmos គឺជាបទពិសោធន៍សំឡេងដ៏អស្ចារ្យដែលបង្កើត, រំកិលសំឡេងដែលនៅជុំវិញអ្នកដោយប្រើអូប៉ាល័ររបស់ទូរទស្សន៍។

ម៉ឺនុយ ដែលបើក/បិទ តម្លៃលំនាំដើមគឺ **បើក**។ ឲ្យតែឥទ្ធិពលរបស់ **Dolby Atmos**, អនុវត្តមាតិកា Dolby Atmos។ (ម៉ឺនុយពេលបើក **បើក**)

- មាតិកា Dolby Atmos មិនអាចត្រូវបានលេង។

## ការកំណត់របៀបសំឡេង

→ → **សំឡេង** → **ការកំណត់របៀបសំឡេង**

### របៀបសំឡេង

អ្នកអាចជ្រើសរើសទម្រង់សំឡេងដែលសមស្របបំផុតសម្រាប់ប្រភេទនីមួយៗបាន។

- **សំឡេង AI** / **សំឡេង AI Pro** : ស្វ័យបង្កើតប្រសិទ្ធភាពសំឡេងដែលអាស្រ័យលើប្រភេទមេឌៀ ឬមាតិកា។
- **ស្តង់ដារ** : បង្កើនប្រសិទ្ធភាពសំឡេងសម្រាប់ប្រភេទមេឌៀ ឬមាតិកាទាំងអស់។

- **រោងកុន** : បង្កើនប្រសិទ្ធភាពសំឡេងសម្រាប់ភាពយន្ត។
- **សំឡេងច្បាស់ III** / **សំឡេងច្បាស់ IV** : បង្កើនភាពច្បាស់នៃសំឡេង។
- **កីឡា** / **បាល់ទាត់** / **Cricket** : បង្កើនប្រសិទ្ធភាពសំឡេងសម្រាប់ល្បែង ឬហ្គេមកីឡា។
- **តន្ត្រី** : បង្កើនប្រសិទ្ធភាពសំឡេងសម្រាប់តន្ត្រី។
- **ហ្គេម** : បង្កើនប្រសិទ្ធភាពសំឡេងសម្រាប់ការលេងហ្គេម។

### លំនឹង

អ្នកអាចលៃតម្រូវកម្រិតសំឡេងនៃប្រដាប់បំពងសំឡេងខាងឆ្វេង និងខាងស្ដាំបាន។

### សំឡេងរងំបែបនិមិត្តបន្ថែម / សំឡេងរងំរណ្ដំបែបនិមិត្តបន្ថែម / សំឡេងរងំបែប ULTRA / សំឡេងរងំរណ្ដំបែប ULTRA / សំឡេងរងំបែប OLED

រីករាយនឹងផ្នែកនៃតន្ត្រីដែលបង្កប់ជាមួយនឹងប្រសិទ្ធភាពសំឡេងក្នុងប៉ុស្ដិ៍និម្មិតចម្រុះ។

- ជម្រើសនេះអាចបើកបានប្រសិនបើ **របៀបសំឡេង**ត្រូវបានកំនត់ជា**ស្តង់ដារ**។

### អ៊ីក្វាឡាយ

អ្នកអាចកំណត់សំឡេងដែលចង់បានដោយលៃតម្រូវអង្គធ្វើងសំឡេងបានដោយផ្ទាល់។
(100 Hz/300 Hz/1 kHz/3 kHz/10 kHz)

- ជម្រើសនេះអាចបើកបានប្រសិនបើ **របៀបសំឡេង**ត្រូវបានកំនត់ជា**ស្តង់ដារ**។

### កំណត់ឡើងវិញ

អ្នកអាចប្ដូរសំណុំកំណត់បែបផែនសំឡេងបាន។

- ជម្រើសនេះអាចបើកបានប្រសិនបើ **របៀបសំឡេង**ត្រូវបានកំនត់ជា**ស្តង់ដារ**។

- កំណត់នេះគ្រាន់តែអាចរកបានសម្រាប់ប្រដាប់បំពងសំឡេងទូរទស្សន៍ខាងក្រៅប៉ុណ្ណោះ។
- ធាតុដែលអាចកំណត់រចនាសម្ព័ន្ធបានខុសគ្នាទៅតាមម៉ូដែល។

## ការកំណត់សំឡេងចេញ

⚙ → ⋮ → **សំឡេង** → **សំឡេងចេញ**

- នៅពេល **ការឆ្លើយតបនៅក្នុងហ្គេមភ្លាមៗ** ត្រូវបានកំណត់ទៅ **បើក** សំឡេងអាចនឹងមានការយឺតយ៉ាវ ប្រសិនបើអ្នកកំណត់ **សំឡេងចេញ** ទៅ **ឧបករណ៍បំពងសំឡេង WiSA**/**អុបទិក**/**HDMI ARC**។
ប្ដូរទៅ **ឧបករណ៍បំពងសំឡេងខាងក្នុងទូរទស្សន៍** ឬប្ដូរ ⚙ → ⋮ → **សំឡេង** → **ការកំណត់បន្ថែម** → **ទម្រង់សំឡេងធាតុបញ្ចូល HDMI** ទៅ **PCM**។

#### ឧបករណ៍បំពងសំឡេងខាងក្នុងទូរទស្សន៍

អូឌីយោត្រូវបានចាក់លេងតាមរយៈប្រដាប់បំពងសំឡេងខាងក្រៅទូរទស្សន៍។

## Bluetooth

ភ្ជាប់ឧបករណ៍សំឡេង Bluetooth ដោយឥតខ្សែ ដើម្បីរីករាយជាមួយសំឡេងទូរទស្សន៍បានការតែងាយស្រួល។
សូមពិនិត្យមើលសៀវភៅណែនាំសម្រាប់អ្នកប្រើប្រាស់ដែលនិយាយអំពីឧបករណ៍សំឡេង Bluetooth ដើម្បីទទួលបានព័ត៌មានលម្អិតអំពីរបៀបភ្ជាប់ និងប្រើប្រាស់ឧបករណ៍។

- ចុច ⊜ ដើម្បីមើលបណ្តាឧបករណ៍ដែលបានតភ្ជាប់ ឬឧបករណ៍ដែលគេអាចតភ្ជាប់ទៅឧបករណ៍ណាមួយក្នុងចំណោមឧបករណ៍ទាំងនេះបាន។
- LG Sound Sync ឧបករណ៍នឹងព្យាយាមភ្ជាប់ទៅឧបករណ៍ដែលទើបប្រើថ្មីៗដោយស្វ័យប្រវត្តិនៅពេលដែលអ្នកបើកទូរទស្សន៍។
- យើងខ្ញុំសូមណែនាំឲ្យអ្នកប្រើឧបករណ៍អូឌីយោ LG ដែលស្គាល់ LG Sound Syncដោយការប្រើទម្រង់ LG TV ឬទម្រង់ LG Sound Sync លើឧបករណ៍។

- បើការតភ្ជាប់ឧបករណ៍មិនបានសម្រេច ពិនិត្យមើលថាមពលនៃឧបករណ៍ដែលតភ្ជាប់ និងពិនិត្យមើលថាតើឧបករណ៍អូឌីយោកំពុងដើរស្រួលឬក៏អត់។
- ដោយអាស្រ័យលើប្រភេទឧបករណ៍ Bluetooth ឧបករណ៍នេះអាចនឹងមិនតភ្ជាប់បានត្រឹមត្រូវបើមិនដូច្នេះទេ ដំណើរការមិនប្រក្រតីអាចនឹងកើតមានឡើងដែលមានប្រភេទដូចជាវីដេអូ និងអូឌីយោដែលបានធ្វើសមកាលកម្ម។
( កាសប្រើសម្រាប់តែឧបករណ៍ចល័តប្រហែលជាមិនដំណើរការទេ។ )
- សំឡេងអាចត្រដិត ឬគុណភាពសំឡេងអាចមានការធ្លាក់ចុះ បើ:

  - ឧបករណ៍ Bluetooth នៅឆ្ងាយពីទូរទស្សន៍ពេក
  - មានរបាំងរវាងឧបករណ៍ Bluetooth និងទូរទស្សន៍
  - បានប្រើរួមគ្នាជាមួយនឹងគ្រឿងបរិក្ខារវិទ្យុដែលមានប្រភេទដូចជា ជើងក្រាន់មីក្រូវេវ ឬ LAN ឥតខ្សែ។

- ប្រសិនបើ **របៀបរូបភាព** ត្រូវបានកំណត់ជា **ហ្គេម** និង **សំឡេងចេញ** ត្រូវបានកំណត់ជា **Bluetooth**ការផ្លាស់ប្តូរ **របៀបរូបភាព** ទៅ **ស្តង់ដារ**។
- ប្រសិនបើអ្នកនៅតែជួបនឹងបញ្ហាទៀត យើងសូមណែនាំឱ្យប្រើការតភ្ជាប់ដោយប្រើខ្សែ។ ( ឌីជីថលអុបទិក, រន្ធ **HDMI (ARC)** )

## ឧបករណ៍បំពងសំឡេង WiSA

អ្នកអាចភ្ជាប់ទូរទស្សន៍ជាមួយ **ឧបករណ៍បំពងសំឡេង WiSA** ដោយឥតប្រើខ្សែបាន ដើម្បីរីករាយនឹងសំឡេងដែលមានកម្រិតគុណភាពខ្ពស់។
ជ្រើសរើស ⊜ ដើម្បីកែសម្រួលការកំណត់លម្អិតសម្រាប់ **ឧបករណ៍បំពងសំឡេង WiSA**។

- អាចនឹងមិនស្គាល់ម៉ូដែលមួយចំនួន។
- ដើម្បីប្រើឧបករណ៍បំពងសំឡេង WiSA អ្នកត្រូវភ្ជាប់ឧបករណ៍របស់វាជាមុនសិន។

- បញ្ហាក្នុងការភ្ជាប់រវាងឧបករណ៍ WiSA ជាមួយនឹងឧបករណ៍បំពងសំឡេង WiSA អាចនឹងកើតមានឡើង នៅក្នុងមជ្ឈដ្ឋានដែលមានការរំខានលើរលកសញ្ញា។ ក្នុងករណីនេះ សូមទាក់ទងទៅក្រុមហ៊ុនផលិតឧបករណ៍បំពងសំឡេង។
- សម្រាប់ព័ត៌មានបន្ថែមអំពីការទិញផលិតផលដែលមានការទទួលស្គាល់ពី WiSA សូមពិនិត្យមើលនៅលើ www.wisaassociation.org ។

### ឧបករណ៍ចល័ត

ប្រសិនបើអ្នកដំឡើងកម្មវិធី LG ThinQ នៅលើឧបករណ៍ឆ្លាតវៃ រួចភ្ជាប់វាជាមួយទូរទស្សន៍ អ្នកអាចប្រើឧបករណ៍នោះជាឧបករណ៍បំពងសំឡេងសម្រាប់ទូរទស្សន៍បាន។

### អុបទិក

អ្នកអាចភ្ជាប់ឧបករណ៍អូឌីយោដែលស្គាល់ **អុបទិក** ទៅរន្ធដោតខ្សែអុបទិកនៃអូឌីយោឌីជីថល ដែលនឹងរីករាយស្ដាប់សំឡេងទូរទស្សន៍របស់អ្នកដែលមានគុណភាពកាន់តែល្អ និងងាយស្រួលខ្លាំង។

- គ្រាន់តែមានស្រាប់ម៉ូដែលមានរន្ធដោតខ្សែអុបទិកឌីជីថលប៉ុណ្ណោះ។
- សម្រាប់ឧបករណ៍មួយចំនួន អ្នកអាចកែសម្រួលកម្រិតសំឡេងបានដោយប្រើតេឡេបញ្ជាទូរទស្សន៍។

### HDMI ARC

សំឡេងពីទូរទស្សន៍អាចត្រូវបានបញ្ចូលតាមរយៈឧបករណ៍សំឡេងខាងក្រៅដែលបានតភ្ជាប់តាមរយៈរន្ធ **HDMI (ARC)**។

- ជ្រើសរើស **HDMI ARC** ដើម្បីបើក SIMPLINK ដោយស្វ័យប្រវត្តិ។ នៅពេល SIMPLINK ត្រូវបានបិទ ការកំណត់អូប៉ាល័រចេញត្រឡប់ទៅការកំណត់លំនាំដើមដោយស្វ័យប្រវត្តិ សម្រាប់ការបញ្ចេញសំឡេងដែលមិនរំខាន។

### សំឡេងចេញ (ខ្សែក្រៅ) / កាសមានខ្សែ

ជ្រើសរើស **កាសមានខ្សែ** ឬ **សំឡេងចេញ (ខ្សែក្រៅ)** ដើម្បីបង្កើនប្រសិទ្ធភាពទិន្នន័យចេញនៃអូឌីយោដោយអាស្រ័យលើឧបករណ៍ដែលបានតភ្ជាប់។

- អាចនឹងមិនស្គាល់ម៉ូដែលមួយចំនួន។
- បើអ្នកភ្ជាប់កាសស្ដាប់មានខ្សែ នៅខណៈដែលទូរទស្សន៍កំពុងមានបើកថាមពល វាស្វ័យរកឃើញកាសស្ដាប់មានខ្សែ និងបញ្ជូនអូឌីយោតាមរយៈវា។

## ការចាក់លេងអូឌីយោតាមរយៈប្រដាប់បំពងសំឡេងខាងក្រៅទូរទស្សន៍ និងឧបករណ៍អូឌីយោខាងក្រៅដំណាលៗគ្នា។

អូឌីយោអាចមានការចាក់លេងបានតាមរយៈឧបករណ៍ចម្រុះដំណាលៗគ្នា។

### សំឡេងរងំតាម Bluetooth + ឧបករណ៍បំពងសំឡេងខាងក្នុងទូរទស្សន៍

សំឡេងបញ្ចេញដំណាលគ្នាពីឧបករណ៍បំពងសំឡេងដែលភ្ជាប់មកជាមួយស្រាប់របស់ទូរទស្សន៍ និងឧបករណ៍បំពងសំឡេង Bluetooth ផ្តល់នូវសំឡេងរងំដូចសំឡេងពិតៗ នៅពេលទស្សនាភាពយន្ត ឬរឿងភាគ។
អ្នកអាចភ្ជាប់ជាមួយឧបករណ៍ Bluetooth ដែលមានម៉ូដែលដូចគ្នាបានរហូតដល់ពីរ ដើម្បីកំណត់សំឡេងរងំឆ្វេង/ស្តាំ។

01 ជ្រើសរើស → **ការរៀបចំសំឡេងរងំតាម Bluetooth** ដើម្បីភ្ជាប់ឧបករណ៍ Bluetooth ។

02 ដំណើរការ **ការពន្យារសំឡេង**
ដើម្បីធ្វើសមកាលកម្មឧបករណ៍បំពងសំឡេងខាងក្នុងរបស់ទូរទស្សន៍ ជាមួយឧបករណ៍បំពងសំឡេងរបស់ Bluetooth ។ អ្នកអាចកែសម្រួលវាបានដោយផ្ទាល់ ឬដោយស្វ័យប្រវត្តិ។

- នៅពេលអ្នកកំណត់ **សំឡេងចេញ** ទៅ **សំឡេងរងំតាម Bluetooth + ឧបករណ៍បំពងសំឡេងខាងក្នុងទូរទស្សន៍** ប្រសិនបើ **របៀបរូបភាព** គឺជា **ហ្គេម** វានឹងផ្លាស់ប្តូរទៅ **ស្តង់ដារ** ហើយ **Dolby Atmos** នឹងត្រូវបានបិទ។
- នៅពេលប្រើប្រាស់មុខងារ Screen Share វីដេអូ និងសំឡេងអាចនឹងមិនធ្វើសមកាលកម្មឡើយ។ យើងសូមណែនាំឱ្យប្រើ **ឧបករណ៍បំពងសំឡេងខាងក្នុងទូរទស្សន៍** នៅក្នុង **សំឡេងចេញ**។
- ឧបករណ៍ពីរប្រហែលជាមិនអាចភ្ជាប់ជាមួយគ្នាក្នុងពេលតែមួយបានទេ អាស្រ័យលើប្រភេទឧបករណ៍ Bluetooth របស់អ្នក។
- ដោយអាស្រ័យលើប្រភេទឧបករណ៍ Bluetooth ឧបករណ៍នេះអាចនឹងមិនតភ្ជាប់បានត្រឹមត្រូវ បើមិនដូច្នេះទេ ដំណើរការមិនប្រក្រតីអាចនឹងកើតមានឡើងដែលមានប្រភេទដូចជាវីដេអូ និងអូឌីយ៉ោដែលបានធ្វើសមកាលកម្ម។

### អុបទិក + ឧបករណ៍បំពងសំឡេងខាងក្នុងទូរទស្សន៍

អូឌីយ៉ោត្រូវបានចាក់លេងតាមរយៈប្រដាប់បំពងសំឡេងដែលមានតភ្ជាប់នឹងទូរទស្សន៍ស្រាប់ ហើយឧបករណ៍អូឌីយ៉ោដែលតភ្ជាប់ទៅរន្ធដោតអូឌីយ៉ោចេញតាមខ្សែអុបទិកឌីជីថល ដំណាលៗគ្នា។

### កាសមានខ្សែ + ឧបករណ៍បំពងសំឡេងខាងក្នុងទូរទស្សន៍

អូឌីយ៉ោត្រូវបានចាក់លេងតាមរយៈប្រដាប់បំពងសំឡេងខាងក្រៅទូរទស្សន៍ និង **កាសមានខ្សែ** ដំណាលៗគ្នា។

- អាចនឹងមិនស្គាល់ម៉ូដែលមួយចំនួន។
- បើអ្នកភ្ជាប់កាសស្តាប់មានខ្សែ នៅខណៈដែលទូរទស្សន៍កំពុងមានបើកថាមពល វាស្វ័យរកឃើញកាសស្តាប់មានខ្សែ និងបញ្ជូនអូឌីយ៉ោតាមរយៈវា។

## ប្រភេទដំឡើងទូរទស្សន៍

⚙ → ⋮ → **សំឡេង** → **ការកំណត់បន្ថែម** → **ប្រភេទដំឡើងទូរទស្សន៍**

ទម្រង់នេះបង្កើនប្រសិទ្ធភាពសំឡេងដោយអាស្រ័យលើការរៀបចំទូរទស្សន៍។

### ជើងបញ្ឈរ

ជ្រើសរើសវា ប្រសិនបើដំឡើងទូរទស្សន៍ដោយដាក់បញ្ឈរ។

### ចាប់ភ្ជាប់ជញ្ជាំង

ជ្រើសរើសវា ប្រសិនបើដំឡើងទូរទស្សន៍ជាប់នឹងជញ្ជាំង។

- កំណត់នេះគ្រាន់តែអាចរកបានសម្រាប់ប្រដាប់បំពងសំឡេងទូរទស្សន៍ខាងក្រៅប៉ុណ្ណោះ។

## ការដាក់កំណត់ទម្រង់កម្រិតសំឡេង

⚙ → ⋮ → **សំឡេង** → **ការកំណត់បន្ថែម** → **របៀបកម្រិតសំឡេង**

### កម្រិតសំឡេងស្វ័យប្រវត្តិ

ចុច **បើក** ដើម្បីកែសម្រួលកម្រិតសំឡេងដោយស្វ័យប្រវត្តិ សម្រាប់ក្រុមហ៊ុនផ្សាយផ្សេងគ្នា ដើម្បីឱ្យអ្នកអាចស្ដាប់ប៉ុស្តិ៍តាមកម្រិតសំឡេងដែលត្រូវការបានជានិច្ច ទោះបីជាប្ដូរប៉ុស្តិ៍ហើយក៏ដោយ។

### ចំនួនកើននៃកម្រិតសំឡេង

ជ្រើសរើស **ទាប**/**មធ្យម**/**ខ្ពស់** ដើម្បីលៃតម្រូវវិសាលភាពកម្រិតសំឡេង។ លេខកាន់តែធំ កម្រិតសំឡេងកាន់តែខ្លាំង។

- កំណត់នេះគ្រាន់តែអាចរកបានសម្រាប់ប្រដាប់បំពងសំឡេងទូរទស្សន៍ខាងក្រៅប៉ុណ្ណោះ។

## ការកំណត់សំឡេងទូរទស្សន៍ឌីជីថល

⚙ → ⋮ → **សំឡេង** → **ការកំណត់បន្ថែម** → **ការកំណត់សំឡេងទូរទស្សន៍ឌីជីថល**

នៅពេលដែលមានប្រភេទអូឌីយោផ្សេងក្នុងសញ្ញាទិន្នន័យចូល មុខងារនេះនឹងអនុញ្ញាតឲ្យអ្នកជ្រើសរើសប្រភេទអូឌីយោដែលអ្នកចង់បាន។

បើមានកំណត់ទៅជា **ស្វ័យប្រវត្តិ** លំដាប់លំដោយស្វែងរក គឺ AC4 → HE-AAC → Dolby Digital Plus → Dolby Digital → MPEG ហើយទិន្នន័យចេញត្រូវបានបង្កើតឡើងតាមទម្រង់ឯកសារអូឌីយោទីមួយដែលបានរកឃើញ។

- លំដាប់លំដោយស្វែងរកអាចប្រែប្រួលទៅតាមប្រទេស។ : AC4 → HE-AAC → Dolby Digital Plus → Dolby Digital → MPEG។
- បើទម្រង់ឯកសារអូឌីយោដែលបានជ្រើសរើសគ្មានការស្គាល់ទេនោះ ទម្រង់ឯកសារអូឌីយោមួយទៀតអាចនឹងមានការប្រើសម្រាប់ទិន្នន័យចេញ។

- អាចនឹងមិនស្គាល់ម៉ូដែលមួយចំនួន។

## ការលៃតម្រូវសមកាលកម្ម AV

⚙ → ⋮ → **សំឡេង** → **ការកំណត់បន្ថែម** → **ការកែសម្រួលសកមកាលកម្ម AV**

ការលៃតម្រូវសមកាលកម្មនៃសំឡេងដែលចេញពីប្រដាប់បំពងសំឡេងដែលកំពុងដំណើរការ។
កាន់តែខិតជិត ❯ ការចេញសំឡេងកាន់តែយឺត។

បើអ្នកជ្រើសរើស **Bypass**លទ្ធផល ឬទិន្នន័យចេញដែលសញ្ញា ឬសំឡេងផ្សាយបានមកពីឧបករណ៍ខាងក្រៅដោយគ្មានអូឌីយោណាមួយនោះ នឹងពន្យា។ អូឌីយោអាចក្លាយជាលទ្ធផល ឬសញ្ញាចេញមុខវីដេអូបាន ដោយសារម៉ោងដែលទូរទស្សន៍ប្រើដំណើរការទិន្នន័យចូលនៃវីដេអូ។

- ជម្រើសដែលមានខុសគ្នាទៅតាមការកំណត់ **សំឡេងចេញ**។

## ទម្រង់សំឡេងធាតុបញ្ចូល HDMI

⚙ → ⋮ → **សំឡេង** → **ការកំណត់បន្ថែម** → **ទម្រង់សំឡេងធាតុបញ្ចូល HDMI**

អ្នកអាចកំណត់ទម្រង់សំឡេងសម្រាប់ធាតុបញ្ចូល HDMI នីមួយៗបាន។
នៅពេលសំឡេងដែលផ្តល់ជូនតាមរយៈរន្ធ HDMI មិនបានធ្វើសមកាលកម្មទេ សូមកំណត់វាទៅ **PCM**។

## LG Sound Sync

⚙ → ⋮ → **សំឡេង** → **ការកំណត់បន្ថែម** → **LG Sound Sync**

ភ្ជាប់ឧបករណ៍ LG Sound Sync ទៅរន្ធធាតុបញ្ចេញឌីជីថលអុកទិក រួចកំណត់ **សំឡេងចេញ** ទៅ **អុបទិក**។
នៅពេលកំណត់លក្ខណៈពិសេសនេះទៅ
**បើក**នោះអ្នកអាចកែសម្រួលកម្រិតសំឡេងរបស់ឧបករណ៍ដែលភ្ជាប់ LG Sound Sync ដោយប្រើតេឡេបញ្ជាទូរទស្សន៍បាន។

- ប្រសិនបើលក្ខណៈពិសេសនៃថាមពលស្វ័យប្រវត្តិរបស់របារសំឡេងដែលស្គាល់ LG Sound Sync ត្រូវបានកំណត់ទៅ បើក នោះរបារសំឡេងនឹងបើក ឬបិទ ដំណាលគ្នាដែរ នៅពេលដែលបើក ឬបិទទូរទស្សន៍។

## ការកំណត់ សំឡេងចេញឌីជីថល

⚙ → ⋮ → **សំឡេង** → **ការកំណត់បន្ថែម** → **សំឡេងចេញឌីជីថល**

អ្នកអាចកំណត់រចនាសម្ព័ន្ធសំណុំកំណត់ **សំឡេងចេញឌីជីថល** បាន។

- ការកំណត់នេះអាចប្រើតែនៅពេល ⚙ → ⋮ → **សំឡេង** → **សំឡេងចេញ** ត្រូវបានកំណត់ទៅ **អុបទិក/HDMI ARC** ប៉ុណ្ណោះ។

- នៅពេលដែលបើកមុខងារ**ឆ្លងកាត់** សម្លេងនឹងមិនអាចលឺបានទេ។
- លទ្ធផលកូឌិកតាមរយៈឧបករណ៍អាចខុសគ្នាពីរលកសញ្ញាបញ្ចូល។

| | ទិន្នន័យចូលនៃសំឡេង | ទិន្នន័យចេញនៃសំឡេងឌីជីថល |
|---|---|---|
| **PCM** | ទាំងអស់ | PCM |
| **ស្វ័យប្រវត្តិ / ឆ្លងកាត់** | MPEG | PCM |
| | Dolby Digital | Dolby Digital |
| | Dolby Digital Plus / Atmos | (Optical) Dolby Digital<br>(HDMI ARC) Dolby Digital Plus / Atmos |
| | Dolby TrueHD (សម្រាប់ HDMI តែប៉ុណ្ណោះ) | (Optical) Dolby Digital<br>(HDMI ARC) Dolby Digital Plus / Atmos<br>(HDMI ARC eARC បើក) TrueHD[1)] |
| | HE-AAC | Dolby Digital |

1) នៅពេលភ្ជាប់ជាមួយ eARC
ប្រភេទសំឡេងបញ្ចេញនឹងពឹងផ្អែកលើប្រភេទសំឡេងដែលឧបករណ៍ដែលបានភ្ជាប់នោះស្គាល់។

- Dolby TrueHD , eARC , Dolby Atmos : អាចនឹងមិនស្គាល់ម៉ូដែលមួយចំនួន។

## ការប្រើ eARC ដែលស្គាល់ឧបករណ៍សំឡេង

⚙ → ⋮ → **សំឡេង** → **ការកំណត់បន្ថែម** → **eARC**

eARC គឺជាបច្ចេកវិទ្យាដែលអាចផ្ញើ និងទទួលព័ត៌មានសំឡេងច្រើនរហ័សជាងមុន ដោយសារតែកម្រិតបញ្ជូនរបស់វាធំជាងកម្រិតបញ្ជូនរបស់ ARC ដែលមានស្រាប់។ អ្នកអាចរីករាយនឹងសំឡេងទូរទស្សន៍ ដែលមានគុណភាពខ្ពស់ជាង ARC តាមរយៈឧបករណ៍សំឡេងដែលបានភ្ជាប់។

01 ភ្ជាប់ឧបករណ៍សំឡេងដែលស្គាល់ eARC ទៅរន្ធ **HDMI (ARC)** ។

02 កំណត់ **សំឡេងចេញ** ទៅជា **HDMI ARC**។

03 កំណត់ **eARC** ទៅជា **បើក**។

# ប៉ុស្តិ៍

## កំណត់ប៉ុស្តិ៍ដោយស្វ័យប្រវត្តិ

⚙ → ⋮ → **ប៉ុស្តិ៍** → **ការរាវប៉ុស្តិ៍ និងការកំណត់** → **ការរាវប៉ុស្តិ៍ដោយស្វ័យប្រវត្តិ**

ចាប់ប៉ុស្តិ៍ដោយស្វ័យប្រវត្តិ។

01 ជ្រើសរើសប្រទេសដែលកំពុងប្រើទូរទស្សន៍។
ការកំណត់ប៉ុស្តិ៍ផ្លាស់ប្តូរអាស្រ័យលើប្រទេសដែលអ្នកជ្រើសរើស។

02 ចាប់ផ្តើម **ការរាវប៉ុស្តិ៍ដោយស្វ័យប្រវត្តិ**។

03 ជ្រើសរបៀបរាវប៉ុស្តិ៍

04 កំណត់ការប្តូរដោយស្វ័យប្រវត្តិតាមការណែនាំលើកញ្ចក់ទូរទស្សន៍។

- ប្រសិនបើគេតភ្ជាប់ប្រភពចូលមិនបានត្រឹមត្រូវទេការចុះឈ្មោះប៉ុស្តិ៍មិនដំណើរការទេ។
- **ការរាវប៉ុស្តិ៍ដោយស្វ័យប្រវត្តិ** ចាប់បានតែប៉ុស្តិ៍ដែលកំពុងផ្សាយប៉ុណ្ណោះ។
- ប្រសិនបើបើក **ការចាក់សោប៉ុស្តិ៍** វិនដូលោតឡើងនឹងបង្ហាញដើម្បីសួររកពាក្យសម្ងាត់។

### កំណត់ការកំណត់ខ្សែ

នៅពេលកំពុងស្វែងរកប៉ុស្តិ៍ដោយប្រើការកំណត់ពេញលេញ វាអាចចំណាយពេលយូរបន្តិច។
តម្លៃខាងក្រោមត្រូវការដើម្បីស្វែងរកប៉ុស្តិ៍ដែលមានឲ្យបានលឿន និងត្រឹមត្រូវ។
តម្លៃដែលប្រើជាធម្មតាត្រូវបានផ្តល់នៅ "លំនាំដើម" ។
ឧបករណ៍ដែលអាចកំណត់បានខុសគ្នាទៅតាម **ប្រភេទ**។

#### ហ្វ្រេកង់ (kHz)

បញ្ចូលហ្វ្រេកង់ដែលកំណត់អ្នកប្រើប្រាស់។

#### អត្រានិមិត្តសញ្ញា (kS/s)

ល្បឿនរបស់ឧបករណ៍ដូចជាម៉ូឌឹមបញ្ជូនទៅប៉ុស្តិ៍មួយ។

#### ការបែងចែករលកសញ្ញា

ការផ្ទុករលកសញ្ញាសំឡេង ឬវីដេអូ ទៅលើឧបករណ៍ផ្ទុក។

### លេខសម្គាល់បណ្ដាញ

អ្នកំណត់តែមួយគត់ដែលបានលៃទុកសម្រាប់អ្នកប្រើប្រាស់នីមួយៗ។

### ហ្វ្រេកង់ចាប់ផ្ដើម (kHz)

បញ្ចូលលំដាប់ហ្វ្រេកង់ចាប់ផ្ដើមដែលកំណត់អ្នកប្រើប្រាស់។

### ហ្វ្រេកង់បញ្ចប់ (kHz)

បញ្ចូលលំដាប់ហ្វ្រេកង់ចុងក្រោយដែលកំណត់អ្នកប្រើប្រាស់។

**កំណត់ការកំណត់ផ្កាយរណប**

អ្នកអាចបន្ថែម/លុប/កំណត់ផ្កាយរណបដែលអ្នកចង់បាន។

- ប្រសិនបើម៉ូដរបស់ប៉ុស្តិ៍ត្រូវកំណត់ជាផ្កាយរណប

### ផ្កាយរណប

ជ្រើសរើសផ្កាយរណបដែលអ្នកចង់បាន។

### ហ្វ្រេកង់ LNB

ជ្រើសរើសតម្លៃមួយពី 9750/10600, 9750/10750, 9750, 10600, 10750, 11300, 5150, MDU1, MDU2, MDU3, MDU4, MDU5។ ប្រសិនបើអ្នកជ្រើសរើសយក 9750/10600, 9750/10750(MHz), **កម្រិតសំឡេង 22kHz** ត្រូវបានបិទ។
ប្រសិនបើអ្នករកមិនឃើញតម្លៃហ្វ្រេកង់ LNB ពីបញ្ជីទេ ត្រូវជ្រើសរើសអ្នកប្រើ និងបញ្ចូលហ្វ្រេកង់ដោយដៃ។

- អាចនឹងមិនស្គាល់ម៉ូដែលមួយចំនួន។

### ឧបករណ៍បញ្ជូនរលកសញ្ញា

ជ្រើសរើសឧបករណ៍ទទួលដែលអ្នកចង់បើក។

### កម្រិតសំឡេង 22kHz

នៅពេលប្រើការប្ដូរ 22kHz Tone switch ជ្រើសរើស 22kHz ឬ 0 Hz ។ ប្រសិនបើអ្នកប្រើ **កម្រិតសំឡេង 22kHz**, ប្រភេទ Unicable និងMotor ត្រូវបានបិទ។

### ថាមពេល LNB

ដើម្បីឲ្យឧបករណ៍ផ្គត់ផ្គង់ភ្លើងដំណើរការបានសម្រាប់ LNB ត្រូវជ្រើសរើស **បើក**។ ប្រសិនបើអ្នកជ្រើសរើស **បិទ**, **ប្រភេទម៉ូទ័រ** ត្រូវបានបិទ។

### DiSEqC

នៅពេលប្រើ DiSEqC ជ្រើសរើសជម្រើសមួយពី A~D/ToneA~B។ ប្រសិនបើអ្នកប្រើ **DiSEqC**, Unicable និង Motor ត្រូវបានបិទ។

## Unicable

ជ្រើសរើសបើក ដើម្បីប្រើយូនីខេបល និងកំណត់នៅក្នុងមីនុយ **ការកំណត់ Unicable**។ នៅពេលយូនីខេបល ដំណើរការ **កម្រិតសំឡេង 22kHz**, **DiSEqC**, **ប្រភេទម៉ូទ័រ** ត្រូវបានបិទ។

- មុខងារនេះត្រូវបានបង្ហាញជា **SatCR** នៅលើម៉ូដែលមួយចំនួន។

## ប្រភេទម៉ូទ័រ

ជ្រើសរើសប្រភេទម៉ូទ័រ ដើម្បីប្រើប្រាស់ម៉ូទ័រ និងក្នុងមីនុយការកំណត់ម៉ូទ័រ។ នៅពេលម៉ូទ័រអាចប្រើបាន នោះ, **កម្រិតសំឡេង 22kHz**, **DiSEqC**, **Unicable** មិនអាចប្រើបានទេ។

- ប្រសិនបើអ្នកកំណត់ផ្កាយរណបទៅជាអ្វីផ្សេង អ្នកត្រូវបន្ថែមប្រដាប់ទទួលទូរលេខដោយប្រើការកែសម្រួលប្រដាប់ទទួលទូរលេខ។
- នៅពេលជ្រើសរើសយក 22kHz Tone និង DiSEqC អ្នកត្រូវតែតភ្ជាប់ពួកវានៅក្នុងទីតាំងដូចគ្នាដូចដែលបានបង្ហាញនៅ OSD ។
- ប្រសិនបើអ្នកលុបផ្កាយរណប នោះប៉ុស្តិ៍ទាំងអស់ដែលរក្សាទុកនៅក្នុងផ្កាយរណបនឹងត្រូវលុបចោល ។

**កំណត់ការកំណត់ម៉ូទ័រ**

**DiSEqC 1.2** : គ្រប់គ្រងម៉ូទ័រ ដើម្បីប្តូរទីតាំងចានផ្កាយរណប។

## ទិសដៅថាស

ជ្រើសរើសទិសដៅដែលអ្នកចង់ប្តូរម៉ូទ័រ។

## របៀបថាស

ម៉ូដពីរអាចប្រើបាន៖ ជំហានបន្ទាប់ និងបន្ត។

- ជំហាន : ម៉ូទ័រប្តូរបានអាស្រ័យដោយតម្លៃដែលអ្នកបញ្ចូល (ពី1 ទៅ 128) ។
- **បន្ត** : ម៉ូទ័របន្តប្តូររហូតដល់អ្នកចុចបញ្ឈប់។

## សាកល្បងឧបករណ៍បញ្ជូនរលកសញ្ញា

ជ្រើសរើសសាកល្បងប្រដាប់ទទួលទូរលេខដែលអ្នកចង់បើក។

## កំណត់កម្រិត

កំណត់ការប្តូរម៉ូទ័រទៅខាងកើត ឬខាងលិច ដើម្បីរំកិលទៅតាមទិសដៅដែលកំណត់។

- បើក : អ្នកអាចកំនត់ការប្តូរទៅទិសដៅបច្ចុប្បន្នដោយជ្រើសរើសខាងលិច/ខាងកើត។
- បិទ : អ្នកអាចបោះបង់ចំនួនដែលអ្នកបានកំណត់រួច។

**ចូលទៅកាន់ 0**

អ្នកអាចប្តូរម៉ូទ័រទៅសូន្យ។

**USALS** : កំណត់ទីតាំងបច្ចុប្បន្ន (រយៈបណ្តោយ/រយៈទទឹង)។

## ដើម្បីប្រើការប្តូរប៉ុស្តិ៍ដោយដៃ

→ ⋮ → **ប៉ុស្តិ៍** → **ការរាវប៉ុស្តិ៍** (**ការរាវប៉ុស្តិ៍ និងការកំណត់**) → **ការរាវប៉ុស្តិ៍ដោយផ្ទាល់**

មុខងារនេះគឺសម្រាប់ការស្វែងរក និងការរក្សាទុកប៉ុស្តិ៍ដោយផ្ទាល់ដៃ។
អ្នកអាចពិនិត្យកម្លាំងរលកសញ្ញានៃការផ្សព្វផ្សាយឌីជីថល។

## អាប់ដេតបញ្ជីប៉ុស្តិ៍

→ ⋮ → **ប៉ុស្តិ៍** → **ការរាវប៉ុស្តិ៍ និងការកំណត់** → **អាប់ដេតបញ្ជីប៉ុស្តិ៍**

ប្រសិនបើម៉ូដរបស់ប៉ុស្តិ៍ត្រូវកំណត់ជាខ្សែ

វាធ្វើបច្ចុប្បន្នភាពព័ត៌មានបញ្ជីប៉ុស្តិ៍ដែលបានប្តូរដោយផ្អែកលើស្ថានភាពនៃការផ្សព្វផ្សាយរបស់ប្រទេស។
បន្ទាប់ពីធ្វើបច្ចុប្បន្នភាពរួច បញ្ជីប៉ុស្តិ៍អាចប្រែប្រួល។ ប្រសិនបើមិនចង់បាន សូមចុច **បិទ**

ប្រសិនបើម៉ូដរបស់ប៉ុស្តិ៍ត្រូវកំណត់ជាផ្កាយរណប

មានការធ្វើបច្ចុប្បន្នភាពព័ត៌មានបញ្ជីប៉ុស្តិ៍ដែលបានប្តូរផ្អែកលើស្ថានភាព និងផ្កាយរណបនៃការផ្សព្វផ្សាយរបស់ប្រទេស។
មានការធ្វើបច្ចុប្បន្នភាពបញ្ជីប៉ុស្តិ៍នៅពេលទូរទស្សន៍បិទរយៈពេលយូរ។
បន្ទាប់ពីធ្វើបច្ចុប្បន្នភាពរួច បញ្ជីប៉ុស្តិ៍អាចប្រែប្រួល។ ប្រសិនបើអ្នកមិនចង់បាន សូមជ្រើសរើស **បិទ**។

ប្រសិនបើម៉ូដរបស់ប៉ុស្តិ៍ត្រូវកំណត់ជាអង់តែន

វាធ្វើបច្ចុប្បន្នភាពព័ត៌មានបញ្ជីប៉ុស្តិ៍ដែលបានប្តូរដោយផ្អែកលើស្ថានភាពនៃការផ្សព្វផ្សាយរបស់ប្រទេស។
វាធ្វើបច្ចុប្បន្នភាពបញ្ជីប៉ុស្តិ៍នៅពេលបិទទូរទស្សន៍។ បន្ទាប់ពីធ្វើបច្ចុប្បន្នភាពរួច បញ្ជីប៉ុស្តិ៍អាចប្រែប្រួល។ ប្រសិនបើអ្នកមិនចង់បាន សូមជ្រើសរើស **បិទ**។

- អាចនឹងមិនស្គាល់ម៉ូដែលមួយចំនួន។

## ដើម្បីប្រើតេស្តិ៍សញ្ញា

⚙ → ⋮ → **ប៉ុស្តិ៍ → ការរាវប៉ុស្តិ៍ (ការរាវប៉ុស្តិ៍ និងការកំណត់) → ការសាកល្បងរលកសញ្ញា**

បង្ហាញ MUX និងព័ត៌មានសេវា។ល។

- តេស្តរលកសញ្ញាមាននៅតែក្នុងទម្រង់អង់តែន ឬខ្សែ។
- អាចនឹងមិនស្គាល់ម៉ូដែលមួយចំនួន។

## កែសម្រួលប៉ុស្តិ៍

អ្នកអាចកែសម្រួលប៉ុស្តិ៍ដែលជ្រើសរើសរួចពីប៉ុស្តិ៍ដែលបានរក្សាទុក ឬបន្ថែម/លុបប៉ុស្តិ៍ទាំងនោះទៅ/ចេញពីប៉ុស្តិ៍សំណព្វ។

### កែសម្រួលបញ្ជីប៉ុស្តិ៍ទាំងអស់

⚙ → ⋮ → **ប៉ុស្តិ៍ → កម្មវិធីគ្រប់គ្រងប៉ុស្តិ៍ → កែរាវប៉ុស្តិ៍ទាំងអស់**

អ្នកអាចចាក់សោ ឬដោះសោប៉ុស្តិ៍ដែលជ្រើសរើសរួចពីប៉ុស្តិ៍ដែលបាន រក្សាទុក ឬអ្នកអាចកំណត់ប៉ុស្តិ៍ទាំងនោះដើម្បីរំលងនៅពេលប្តូរប៉ុស្តិ៍។




❶ កំណត់ជម្រើសតម្រៀបតាមប្រភេទ។

❷ **ចាក់សោ / ដោះសោ** : ចាក់សោប៉ុស្តិ៍ដែលជ្រើសរើសរួច ឬដោះសោប៉ុស្តិ៍ដែលចាក់សោ។
**រំលង / ស្តារឡើងវិញ** : កំណត់ប៉ុស្តិ៍ដែលជ្រើសរើសរួចដើម្បីរំលងនៅពេលប្តូរប៉ុស្តិ៍ ឬបិទជម្រើសរំលងប៉ុស្តិ៍ដែលកំណត់ពីមុនថាត្រូវរំលង។
**ប្តូរ** : រំកិលប៉ុស្តិ៍ដែលជ្រើសរើសរួច។
**កែសម្រួលលេខប៉ុស្តិ៍** : ប្តូរលេខប៉ុស្តិ៍ដែលជ្រើសរើសរួច។
**លុប** : លុបប៉ុស្តិ៍ដែលជ្រើសរើសរួច។

- មុខងារដែលមាន ប្រហែលជាមានភាពខុសគ្នាអាស្រ័យលើរលកសញ្ញាផ្សព្វផ្សាយ។
- សម្រាប់ ម៉ូដែលដែលដំណើរការជាមួយកម្មវិធីផ្កាយរណប
  អ្នកអាចគ្រប់គ្រងប៉ុស្តិ៍ផ្កាយរណបនៅក្នុង **កែសម្រួលប៉ុស្តិ៍ផ្កាយរណប (កម្រិតខ្ពស់)**។

### កែសម្រួលបញ្ជីប៉ុស្តិ៍សំណព្វទាំងអស់

⚙ → ⋮ → **ប៉ុស្តិ៍ → កម្មវិធីគ្រប់គ្រងប៉ុស្តិ៍ → កែសម្រួលសំណព្វ**

អ្នកអាចបន្ថែម ឬលុបប៉ុស្តិ៍ដែលចង់បានទៅ/ពីប៉ុស្តិ៍សំណព្វ ប្តូរទីតាំងរបស់ប៉ុស្តិ៍ទាំងនោះ ។ល។




1. ជ្រើសរើសប៉ុស្តិ៍ដែលចង់បានពីបញ្ជីប៉ុស្តិ៍ទាំងអស់ហើយចុចប៊ូតុងដើម្បីបន្ថែមប៉ុស្តិ៍ទាំងនោះទៅបញ្ជីប៉ុស្តិ៍សំណព្វ។
2. លុបប៉ុស្តិ៍ដែលជ្រើសរើសរួចចេញពីបញ្ជីប៉ុស្តិ៍សំណព្វ។
3. **ប្តូរ** : ជ្រើសរើសប៉ុស្តិ៍មួយ ឬច្រើននៅក្នុងបញ្ជីប៉ុស្តិ៍ដែលអ្នកពេញចិត្ត បន្ទាប់មកចុចប៊ូតុង **ប្តូរ** រួចហើយជ្រើសរើសកន្លែងដែលត្រូវផ្លាស់ទីវាទៅ។
   ប៉ុស្តិ៍ដែលបានជ្រើសរើសនឹងផ្លាស់ទីទៅទីតាំងដែលអ្នកបានជ្រើសរើស។
   **ប្តូរឈ្មោះក្រុមសំណព្វ** : ប្តូរឈ្មោះបញ្ជីប៉ុស្តិ៍សំណព្វ។
   **តម្រៀបតាមប៉ុស្តិ៍** : តម្រៀបបញ្ជីប៉ុស្តិ៍សំណព្វតាមប៉ុស្តិ៍។

## អត្ថបទព័ត៌មានច្រើន

⚙ → ⋮ → **ប៉ុស្តិ៍ → ពហុដំណឹង**

អ្នកអាចមើលពីជ្រុងដែលអ្នកចូលចិត្តលើទូរទស្សន៍តាមរយៈការផ្សាយដែលថតចេញពីជ្រុងផ្សេងៗគ្នា។

- អាចនឹងមិនស្គាល់ម៉ូដែលមួយចំនួន។

## ស្វែងយល់បន្ថែមអំពី HbbTV

HbbTV (Hybrid Broadcast Broadband TV)
គឺជាស្តង់ដារផ្សព្វផ្សាយថ្មីមួយដែលអាចប្រើសេវាប្រភេទអត្ថបទបង្ហាញលេងទូរទស្សន៍ពិសេស ដែលផ្សព្វផ្សាយដោយកម្មវិធីផ្សព្វផ្សាយទូរទស្សន៍ ដើម្បីបញ្ចូល ឬភ្ជាប់ទៅនឹងសេវាលើប្រព័ន្ធអ៊ីនធឺណិតលើរលកអាកាសទៅ Smart TV ដែលបានភ្ជាប់។
ដើម្បីមើលព័ត៌មានលម្អិត សូមចុច **រីករាយជាមួយទូរទស្សន៍បន្តផ្ទាល់ → HbbTV** ក្នុង **ការណែនាំសម្រាប់អ្នកប្រើប្រាស់**។

- អាចនឹងមិនស្គាល់ម៉ូដែលមួយចំនួន។

## ចម្លងប៉ុស្តិ៍

⚙ → ⋮ → **ប៉ុស្តិ៍** → **ចម្លងប៉ុស្តិ៍**

បញ្ចេញព័ត៌មានបញ្ជីប៉ុស្តិ៍ទូរទស្សន៍របស់អ្នក ទៅឧបករណ៍ផ្ទុកយូអេសប៊ីដែលបានតភ្ជាប់ ឬបញ្ចូលព័ត៌មានបញ្ជីប៉ុស្តិ៍ទូរទស្សន៍របស់អ្នកពីឧបករណ៍ផ្ទុកយូអេសប៊ីដែលបានតភ្ជាប់។

- សម្រាប់ម៉ូដែលផ្កាយរណប

# ការតភ្ជាប់

## ការកំណត់ឈ្មោះទូរទស្សន៍

⚙ → ⋮ → **ការតភ្ជាប់** → **ឈ្មោះទូរទស្សន៍**

អ្នកអាចប្រើក្តារចុចលើអេក្រង់ ដើម្បីកំណត់ឈ្មោះទូរទស្សន៍ឆ្លាតវៃឲ្យប្រើលើបណ្តាញ។

- អាចបញ្ចូលតួអក្សររហូតដល់ 25 ដោយប្រើអក្ខរក្រមភាសាអង់គ្លេស។

## ការកំណត់ការតភ្ជាប់បណ្តាញ

⚙ → ⋮ → **ការតភ្ជាប់** → **ការកំណត់ការតភ្ជាប់បណ្តាញ**

ប្រសិនបើអ្នកកែប្រែការកំណត់របស់បណ្តាញ អ្នកអាចប្រើសេវាជាច្រើន ដូចជាមាតិកា និងកម្មវិធីលើប្រព័ន្ធអ៊ីនធឺណិត។

#### ការកំណត់បណ្តាញមានខ្សែ

សូមជ្រើសរើស **ការតភ្ជាប់ដោយប្រើខ្សែ (អ៊ីសឺណិត)**។
ប្រសិនបើរ៉ោតទ័រភ្ជាប់ទៅបណ្តាញដែលស្គាល់លក្ខណៈពិសេស DHCP នោះការភ្ជាប់ទូរទស្សន៍ និងរ៉ោតទ័រតាមខ្សែ នឹងភ្ជាប់ទៅបណ្តាញដោយស្វ័យប្រវត្តិ។
ប្រសិនបើវាមិនស្គាល់ការរៀបចំដោយស្វ័យប្រវត្តិទេ អ្នកអាចជ្រើសរើស **កែសម្រួល** ដើម្បីរៀបចំការតភ្ជាប់បណ្តាញរបស់អ្នកដោយផ្ទាល់បាន។

#### ការកំណត់បណ្តាញឥតខ្សែ

សូមជ្រើសរើស **ការតភ្ជាប់ Wi-Fi**។
ប្រសិនបើអ្នករៀបចំទូរទស្សន៍សម្រាប់បណ្តាញឥតខ្សែ អ្នកអាចពិនិត្យមើល និងតភ្ជាប់ទៅបណ្តាញអ៊ីនធឺណិតឥតខ្សែដែលមាន។

### បន្ថែមបណ្ដាញឥតខ្សែដែលបានលាក់

ប្រសិនបើអ្នកបញ្ចូលឈ្មោះបណ្ដាញដោយផ្ទាល់ អ្នកអាចបន្ថែមបណ្ដាញឥតខ្សែ។

### ភ្ជាប់តាមរយៈ WPS PBC

ប្រសិនបើរ៉ោតទ័រឥតខ្សែដែលអ្នកចង់ភ្ជាប់មានលក្ខណៈពិសេសនៃការកំណត់រចនាសម្ព័ន្ធប៊ូតុងចុចសម្រាប់រៀបចំការការពារ Wi-Fi (WPS-PBC) នោះអ្នកអាចភ្ជាប់រ៉ោតទ័រឥតខ្សែបានយ៉ាងងាយស្រួល ដោយចុចប៊ូតុង WPS-PBC នៅលើរ៉ោតទ័រនោះ។ ចុចប៊ូតុង WPS-PBC របស់រ៉ោតទ័រឥតខ្សែ រួចចុចប៊ូតុង [ភ្ជាប់] របស់ទូរទស្សន៍។

### ភ្ជាប់តាមរយៈ WPS PIN

នេះគឺជាវិធីក្នុងការភ្ជាប់ទៅចំណុចចូលប្រើ ដោយប្រើលេខសម្គាល់ផ្ទាល់ខ្លួនសម្រាប់រៀបចំការការពារ Wi-Fi (WPS-PIN)។ ជ្រើសរើសចំណុចចូលប្រើ (AP) ដែលអ្នកចង់ភ្ជាប់។ បញ្ចូលកូដ PIN ដែលបង្ហាញនៅលើឧបករណ៍ Wi-Fi របស់ចំណុចចូលប្រើ។

### ការកំណត់ Wi-Fi កម្រិតខ្ពស់

បន្ទាប់ពីអ្នកភ្ជាប់ទៅបណ្ដាញឥតខ្សែរួចហើយ អ្នកអាចមើលព័ត៌មានអំពីការតភ្ជាប់បានដូចជា ព័ត៌មានលម្អិតអំពីអាសយដ្ឋាន IP ជាដើម។ លើសពីនេះទៀត អ្នកអាចប្ដូរអាសយដ្ឋាន IP និងអាសយដ្ឋានម៉ាស៊ីនមេ DNS ដែលអ្នកចង់ភ្ជាប់បាន ដោយចុចប៊ូតុង **កែសម្រួល** ។

- ការរៀបចំ IPv6 មិនស្គាល់ **កែសម្រួល** ទេ។
- សម្រាប់ព័ត៌មានបន្ថែមអំពីរបៀបភ្ជាប់ទៅបណ្ដាញ សូមមើល **ការចាប់ផ្ដើមប្រើទូរទស្សន៍ LG webOS** → **ការភ្ជាប់ទៅបណ្ដាញ** នៅក្នុង **ការណែនាំសម្រាប់អ្នកប្រើប្រាស់**។

## ការកំណត់ការតភ្ជាប់ឧបករណ៍

⚙ → ⋮ → **ការតភ្ជាប់** → **ការកំណត់ការតភ្ជាប់ឧបករណ៍**

អ្នកអាចភ្ជាប់ព័ត៌មានអំពីឧបករណ៍ដែលភ្ជាប់ជាមួយទូរទស្សន៍ និងកំណត់រចនាសម្ព័ន្ធនៃការកំណត់ ដែលទាក់ទងនឹងប្រតិបត្តិការ។

### ការចាប់ឧបករណ៍ដោយស្វ័យប្រវត្តិ

វាកំណត់ឱ្យអ្នកអាចគ្រប់គ្រងឧករណ៍ដែលបានភ្ជាប់តាមរយៈ HDMI ដោយប្រើតេឡេបញ្ជាវេទមន្តដោយស្វ័យប្រវត្តិ។

### SIMPLINK (HDMI-CEC)

តាមរយៈការប្រើប្រាស់តេឡេបញ្ជាតែមួយ អ្នកអាចងាយស្រួលគ្រប់គ្រងឧបករណ៍ផ្សេងៗដូចជា របារសំឡេង

ឬប្រអប់ចាប់ប៉ុស្តិ៍ដែលភ្ជាប់ជាមួយទូរទស្សន៍ ដែលមានរន្ធ HDMI។
ដើម្បីមើលព័ត៌មានលម្អិត សូមចុច **របៀបប្រើទូរទស្សន៍** → **ការភ្ជាប់ទៅ SIMPLINK (HDMI-CEC)** ក្នុង **ការណែនាំសម្រាប់អ្នកប្រើប្រាស់**។

- អាចភ្ជាប់ឧបករណ៍បានរហូតដល់បី និងអាចប្រើដំណាលគ្នាបាន។

## ការធ្វើសមកាលកម្មថាមពលដោយស្វ័យប្រវត្តិ

ប្រសិនបើ Auto Power Sync ត្រូវបានកំណត់ទៅ **បើក**នោះការបើកឧបករណ៍ដែលភ្ជាប់ SIMPLINK នឹងធ្វើឲ្យទូរទស្សន៍បើក។ នៅពេលអ្នកបិទទូរទស្សន៍ នោះឧបករណ៍នឹងបិទដែរ។

## ភ្ជាប់ឧបករណ៍បញ្ជាតាម Bluetooth

អ្នកអាចភ្ជាប់និងប្រើឧបករណ៍ដូចជា ដៃហ្គេម mouse ឬក្តារចុចដែល អាចប្រើ Bluetooth ជាមួយទូរទស្សន៍របស់អ្នក។
បើកឧបករណ៍ កំណត់វាទៅទម្រង់ផ្គូផ្គង ហើយបន្ទាប់មកចុច **ភ្ជាប់** លើអេក្រង់ទូរទស្សន៍របស់អ្នក។ នៅពេលបើកឧបករណ៍ដែលអ្នកបានភ្ជាប់ពីមុន
វានឹងភ្ជាប់ជាមួយទូរទស្សន៍របស់អ្នកដោយស្វ័យប្រវត្តិ។ ដើម្បីផ្តាច់ការតភ្ជាប់ដែលមានស្រាប់ ចុច **ផ្តាច់**។

- អ្នកគួរប្រើផលិតផលដែលត្រូវបានធ្វើតេស្តសមត្ថភាពប្រើប្រាស់ជាមួយទូរទស្សន៍ LG។
  Mouse ដែលប្រើ Bluetooth : Logitech M535, Logitech MX Master 2S, Apple Magic Mouse2
  ក្តារចុច Bluetooth : Logitech K480, Arteck HB030B, Arteck HB192, Apple Magic Keyboard
  ដៃហ្គេម Bluetooth : Sony DualShock 4, ឧបករណ៍បញ្ជា Microsoft Xbox One S, ឧបករណ៍បញ្ជា Microsoft Xbox Series X, ឧបករណ៍បញ្ជា NVIDIA SHIELD
- ម៉ូដែលដែលអាចប្រើ Bluetooth ទើបអាចប្រើលក្ខណៈពិសេសនេះបាន។
- ការភ្ជាប់ឧបករណ៍ Bluetooth ច្រើនអាចបណ្តាលឱ្យមានការតភ្ជាប់ ឬប្រតិបត្តិការខ្សោយ។
- ប្រសិនបើឧបករណ៍ Bluetooth ស្ថិតនៅឆ្ងាយពីទូរទស្សន៍ពេក ឬមានអ្វីបាំង ពួកវាប្រហែលជាមិនដំណើរការជាធម្មតាទេ។
- អាស្រ័យទៅតាមឧបករណ៍ភ្ជាប់ខាងក្រៅ (រ៉ោតទ័រឥតខ្សែ ម៉ាស៊ីនមីក្រូវ៉េវ ។ល។) បញ្ហាក្នុងការទំនាក់ទំនងអាចនឹងកើតមានឡើង។
- ប្រសិនបើឧបករណ៍ដែលអ្នកបានជ្រើសរើសពី **ឧបករណ៍ដែលបានចុះឈ្មោះ** មិនភ្ជាប់ឡើងវិញទេ សូម **ផ្តាច់** រួចភ្ជាប់ឧបករណ៍ឡើងវិញ។
- វាខុសគ្នាទៅតាមឧបករណ៍។ សម្រាប់ព័ត៌មានបន្ថែមអំពីឧបករណ៍ដែលអ្នកចង់តភ្ជាប់ សូមអានការណែនាំពីរបៀបប្រើប្រាស់របស់វា។

## ការកំណត់អង្គបញ្ជាសកល

ប្រសិនបើអ្នករៀបចំតេឡេបញ្ជាសកល នោះអ្នកអាចគ្រប់គ្រងឧបករណ៍ភ្ជាប់ខាងក្រៅដែលភ្ជាប់ទៅទូរទស្សន៍ដោយប្រើតេឡេបញ្ជាវេទមន្ត
ជំនួសឱ្យតេឡេបញ្ជារបស់ឧបករណ៍ទាំងនោះផ្ទាល់។
សម្រាប់ព័ត៌មានបន្ថែម សូមមើល **របៀបប្រើទូរទស្សន៍** → **ការប្រើប្រាស់តេឡេបញ្ជាសកល** ក្នុង **ការណែនាំសម្រាប់អ្នកប្រើប្រាស់**។

- ធាតុដែលអាចកំណត់រចនាសម្ព័ន្ធបានខុសគ្នាទៅតាមម៉ូដែល។

## ការគ្រប់គ្រងការតភ្ជាប់ឧបករណ៍ចល័ត

⚙ → ⋮ → **ការតភ្ជាប់** → **ការគ្រប់គ្រងការតភ្ជាប់ឧបករណ៍ចល័ត**

អ្នកអាចកំណត់ ដើម្បីប្រើឧបករណ៍ឆ្លាតវៃ ដែលភ្ជាប់ជាមួយទូរទស្សន៍ ដើម្បីដំណើរការទូរទស្សន៍ ឬគ្រប់គ្រងប្រវត្តិនៃការតភ្ជាប់បាន។

### បើកទូរទស្សន៍ដោយប្រើឧបករណ៍ចល័ត

ប្រសិនបើ **បើកតាមរយៈ Wi-Fi** ឬ **បើកតាមរយៈ Bluetooth** ត្រូវបានកំណត់ទៅ **បើក** នោះអ្នកអាចបើកទូរទស្សន៍របស់អ្នក ដោយប្រើកម្មវិធីដែលស្គាល់ **បើកទូរទស្សន៍ដោយប្រើឧបករណ៍ចល័ត** បាន។

- ទូរទស្សន៍គួរតែបានតភ្ជាប់បណ្ដាញ។
- ទូរទស្សន៍និងឧបករណ៍ដែលត្រូវប្រើគួរតែបានតភ្ជាប់បណ្ដាញតែមួយ។
- គេត្រូវតែប្រើមុខងារពិសេស **បើកតាមរយៈ Wi-Fi** នៅក្នុងកូនកម្មវិធីមួយក្នុងឧបករណ៍ទំនើប ដែលស្គាល់មុខងារពិសេសនេះ។
- គេគ្រាន់តែអាចប្រើមុខងារពិសេស **បើកតាមរយៈ Bluetooth** ទូរស័ព្ទទំនើប ឬទូរស័ព្ទទំនើប ពិតប្រាកដរបស់ LG Electronics ប៉ុណ្ណោះ។
- ទូរទស្សន៍ត្រូវតែបានដោតជាមួយឌុយភ្លើង។
- ដើម្បីតភ្ជាប់លើកដំបូង សូមប្រាកដថាឧបករណ៍ដែលត្រូវប្រើរួចរាល់ដើម្បីតភ្ជាប់។
- អាចនឹងមិនស្គាល់ម៉ូដែលមួយចំនួន។

### Screen Share

អ្នកអាចលុបប្រវត្តិនៃការតភ្ជាប់របស់ឧបករណ៍ ដែលបានភ្ជាប់ជាមួយទូរទស្សន៍តាមរយៈ Screen Share។

### ការចែករំលែកសំឡេង

អ្នកអាចលុបប្រវត្តិនៃការតភ្ជាប់របស់ឧបករណ៍ឆ្លាតវៃ ដែលត្រូវបានភ្ជាប់ជាមួយទូរទស្សន៍ តាមរយៈ Bluetooth ។

# ទូទៅ

## ការកំណត់ សេវាកម្ម AI

⚙ → ⋮ → **ទូទៅ** → **សេវាកម្ម AI**

អ្នកអាចបើកសេវាកម្មដែលបានណែនាំ ដោយផ្អែកលើប្រវត្តិប្រើប្រាស់។

### រូបភាព AI / រូបភាព AI Pro

នៅពេលកំណត់ទៅ **បើក**
នោះគុណភាពរូបភាពនឹងត្រូវបានកែលម្អឱ្យប្រសើរជាងមុនដោយស្វ័យប្រវត្តិ
សម្រាប់លក្ខណៈរបស់មាតិកា ដោយផ្អែកលើក្បួនដោះស្រាយ
ដែលចងចាំដោយបច្ចេកទេសនៃការរៀនស៊ីជម្រៅ។

- វាអាចប្រើសម្រាប់ការផ្សាយឌីជីថល វីដេអូក្នុងឧបករណ៍មេម៉ូរី USB និងធាតុបញ្ចូលវីដេអូ HDMI តែប៉ុណ្ណោះ។
- ប្រសិនបើ → → **រូបភាព** → **ការកំណត់របៀបរូបភាព** → **របៀបរូបភាព** គឺជា **ហ្គេម**អ្នកមិនអាចរៀបចំលក្ខណៈពិសេសនេះបានទេ។
- វាមិនដំណើរការជាមួយខ្លឹមសារដែលបានការពារការចម្លងទេ។

### ការគ្រប់គ្រងពន្លឺ AI

នៅពេលកំណត់ទៅ **បើក** ពន្លឺអេក្រង់នឹងត្រូវបានកែសម្រួលដោយស្វ័យប្រវត្តិ
ដោយផ្អែកលើពន្លឺនៅជុំវិញទូរទស្សន៍។

### ការជ្រើសរើសប្រភេទដោយស្វ័យប្រវត្តិ

នៅពេលកំណត់ទៅ **បើក**
គុណភាពរូបភាពនឹងត្រូវបានកែលម្អឱ្យប្រសើរជាងមុនដោយស្វ័យប្រវត្តិ
សម្រាប់ប្រភេទខ្លឹមសារតាមរយៈភាពឆ្លាតវៃសិប្បនិម្មិត។

- វាមិនដំណើរការជាមួយខ្លឹមសារដែលបានការពារការចម្លងទេ។

### សំឡេង AI / សំឡេង AI Pro

ប្រសិនបើកំណត់ទៅ **បើក** នោះវាផ្តល់នូវសំឡេងកម្រិតគុណភាពខ្ពស់បំផុត
និងបែបផែនសំឡេងពិតៗ ដោយផ្អែកលើភាពវៃឆ្លាតសិប្បនិម្មិតទៅតាមមាតិកា។

- កំណត់នេះគ្រាន់តែអាចរកបានសម្រាប់ប្រដាប់បំពងសំឡេងទូរទស្សន៍ខាងក្រៅប៉ុណ្ណោះ។
- នៅពេលកំណត់លក្ខណៈពិសេសនេះទៅ **បើក**, → → **សំឡេង** → **ការកំណត់របៀបសំឡេង** → **របៀបសំឡេង** ត្រូវបានប្តូរទៅ **សំឡេង AI/សំឡេង AI Pro**។

### ការកែប្រែសម្លេងដោយខ្លួនឯងដោយបច្ចេកវិទ្យា AI

ដោយការប្រើមុខងារពិសេស **ការកែប្រែសម្លេងដោយខ្លួនឯងដោយបច្ចេកវិទ្យា AI**
អ្នកអាចរាវរកឃើញចន្លោះដែលដំឡើងទូរទស្សន៍អ្នកដែលប្រើមីក្រូហ្វូន តេឡេពិសេសរបស់អ្នក
ដើម្បីបង្កើនប្រសិទ្ធភាពអូឌីយោនៃទូរទស្សន៍នៅកន្លែងរបស់អ្នក។
ជ្រើសរើស **ចាប់ផ្តើមការសម្រួលសំឡេងថ្មី** ដើម្បីវាស់ស្ទង់ទីកន្លែងដែលត្រូវដំឡើងទូរទស្សន៍។
នៅពេលដំណើរការរាវរកបានចប់សព្វគ្រប់ហើយ អ្នកអាចជ្រើសរើសទម្រង់អូឌីយោដែល
អ្នកចង់បាន។

- **បិទ** : ជម្រើសនេះបិទការប្រើ **ការកែប្រែសម្លេងដោយខ្លួនឯងដោយបច្ចេកវិទ្យា AI**-អូឌីយោដែលលៃតម្រូវ។
  ការជ្រើសរើសជម្រើសនេះ បង្កើតបានសំឡេងតាមលំនាំដើមនៃទូរទស្សន៍អ្នកដោយមិនចាំបាច់ធ្វើការលៃតម្រូវណាមួយចំពោះវា។
- **ស្តង់ដារ** : ការជ្រើសរើសជម្រើសនេះ បង្កើតបាន **ការកែប្រែសម្លេងដោយខ្លួនឯងដោយបច្ចេកវិទ្យា AI**-អូឌីយោដែលលៃតម្រូវក្នុងទម្រង់ស្តង់ដារ។ ទម្រង់នេះផ្តល់នូវសំឡេងច្បាស់ និងដូចធម្មជាតិ។
- **បន្ថែមកម្លាំងបាស** : ការជ្រើសរើសជម្រើសនេះ បង្កើតបាន **ការកែប្រែសម្លេងដោយខ្លួនឯងដោយបច្ចេកវិទ្យា AI**-អូឌីយោដែលលៃតម្រូវដែលផ្តោតលើបាស។
- **បង្កើនកម្រិតសំឡេង** : ការជ្រើសរើសជម្រើសនេះ បង្កើតបាន **ការកែប្រែសម្លេងដោយខ្លួនឯងដោយបច្ចេកវិទ្យា AI**-អូឌីយោដែលលៃតម្រូវដែលផ្តោតលើត្រីសូរ។

- បើមានច្រើនជាងកម្រិតសំឡេងរំខានក្នុងបណ្តាល័យ (លើសពី 30 ~ 40 dBA) យើងខ្ញុំសូមណែនាំឲ្យអ្នកបញ្ចូលពីគម្លាត 3 ម៉ែត្រ។
- មុខងារនេះអាចមិនដំណើរការបានត្រឹមត្រូវ។
  - សំឡេងរំខានផ្ទៃខាងក្រោយ មានទំហំធំខ្លាំងរហូតដាង 40 dBA។
  - ចម្ងាយរវាងទូរទស្សន៍ និង Magic Remote គឺ 16.4 ហ្វីត (5 ម៉ែត្រ) ឬលើសពីនេះ។

## សំគាល់សម្លេង

### សេវាកម្មសំគាល់សម្លេង

អ្នកអាចជ្រើសរើសសេវាកម្មសម្គាល់ការនិយាយ។

- សេវាកម្មដែលមានផ្តល់ជូនអាចខុសគ្នាទៅតាមការកំណត់សម្រាប់ភាសា ឬប្រទេសរបស់អ្នក។

### ការកំណត់ការសម្គាល់សំឡេង

អ្នកអាចប្រើការកំណត់សម្រាប់លក្ខណៈពិសេសនៃការសម្គាល់សំឡេង។

### ជំនួយសម្រាប់ការសម្គាល់សំឡេង

អ្នកអាចមើលបញ្ជីលក្ខណៈពិសេសដែលអ្នកអាចប្រើបាន តាមរយៈការគ្រប់គ្រងសំឡេង។

## ការណែនាំ AI

អ្នកអាចទទួលបានសារណែនាំអំពីមាតិកា ដោយផ្អែកលើប្រវត្តិទស្សនាមាតិកា និងប្រវត្តិប្រើប្រាស់កម្មវិធីរបស់អ្នក។

### ការណែនាំអំពីមាតិកា

អ្នកអាចទទួលបានការណែនាំអំពីមាតិកា ឬការណែនាំអំពីលក្ខណៈពិសេសថ្មីៗ ដោយផ្អែកលើទម្លាប់នៃការទស្សនាទូរទស្សន៍ និងការប្រើប្រាស់កម្មវិធីរបស់អ្នក។

- ដើម្បីមើលព័ត៌មានលម្អិត សូមចុច **ការរីករាយប្រើប្រាស់ LG Content Store** → **ការណែនាំអំពីមាតិកា** ក្នុង **ការណែនាំសម្រាប់អ្នកប្រើប្រាស់**។

### ការណែនាំដែលស្របនឹងបុគ្គល ដោយផ្អែកតាមបណ្ដាញ

អ្នកអាចទទួលបានការណែនាំសម្រាប់ប៊ូតុង
និងមាតិកាដែលផ្អែកលើប្រវត្តិទស្សនាតាមរយៈបណ្ដាញ។

- **បើក** : ទទួលបានការណែនាំច្រើនទៀតតាមរយៈម៉ាស៊ីនមេ។
- **បិទ** : យើងណែនាំមាតិកាមូលដ្ឋាន ដោយផ្អែកលើប្រវត្តិទស្សនារបស់អ្នក។

### លុបទិន្នន័យប្រើប្រាស់

វាកំណត់ប្រវត្តិទស្សនាមាតិកា និងប្រវត្តិប្រើប្រាស់កម្មវិធីឡើងវិញ។
ប្រសិនបើអ្នកកំណត់ពួកវាឡើងវិញ
វានឹងចំណាយពេលបន្តិចដើម្បីទទួលការណែនាំសម្រាប់មាតិកាម្ដងទៀត។

### ការជូនដំណឹងអំពីកីឡា

ទៅកាន់កម្មវិធី **ការជូនដំណឹងអំពីកីឡា** ។

- ធាតុដែលអាចកំណត់រចនាសម្ព័ន្ធបានខុសគ្នាទៅតាមម៉ូដែល។

## ការកំណត់រចនាសម្ព័ន្ធការកំណត់ភាសា

⚙ → ⋮ → **ទូទៅ** → **ភាសា (Language)**

អ្នកអាចជ្រើសរើសភាសាម៉ឺនុយឲ្យបង្ហាញលើអេក្រង់ និងភាសាតន្ត្រីនៃការផ្សាយឌីជីថល។

### ភាសាក្នុងម៉ឺនុយ (Menu Language)

អ្នកអាចជ្រើសរើសភាសាមួយក្នុងចំណោមភាសានៅក្នុងម៉ឺនុយជាច្រើនដើម្បីឲ្យបង្ហាញលើអេក្រង់។
ភាសាសម្រាប់ការសម្គាល់ការនិយាយនឹងត្រូវបានកំណត់ទៅភាសាដែលបានជ្រើសរើសសម្រាប់ម៉ឺនុយដោយស្វ័យប្រវត្តិ។

- ការសម្គាល់ការនិយាយត្រូវបានប្រើប្រាស់សម្រាប់ម៉ូឌែលមួយចំនួនតែប៉ុណ្ណោះ។

### ភាសាជាសំឡេងចម្បង / ភាសាជាសំឡេងបន្ទាប់បន្សំ

អ្នកអាចជ្រើសរើសភាសាដែលអ្នកចង់បាននៅពេលមើលកម្មវិធីផ្សាយឌីជីថល ដែលរួមមានភាសាតន្ត្រីច្រើនភាសា។
សម្រាប់កម្មវិធីដែលមិនគាំទ្រច្រើនភាសា ភាសាលំនាំដើមនឹងត្រូវបានប្រើ។

- អនុវត្តចំពោះការផ្សព្វផ្សាយបែបឌីជីថល។

### ភាសាក្តារចុច

ជ្រើសរើសភាសា ដើម្បីប្រើលើក្តារចុចលើអេក្រង់។

**ដើម្បីកំណត់ភាសារបស់អត្ថបទដែលបង្ហាញលើទូរទស្សន៍**

កំណត់ភាសារបស់អត្ថបទដែលបង្ហាញលើទូរទស្សន៍។
ដើម្បីមើលព័ត៌មានលម្អិត សូមចុច **វិករាយជាមួយទូរទស្សន៍បន្តផ្ទាល់** → **អក្សរសន្ទស្សន៍** ក្នុង **ការណែនាំសម្រាប់អ្នកប្រើប្រាស់**។

- តែក្នុងទម្រង់ឌីជីថលប៉ុណ្ណោះ

## ការកំណត់ទីតាំង

⚙ → ⋮ → **ទូទៅ** → **ទីតាំង**

អ្នកអាចប្តូរការកំណត់ទីតាំងទូរទស្សន៍ឆ្លាតវៃរបស់អ្នក។

### ការកំណត់អាសយដ្ឋាន

អ្នកអាចកំណត់ **តំបន់** និង **ទីក្រុង** នៃទូរទស្សន៍របស់អ្នកបាន។

### ប្រទេសផ្សព្វផ្សាយ

អ្នកអាចកំណត់ប្រទេសផ្សាយលើទូរទស្សន៍របស់អ្នក។

### លេខកូដតំបន់ផ្តល់សេវាកម្ម

មុខងារនេះត្រូវបានប្រើដើម្បីកំណត់ទីតាំងផ្សាយរបស់ទូរទស្សន៍ ដោយបញ្ចូលលេខកូដប្រទេសរបស់អ្នក។

### ប្រទេសផ្តល់សេវាកម្ម LG

ប្រសិនបើអ្នកមិនកំណត់ **កំណត់ដោយស្វ័យប្រវត្តិ**, អ្នកអាចជ្រើសរើសប្រទេសដោយដៃ។

- អ្នកត្រូវតែកំណត់ប្រទេសដោយដៃ នៅពេលអ្នកមិនបានតភ្ជាប់បណ្តាញ។
- ធាតុដែលអាចកំណត់រចនាសម្ព័ន្ធបានខុសគ្នាទៅតាមម៉ូដែល។

## ម៉ោង

⚙ → ⋮ → **ទូទៅ** → **ម៉ោង**

អ្នកអាចពិនិត្យមើលការកំណត់ដែលពាក់ព័ន្ធនឹងការកំណត់រចនាសម្ព័ន្ធ ឬម៉ោងបាន។

**កំណត់ដោយស្វ័យប្រវត្តិ**

ម៉ោងទូរទស្សន៍ត្រូវបានកំណត់ទៅម៉ោងនៃព័ត៌មានផ្សាយឌីជីថលដោយស្វ័យប្រវត្តិ ដែលផ្ញើពីស្ថានីយផ្សាយ ឬម៉ោងដែលផ្ញើពីម៉ាស៊ីនមេ។

### ម៉ោង / កាលបរិច្ឆេទ / ល្វែងម៉ោង

អ្នកអាចកំណត់ពេលវេលា និងកាលបរិច្ឆេទដោយដៃ ប្រសិនបើពេលវេលាបច្ចុប្បន្នបានកំណត់ដោយស្វ័យប្រវត្តិមិនត្រឹមត្រូវ។

- ប្រសិនបើអ្នកកំណត់ម៉ោងដោយផ្ទាល់ តាមរយៈអង់តែនដែលភ្ជាប់ ព័ត៌មានអំពីកាលវិភាគ ការណែនាំអំពីកម្មវិធី ។ល។ ប្រហែលជាមិនដំណើរការត្រឹមត្រូវនោះទេ។

### ល្វែងម៉ោងតាមបំណង

នៅពេលជ្រើសរើស **តាមបំណង** នៅក្នុង **ល្វែងម៉ោង**, ម៉ឺនុយ **ល្វែងម៉ោងតាមបំណង** ត្រូវបានបើក។

### កម្មវិធីកំណត់ម៉ោង

#### កម្មវិធីកំណត់ម៉ោងដេក

កំណត់ទូរទស្សន៍ឲ្យបិទតាមពេលវេលាដែលបានបញ្ជាក់។
ប្រសិនបើអ្នកមិនចង់ប្រើ **កម្មវិធីកំណត់ម៉ោងដេក** សូមជ្រើសរើស **បិទ**។

#### បើកកម្មវិធីកំណត់ម៉ោង

កំណត់ **បើកកម្មវិធីកំណត់ម៉ោង** ទៅជា **បើក**។
ទូរទស្សន៍ត្រូវបានបើក និងបង្ហាញប៉ុស្តិ៍ដែលបានកំណត់ នៅម៉ោងកំណត់។

- **ម៉ោង** : កំណត់ម៉ោងដែលត្រូវបើកទូរទស្សន៍។
- **ប្រើការកំណត់ម៉ោងឡើងវិញ** : កំណត់ថ្ងៃនៃសប្តាហ៍។ កំណត់ជម្រើសទៅ **គ្មាន** ដើម្បីដំណើរការលក្ខណៈពិសេសនេះតែម្តងប៉ុណ្ណោះ។
- **ធាតុបញ្ចូល** : កំណត់ធាតុបញ្ចូលខាងក្រៅសម្រាប់បង្ហាញ នៅពេលបើកថាមពល។
- **កំណត់ម៉ោងឲ្យប៉ុស្តិ៍** : កំណត់ប៉ុស្តិ៍សម្រាប់បង្ហាញ នៅពេលបើកថាមពល។ ជម្រើសនេះអាចកំណត់បាន តែនៅពេលដែលកំណត់ **ធាតុបញ្ចូល** ទៅ **ទូរទស្សន៍** ប៉ុណ្ណោះ។
- **កម្រិតសំឡេង** : កំណត់កម្រិតសំឡេងសម្រាប់ប្រើ នៅពេលបើកថាមពល។

#### បិទកម្មវិធីកំណត់ម៉ោង

កំណត់ **បិទកម្មវិធីកំណត់ម៉ោង** ទៅ **បើក**។
ទូរទស្សន៍បិទនៅម៉ោងកំណត់។

- **ម៉ោង** : កំណត់ម៉ោងដែលត្រូវបិទទូរទស្សន៍។
- **ប្រើការកំណត់ម៉ោងឡើងវិញ** : កំណត់ថ្ងៃនៃសប្តាហ៍។ កំណត់ជម្រើសទៅ **គ្មាន** ដើម្បីដំណើរការលក្ខណៈពិសេសនេះតែម្តងប៉ុណ្ណោះ។

### **បិទថាមពលដោយស្វ័យប្រវត្តិរយៈពេល 4 ម៉ោង**

ប្រសិនបើអ្នកមិនចុចប៊ូតុងណាមួយរយៈពេល 4 ម៉ោង
បន្ទាប់ពីបើកទូរទស្សន៍ដោយលក្ខណៈពិសេសដូចជា **បើកកម្មវិធីកំណត់ម៉ោង**ទេ
ទូរទស្សន៍នោះនឹងបិទដោយស្វ័យប្រវត្តិ។
ដើម្បីប្រាកដថា ទូរទស្សន៍មិនបិទដោយស្វ័យប្រវត្តិ កំណត់
**បិទថាមពលដោយស្វ័យប្រវត្តិរយៈពេល 4 ម៉ោង** ទៅ **បិទ**។

- អាចនឹងមិនស្គាល់ម៉ូដែលមួយចំនួន។

- ដើម្បីប្រើ **បើកកម្មវិធីកំណត់ម៉ោង/បិទកម្មវិធីកំណត់ម៉ោង**, កំណត់ពេលវេលាឲ្យបានត្រឹមត្រូវ។
- ប្រសិនបើ **ប្រើការកំណត់ម៉ោងឡើងវិញ** នៃ **បើកកម្មវិធីកំណត់ម៉ោង/បិទកម្មវិធីកំណត់ម៉ោង** ត្រូវបានកំណត់ទៅ **គ្មាន**
ប្រសិនបើដល់ម៉ោងដែលបានកំណត់នៅក្នុង **បើកកម្មវិធីកំណត់ម៉ោង** ពេលកំពុងមើលទូរទស្សន៍ នោះថាមពលនឹងបើកដោយស្វ័យប្រវត្តិ នៅពេលដល់ម៉ោងកំណត់ ហើយទូរទស្សន៍នឹងបិទនៅថ្ងៃបន្ទាប់ ឬពេលក្រោយ។
ប្រសិនបើដល់ម៉ោងដែលបានកំណត់នៅក្នុង **បិទកម្មវិធីកំណត់ម៉ោង** ពេលទូរទស្សន៍កំពុងដំណើរការ នោះថាមពលនឹងបិទដោយស្វ័យប្រវត្តិ នៅពេលដល់ម៉ោងកំណត់ ពេលកំពុងមើលទូរទស្សន៍នៅថ្ងៃបន្ទាប់ ឬពេលក្រោយ។

## ការបើក **ការចាក់សោកម្មវិធីទូរទស្សន៍**

មុខងារនេះ ដំណើរការបានដោយអាស្រ័យលើព័ត៌មានដែលបានពីស្ថានីយ៍ផ្សាយ។ អាស្រ័យហេតុ បើសញ្ញាមានព័ត៌មានមិនត្រឹមត្រូវ មុខងារនេះដំណើរការទៅបានទេ។
ទប់ស្កាត់កុំឲ្យកុមារមើលកម្មវិធីជាក់សម្រាប់មនុស្សធំដោយអាស្រ័យលើកម្រិតវាយតម្លៃដែលបានកំណត់។ វាយបញ្ចូលពាក្យសម្ងាត់ដើម្បីមើលកម្មវិធីដែលខ្ទប់ហើយ។ ការវាយតម្លៃខុសៗគ្នាទៅតាមប្រទេស។

01 ចុចប៊ូតុង ⚙ លើតេឡេ។

02 សូមជ្រើសរើស ⋮ → **ទូទៅ** → **សុវត្ថិភាព**។

03 កំណត់ **សុវត្ថិភាព** ទៅជា **បើក**។

04 ជ្រើសរើស **ការចាក់សោកម្មវិធីទូរទស្សន៍**។

- ស្គាល់តែនៅក្នុងទម្រង់ឌីជីថលប៉ុណ្ណោះ។
- អាចនឹងមិនស្គាល់ម៉ូដែលមួយចំនួន។
- ពាក្យសម្ងាត់ចាប់ផ្ដើមដំបូងត្រូវបានគេកំណត់ជា “0000”។

## ការបើក **ការចាក់សោប៉ុស្តិ៍**

ខ្ទប់ប៉ុស្តិ៍ដែលមានផ្ទុកមេឌៀ ឬមាតិកាដែលមិនត្រឹមត្រូវសម្រាប់កុមារ។ អាចមានការជ្រើសរើសប៉ុស្តិ៍នានាបាន តែអេក្រង់នៅទទេ ហើយអូឌីយោត្រូវបានដាក់ឲ្យស្ងាត់សំឡេង។ ដើម្បីមើលប៉ុស្តិ៍ដែលចាក់សោហើយបាន វាយបញ្ចូលពាក្យសម្ងាត់។

01 ចុចប៊ូតុង ⚙ លើតេឡេ។

02 សូមជ្រើសរើស ⋮ → **ទូទៅ** → **សុវត្ថិភាព**។

03 កំណត់ **សុវត្ថិភាព** ទៅជា **បើក**។

04 ជ្រើសរើស **ការចាក់សោប៉ុស្តិ៍**។

05 ជ្រើសរើសប៉ុស្តិ៍ដែលត្រូវចាក់សោ។

06 ជ្រើសរើស **ចាក់សោ / ដោះសោ**។

- ពាក្យសម្ងាត់ចាប់ផ្ដើមដំបូងត្រូវបានគេកំណត់ជា “0000”។
  នៅពេលភាសាបារាំង ឬន័រវេត្រូវបានជ្រើសរើសសម្រាប់ប្រទេស ពាក្យសម្ងាត់មិនមែន “0000” ទេប៉ុន្តែគឺ “1234”។

## ការបើក ការចាក់សោកម្មវិធី

អ្នកអាចចាក់សោ ឬដោះសោកម្មវិធីបាន។

01 ចុចប៊ូតុង ⚙ លើតេឡេ។

02 សូមជ្រើសរើស ⋮ → **ទូទៅ** → **សុវត្ថិភាព**។

03 កំណត់ **សុវត្ថិភាព** ទៅជា **បើក**។

04 ជ្រើសរើស **ការចាក់សោកម្មវិធី**។

05 ជ្រើសរើសកម្មវិធីដែលត្រូវចាក់សោ។

- ពាក្យសម្ងាត់ចាប់ផ្ដើមដំបូងត្រូវបានគេកំណត់ជា “0000”។
  នៅពេលភាសាបារាំង ឬន័រវេត្រូវបានជ្រើសរើសសម្រាប់ប្រទេស ពាក្យសម្ងាត់មិនមែន “0000” ទេប៉ុន្តែគឺ “1234”។
- មុខងារសោមិនអាចរកបានភ្លាមៗសម្រាប់កម្មវិធីដែលកំពុងដំណើរការទេ។

## ការបើក បានចាក់សោធាតុបញ្ចូល

អ្នកអាចចាក់សោ ឬដោះសោទិន្នន័យបញ្ចូលបាន។

01 ចុចប៊ូតុង ⚙ លើតេឡេ។

02 សូមជ្រើសរើស ⋮ → **ទូទៅ** → **សុវត្ថិភាព**។

03 កំណត់ **សុវត្ថិភាព** ទៅជា **បើក**។

04 ជ្រើសរើស **បានចាក់សោធាតុបញ្ចូល**។

05 ជ្រើសរើសទិន្នន័យបញ្ចូលដែលត្រូវចាក់សោ។

- ពាក្យសម្ងាត់ចាប់ផ្ដើមដំបូងត្រូវបានគេកំណត់ជា “0000”។
  នៅពេលភាសាបារាំង ឬន័រវេត្រូវបានជ្រើសរើសសម្រាប់ប្រទេស ពាក្យសម្ងាត់មិនមែន “0000” ទេប៉ុន្តែគឺ “1234”។

## កំណត់ពាក្យសម្ងាត់ឡើងវិញ

⚙ → ⋮ → **ទូទៅ** → **សុវត្ថិភាព** → **កំណត់ពាក្យសម្ងាត់ឡើងវិញ**

កំណត់ ឬប្តូរពាក្យសម្ងាត់សម្រាប់ទូរទស្សន៍។

- ពាក្យសម្ងាត់ចាប់ផ្តើមដំបូងត្រូវបានគេកំណត់ជា "0000"។
  នៅពេលភាសាបារាំង ឬន័រវេត្រូវបានជ្រើសរើសសម្រាប់ប្រទេស ពាក្យសម្ងាត់មិនមែន "0000" ទេប៉ុន្តែគឺ "1234"។

## ការកំណត់ពាក្យសម្ងាត់ដែលបាត់ឡើងវិញ

ប្រសិនបើអ្នកបានភ្លេចពាក្យសម្ងាត់ដែលអ្នកបានកំណត់ អ្នកអាចកំណត់វាឡើងវិញបានតាមវិធីដូចខាងក្រោម៖

01 ចុចប៊ូតុង ⚙ លើតេឡេ។

02 សូមជ្រើសរើស ⋮ → **ទូទៅ** → **សុវត្ថិភាព**។

03 ចុច ⊞ (ប៉ុស្តិ៍) ∧ → ⊞ (ប៉ុស្តិ៍) ∧ → ⊞ (ប៉ុស្តិ៍) ∨ → ⊞ (ប៉ុស្តិ៍) ∧ នៅលើតេឡេ។
បង្អួចបញ្ចូលពាក្យសម្ងាត់មេនឹងបង្ហាញឡើង។

04 បញ្ចូលលេខ "0313" នៅក្នុងបង្អួចបញ្ចូលពាក្យសម្ងាត់មេ ហើយបន្ទាប់មកចុច **បញ្ចូល**។
ពាក្យសម្ងាត់នឹងត្រូវបានកំណត់ឡើងវិញ។

## ការគ្រប់គ្រងគណនី LG របស់អ្នក

នៅក្នុងផ្នែក **ការគ្រប់គ្រងគណនី** អ្នកអាចប្រើអាសយដ្ឋានអ៊ីមែលរបស់អ្នក ដើម្បីបង្កើតគណនី LG ថ្មីមួយបាន។
សម្រាប់ព័ត៌មានបន្ថែម ចូលទៅ **ការចាប់ផ្តើមប្រើទូរទស្សន៍ LG webOS** → **ការគ្រប់គ្រងគណនី** ក្នុង **ការណែនាំសម្រាប់អ្នកប្រើប្រាស់**។

## ការកំណត់ទំព័រដើម

⚙ → ⋮ → **ទូទៅ** → **ការកំណត់ទំព័រដើម**

### ការចាប់ផ្តើមទំព័រដើមដោយស្វ័យប្រវត្តិ

អ្នកអាចកំណត់អេក្រង់ដើម ឱ្យដំណើរការដោយស្វ័យប្រវត្តិ នៅពេលបើកទូរទស្សន៍។

### ស្លាយលើអេក្រង់

អ្នកអាចកំណត់ ស្លាយលើអេក្រង់។

### ការផ្តល់ជូនពិសេសនៅទំព័រដើម

អ្នកអាចបើក ឬបិទការផ្សាយពាណិជ្ជកម្មបាននៅលើអេក្រង់ដើម។

### ចលនាទំព័រដើម

អ្នកអាចបើក ឬបិទបែបផែនគំនូរជីវចល
ដែលបង្ហាញនៅលើអេក្រង់ដើមក្នុងរយៈពេលជាក់លាក់ណាមួយ។

- ធាតុដែលអាចកំណត់រចនាសម្ព័ន្ធបានខុសគ្នាទៅតាមម៉ូដែល។

## ការកំណត់ទស្សន៍ទ្រនិចរបស់Magic Remote

⚙ → ⋮ → ទូទៅ → ការកំណត់បន្ថែម → ជម្រើសទ្រនិច

អ្នកអាចកំណត់ល្បឿន និងទំហំសញ្ញាព្រួញតាមការចង់បាន នៅពេលដែលវាស្ថិតនៅលើអេក្រង់។

### ល្បឿនតាមដាន

កំណត់ល្បឿនទស្សន៍ទ្រនិច។

### ទំហំទស្សន៍ទ្រនិច

ជ្រើសរើសទំហំទស្សន៍ទ្រនិច។

## ដើម្បីប្រើជំនួយការកំណត់

⚙ → ⋮ → ទូទៅ → ការកំណត់បន្ថែម → ជំនួយការកំណត់

ប្រសិបើអ្នកជ្រើសរើសម៉ឺនុយការកំណត់ អ្នកនឹងឃើញជំនួយនៃការកំណត់។ បិទ/បើកប្រអប់ពិពណ៌នាក្នុងការកំណត់។




## ការកំណត់ភាពថ្លារបស់ម៉ឺនុយ

⚙ → ⋮ → ទូទៅ → ការកំណត់បន្ថែម → ភាពមើលម៉ឺនុយថ្លះ

តាមរយៈការកំណត់មុខងារនេះទៅជា **បើក**, អ្នកអាចធ្វើឱ្យម៉ឺនុយមួយចំនួន (ឧទាហរណ៍ម៉ឺនុយ

ផ្សាយបន្តផ្ទាល់ **ស្វែងរក** ។ល។) ទៅជាថ្លា។

## ការផ្សព្វផ្សាយធាតុរក្សាអេក្រង់

⚙ → ⋮ → **ទូទៅ** → **ការកំណត់បន្ថែម** → **ការផ្សព្វផ្សាយធាតុរក្សាអេក្រង់**

អ្នកអាចបើក ឬបិទការផ្សាយពាណិជ្ជកម្មដែលបង្ហាញនៅលើធាតុរក្សាអេក្រង់របស់កម្មវិធីជាក់លាក់។ ការកំណត់ទៅ**បិទ** អាចឱ្យអ្នកបិទការផ្សាយពាណិជ្ជកម្មដែលបង្ហាញនៅលើធាតុរក្សាអេក្រង់។

## កំណត់រចនាសម្ព័ន្ធអេក្រង់នៅពេលមិនមានសញ្ញា

⚙ → ⋮ → **ទូទៅ** → **ការកំណត់បន្ថែម** → **រូបភាពមិនមានរលកសញ្ញាទេ**

អ្នកអាចបិទ ឬបើករូបភាពបានបង្ហាញនៅពេលមិនមានសញ្ញា។

### បើក

រូបភាពលំនាំដើមត្រូវបានបង្ហាញ ប្រសិនបើគ្មានសញ្ញា។

### បិទ

សារ **គ្មានរលកសញ្ញាទេ** ត្រូវបានបង្ហាញប្រសិនបើគ្មានសញ្ញា។

## ការប្រើទម្រង់ ECO

⚙ → ⋮ → **ទូទៅ** → **ការកំណត់បន្ថែម** → **របៀប Eco**

កំណត់ជម្រើសថាមពល ដើម្បីកាត់បន្ថយការប្រើប្រាស់ថាមពល។

### បិទថាមពលដោយប្រវត្តិ

កំណត់ឲ្យទូរទស្សន៍បិទដោយស្វ័យប្រវត្តិ នៅពេលដែលមិនមានធាតុនៅចន្លោះពេលជាក់លាក់ណាមួយ។

### របៀប HDD Eco

ប្រសិនបើអ្នកកំណត់ទម្រង់ទៅ **បើក**, ថាសរឹងយូអេសប៊ីដែលបាតភ្ជាប់ជាមួយទូរទស្សន៍នឹងចូលក្នុងទម្រង់សន្សំថាមពល នៅពេលដែលបានចាកចេញយូរ។

- ធាតុដែលអាចកំណត់រចនាសម្ព័ន្ធបានខុសគ្នាទៅតាមម៉ូដែល។

## ការប្តូរទម្រង់ទូរទស្សន៍

⚙ → ⋮ → **ទូទៅ** → **ការកំណត់បន្ថែម** → **ដើម/របៀបហាង**

អ្នកអាចជ្រើសរើសរវាង **របៀបនៅផ្ទះ** និង **របៀបហាង**។

ដើម្បីប្រើទូរទស្សន៍នៅផ្ទះ ជ្រើសរើស **របៀបនៅផ្ទះ**។
ជ្រើសរើសតែ **របៀបហាង** ប៉ុណ្ណោះ នៅពេលដែលទូរទស្សន៍នឹងត្រូវបានបង្ហាញនៅក្នុងហាង។
**របៀបហាង** ផ្តល់ជូនការកំណត់ដែលស្របតាមបុគ្គលសម្រាប់ការបង្ហាញនៅក្នុងហាង។

## ការកំណត់ថាមពលទូរទស្សន៍

⚙ → ⋮ → **ទូទៅ** → **ការកំណត់បន្ថែម** → **ចាប់ផ្តើមរហ័ស+**

ការកំណត់នេះដាក់ទូរទស្សន៍របស់អ្នកក្នុងទម្រង់រង់ចាំ នៅពេលវាបិទ ដូច្នេះវានឹងជួយឲ្យប្រើមុខងាររបស់ទូរទស្សន៍បានកាន់តែលឿននៅពេលបើកលើកក្រោយ។
កំណត់ **ចាប់ផ្តើមរហ័ស+** ទៅ **បើក**។

- អាចនឹងមិនស្គាល់ម៉ូដែលមួយចំនួន។
- ការបើកជម្រើសនេះអាចបង្កើនការប្រើប្រាស់ថាមពល។

## ដើម្បីកំណត់សញ្ញាបង្ហាញថាមពល

⚙ → ⋮ → **ទូទៅ** → **ការកំណត់បន្ថែម** → **ពន្លឺរង់ចាំ**

អ្នកអាចបិទ ឬបើកពន្លឺរង់ចាំ។

- អាចនឹងមិនស្គាល់ម៉ូដែលមួយចំនួន។

## ការផ្សាយពាណិជ្ជកម្ម

⚙ → ⋮ → **ទូទៅ** → **ការកំណត់បន្ថែម** → **ការផ្សាយពាណិជ្ជកម្ម**

ប្រសិនបើទូរទស្សន៍របស់អ្នកតភ្ជាប់អ៊ីនធឺណិត webOS អាចប្រើប្រូកង់ ដោយកំណត់ខូឃីដើម្បីបន្តតាមដានចំនួនដងនៃការផ្សាយពាណិជ្ជកម្មដែលបង្ហាញលើទូរទស្សន៍របស់អ្នក។ ព័ត៌មាននេះត្រូវបានប្រើដើម្បីជួយកំណត់ចំនួនដងនៃការបង្ហាញការផ្សាយពាណិជ្ជកម្មដដែលៗ។ អ្នកអាចសម្អាតខូឃី ឬបើក ឬបិទវាគ្រប់ពេលដោយចូលទៅការកំណត់ **ការផ្សាយពាណិជ្ជកម្ម** នៅលើទូរទស្សន៍របស់អ្នក។
មិនមានព័ត៌មានដែលអាចកំណត់អត្តសញ្ញាណជាបុគ្គលបាននៅជាប់នឹងខូឃីនេះទេ។

- អាចនឹងមិនស្គាល់ម៉ូដែលមួយចំនួន។

# លទ្ធភាពប្រើប្រាស់

## មីនុយសម្រាប់អ្នកខ្សោយភ្នែក

→ ⋮ → **លទ្ធភាពប្រើប្រាស់** → **ការពិពណ៌នាជាសំឡេង**

មាតិកានៅលើអេក្រង់នឹងត្រូវបានពិពណ៌នាជាសំឡេងសម្រាប់អ្នកដែលមានបញ្ហាក្នុងការមើល។

អ្នកអាចប្រើប្រាស់មុខងារនេះបាន ប្រសិនក្រុមហ៊ុនផ្សព្វផ្សាយមាន **ការពិពណ៌នាជាសំឡេង** សម្រាប់អ្នកខ្សោយភ្នែក។

- អាចនឹងមិនស្គាល់ម៉ូដែលមួយចំនួន។

## ប្រភេទអូឌីយ៉ូ

→ ⋮ → **លទ្ធភាពប្រើប្រាស់** → **ប្រភេទអូឌីយ៉ូ**

អក្សររត់ឬឯកសារជាសំឡេងត្រូវបានផ្ដល់ជូនសម្រាប់អ្នកដែលពិបាកស្ដាប់ ឬខ្សោយការមើលឃើញ។

### ធម្មតា

ជ្រើសរើសសំឡេងលំនាំដើម។

### ការពិពណ៌នាជាសំឡេង

សម្រាប់អ្នកខ្សោយការមើលឃើញ សូមជ្រើសរើសសំឡេងលំនាំដើមដែលចង់បាន ជាមួយនឹងសំឡេងជំនួយសម្រាប់អ្នកពិការ។

### អត្ថបទពិពណ៌នាជាការនិយាយ

សម្រាប់អ្នកខ្សោយភ្នែក សូមជ្រើសរើសតែសំឡេងជំនួយសម្រាប់អ្នកពិការបានហើយ។

### អូឌីយ៉ូបំពេញបន្ថែមណាមួយ

បង្ហាញសំឡេងបន្ថែមទាំងអស់។

- អាចនឹងមិនស្គាល់ម៉ូដែលមួយចំនួន។

## មុខងារសំឡេងបន្ថែម

→ ⋮ → **លទ្ធភាពប្រើប្រាស់** → **ការជ្រើសរើសសំឡេងបន្ថែម**

អក្សររត់ឬឯកសារជាសំឡេងត្រូវបានផ្ដល់ជូនសម្រាប់អ្នកដែលពិបាកស្ដាប់ ឬខ្សោយការមើលឃើញ។

### គ្មាន

ជ្រើសរើសសំឡេងលំនាំដើម។

### ការពិពណ៌នាជាសំឡេង

សម្រាប់អ្នកខ្សោយការមើលឃើញ សូមជ្រើសរើសសំឡេងលំនាំដើមដែលចង់បានជាមួយនឹងសំឡេងជំនួយសម្រាប់អ្នកពិការ។

### ជម្រះសំឡេង

សម្រាប់អ្នកខ្សោយក្នុងការស្តាប់ សូមជ្រើសរើសផលិតផលស្មាត និងសំឡេងជំនួយសម្រាប់អ្នកពិការដែលចង់បាន។

### អត្ថបទពិពណ៌នាជាការនិយាយ

សម្រាប់អ្នកខ្សោយភ្នែក សូមជ្រើសរើសតែសំឡេងជំនួយសម្រាប់អ្នកពិការបានហើយ។

- អាចនឹងមិនស្គាល់ម៉ូដែលមួយចំនួន។

## ប្តូរមឺនុយទៅអេក្រង់មានកម្រិតខ្លាំង

⚙ → ⋮ → **លទ្ធភាពប្រើប្រាស់** → **ភាពដិតខ្លាំង**

នៅពេលមុខងារនេះត្រូវបានកំណត់ទៅជា **បើក**,
វានឹងកែផ្ទៃខាងក្រោយនៃមឺនុយមួយចំនួនលើកញ្ចក់ទូរទស្សន៍ និងពណ៌អក្សរ ដើម្បីកំណត់

### មាត្រដ្ឋានប្រផេះ

⚙ → ⋮ → **លទ្ធភាពប្រើប្រាស់** → **មាត្រដ្ឋានប្រផេះ**

ប្តូរពណ៌ម៉ឺនុយនៅលើអេក្រង់ទៅពណ៌សខ្មៅ
ដើម្បីធ្វើឱ្យភាពមិនច្បាស់របស់វាមានភាពច្បាស់ខ្លាំង។ កំណត់ទៅជា **បើក**។

### បញ្ច្រាសពណ៌

⚙ → ⋮ → **លទ្ធភាពប្រើប្រាស់** → **បញ្ច្រាសពណ៌**

ដើម្បីធ្វើឱ្យម៉ឺនុយងាយស្រួលមើលជាងមុននៅលើអេក្រង់ អ្នកអាចប្តូរ និងកែសម្រួលពណ៌នានានៅក្នុងម៉ឺនុយមួយចំនួនបាន។ កំណត់ទៅជា **បើក**។

## ដើម្បីសម្រាប់អ្នកពិបាកស្តាប់

01 ចុចប៊ូតុង ⚙ លើតេឡេ។

02 ជ្រើសរើសចុចលើ ⋮ → **លទ្ធភាពប្រើប្រាស់**។

03 កំណត់ **អត្ថបទពិពណ៌នា** ទៅជា **បើក**។

04 កំណត់ **លំបាកក្នុងការស្ដាប់** ទៅជា **បើក**។
អក្សររត់នឹងត្រូវបានផ្ដល់ជូនសម្រាប់អ្នកខ្សោយការស្ដាប់។

- នៅពេលបើក **លំបាកក្នុងការស្ដាប់ បើក** វានឹងទទួលបានអាទិភាពខ្ពស់ជាងអក្សររត់ទូទៅ។
- អាចនឹងមិនស្គាល់ម៉ូដែលមួយចំនួន។

### ដើម្បីកំណត់អក្សររត់

→ → **លទ្ធភាពប្រើប្រាស់** → **អត្ថបទពិពណ៌នា**

មើលអក្សររត់នៅពេលស្ថានីយទូរទស្សន៍ផ្ដល់ជាកម្មវិធីមានអក្សររត់ពីក្រោម។
ប្ដូរ **អត្ថបទពិពណ៌នាបិទ** ទៅជា **បើក** ហើយជ្រើសរើសការកំណត់ចំណងជើង។

- អាចនឹងមិនស្គាល់ម៉ូដែលមួយចំនួន។
- អនុវត្តចំពោះការផ្សព្វផ្សាយបែបឌីជីថល។

# ជំនួយ

## ការអាប់ដេតផ្នែកទន់

→ → **ជំនួយ** → **ការអាប់ដេតផ្នែកទន់**

ប្រើប្រាស់ការធ្វើបច្ចុប្បន្នភាពសូហ្វវែរដើម្បីពិនិត្យមើល និងទទួលបានកំណែចុងក្រោយបង្អស់។

### អនុញ្ញាតការអាប់ដេតស្វ័យប្រវត្តិ

ប្រសិនបើកំណត់ទៅ **បើក** នៅពេលដែលមានការអាប់ដេតថ្មី បន្ទាប់ពីការរកមើលកំណែរួច ការអាប់ដេតនឹងដំណើរការដោយស្វ័យប្រវត្តិ ដោយមិនសួរឡើយ។

### ពិនិត្យរកការអាប់ដេត

នៅពេលកំពុងពិនិត្យកំណែបច្ចុប្បន្នភាពចុងក្រោយបង្អស់ អ្នកអាចអនុវត្តបានតែការធ្វើបច្ចុប្បន្នភាព ប្រសិនបើឯកសារបច្ចុប្បន្នភាពនៃកំណែចុងក្រោយអាចប្រើបាន។ ទូរទស្សន៍ពិនិត្យមើលសូហ្វវែររបស់អ្នកដោយស្វ័យប្រវត្តិ ប៉ុន្តែប្រសិនបើចាំបាច់ អ្នកអាចប្រើសៀវភៅពិនិត្យណែនាំ។

- ធាតុដែលអាចកំណត់រចនាសម្ព័ន្ធបានខុសគ្នាទៅតាមម៉ូដែល។
- កំណែថ្មីចុងក្រោយបំផុតអាចប្រើបានតាមរយៈ សញ្ញាផ្សព្វផ្សាយឌីជីថល ឬភ្ជាប់អ៊ីនធឺណិត។
- ការប្ដូរប៉ុស្តិ៍ពេលកំពុងទាញយកសូហ្វវែរដោយប្រើសញ្ញាផ្សព្វផ្សាយឌីជីថលធ្វើឲ្យរំខានដល់ដំណើរការទ ាញយក។ ការថយមកប៉ុស្តិ៍ដើមវិញធ្វើឲ្យការទាញយកបន្តវិញ។

- ប្រសិនបើសូហ្វវែរមិនត្រូវបានធ្វើបច្ចុប្បន្នភាពទេ នោះមុខងារមួយចំនួននឹងមិនដំណើរការឡើយ។
- នៅក្នុងប្រទេសខ្លះ **អនុញ្ញាតការអាប់ដេតស្វ័យប្រវត្តិ** មិនត្រូវបានបង្ហាញទេ ប្រសិនបើអ្នកមិនត្រូវបានតភ្ជាប់អ៊ីនធឺណិត។

## ព័ត៌មានអំពីទូរទស្សន៍

⚙ → ⋮ → **ជំនួយ** → **ព័ត៌មានអំពីទូរទស្សន៍**

អ្នកអាចមើលព័ត៌មានដូចជា **ម៉ូដែល**, **លេខស៊េរី**, **ឈ្មោះឧបករណ៍** បាន។

## ការប្រើ ការជូនដំណឹង

⚙ → ⋮ → **ជំនួយ** → **ការជូនដំណឹង**

អ្នកអាចមើលការជូនដំណឹងទាំងអស់ពីកម្មវិធីទូរទស្សន៍ និងសេវាកម្ម LG នៅពេលតែមួយ។ អ្នកអាចមើល និងលុបសារជូនដំណឹងនីមួយៗបាន។ សម្រាប់ការជូនដំណឹងដែលស្គាល់ផ្លូវកាត់ អ្នកអាចចូលទៅកាន់កម្មវិធី ឬគេហទំព័រនោះដោយផ្ទាល់បាន។




1. អ្នកអាចពិនិត្យមើលព័ត៌មានលម្អិតបាន ដោយជ្រើសរើសធាតុដែលអ្នកចង់ពិនិត្យ។ អ្នកអាចចាប់ផ្ដើមកម្មវិធីបាន ប្រសិនបើវាស្គាល់ផ្លូវកាត់។
2. អ្នកអាចលុបការជូនដំណឹងនានាចោលបាន។
3. អ្នកអាចលុបការជូនដំណឹងទាំងអស់ចោលបាន។

## ការកំណត់បន្ថែម

⚙ → ⋮ → **ជំនួយ** → **ការកំណត់បន្ថែម**

### ការសាកល្បងរូបភាព

បន្ទាប់ពីធ្វើតេស្តដើម្បីផ្ទៀងផ្ទាត់ថា រលកសញ្ញារូបភាពត្រូវបានបញ្ចេញធម្មតារួច

អ្នកអាចជ្រើសរើសថាតើវាមានលក្ខណៈប្រក្រតីនៅលើអេក្រង់ឬអត់។
បើគ្មានបញ្ហានៅក្នុងការធ្វើតេស្តទេនោះ ពិនិត្យមើលឧបករណ៍ខាងក្រៅដែលបានតភ្ជាប់ ឬសញ្ញាផ្សាយ។

### ការសាកល្បងសំឡេង

ចាប់ផ្តើមដំណើរការធ្វើតេស្តសំឡេង ដើម្បីពិនិត្យឲ្យដឹងថា លទ្ធផលនៃសញ្ញាសំឡេងចេញមានលក្ខណៈធម្មតាឬក៏អត់ រួចហើយជ្រើសរើសលក្ខខណ្ឌដែលកើតមានកំហុស។
បើគ្មានបញ្ហានៅក្នុងការធ្វើតេស្តទេនោះ ពិនិត្យមើលឧបករណ៍ខាងក្រៅដែលបានតភ្ជាប់ ឬសញ្ញាផ្សាយ។

### កិច្ចព្រមព្រៀងអ្នកប្រើ

ទាំងនេះគឺជាលក្ខខណ្ឌសម្រាប់ឯកជនភាពនៃការប្រើប្រាស់សេវាកម្មដែលពាក់ព័ន្ធនឹងទូរទស្សន៍ឆ្លាតវៃ។

### កំណត់សម្គាល់ផ្នែកច្បាប់

នេះគឺជាកំណត់សម្គាល់ផ្នែកច្បាប់ សម្រាប់សេវាកម្មដែលផ្តល់ជូនតាមរយៈទូរទស្សន៍។

### កំណត់សម្គាល់ផ្នែកទន់នៃប្រភពបើកចំហ

អ្នកអាចមើលការណែនាំសម្រាប់ធាតុនីមួយៗបាន។

## ស្តារទៅការកំណត់លំនាំដើមឡើងវិញ

⚙ → ⋮ → **ជំនួយ** → **កំណត់ឡើងវិញទៅជាការកំណតដំបូង**

កំណត់ទូរទស្សន៍ដូចការកំណត់ពិដំបូងរបស់វាវិញ។ វានឹងត្រឡប់ការកំណត់ទាំងអស់ទៅតម្លៃលំនាំដើមពួកវា។

បន្ទាប់ពីកំណត់ឡើងវិញទូរទស្សន៍នឹងបិទ ហើយបើកដោយស្វ័យប្រវត្តិ។

- ប្រសិនបើ **សុវត្ថិភាព** ត្រូវបានកំណត់ទៅ **បើក**, អ្នកគួរតែបញ្ចូលពាក្យសម្ងាត់ដើម្បី **កំណត់ឡើងវិញទៅជាការកំណតដំបូង**។
- កុំបិទពេលចាប់ផ្តើម។
- យើងខ្ញុំសូមណែនាំឲ្យអ្នកដាក់កំណត់ទូរទស្សន៍ឡើងវិញទៅជា **កំណត់ឡើងវិញទៅជាការកំណតដំបូង** សិន មុននឹងអ្នកលក់វា ឬផ្ទេរវាទៅឲ្យភាគីទីបី។

# ការដោះស្រាយបញ្ហា

## ធ្វើការត្រួតពិនិត្យដោយប្រើ Quick Help

### ធ្វើការត្រួតពិនិត្យដោយប្រើ Quick Help

នៅពេលដែលទូរទស្សន៍ដំណើរការមិនប្រក្រតីទេ
អ្នកអាចទទួលបានជំនួយដើម្បីដោះស្រាយបញ្ហានេះបាន។
ចុចប៊ូតុង ⚙ នៅលើតេឡេបញ្ជា រួចជ្រើសរើស ⋮ → **ជំនួយ** → **Quick Help**។
អ្នកក៏អាចចុចប៊ូតុងលេខ **9** របស់តេឡេបញ្ជាឱ្យជាប់ ដើម្បីដំណើរការ **Quick Help** ផងដែរ។

#### ការកំណត់ការបង្កើនគុណភាព

អ្នកអាចពិនិត្យមើលស្ថានភាពទូទៅរបស់ទូរទស្សន៍អ្នក និងមើល
ព្រមទាំងប្តូរតម្លៃនៃការកំណត់ការណែនាំបានដោយស្វ័យប្រវត្តិ។

#### ពិនិត្យមើលធាតុ

ជ្រើសរើសធាតុដែលមានបញ្ហា ដើម្បីឱ្យអ្នកអាចទទួលបានជំនួយដើម្បីដោះស្រាយបញ្ហានោះ។

- **ការវិនិច្ឆ័យនៃការកំណត់ទូរទស្សន៍ដោយខ្លួនឯង** : ជ្រើសរើសធាតុដែលត្រូវនឹងបញ្ហា ដើម្បីអាចរកឃើញការណែនាំដែលអាចជួយឱ្យអ្នកដោះស្រាយបញ្ហានោះបាន។
- **ពិនិត្យមើលស្ថានភាពទូរទស្សន៍** : អ្នកអាចពិនិត្យមើលស្ថានភាពបច្ចុប្បន្នរបស់ទូរទស្សន៍អ្នក ដើម្បីមើលធាតុដែលបានជ្រើសរើស។

#### សេវាកម្មតេឡេបញ្ជា LG

អ្នកទទួលបានជំនួយក្នុងការដោះស្រាយបញ្ហា តាមរយៈតេឡេបញ្ជា។

- អាចនឹងមិនស្គាល់ម៉ូដែលមួយចំនួន។

- នៅពេលដែលគ្មានមាតិកាដែលពាក់ព័ន្ធនៅក្នុង **Quick Help** សូមពិនិត្យមើល **ការដោះស្រាយបញ្ហា** នៅក្នុង **ការណែនាំសម្រាប់អ្នកប្រើប្រាស់**។
- ប្រសិនបើអ្នកនៅតែមិនអាចដោះស្រាយបញ្ហានេះបានទៀត សូមទាក់ទងមជ្ឈមណ្ឌលផ្តល់សេវាអតិថិជនរបស់យើង។

# ការដោះស្រាយបញ្ហាតេឡេបញ្ជា/ថាមពល

## ការដោះស្រាយបញ្ហាតេឡេបញ្ជា/ថាមពល

ប្រសិនបើអ្នកជួបបញ្ហាមួយចំនួនដូចខាងក្រោម នៅពេលកំពុងប្រើប្រាស់ផលិតផល សូមពិនិត្យដូចខាងក្រោម។ វាប្រហែលមិនមានបញ្ហាជាមួយផលិតផលទេ។

### ខ្ញុំមិនអាចបើកទូរទស្សន៍បានទេ។

- សូមប្រាកដថាឌុយភ្លើងទូរទស្សន៍របស់អ្នក បានតភ្ជាប់ទៅនឹងព្រីភ្លើងបានត្រឹមត្រូវ។
- ប្រសិនបើអ្នកកំពុងប្រើប្រាស់ព្រីភ្លើងច្រើន ពិនិត្យ ថាតើវាកំពុងដំណើរការត្រឹមត្រូវទេ។ ដើម្បីពិនិត្យមើលថាតើគំនូសថាមពលកំពុងដំណើរការត្រឹមត្រូវដែរឬទេ ដោតឌុយទូរទស្សន៍ដោយផ្ទាល់ទៅនឹងរន្ធព្រីនៅជញ្ជាំង ហើយបង្កេតមើលប្រតិបត្តិការរបស់អ្នក។
- ព្យាយាមបើកដោយប្រើប៊ូតុងនៅលើទូរទស្សន៍របស់អ្នក។

### ថាមពលត្រូវបានបើក ប៉ុន្តែអេក្រង់បង្ហាញនៅពេលក្រោយ។

- នេះគឺដោយសារមានដំណើរការលុបសំឡេងចេញ ដើម្បីបំបាត់សំឡេងមួយចំនួនចោលដែលអាចកើតមាននៅពេលបើក។ នេះមិនមែនមានន័យថាផលិតផលខូចទេ។

### ទស្សន៍ទ្រនិចរបស់Magic Remoteមិនលេចឡើងនៅលើអេក្រង់ទេ។

- តម្រង់តេឡេបញ្ជាទៅទូរទស្សន៍ រួចចុចប៊ូតុង **GUIDE** ឱ្យជាប់ រហូតដល់ការណែនាំលេចឡើង។ តេឡេដែលបានចុះឈ្មោះពីមុនត្រូវបានលុបចោល ហើយចុះឈ្មោះម្តងទៀត។
- ប្តូរថ្មចេញ នៅពេលមានសារនៅលើអេក្រង់ទូរទស្សន៍ប្រាប់អ្នកថាត្រូវប្តូរថ្ម។ (ប្រើប្រាស់ថ្មអាល់កាឡាំង។)
- ប្រសិនបើ → → **លទ្ធភាពប្រើប្រាស់** → **ការណែនាំជាសំឡេង** ត្រូវបានកំណត់ទៅ **បើក** សញ្ញាព្រួញរបស់តេឡេបញ្ជាវេទមន្តនឹងមិនលេចឡើងទេ។ កំណត់ **ការណែនាំជាសំឡេង** ទៅជា **បិទ**។ (អាចនឹងមិនស្គាល់ម៉ូដែលមួយចំនួន។)

### ខ្ញុំមិនអាចបើកទូរទស្សន៍ដោយប្រើតេឡេបានទេ។

- សូមប្រាកដថាឌុយភ្លើងទូរទស្សន៍របស់អ្នក បានតភ្ជាប់ទៅនឹងព្រីភ្លើងបានត្រឹមត្រូវ។
- ប្តូរថ្មនៅក្នុងតេឡេ។ (ប្រើប្រាស់ថ្មអាល់កាឡាំង។)
- ពិនិត្យមើលថាតើមានឧបសគ្គរារាំងរលកសញ្ញានៅពីមុខឧបករណ៍ទទួលសញ្ញាពីតេឡេបញ្ជារបស់ទូរទស្សន៍ឬអត់។ ប្រសិនបើមានឧបសគ្គដូចជា មានរបារសំឡេងនៅពីមុខឧបករណ៍ទទួលសញ្ញានៅខាងក្រោមទូរទស្សន៍ នោះការសម្គាល់ IR

អាចនឹងដំណើរការមិនបានត្រឹមត្រូវឡើយ។

### ថាមពលដាច់ភ្លាមៗ។

- សូមពិនិត្យមើលថាតើបានកំណត់ **បិទកម្មវិធីកំណត់ម៉ោង**, **គ្មាន** ឬ **គ្មានប្រតិបត្តិការបិទដោយស្វ័យប្រវត្តិ** ឬអត់។
- ទូរទស្សន៍នឹងត្រូវបានបិទដោយស្វ័យប្រវត្តិ ប្រសិនបើអ្នកមិនចុចប៊ូតុងណាមួយក្នុងរយៈពេល 4 ម៉ោង ទោះបីជាក្រោយពីបើកទូរទស្សន៍ នៅម៉ោងដែលបានកំណត់ដោយ **ការរំលឹក** ឬ **បើកកម្មវិធីកំណត់ម៉ោង** ក៏ដោយ។
- សៀគ្វីសម្រាប់ការពារខាងក្នុងក៏នឹងអាចត្រូវបានបើកដំណើរការផងដែរ ដោយសារតែសីតុណ្ហភាពខាងក្នុងរបស់ផលិតផលបានកើនឡើងខុសពីធម្មតា ឬលើសកម្រិត។

# ការដោះស្រាយបញ្ហាអេក្រង់

## ការដោះស្រាយបញ្ហាអេក្រង់

ប្រសិនបើអ្នកជួបបញ្ហាមួយចំនួនដូចខាងក្រោម នៅពេលកំពុងប្រើប្រាស់ផលិតផល សូមពិនិត្យដូចខាងក្រោម។ វាប្រហែលមិនមានបញ្ហាជាមួយផលិតផលទេ។

ដំបូងបង្អស់ អនុវត្ត ⚙ → ⋮ → **ជំនួយ** → **ការកំណត់បន្ថែម** → **ការសាកល្បងរូបភាព** ដើម្បីពិនិត្យមើលភាពខុសប្រក្រតីក្នុងទូរទស្សន៍។
ប្រសិនបើអ្នកកំពុងប្រើset-top box, បិទវា ហើយបន្ទាប់មកបើកវាវិញ។
សូមប្រាកដថា set-top box ត្រូវបានតភ្ជាប់ជាមួយទូរទស្សន៍របស់អ្នកបានត្រឹមត្រូវ។

### វានិយាយថាមិនមានរលកសញ្ញានៅលើអេក្រង់ទេ។

- ពិនិត្យមើលថាតើខ្សែដែលមានអ័ក្សរួមគ្នា ឬខ្សែបានតភ្ជាប់ជាមួយឧបករណ៍ខាងក្រៅត្រូវបានតភ្ជាប់ជាមួយទូរទស្សន៍បានត្រឹមត្រូវដែរឬទេ។
- ចូលទៅ ⮹ ដើម្បីជ្រើសរើសការចូលដែលបានតភ្ជាប់។
- ពិនិត្យថាតើឧបករណ៍ខាងក្រៅ ដូចជាឧបករណ៍ចាប់រលកសញ្ញា ឬឧបករណ៍ចាក់ Blu-ray បើកឬនៅ។

### ខ្ញុំមិនអាចមើលប៉ុស្តិ៍មួយចំនួនបានទេ។

- ចាប់ផ្តើម ⚙ → ⋮ → **ប៉ុស្តិ៍** → **ការរាវប៉ុស្តិ៍** (**ការរាវប៉ុស្តិ៍ និងការកំណត់**) → **ការរាវប៉ុស្តិ៍ដោយស្វ័យប្រវត្តិ**។

- ប្រសិនបើអ្នកកំពុងប្រើប្រាស់ set-top box សូមពិគ្រោះយោបល់ជាមួយអ្នកចែកចាយ។

## អេក្រង់ញ័រឬបន្ទាប់ពីបន្ទាត់ផ្ដេក/បញ្ឈរបង្ហាញមួយស្របក់ និងមានក្រឡា។

- តភ្ជាប់ទូរសព្ទឥតខ្សែ ម៉ាស៊ីនផ្លុំសក់ ឧបករណ៍ស្វាន ។ល។ ជាមួយនឹងរន្ធថាមពលខុសៗគ្នា។ បញ្ហាអាចបណ្ដាលមកពីឧបករណ៍អគ្គិសនីមានប្រេកង់ខ្ពស់ដូចជា ទូរទស្សន៍ផ្សេង ឬប្រភពអេឡិចត្រូម៉ាញ៉េទិកខ្លាំងនៅជិត។

## ប៉ុស្តិ៍នីមួយៗមានគុណភាពរូបភាពខុសៗគ្នា។

- ប៉ុស្តិ៍អាចមានគុណភាពរូបភាពខុសគ្នា ដោយអាស្រ័យលើប្រភេទវីដេអូដែលផ្ដល់ជូនដោយក្រុមហ៊ុនផ្សាយ។
- ប្រសិនបើអ្នកកំពុងប្រើប្រាស់ set-top box សូមពិគ្រោះយោបល់ជាមួយអ្នកចែកចាយ។
- ដំណើរការ **ការសាកល្បងរូបភាព** ជាមុនសិន។ ប្រសិនបើវាដំណើរការធម្មតា មានន័យថាអាចមានបញ្ហាទាក់ទងនឹងរលកសញ្ញាផ្សាយ។

## គុណភាពរូបភាពពីវីដេអូដែលមើលឃើញនៅហាងគឺមានភាពខុសគ្នា។

- គុណភាពរូបភាពពីវីដេអូដែលបញ្ចាំងនៅហាងអាចមានភាពខុសគ្នា ដោយអាស្រ័យលើប្រភេទវីដេអូដែលផ្ដល់ជូនដោយក្រុមហ៊ុនផ្សាយ។
- ដំណើរការ **ការសាកល្បងរូបភាព** ជាមុនសិន។ ប្រសិនបើវាដំណើរការធម្មតា មានន័យថាអាចមានបញ្ហាទាក់ទងនឹងរលកសញ្ញាផ្សាយ។

## កម្មវិធីបានផ្សាយជាលក្ខណៈឌីជីថលបញ្ឈប់ ឬអេក្រង់របស់វាខូច។

- វាកើតឡើងនៅពេលសញ្ញាខ្សោយ ឬការទទួលមិនស្ថិតស្ថេរ។ កែតម្រូវទិសអង់តែន ឬពិនិត្យមើលការតភ្ជាប់ខ្សែ។
- ⚙ → ⋮ → **ប៉ុស្តិ៍** → **ការរាវប៉ុស្តិ៍** (**ការរាវប៉ុស្តិ៍ និងការកំណត់**) → **ការរាវប៉ុស្តិ៍ដោយផ្ទាល់**
ប្រសិនបើកម្លាំងសញ្ញាខ្សោយពេកក្នុង **ការរាវប៉ុស្តិ៍ដោយផ្ទាល់**, ទាក់ទងស្ថានីយផ្សាយឬការិយាល័យគ្រប់គ្រងឲ្យពិនិត្យមើលសញ្ញា។
- ប្រសិនបើអ្នកកំពុងប្រើប្រាស់ set-top box សូមពិគ្រោះយោបល់ជាមួយអ្នកចែកចាយ។

## នៅពេលរន្ធ HDMI កំពុងត្រូវបានប្រើប្រាស់ បន្ទាត់បញ្ឈរ ឬពណ៌ព្រាលនឹងបង្ហាញនៅលើគែមខាងលើ/ខាងក្រោម/ខាងឆ្វេង/ខាងស្ដាំនៃអេក្រង់។

- ⚙ → ⋮ → **រូបភាព** → **ការកំណត់ផលធៀប** → **ទើបស្កេន**
កំណត់ **ទើបស្កេន** ទៅ **បិទ**។
**ទើបស្កេន** បង្ហាញអ្នកនូវរូបភាពដើមដូចទ្រង់ទ្រាយរបស់អ្នក។ ប្រសិនបើសេវាខ្សោយ ផ្នែកខាងលើ/ខាងក្រោម/ខាងឆ្វេង/ខាងស្ដាំនៃអេក្រង់អាចនឹងបង្ហាញដង្កូវទឹក។

## ខ្ញុំមិនឃើញអ្វីទេ ឬរូបភាពនៅតែលោតភ្លឹបភ្លែតៗនៅពេលខ្ញុំព្យាយាមតភ្ជាប់ខ្សែ HDMI ។

- ពិនិត្យមើលថាតើខ្សែ HDMI® របស់អ្នកត្រូវតាមលក្ខណៈនេះ។ អ្នកអាចឃើញវាលោតភ្លឹបភ្លែតៗ ឬអេក្រង់ទទេប្រសិនបើខ្សែ HDMI® មានបញ្ហា (រមួល, ខូច)។
- សូមប្រាកដថាខ្សែត្រូវបានតភ្ជាប់ជាមួយរន្ធបានត្រឹមត្រូវ។ ការភ្ជាប់មិនល្អ ឬរលុងអាចបណ្ដាលឲ្យមានបញ្ហាក្នុងការបង្ហាញលើអេក្រង់។
- ប្រសិនបើកំពុងប្រើប្រាស់ UHD set-top box កែតម្រូវ → → **រូបភាព** → **ការកំណត់បន្ថែម** → **HDMI ULTRA HD Deep Color**។

## អេក្រង់មើលទៅស្រអាប់ ឬព្រិលៗ។

- → → **រូបភាព** → **ការកំណត់របៀបរូបភាព** → **របៀបរូបភាព**
ប្ដូរ **របៀបរូបភាព** ទៅតាមទម្រង់រូបភាពដែលអ្នកចង់បាន។ (**ស្ដង់ដារ**, **ពណ៌ដិត**។ល។)
វាអនុវត្តចំពោះតែទម្រង់ចូលបច្ចុប្បន្នប៉ុណ្ណោះ។
- → → **រូបភាព** → **ការកំណត់របៀបរូបភាព** → **ជម្រើ◌ាសរូបថតត** → **ការថែរក្សាចលនាភ្នែក**
ប្ដូរ **ការថែរក្សាចលនាភ្នែក** ទៅ **បិទ**។ វាអនុវត្តចំពោះតែទម្រង់ចូលបច្ចុប្បន្នប៉ុណ្ណោះ។
- → → **រូបភាព** → **ការសន្សំសំចៃថាមពល**
ប្ដូរ **ការសន្សំសំចៃថាមពល** ទៅ **បិទ** ឬ **អប្បបរមា**។
- → → **រូបភាព** → **ការកំណត់បន្ថែម** → **របៀបផាសុខភាពភ្នែក**
ប្ដូរ **របៀបផាសុខភាពភ្នែក** ទៅ **បិទ**។

## អេក្រង់ក្លាយជាពណ៌ស ខ្មៅ ឬបង្ហាញពណ៌ចម្លែក។

- ពិនិត្យមើលខ្សែចូល ឬការតភ្ជាប់ខ្សែ។
- ចូលទៅ ដើម្បីជ្រើសរើសការចូលដែលបានតភ្ជាប់។
- អ្នកអាចឃើញអេក្រង់ពណ៌ស ខ្មៅ ប្រសិនបើអ្នកបានតភ្ជាប់ **COMPONENT IN** ប៉ុន្តែបានជ្រើសរើស**AV**។
ចូលទៅ ហើយជ្រើសរើស **សមាសភាគ**។
- នៅពេលអ្នកកំពុងតភ្ជាប់ជាមួយ **AV IN** ឬ **COMPONENT IN**, ពិនិត្យមើលដើម្បីប្រាកដថាខ្សែនីមួយៗត្រូវគ្នាជាម◌ួយនឹងការតភ្ជាប់ពណ៌ដែលទាក់ទង។ សម្រាប់ខ្សែសមាសធាតុ សូមប្រាកដថាខ្សែវីដេអូ (ពណ៌ក្រហម) និងខ្សែសំឡេង (ពណ៌ក្រហម)ត្រូវបានតភ្ជាប់ត្រឹមត្រូវដែរឬទេ។
- រន្ធ**AV IN**/**COMPONENT IN** មានតែក្នុងម៉ូដែលជាក់លាក់មួយចំនួនប៉ុណ្ណោះ។

## វីដេអូ ULTRA HD មិនបង្ហាញទេ។

- តាមរយៈការប្រើប្រាស់ខ្សែ HDMI មួយចំនួន រលកសញ្ញាអាចនឹងមិនទទួលបានទេ។
- ប្ដូរការកំណត់នៃឧបករណ៍ផ្ទុកទៅរលកសញ្ញាដែលស្គាល់។

# ការដោះស្រាយបញ្ហាសំឡេង

## ការដោះស្រាយបញ្ហាសំឡេង

ប្រសិនបើអ្នកជួបបញ្ហាមួយចំនួនដូចខាងក្រោម នៅពេលកំពុងប្រើប្រាស់ផលិតផល សូមពិនិត្យដូចខាងក្រោម។ វាប្រហែលមិនមានបញ្ហាជាមួយផលិតផលទេ។

ដំបូងបង្អស់ អនុវត្ត → → **ជំនួយ** → **ការកំណត់បន្ថែម** → **ការសាកល្បងសំឡេង** ដើម្បីពិនិត្យមើលភាពខុសប្រក្រតីក្នុងទូរស្សន៍។
ប្រសិនបើអ្នកកំពុងប្រើset-top box, បិទវា ហើយបន្ទាប់មកបើកវាវិញ។
សូមប្រាកដថា set-top box ត្រូវបានតភ្ជាប់ជាមួយទូរទស្សន៍របស់អ្នកបានត្រឹមត្រូវ។

### អេក្រង់គ្មានបញ្ហាទេ ប៉ុន្តែវាមិនឮសំឡេង។

- សាកល្បងប៉ុស្តិ៍ផ្សេង។
- ប្រសិនបើអ្នកប្រើ set-top box នឹងគ្មានសំឡេងទេ បើអ្នកបានកំណត់កម្រិតសំឡេងរបស់ set-top box ឬទូរទស្សន៍របស់អ្នកទៅ 0 ឬបិទសំឡេង។ កំណត់កម្រិតសំឡេងតាមកម្រិតសមរម្យ។
- → → **សំឡេង** → **សំឡេងចេញ**
  កំណត់ **សំឡេងចេញ** ទៅ **អុបទិក + ឧបករណ៍បំពងសំឡេងខាងក្នុងទូរទស្សន៍** ឬឬ **ឧបករណ៍បំពងសំឡេងខាងក្នុងទូរទស្សន៍** បន្ទាប់មកពិនិត្យមើលវាម្តងទៀត។
  ប្រសិនបើអ្នកអាចស្តាប់ឮសំឡេងដោយគ្មានបញ្ហាទេ
  សូមពិនិត្យមើលការតភ្ជាប់ឧបករណ៍បំពងសំឡេងខាងក្រៅ ដូចជារបារសំឡេង
  និងការកំណត់ឧបករណ៍បំពងសំឡេងខាងក្រៅទាំងនោះ។

### មិនមានសំឡេងចេញពីអូប៉ាល័រទេ។

- → → **សំឡេង** → **ការកំណត់របៀបសំឡេង** → **លំនឹង**
  កែតម្រូវសមតុល្យតាមការចាំបាច់ជាមួយប៊ូតុងរុករកនៅក្នុង **លំនឹង**។
- នៅពេលអ្នកតភ្ជាប់ជាមួយ **AV IN**/**COMPONENT IN**, ពិនិត្យមើលថាខ្សែ(ពណ៌ស/ក្រហម)ខាងឆ្វេង/ស្តាំរបស់សំឡេងត្រូវបានតភ្ជាប់បានត្រឹមត្រូវដែរឬទេ។ (រន្ធ**AV IN**/**COMPONENT IN** មានតែក្នុងម៉ូដែលជាក់លាក់មួយចំនួនប៉ុណ្ណោះ។)

### សំឡេងទូរទស្សន៍មិនត្រូវបានធ្វើសមកាលកម្មជាមួយរូបភាព ឬពេលខ្លះសំឡេងដាច់ៗ។

- ប្រសិនបើវាកើតឡើងតែលើប៉ុស្តិ៍មួយចំនួន វាប្រហែលជាបណ្តាលមកពីសញ្ញាបញ្ជូនរបស់ក្រុមហ៊ុនផ្សាយ។ សូមឲ្យក្រុមហ៊ុនផ្តល់សេវាកម្មផ្សាយរបស់អ្នក(ខ្សែកាប/ខ្សែ)ដោះស្រាយបញ្ហា។
- ប្រសិនបើប៉ុស្តិ៍ទាំងអស់មិនធ្វើសមកាលកម្មទេ ចូលទៅ → → **សំឡេង** → **ការកំណត់បន្ថែម** → **ការកែសម្រួលសកមកាលកម្ម AV** និងកែសម្រួលការធ្វើសមកាលកម្ម។
- ប្រសិនបើអ្នកកំពុងប្រើប្រាស់ set-top box សូមពិគ្រោះយោបល់ជាមួយអ្នកចែកចាយ។

### កម្រិតសំឡេងប្តូរនៅពេលខ្ញុំប្តូរប៉ុស្តិ៍។

- កម្រិតសំឡេងនៃលទ្ធផលបញ្ជូនពីស្ថានីយផ្សាយផ្សេងៗអាចខុសគ្នា។
- ⚙ → ⋮ → **សំឡេង** → **ការកំណត់បន្ថែម** → **របៀបកម្រិតសំឡេង** → **កម្រិតសំឡេងស្វ័យប្រវត្តិ**
  កំណត់ **កម្រិតសំឡេងស្វ័យប្រវត្តិ** ទៅ **បើក**។
- ប្រសិនបើអ្នកកំពុងប្រើប្រាស់ set-top box សូមពិគ្រោះយោបល់ជាមួយអ្នកចែកចាយ។

### សំឡេងមិនដំណើរការ ឬលេងតែតន្ត្រីក្នុងផ្ទៃខាងក្រោយក្នុងកម្មវិធីមួយចំនួន។ (កម្មវិធីបានផលិតសម្រាប់នាំចេញដោយក្រុមហ៊ុនផ្សាយ)

- **ដំណើរការ (OK)** →
  កំណត់ចំណូលចិត្តភាសារបស់អ្នកនៅក្នុង **ភាសាជាសំឡេង**។

# ការដោះស្រាយបញ្ហានៃការតភ្ជាប់ទៅកុំព្យូទ័រ

## ការដោះស្រាយបញ្ហានៃការតភ្ជាប់ទៅកុំព្យូទ័រ

ចុច ហើយសង្កត់ឲ្យយូរលើប៊ូតុង ⮐ ដែលនៅលើតេឡេបញ្ជាពីចម្ងាយរបស់អ្នក។ ជ្រើសរើស ⚙ → **កែសម្រួល** នៅជ្រុងខាងលើផ្នែកខាងស្តាំនៃ **ផ្ទាំងគ្រប់គ្រងផ្ទះ**។ នៅក្នុងរបៀបកែសម្រួល សូមកំណត់រូបប្រចក HDMI ដែលបានភ្ជាប់ទៅកុំព្យូទ័រទៅ **កុំព្យូទ័រ** ដើម្បីអនុវត្តការកំណត់សមាមាត្រ និងវីដេអូដែលត្រូវនឹងកុំព្យូទ័រ។ ដើម្បីភ្ជាប់ឧបករណ៍ផ្សេងទៅច្រកបញ្ចូលតែមួយ អ្នកត្រូវកំណត់រូបតំណាងម្តងទៀត ដោយសារការកំណត់រូបរបៀបកែសម្រួលនឹងមិនត្រូវបានស្តារដោយស្វ័យប្រវត្តិទេ។

ប្រសិនបើអ្នកជួបបញ្ហាមួយចំនួនដូចខាងក្រោម នៅពេលកំពុងប្រើប្រាស់ផលិតផល សូមពិនិត្យដូចខាងក្រោម។ វាប្រហែលមិនមានបញ្ហាជាមួយផលិតផលទេ។

### អេក្រង់នៅតែទទេបន្ទាប់ពីវាត្រូវបានតភ្ជាប់ជាមួយកុំព្យូទ័រ។

- ពិនិត្យមើលថាកុំព្យូទ័រត្រូវបានតភ្ជាប់ជាមួយទូរទស្សន៍បានត្រឹមត្រូវដែរឬទេ។
- បិទទូរទស្សន៍ ហើយបើកវិញដោយប្រើតេឡេ។
- ចាប់ផ្តើមកុំព្យូទ័រឡើងវិញជាមួយទូរទស្សន៍បានបើក។
- ត្រូវប្រាកដថា កម្រិតច្បាស់នៃរូបភាពបង្ហាញដែលកំណត់នៅលើកុំព្យូទ័រ ត្រូវបានកំណត់ទៅគុណភាពបង្ហាញដែលស្គាល់ HDMI-PC របស់ទូរទស្សន៍។
- ដើម្បីប្រើម៉ូនីទ័រពីរ ពិនិត្យមើលថាកុំព្យូទ័រ ឬកុំព្យូទ័រយួរដៃគាំទ្រទម្រង់ម៉ូនីទ័រពីរ។

- តភ្ជាប់ខ្សែ HDMI ល្បឿនលឿនឡើងវិញ។
- ប្រសិនបើអ្នកបានតភ្ជាប់ច្រកចេញ RGB នៃកុំព្យូទ័ររបស់អ្នកជាមួយ **HDMI IN** របស់ទូរទស្សន៍ អ្នកត្រូវត្រូវមានក្បាលតភ្ជាប់ពី RGB ទៅ HDMI ។
  អ្នកនឹងមិនឃើញអ្វីទេលើអេក្រង់ បើអ្នកប្រើក្បាលតភ្ជាប់ HDMI ទៅ RGB ។

### អេក្រង់បង្ហាញមិនពេញលេញ ឬម្ខាងធំម្ខាងតូច នៅពេលភ្ជាប់ទៅកុំព្យូទ័រ។

- កំណត់កម្រិតច្បាស់របស់កុំព្យូទ័រជាមួយឧបករណ៍បានគាំទ្រដោយទូរទស្សន៍។
  សម្រាប់ព័ត៌មានបន្ថែម សូមមើល **ការទទួលបានព័ត៌មាន** → **គុណភាពបង្ហាញដែលបានគាំទ្រ៖ HDMI-PC** ក្នុង **ការណែនាំសម្រាប់អ្នកប្រើប្រាស់**។
- កំណត់ឈ្មោះរបស់ឧបករណ៍ HDMI ដែលបានតភ្ជាប់ជាមួយកុំព្យូទ័រ។
  ចុច ហើយសង្កត់ឲ្យយូរលើប៊ូតុង ដែលនៅលើគេឡេបញ្ជាពីចម្ងាយរបស់អ្នក។ ជ្រើសរើស → **កែសម្រួល** នៅជ្រុងខាងលើផ្នែកខាងស្តាំ។ ប្តូររូបរន្ធ HDMI ដែលភ្ជាប់ជាមួយ **ធាតុបញ្ចូល** ទៅកុំព្យូទ័រ រួចជ្រើសរើស **រក្សាទុក**។

### សំឡេងមិនឮ នៅពេលកុំព្យូទ័រត្រូវបានតភ្ជាប់ជាមួយខ្សែ HDMI ។

- សូមចូលទៅកាន់ផ្ទាំងគ្រប់គ្រង → សំឡេង → ឧបករណ៍ចាក់ → LGTV ដើម្បីកំណត់ឧបករណ៍លំនាំដើមពីការកំណត់កុំព្យូទ័រ។
- សូមពិគ្រោះយោបល់ជាមួយអ្នកផលិតថាតើកាតក្រាហ្វិករបស់អ្នកគាំទ្រការចេញសំឡេង HDMI ដែរឬទេ។

# ការដោះស្រាយបញ្ហានៃការចាក់ភាពយន្ត

## ការដោះស្រាយបញ្ហានៃការចាក់ភាពយន្ត

ប្រសិនបើអ្នកជួបបញ្ហាមួយចំនួនដូចខាងក្រោម នៅពេលកំពុងប្រើប្រាស់ផលិតផល សូមពិនិត្យដូចខាងក្រោម។ វាប្រហែលមិនមានបញ្ហាជាមួយផលិតផលទេ។
សម្រាប់ព័ត៌មានបន្ថែមអំពីឯកសារដែលអាចប្រើបាន សូមមើល ឯកសារវីដេអូដែលបានគាំទ្រពី **ការភ្ជាប់ទៅឧបករណ៍ខាងក្រៅ** → **មើលរូបថត និងវីដេអូ** នៅក្នុង **ការណែនាំសម្រាប់អ្នកប្រើប្រាស់**។

### ខ្ញុំមិនអាចរកឃើញឯកសារក្នុង **រូបថត និងវីដេអូ**។

- ពិនិត្យមើលថាឯកសារក្នុងឧបករណ៍ផ្ទុកយូអេសប៊ីអាចអានបានលើកុំព្យូទ័រដែរឬទេ។
- ជ្រើសរើស ដើម្បីមើលថាតើ **តម្រង** ត្រូវបានកំណត់ទៅ **រូបថត និងវីដេអូ** ឬអត់។

## ខ្ញុំឃើញសារមួយដែលនិយាយថា មិនគាំទ្រឯកសារ។

- ពិនិត្យមើលថាឯកសារលេងដោយគ្មានបញ្ហាលើកម្មវិធីលេងវីដេអូក្នុងកុំព្យូទ័រដែរឬទេ។ (ពិនិត្យមើលឯកសារក្រែងលោវាខូច។)
- ពិនិត្យមើលថាផ្នែកបន្ថែមឯកសារត្រូវបានគាំទ្រដែរឬទេ។
- ពិនិត្យមើលថាគុណភាពបង្ហាញត្រូវបានគាំទ្រដែរឬទេ។
- ពិនិត្យមើលថាកូឌិកវីដេអូត្រូវបានគាំទ្រដែរឬទេ។
- ពិនិត្យមើលថាវាស្គាល់អត្រាហ្វ្រេមដែរឬអត់។

## ខ្ញុំទទួលបានសារមួយនិយាយថា "សំឡេងនេះមិនត្រូវបានគាំទ្រទេ" ឬវីដេអូកំពុងលេងធម្មតា ប៉ុន្តែមិនមានសំឡេង។

- ពិនិត្យមើលថាឯកសារលេងដោយគ្មានបញ្ហាលើកម្មវិធីលេងវីដេអូក្នុងកុំព្យូទ័រដែរឬទេ។ (ពិនិត្យមើលឯកសារក្រែងលោវាខូច។)
- ពិនិត្យមើលថាផ្នែកបន្ថែមឯកសារត្រូវបានគាំទ្រដែរឬទេ។
- ពិនិត្យមើលថាកូឌិកសំឡេងត្រូវបានគាំទ្រដែរឬទេ។
- ពិនិត្យមើលថាអត្រាប៊ីតត្រូវបានគាំទ្រដែរឬទេ។
- ពិនិត្យមើលថាវាស្គាល់ប្រេកង់គំរូដែរឬអត់។
- ពិនិត្យមើលថាវាស្គាល់ចំនួនប៉ុស្តិ៍សំឡេងដែរឬអត់។

## ខ្ញុំមិនអាចឃើញអក្សររត់។

- ពិនិត្យមើលថាឯកសារលេងដោយគ្មានបញ្ហាលើកម្មវិធីលេងវីដេអូក្នុងកុំព្យូទ័រដែរឬទេ។ (ពិនិត្យមើលឯកសារក្រែងលោវាខូច។)
- ពិនិត្យមើលថាឯកសារវីដេអូ និងអក្សររត់មានឈ្មោះដូចគ្នាដែរឬទេ។
- ពិនិត្យមើលផងដែរថាទាំងឯកសារវីដេអូ និងឯកសារអក្សររត់នៅក្នុងថតឯកសារតែមួយ។
- ពិនិត្យមើលថាឯកសារអក្សររត់ត្រូវបានគាំទ្រដែរឬទេ។
- ពិនិត្យមើលថាភាសាត្រូវបានគាំទ្រដែរឬទេ។
  (អ្នកអាចពិនិត្យមើលភាសារបស់ឯកសារអក្សររត់ ដោយបើកឯកសារក្នុងកម្មវិធី Notepad ។)
- ប្រសិនបើការអ៊ិនកូដអក្សររត់ត្រូវបានកំណត់ត្រឹមត្រូវ អក្សររត់អាចមិនត្រូវបានបង្ហាញត្រឹមត្រូវដែរ។
  ជ្រើសរើស … → SUB នៅក្នុងបន្ទះគ្រប់គ្រងនៅខាងក្រោមអេក្រង់លេងវីដេអូឡើងវិញ ហើយប្ដូរតម្លៃ **ទំព័រលេខកូដ**។
- ប្រសិនបើអ្នកលេងឯកសារវីដេអូបានរក្សាទុកក្នុងឧបករណ៍ផ្សេង ដោយប្រើមុខងារចែករំលែកមាតិកា អក្សររត់មិនអាចប្រើបាន អាស្រ័យលើកម្មវិធីដែលអ្នកប្រើ។
- មិនគាំទ្រចំណងជើងរង ប្រសិនបើអ្នកកំពុងលេងវីដេអូតាម NAS ។
  សូមពិគ្រោះយោបល់ជាមួយអ្នកផលិត NAS របស់អ្នក។

## ឧបករណ៍ផ្ទុកយូអេសប៊ីរបស់ខ្ញុំមិនបានស្គាល់នៅពេលបានតភ្ជាប់។

- ពិនិត្យមើលថាតើឧបករណ៍ផ្ទុកយូអេសប៊ីបានគាំទ្រដោយទូរទស្សន៍ដែរឬទេ។ សម្រាប់ព័ត៌មានបន្ថែម សូមមើល **ការភ្ជាប់ទៅឧបករណ៍ខាងក្រៅ** → **ការតភ្ជាប់យូអេសប៊ី** ក្នុង **ការណែនាំសម្រាប់អ្នកប្រើប្រាស់**។

# ការដោះស្រាយបញ្ហានៃការថត

## ការដោះស្រាយបញ្ហានៃការថត

សូមយោងតាម **វិករាយជាមួយទូរទស្សន៍បន្តផ្ទាល់** → **ការថត** នៅក្នុង **ការណែនាំសម្រាប់អ្នកប្រើប្រាស់** សម្រាប់ព័ត៌មានលម្អិតអំពីការថត។

### តើខ្ញុំអាចចាប់ផ្តើមថតដោយរបៀបណា?

- តភ្ជាប់ឧបករណ៍ផ្ទុកយូអេសប៊ីជាមួយទំហំផ្ទុកសរុបយ៉ាងហោចណាស់ 4 ជីកាបៃ។ ឧបករណ៍ត្រូវតែមានទំហំទំនេរយ៉ាងហោចណាស់ 1 ជីកាបៃ។ (សូមយោងតាម **ការភ្ជាប់ទៅឧបករណ៍ខាងក្រៅ** → **ការតភ្ជាប់យូអេសប៊ី** នៅក្នុង **ការណែនាំសម្រាប់អ្នកប្រើប្រាស់** សម្រាប់ព័ត៌មានលម្អិតអំពីឧបករណ៍ផ្ទុកយូអេសប៊ី។)
  ចុចលើប៊ូតុង **ដំណើរការ (OK)** លើតេឡេរបស់អ្នក។ ចុច ● ដែលបង្ហាញនៅផ្នែកខាងក្រោមខាងឆ្វេងនៃអេក្រង់ ដើម្បីចាប់ផ្តើមថត។

### តើសញ្ញាណាមួយគាំទ្រដល់ការថត?

- ការថតដែលបានកំណត់កាលវិភាគ និងការថតក្នុងពេលជាក់ស្តែងអាចប្រើបានសម្រាប់តែកម្មវិធីដែលទទួលដោយផ្ទាល់ពីទូរទស្សន៍ប៉ុណ្ណោះ។
- មិនអាចថតប៉ុស្តិ៍ដែលមានប្រភពពីប្រអប់ចាប់ប៉ុស្តិ៍បានទេ។
- មាតិកាដែលបានការពារមិនត្រូវបានថតទេ។

### តើ **ការថតដែលបានកំណត់ពេល** អាចប្រើប្រាស់បានទេ សូម្បីតែពេលបិទទូរទស្សន៍?

- **ការថតដែលបានកំណត់ពេល** ចាប់ផ្តើម និងបញ្ចប់ការថតតាមពេលវេលាបានកំណត់ សូម្បីតែពេលបិទទូរទស្សន៍។
- **ការថតដែលបានកំណត់ពេល** មិនដំណើរការទេ ប្រសិនបើមិនដោតឌុយខ្សែភ្លើងទូរទស្សន៍។

# ការដោះស្រាយបញ្ហានៃការតភ្ជាប់បណ្ដាញ

## ការដោះស្រាយបញ្ហានៃការតភ្ជាប់បណ្ដាញ

ប្រសិនបើអ្នកជួបបញ្ហាមួយចំនួនដូចខាងក្រោម នៅពេលកំពុងប្រើប្រាស់ផលិតផល សូមពិនិត្យដូចខាងក្រោម។ វាប្រហែលមិនមានបញ្ហាជាមួយផលិតផលទេ។

អ្នកអាចពិនិត្យស្ថានភាពតភ្ជាប់បណ្ដាញ ដូចបង្ហាញនៅខាងក្រោម។

- ⚙ → ⋮ → **ការតភ្ជាប់** → **ការកំណត់ការតភ្ជាប់បណ្ដាញ** → **ការតភ្ជាប់ដោយប្រើខ្សែ (អ៊ីសឺណិត)**
- ⚙ → ⋮ → **ការតភ្ជាប់** → **ការកំណត់ការតភ្ជាប់បណ្ដាញ** → **ការតភ្ជាប់ Wi-Fi** → **ការកំណត់ Wi-Fi កម្រិតខ្ពស់**

នៅពេលអក្សរ X លេចឡើងនៅក្បែរទូរទស្សន៍

- ពិនិត្យទូរទស្សន៍ ឬ AP (រ៉ោតទ័រ)។
- ពិនិត្យស្ថានភាពតភ្ជាប់របស់ទូរទស្សន៍ AP (រ៉ោតទ័រ) និងម៉ូដឹមប្រើខ្សែ។
- បិទ និងបើកតាមលំដាប់ដូចខាងក្រោម
  1. បិទ រួចបើកម៉ូដឹមមានខ្សែរបស់អ្នកវិញ ហើយរង់ចាំឱ្យឧបករណ៍កំណត់ឡើងវិញ។
  2. បិទ រួចបើករ៉ោតទ័រមានខ្សែ/ឥតខ្សែវិញ ហើយរង់ចាំឱ្យឧបករណ៍កំណត់ឡើងវិញ។
  3. បើក និងបិទទូរទស្សន៍។
- ប្រសិនបើអ្នកចង់បង្កើតការតភ្ជាប់ LAN ដែលប្រើខ្សែ សូមពិនិត្យមើលថាតើអាសយដ្ឋាន IP អាចទាញយកពីរ៉ោតទ័ររបស់អ្នកបានត្រឹមត្រូវឬអត់។
  ប្រសិនបើអ្នកកំពុងរៀបចំបណ្ដាញរបស់អ្នកដោយផ្ទាល់ សូមពិនិត្យមើលថាតើការកំណត់ទាំងអស់ត្រឹមត្រូវឬអត់។
- ប្រសិនបើអ្នកចង់បង្កើតការតភ្ជាប់ឥតខ្សែ សូមពិនិត្យមើលចំណុចខាងក្រោមផងដែរ។
  ① កំណត់ SSID (ឈ្មោះបណ្ដាញ) រ៉ោតទ័រឬប៉ុស្តិ៍ឥតខ្សែរបស់អ្នក។
  ② កំណត់សោសុវត្ថិភាពរ៉ោតទ័ររបស់អ្នក។
  ប្រសិនបើអ្នកមិនអាចបញ្ចប់ការកំណត់នេះបានទេ សូមមើលសៀវភៅណែនាំអំពីការប្រើប្រាស់រូតទ័រ និងការណែនាំដែលផ្ដល់ដោយក្រុមហ៊ុនផ្ដល់សេវាអ៊ីនធឺណិតរបស់អ្នក។
  ប្រសិនបើអ្នកនៅតែមិនអាចបង្កើតការកំណត់រចនាសម្ព័ន្ធរបស់អ្នកបានទេ សូមទាក់ទងក្រុមហ៊ុនផលិតរ៉ោតទ័ររបស់អ្នក ឬក្រុមហ៊ុនផ្ដល់សេវាអ៊ីនធឺណិតរបស់អ្នក។
- ប្រសិនបើអ្នកកំពុងប្រើប្រាស់ IP ថេរ សូមបញ្ចូល IP ដោយផ្ទាល់។

នៅពេលអក្សរ X លេចឡើងនៅក្បែរច្រកចេញចូល

- ពិនិត្យ AP (រ៉ោតទ័រ) ឬពិគ្រោះជាមួយអ្នកផ្តល់សេវាអ៊ីនធឺណិតរបស់អ្នក។
- ដកម៉ូដឹមខ្សែ/រូតទ័រចេញពីព្រីភ្លើងជាប់ជញ្ជាំង រង់ចាំរយៈពេល 10 វិនាទី រួចភ្ជាប់វាឡើងវិញ។
- ចាប់ផ្តើម (កំណត់ឡើងវិញ)នៅលើ AP (រ៉ោតទ័រ) ឬម៉ូដឹមប្រើខ្សែ។
- ពិនិត្យវេបសាយរបស់អ្នកផលិត AP (រ៉ោតទ័រ) ដើម្បីប្រាដកថា រ៉ោតទ័ររបស់អ្នកមានកំណែកម្មវិធីបង្កប់ចុងក្រោយបំផុត។
- ប្រសិនបើអ្នកមិនអាចបញ្ចប់ការកំណត់នេះបានទេ សូមមើលសៀវភៅណែនាំអំពីការប្រើប្រាស់រូតទ័រ និងការណែនាំដែលផ្តល់ដោយក្រុមហ៊ុនផ្តល់សេវាអ៊ីនធឺណិតរបស់អ្នក។ ប្រសិនបើអ្នកនៅតែមិនអាចបង្កើតការកំណត់រចនាសម្ព័ន្ធរបស់អ្នកបានទេ សូមទាក់ទងក្រុមហ៊ុនផលិតរ៉ោតទ័ររបស់អ្នក ឬក្រុមហ៊ុនផ្តល់សេវាអ៊ីនធឺណិតរបស់អ្នក។




នៅពេលអក្សរ X លេចឡើងនៅក្បែរ DNS

- ពិនិត្យ AP (រ៉ោតទ័រ) ឬពិគ្រោះជាមួយអ្នកផ្តល់សេវាអ៊ីនធឺណិតរបស់អ្នក។
- ដកម៉ូដឹមខ្សែ/រូតទ័រចេញពីព្រីភ្លើងជាប់ជញ្ជាំង រង់ចាំរយៈពេល 10 វិនាទី រួចភ្ជាប់វាឡើងវិញ។
- ចាប់ផ្តើម (កំណត់ឡើងវិញ)នៅលើ AP (រ៉ោតទ័រ) ឬម៉ូដឹមប្រើខ្សែ។
- ពិនិត្យថាតើអាសយដ្ឋាន MAC របស់ TV/AP (រ៉ោតទ័រ) ត្រូវបានចុះឈ្មោះជាមួយ អ្នកផ្តល់សេវាអ៊ីនធឺណិតរបស់អ្នកឬនៅ។ (អាសយដ្ឋាន MAC ដែលបង្ហាញលើផ្ទាំង window ស្ថានភាពបណ្តាញត្រូវចុះបញ្ជីជាមួយអ្នកផ្តល់សេវាអ៊ីនធឺណិតរបស់អ្នក។)
- ប្រសិនបើអ្នកមិនអាចបញ្ចប់ការកំណត់នេះបានទេ សូមមើលសៀវភៅណែនាំអំពីការប្រើប្រាស់រូតទ័រ និងការណែនាំដែលផ្តល់ដោយក្រុមហ៊ុនផ្តល់សេវាអ៊ីនធឺណិតរបស់អ្នក។ ប្រសិនបើអ្នកនៅតែមិនអាចបង្កើតការកំណត់រចនាសម្ព័ន្ធរបស់អ្នកបានទេ សូមទាក់ទងក្រុមហ៊ុនផលិតរ៉ោតទ័ររបស់អ្នក ឬក្រុមហ៊ុនផ្តល់សេវាអ៊ីនធឺណិតរបស់អ្នក។

# ការដោះស្រាយបញ្ហាគណនី LG

## ការដោះស្រាយបញ្ហាគណនី LG

ខ្ញុំបានចុះឈ្មោះជាសមាជិកភាពនៅលើទូរទស្សន៍រួចហើយ។ តើខ្ញុំត្រូវចុះឈ្មោះម្តងទៀត នៅលើគេហទំព័រ (www.lgappstv.com) ដែរទេ?

- អ្នកអាចប្រើគេហទំព័រ តាមរយៈព័ត៌មានសមាជិកភាពដែលអ្នកបានប្រើ នៅពេលចុះឈ្មោះនៅលើទូរទស្សន៍។ អ្នកអាចប្រើគេហទំព័របាន តាមរយៈការចូលគេហទំព័រដោយប្រើពាក្យសម្ងាត់ និងលេខសម្គាល់ ដែលអ្នកបានប្រើនៅពេលចុះឈ្មោះនៅលើទូរទស្សន៍ តាមរយៈការបញ្ចូលព័ត៌មានបន្ថែម

និងបំពេញដំណើរការផ្ទៀងផ្ទាត់តាមអ៊ីមែល។

### ខ្ញុំភ្លេចពាក្យសម្ងាត់របស់ខ្ញុំហើយ។ តើខ្ញុំគួរធ្វើដូចម្ដេច?

- នៅលើអេក្រង់ចូលរបស់ទូរទស្សន៍ សូមចុចប៊ូតុង **ភ្លេចពាក្យសម្ងាត់ឬ?** ដើម្បីចូលទៅកាន់ទំព័រស្វែងរកពាក្យសម្ងាត់។ សូមបញ្ចូលអាសយដ្ឋានអ៊ីមែលរបស់អ្នកនៅលើទំព័រស្វែងរកពាក្យសម្ងាត់ នោះយើងនឹងផ្ញើតំណមួយទៅអ្នក ដើម្បីកំណត់ពាក្យសម្ងាត់របស់អ្នកឡើងវិញ។
- អ្នកក៏អាចកំណត់ពាក្យសម្ងាត់របស់អ្នកនៅក្នុងគណនី LG បានផងដែរ → កំណត់ពាក្យសម្ងាត់ឡើងវិញនៅលើគេហទំព័រ (www.lgappstv.com)។

- ក្នុងប្រទេសមួយចំនួន លទ្ធភាពប្រើប្រាស់វេបសាយ (www.lgappstv.com) អាចត្រូវបានរឹតត្បិត។

# ការដោះស្រាយបញ្ហាខ្លឹមសារ

## ការដោះស្រាយបញ្ហាខ្លឹមសារ

ប្រសិនបើអ្នកជួបបញ្ហាមួយចំនួនដូចខាងក្រោម នៅពេលកំពុងប្រើប្រាស់ផលិតផល សូមពិនិត្យដូចខាងក្រោម។ វាប្រហែលមិនមានបញ្ហាជាមួយផលិតផលទេ។

### អ្នកមិនអាចមើលមាតិកាមួយចំនួននៅក្នុងអេក្រង់ដើមបានទេ។

- អ្នកអាចមិនអាចមើលមាតិកាបានទេ ប្រសិនបើការកំណត់ប្រទេសដែលផ្ដល់សេវាត្រូវបានផ្លាស់ប្ដូរ។ ប្ដូរទៅប្រទេសដែលអ្នកនឹងប្រើប្រាស់សេវាពី ⚙ → ⋮ → **ទូទៅ** → **ទីតាំង** → **ប្រទេសផ្ដល់សេវាកម្ម LG**។
(អាចនឹងមិនស្គាល់ម៉ូដែលមួយចំនួន។)
- ប្រសិនបើអ្នកមិនឃើញកម្មវិធីមួយចំនួន វាអាចបណ្ដាលមកពីអ្នកបានលុបពួកវា។ សូមដំឡើងកម្មវិធីដែលត្រឹមត្រូវម្ដងទៀត។
- ប្រសិនបើកម្មវិធីត្រូវបានលុប អ្នកអាចទាញយកកម្មវិធីនៅ **LG Content Store** រួចដំឡើងវាម្ដងទៀតបាន។ សូមចូលទៅកាន់ ⌂ → **LG Content Store** ដើម្បីស្វែងរក និងដំឡើងកម្មវិធីដែលអ្នកចង់ប្រើ។
- ប្រភេទមាតិកាដែលគាំទ្រមានខុសគ្នាទៅតាមប្រទេស។
- មាតិកាដែលផ្ដល់អាចត្រូវបានកែប្រែ ឬរំខានដោយអ្នកផ្ដល់សេវា។

# ការដោះស្រាយបញ្ហាកម្មវិធីរុករកនៅលើអ៊ីនធឺណិត

# ការដោះស្រាយបញ្ហាកម្មវិធីរុករកនៅលើអ៊ីនធឺណិត

ប្រសិនបើអ្នកជួបបញ្ហាមួយចំនួនដូចខាងក្រោម នៅពេលកំពុងប្រើប្រាស់ផលិតផល សូមពិនិត្យដូចខាងក្រោម។ វាប្រហែលមិនមានបញ្ហាជាមួយផលិតផលទេ។

### ផ្នែកមួយចំនួនរបស់គេហទំព័រដាក់លាក់មិនអាចមើលឃើញ នៅពេលខ្ញុំកំពុងប្រើអ៊ីនធឺណិត។

- **កម្មវិធីរុករកលើអ៊ីនធឺណិត** ស្គាល់តែមេឌៀដើរលើ HTML5 ប៉ុណ្ណោះ គឺវាស្គាល់តែកម្មវិធីជំនួយ Flash។
- **កម្មវិធីរុករកលើអ៊ីនធឺណិត** មិនជួយដល់ការបញ្ចូលកម្មវិធីជំនួយទេ។
- លើ **កម្មវិធីរុករកលើអ៊ីនធឺណិត**ការចាក់លេងឯកសារមេឌៀជាទម្រង់ផ្សេងទៀត មិនអាចធ្វើទៅបានទេ
  : JPEG/PNG/GIF
- អ្នកមិនអាចរក្សាទុកឯកសារភ្ជាប់ ឬរូបភាពបានទេ។
- ប្រសិនបើបើកលក្ខណៈពិសេស **ប្រើការរារាំងការផ្សាយពាណិជ្ជកម្ម** ផ្នែកនៅលើគេហទំព័រដែលបង្ហាញការផ្សាយពាណិជ្ជកម្មនឹងទទេ។ ប្រសិនបើលាក់មាតិកាមួយចំនួននៅលើគេហទំព័រ និងមើលមាតិកាទាំងនោះមិនឃើញទេ សូមសាកល្បងកំណត់ ▤ → **ការកំណត់** → **ប្រើការរារាំងការផ្សាយពាណិជ្ជកម្ម** ទៅ **បិទ** នៅក្នុង **កម្មវិធីរុករកលើអ៊ីនធឺណិត**។ **ពាណិជ្ជកម្មដែលបានឧបត្ថម្ភ** នៅលើទំព័រផ្ទាំងថ្មីនឹងបង្ហាញ ទោះបីជាអ្នកកំណត់លក្ខណៈពិសេស **ប្រើការរារាំងការផ្សាយពាណិជ្ជកម្ម** ទៅ **បិទ** ក៏ដោយ។

### កម្មវិធីបើកអ៊ីនធឺណិតបិទដោយស្វ័យប្រវត្តិ នៅពេលខ្ញុំចូលគេហទំព័រ។

- កម្មវិធីអ៊ីនធឺណិតអាចត្រូវបានបង្ខំឲ្យបិទ ប្រសិនបើទំហំអង្គចងចាំដែលមានមិនគ្រប់គ្រាន់ដើម្បីសម្រួលព័ត៌មានរូបភាពសម្រាប់គេហទំព័រ។

### នៅពេលមើលវីដេអូនៅក្នុង **កម្មវិធីរុករកលើអ៊ីនធឺណិត**វីដេអូត្រូវបានបង្ខំឲ្យបិទ។

- អ្នកអាចកែបញ្ហា ដោយកំណត់ ▤ → **ការកំណត់** → **បច្ចេកវិទ្យាស្ក្រីមមានភាពប្រែប្រួលដែលប្រើ JavaScript** ទៅជា **បិទ** នៅក្នុង **កម្មវិធីរុករកលើអ៊ីនធឺណិត**។ ការកំណត់មិនត្រូវបានអនុវត្តចំពោះផ្ទាំងដែលត្រូវបានបើក មុនពេលផ្លាស់ប្តូរ ហើយត្រូវបានអនុវត្តតែចំពោះផ្ទាំងដែលបានបើកបន្ទាប់ពីការផ្លាស់ប្តូរ។

# ការទទួលបានព័ត៌មាន

# គុណភាពបង្ហាញដែលបានគាំទ្រ៖ HDMI-DTV

## ម៉ូដគាំទ្រ HDMI-DTV

| កម្រិតគុណភាព | ប្រេកង់ផ្ដេក (kHz) | ប្រេកង់បញ្ឈរ |
|---|---|---|
| 640 × 480p | 31.46 | 59.94 |
| | 31.5 | 60 |
| 720 × 480p | 31.46 | 59.94 |
| | 31.5 | 60 |
| 720 × 576p | 31.25 | 50 |
| 1280 × 720p | 37.5 | 50 |
| | 44.95 | 59.94 |
| | 45 | 60 |
| 1920 × 1080i | 28.12 | 50 |
| | 33.71 | 59.94 |
| | 33.75 | 60 |
| 1920 × 1080p | 26.97 | 23.97 |
| | 27 | 24 |

| | | |
|---|---|---|
| | 28.12 | 25 |
| | 33.71 | 29.97 |
| | 33.75 | 30 |
| | 56.25 | 50 |
| | 67.43 | 59.94 |
| | 67.5 | 60 |
| | 112.5 | 100 |
| | 134.86 | 119.88 |
| | 135 | 120 |
| 3840 × 2160p | 53.94 | 23.97 |
| | 54 | 24 |
| | 56.25 | 25 |
| | 67.43 | 29.97 |
| | 67.5 | 30 |
| | 112.5 | 50 |
| | 134.86 | 59.94 |
| | 135 | 60 |

| | | |
|---|---|---|
| 3840 × 2160p [1) 2)] | 225 | 100 |
| | 269.73 | 119.88 |
| | 270 | 120 |
| 4096 × 2160p | 53.94 | 23.97 |
| | 54 | 24 |
| | 56.25 | 25 |
| | 67.43 | 29.97 |
| | 67.5 | 30 |
| | 112.5 | 50 |
| | 134.86 | 59.94 |
| | 135 | 60 |
| 4096 × 2160p [1) 2)] | 225 | 100 |
| | 269.73 | 119.88 |
| | 270 | 120 |

1) ដំណើរការបាននៅពេល **HDMI ULTRA HD Deep Color** ត្រូវកំណត់ទៅជា **បើក**។
2) ស្គាល់តែរន្ធនៃធាតុបញ្ចូល HDMI មួយចំនួនប៉ុណ្ណោះ។

# គុណភាពបង្ហាញដែលបានគាំទ្រ៖ HDMI-PC

# ម៉ូដគាំទ្រ HDMI-PC

| កម្រិតគុណភាព | ប្រេកង់ផ្ដេក (kHz) | ប្រេកង់បញ្ឈរ |
|---|---|---|
| 640 × 350 | 31.46 | 70.09 |
| 720 × 400 | 31.46 | 70.08 |
| 640 × 480 | 31.46 | 59.94 |
| 800 × 600 | 37.87 | 60.31 |
| 1024 × 768 | 48.36 | 60 |
| 1152 × 864 | 54.34 | 60.05 |
| 1360 × 768[4)] | 47.71 | 60.01 |
| 1280 × 1024<br>(សម្រាប់ម៉ូដែល ULTRA HD, 8K តែប៉ុណ្ណោះ) | 63.98 | 60.02 |
| 1920 × 1080<br>(សម្រាប់ម៉ូដែល Full HD, ULTRA HD, 8K តែប៉ុណ្ណោះ) | 67.5 | 60 |
| 1920 × 1080<br>(សម្រាប់ម៉ូដែល ULTRA HD, 8K តែប៉ុណ្ណោះ) | 134.86 | 119.88 |
| | 135 | 120 |
| 2560 × 1440[1)]<br>(សម្រាប់ម៉ូដែល ULTRA HD 50/60 Hz តែប៉ុណ្ណោះ) | 88.78 | 59.95 |
| 2560 × 1440[1) 2)]<br>(សម្រាប់ម៉ូដែល ULTRA HD 100/120 Hz, 8K តែប៉ុណ្ណោះ) | 182.99 | 119.99 |

| | | |
|---|---|---|
| 3840 × 2160<br>(សម្រាប់ម៉ូដែល ULTRA HD, 8K តែប៉ុណ្ណោះ) | 53.94 | 23.97 |
| | 54 | 24 |
| | 56.25 | 25 |
| | 67.43 | 29.97 |
| | 67.5 | 30 |
| | 112.5 | 50 |
| | 134.86 | 59.94 |
| | 135 | 60 |
| 3840 × 2160 1) 2)<br>(សម្រាប់ម៉ូដែល ULTRA HD 100/120 Hz, 8K តែប៉ុណ្ណោះ) | 225 | 100 |
| | 269.73 | 119.88 |
| | 270 | 120 |
| 4096 × 2160<br>(សម្រាប់ម៉ូដែល ULTRA HD, 8K តែប៉ុណ្ណោះ) | 53.94 | 23.97 |
| | 54 | 24 |
| | 56.25 | 25 |
| | 67.43 | 29.97 |
| | 67.5 | 30 |
| | 112.5 | 50 |

| | | |
|---|---|---|
| | 134.86 | 59.94 |
| | 135 | 60 |
| 4096 × 2160 1) 2)<br>(សម្រាប់ម៉ូដែល ULTRA HD 100/120 Hz, 8K តែប៉ុណ្ណោះ) | 225 | 100 |
| | 269.73 | 119.88 |
| | 270 | 120 |
| 7680 × 4320 3)<br>(សម្រាប់ម៉ូដែល 8K តែប៉ុណ្ណោះ) | 107.89 | 23.97 |
| | 108 | 24 |
| | 110 | 25 |
| | 131.87 | 29.97 |
| | 132 | 30 |
| | 220 | 50 |
| | 263.74 | 59.94 |
| | 264 | 60 |
| 1) (សម្រាប់ម៉ូដែល ULTRA HD តែប៉ុណ្ណោះ) ដំណើរការបាននៅពេល **HDMI ULTRA HD Deep Color** ត្រូវកំណត់ទៅជា **បើក**។<br>2) (សម្រាប់ម៉ូដែល 8K តែប៉ុណ្ណោះ) ដំណើរការបាននៅពេល **HDMI ULTRA HD Deep Color** ត្រូវកំណត់ទៅជា **4K**។<br>3) (សម្រាប់ម៉ូដែល 8K តែប៉ុណ្ណោះ) ដំណើរការបាននៅពេល **HDMI ULTRA HD Deep Color** ត្រូវកំណត់ទៅជា **8K**។<br>4) **HDMI ULTRA HD Deep Color** ត្រូវកំណត់ទៅជា **បិទ**។ | | |

- រន្ធ HDMI-PC ខុសគ្នាតាមប្រភេទម៉ូដែល។

សូមមើលសៀវភៅណែនាំដែលមានភ្ជាប់មកជាមួយផលិតផល។

# ព័ត៌មានអំពីអាជ្ញាប័ណ្ណ

## ព័ត៌មានអំពីអាជ្ញាប័ណ្ណ

អាជ្ញាបណ្ណដែលស្គាល់អាចខុសគ្នាទៅតាមម៉ូដែល។

### Dolby

Manufactured under license from Dolby Laboratories. Dolby, Dolby Vision, Dolby Vision IQ, Dolby Audio, Dolby Atmos, and the double-D symbol are trademarks of Dolby Laboratories.

### HDMI

The terms HDMI and HDMI High-Definition Multimedia Interface, and the HDMI Logo are trademarks or registered trademarks of HDMI Licensing Administrator, Inc. in the United States and other countries.

### Bluetooth

The Bluetooth® word mark and logos are registered trademarks owned by the Bluetooth SIG, Inc. and any use of such marks by LG Electronics Inc. is under license. Other trademarks and trade names are those of their respective owners.

### Powered by Quickset

### HEVC

# ១៧។

## ព័ត៌មានផ្សព្វផ្សាយ HEVC

- ការផ្សព្វផ្សាយដែលបញ្ជូនដោយប្រើកូឌិក HEVC អាចនឹងមិនគាំទ្រគ្នា អាស្រ័យតាមប្រទេសផ្សេងៗ។